ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ១៧ មេសា និងការខិតខំតស៊ូរបស់កម្ពុជាដើម្បីគេចឱ្យផុតពីថ្ងៃនេះ

◆ តើអ្វីជា «ភាពវិសាមញ្ញ» ចំពោះភាពយុត្តិធម៌

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨៤ ខែមេសា ឆ្នាំ២០១៥

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៨៤ ខែមេសា ឆ្នាំ២០១៥


## មាតិកា


◆ ១៧ មេសា និងការខិតខំតស៊ូដើម្បីគេចឲ្យផុត ........................................១

◆ យុត្តិធម៌ និងការអត់ឱន ........................................................................៤

◆ សារមន្ទីរនៃការចងចាំ ............................................................................៦

**ផ្នែកឯកសារ**

◆ គង់ ទូន ហៅ តាន់ អនុប្រធានកងធំទី១ ..................................................១២

◆ វីរភាពរបស់យុវជនបដិវត្តន៍អនាមិកម្នាក់ ....................................................១៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ការស្លាប់របស់ជនភៀសខ្លួនវៀតណាម និងអ្នកនេសាទ ..................................២៣

◆ អតីតគណៈកងពលទី២ ភូមិភាគពាយ័ព្យ .....................................................២៦

◆ ចាប់ពីរបបខ្មែរក្រហមដល់ឧប្បត្តិហេតុ ហាំបាលី ...........................................២៩

**ផ្នែកច្បាប់**

◆ តើអ្វីជា "ភាពវិសាមញ្ញ" ចំពោះពាក្យយុត្តិធម៌ ..............................................៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ ប្រទេសកម្ពុជា ៖ ប្រវត្តិនៃអំពើហិង្សា .........................................................៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ មានទោសព្រោះអ្វី? ..................................................................................៥២

◆ ដំណើរភៀសខ្លួនឆ្លងដែនពីរបប ...................................................................៥៧





រូបពីឆ្វេងទៅស្ដាំ ៖ សិល្បករ សេរ៉ា អ៊ីង, ជូលាន ហ្ស៊ីប៊ីស្គី និងអ្នកបកប្រែ ហ៊ុយ សម្ភស្ស ក្នុងពិធីសម្ពោធពិព័រណ៍ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ* ៖** អេង កុកថាយ, លី សុខឃាង, អ៊ីង សេរ៉ា, ជូលាន ហ្ស៊ីប៊ីស្គី, ស៊ាង ចិន្តា, សុខ វណ្ណៈ, ដេវីដ សេហ្សហ៊ើ, សើបាស្ទីន ស្រ្តេងចូ, ជួ សូភា, ជា សីហា ***អ្នកនិពន្ធនិងស្រាវជ្រាវ* ៖** ទាវ សារៈមុនិន្ទ និង ឌី សុជាតា ***អ្នកបកប្រែ* ៖** សយ សូលីដា, សុភ័ក្ត្រ ភាណា ***និពន្ធនាយកទូទៅ* ៖** ឆាំង យុ ***ជំនួយការនិពន្ធនាយក* ៖** សោម ប៊ុនថន ***ក្រាហ្វិកកុំព្យូទ័រ* ៖** សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ* ៖** ឆេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ១៧ មេសា និងការខិតខំតស៊ូរបស់កម្ពុជា ដើម្បីគេចឱ្យផុតពីថ្ងៃនេះ

១៧ មេសា ១៩៧៥ ជាថ្ងៃខ្មៅងងឹតបំផុតក្នុងប្រវត្តិសាស្ត្រពីរពាន់ឆ្នាំរបស់ប្រទេសកម្ពុជា ។ សូម្បីតែការឈ្លានពានរបស់ចម្ប៉ាមកលើទីក្រុងអង្គរ នៅឆ្នាំ១១៧៧ ក៏មិនអាចប្រៀបនឹងព្រឹត្តិការណ៍ ១៧ មេសា បានដែរ ។ សូម្បីតែការឈ្លានពាន និងការលួចប្លន់របស់ទ័ពថៃមកលើទីក្រុងអង្គរ នៅឆ្នាំ១៣៥៣ ក៏មិនអាចប្រៀបធៀបនឹងការលុកលុយរបស់ខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ នៅថ្ងៃ១៧ ខែមេសា ពីព្រោះវាជាថ្ងៃចាប់ផ្ដើមនៃការសម្លាប់រង្គាលប្រជាជនកម្ពុជាគ្រប់រូប គ្រប់វ័យ ដែលមានវណ្ណៈ និន្នាការ និងសាសនាផ្សេងៗពីគ្នាដល់ទៅជិត២លាននាក់ និងជាការចាប់ផ្ដើមនៃប្រព័ន្ធសង្គមដ៏អាក្រក់បំផុតមួយដែលមិនធ្លាប់ជួបប្រទះនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់មនុស្សជាតិ ។ ទោះបីជាអត្រាមរណភាពនៅសម័យខ្មែរក្រហមមានភាពខុសគ្នាទៅតាមទីកន្លែង និងពេលវេលាក៏ដោយ តែវានៅតែជាពេលវេលាដ៏អាក្រក់មួយសម្រាប់មនុស្សគ្រប់រូប ដែលបានឆ្លងកាត់របបខ្មែរក្រហម និងអ្នកដែលមិនមានសំណាងបានរត់គេចខ្លួនទៅបរទេស ។ ចាប់តាំងពីឆ្នាំ១៩៧៩មក សង្គមកម្ពុជាបានកំពុងព្យាយាមជួសជុលរាល់ការខូចខាតដែលបង្កឡើងដោយខ្មែរក្រហម ដែលបានចាប់ផ្ដើមនៅថ្ងៃ១៧ ខែ មេសា ឆ្នាំ១៩៧៥ ។

នៅពេលដែលសម្ដេច ហេង សំរិន ប្រកាសបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា នៅដើមខែធ្នូ ឆ្នាំ១៩៧៨ នៅខេត្ត



កងយោធាខ្មែរក្រហមដើរចូលមកក្រុងភ្នំពេញ តាមបណ្ដោយមហាវិថីព្រះនរោត្តម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ក្របេះ វាជាការចាប់ផ្តើមនៃទីបញ្ចប់របស់របបខ្មែរក្រហម ហើយក៏ជាការចាប់ផ្តើមនៃកិច្ចខិតខំប្រឹងប្រែងដើម្បីនាំប្រទេសកម្ពុជាឲ្យចេញពីអន្លង់មរណៈ និងទុក្ខវេទនាដ៏ជ្រៅបំផុតមួយ ។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានវាយប្រហារខ្មែរក្រហម នៅចុងខែធ្នូ ឆ្នាំ១៩៧៨ និងបានបណ្តេញខ្មែរក្រហមចេញពីប្រទេសកម្ពុជាយ៉ាងឆាប់រហ័ស លើកលែងតែតំបន់ព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ។

របបខ្មែរក្រហម បានបន្សល់ទុកដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជានូវប្រជាជនទន់ខ្សោយ ដែលភាគច្រើនជាស្ត្រី និងកុមារកំព្រាពីរសែននាក់ ។ ចាប់តាំងពីពេលនោះមក របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានដាក់ភារកិច្ចផ្សេងៗ ដែលមានគោលបំណងសំខាន់ចំនួនបីៈ ទី១) កសាងប្រទេសកម្ពុជា និងបង្កបង្កើតឡើងវិញនូវជីវិតវប្បធម៌ និងសាសនា ។ ទី២) ធ្វើយ៉ាងណាទទួលឲ្យបាននូវការទទួលស្គាល់ជាអន្តរជាតិ និងទី៣) ការពារ



ប្រជាជនរស់នៅទីក្រុងភ្នំពេញបានចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ក្រោយពេលកងយោធាខ្មែរក្រហមចូលមកក្រុងភ្នំពេញប៉ុន្មានម៉ោងប៉ុណ្ណោះ

ប្រទេសកម្ពុជាប្រឆាំងនឹងការវិលត្រឡប់មកវិញរបស់ខ្មែរក្រហម រួមទាំងរដ្ឋាភិបាលចម្រុះរបស់ខ្មែរក្រហមដែលបានធ្វើប្រតិបត្តិការសង្គ្រាមទ័ពព្រៃ ។

រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដោយមានជំនួយពីកងទ័ពវៀតណាមសម្រេចបានគោលដៅពីរធំៗខាងលើ ។ ប៉ុន្តែការខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីទទួលបានការទទួលស្គាល់ជាអន្តរជាតិបានបរាជ័យ ទោះបីជាមានការបង្កើតតុលាការប្រជាជនបដិវត្តន៍ដោយមានការចូលរួមពីអន្តរជាតិ ការបង្កើតគណៈកម្មាធិការស្រាវជ្រាវដើម្បីចងក្រងឯកសារស្តីពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ការបំពេញញត្តិរណសិរ្សដែលមានស្នាមផ្តិតមេដៃដល់ទៅ១.១លាននាក់ ការកែលម្អមន្ទីរស-២១ឡើងវិញ ឲ្យទៅជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ការជីកគាស់រណ្តៅសាកសពនៅតាមបរិវេណវាលពិឃាត និងការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធនៅទូទាំងប្រទេសកម្ពុជាក៏ដោយ ។ យុទ្ធនាការរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដើម្បីទទួលបានការសាទរពីសហគមន៍សកលសម្រាប់ការបញ្ចប់អំពើ ប្រល័យពូជសាសន៍ក៏បានបរាជ័យ ។

ជាមួយនឹងការមកដល់របស់អ៊ុនតាក់ (UNTAC) ដែលបានរៀបចំការបោះឆ្នោតប្រជាធិបតេយ្យ ជាលើកដំបូងចាប់តាំងពីទសវត្សរ៍ទី៦០មក នៅខែឧសភា ឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានព្យាយាមជួសជុសការខូចខាតបង្កឡើងដោយខ្មែរក្រហមដែលចាប់ផ្តើមនៅថ្ងៃ១៧ ខែមេសា ។ កិច្ចការចម្បងរបស់របបរដ្ឋកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា គឺត្រូវធ្វើឲ្យមានការផ្លាស់ប្តូរបន្តិចម្តងៗពីកុម្មុយនីស្តកម្ពុជាឲ្យទៅជាសេរីភាវូបនីយកម្ម ។ ដោយសារតែអ្នកសេរីនិយម និងបញ្ញវន្តនៅក្នុងប្រទេសកម្ពុជា ត្រូវបានសម្លាប់ដោយខ្មែរក្រហម កម្ពុជាមានធនធានមនុស្សតិចតួចណាស់ដើម្បីចាប់ផ្តើមនូវសេរីភាវូបនីយកម្មដ៏រលូននិងមានប្រសិទ្ធភាពមួយនៅក្នុងប្រទេសនេះ ។ សមត្ថភាពគឺស្ទើរតែសូន្យ បុគ្គលមានសមត្ថភាពស្ទើរតែគ្មាន ។ ដំណើរការនៃសេរីភាវូបនីយកម្មក៏បានជួបឧបសគ្គមួយចំនួនជាពិសេស អំពើពុករលួយ បក្ខពួកនិយម និងប្រព័ន្ធតុលាការដែលទន់ខ្សោយ ។គ្មាននរណាម្នាក់បានដឹងថា តើប្រព័ន្ធសេរីដំណើរការ ដោយរបៀបណាទេ នៅពេលដែលបុគ្គលម្នាក់ៗត្រូវបានផ្តល់ឲ្យនូវអំណាចនិងសេរីភាពដើម្បីបង្ហាញខ្លួនឯង ។ សេចក្តីលោភលន់បានគ្រប់គ្រងសតិសម្បជញ្ញៈរបស់ពួកគេ ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានចូលរួមដែរ ក្នុងសមរភូមិនយោបាយជាបន្តបន្ទាប់ រួមមានការបញ្ចប់ខ្មែរក្រហមចុងក្រោយ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ កិច្ចចរចាភាពខុសគ្នាផ្នែកនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សរាជានិយម នៅពេលដែលខ្មែរក្រហមត្រូវរលាយសាបសូន្យពីព្រៃ និងទិដ្ឋភាពនយោបាយកម្ពុជា ។ នៅក្នុងទសវត្សរ៍ឆ្នាំ២០០០ សមរភូមិនយោបាយដ៏កាចសាហាវនៅតែបន្ត ហើយប្រទេសកម្ពុជានៅតែជាប្រទេសប្រជាធិបតេយ្យដ៏ក្មេងខ្ចីមួយ និងមានប្រជាជនតិចតួចណាស់ដែលយល់ពីកម្រិតនៃសិទ្ធិនយោបាយប្រជាធិបតេយ្យរបស់ខ្លួន ។ មិនមានបទដ្ឋាន ដែលត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងការប្រកួតប្រជែងខាងនយោបាយប្រជាធិបតេយ្យទេ ។ ជាញឹកញាប់ យើងបានឃើញថា ទាំងគណបក្សកាន់អំណាច និងគណបក្សប្រឆាំងបានអនុវត្តសិទ្ធិលើសពីដែនកំណត់ ។

បញ្ហាប្រឈមជាចម្បងមួយទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលប៉ុនប៉ងចាកចេញឲ្យឆ្ងាយពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដែលចាប់ផ្តើមកាលពីថ្ងៃ១៧ ខែមេសា គឺកសាងសេដ្ឋកិច្ច លើកកម្ពស់ជីវភាពរស់នៅ និងធ្វើឲ្យប្រសើរឡើងនូវការបែកចាយធនធានដោយសមធម៌ ។ ខ្មែរក្រហមបានធ្វើឲ្យកម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាធ្លាក់ដល់ដី ។ បន្ទាប់ពីរយៈកាលនៃការរស់ឡើងវិញនៃតន្ត្រី និងសិល្បៈ ក៏ដូចជាការប្រសើរឡើងនៃសេដ្ឋកិច្ចនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និងទសវត្សរ៍ឆ្នាំ១៩៦០ ប្រជាជនកម្ពុជាទទួលបាននូវស្ថានភាពរស់នៅមួយដ៏សែនក្រីក្រនៅក្រោមរបបខ្មែរក្រហម ដែលពួកគេរស់នៅក្នុងខុមតោកយ៉ាក និងស្ទើរតែមិនមានអ្វីជាកម្មសិទ្ធិទាល់តែសោះ ។ បើប្រៀបធៀបជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅពេលនោះ និងបច្ចុប្បន្នគឺមានភាពខុសគ្នាច្រើនណាស់ ក៏ប៉ុន្តែជីវភាពនាពេលបច្ចុប្បន្ន មានកម្រិតទាបជាងប្រទេសជិតខាងឆ្ងាយ ដែលប្រទេសជិតខាងបាន ចាប់ផ្តើមពីកម្រិតជីវភាពមួយលំបាកជាងប្រទេសកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ ១៧ មេសា គឺជាថ្ងៃខ្មៅងងឹតបំផុតមួយក្នុងប្រវត្តិសាស្ត្រកម្ពុជា ដូច្នេះប្រជាជនកម្ពុជានៅតែកំពុងខិតខំតស៊ូ ដើម្បីគេចផុតពីបណ្តាសាដែលត្រូវបានដាក់មកលើពួកគេនៅថ្ងៃនោះ ។ **អេង កុកថាយ**

# យុត្តិធម៌ និងការអត់ឱន

សំនួរដ៏សំខាន់មួយ ដែលត្រូវបានចោទសួរបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្ដួលរលំនៅខែមករា ឆ្នាំ១៩៧៩ គឺថាតើការអត់ឱនអាចជ្រាបចូល និងនាំមកនូវការផ្សះផ្សានៅក្នុងប្រទេសជាតិមួយ ដែលធ្លាប់បែកបាក់បានដែរឬទេ និងថាតើការអត់ឱនត្រូវតែស្របតាមទស្សនៈយុត្តិធម៌ ឬមួយយ៉ាងណា ។ នៅពេលដែលការអត់ឱនអាចកើតមានឡើងសម្រាប់បុគ្គលមួយចំនួន ដែលជាសញ្ញាបង្ហាញនៃការផ្សះផ្សា យុត្តិធម៌ ជាពិសេសនាំកម្មាភិបាលថ្នាក់កណ្ដាល និងជាន់ខ្ពស់មកកាត់ទោស ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត នៅតែជាការពិបាក ។

សម័យខ្មែរក្រហមនៅតែដក់ជាប់នៅក្នុងចិត្តប្រជាជនខ្មែរទូទៅដែលតែងតែរំលឹកពួកគាត់ពីការរំលោភ បំពានសិទ្ធិមនុស្សដ៏អាក្រក់មួយក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។ សំណួរពិបាកជាងគេសម្រាប់ប្រជាជនខ្មែរទូទៅគឺថា តើត្រូវអត់ឱនឲ្យនរណា និងហេតុអ្វីការអត់ឱននេះមានសារសំខាន់ ។ ក្រៅពីការតស៊ូដ៏លំបាកលំបិនដើម្បីមានជីវិតរស់នៅ អ្នករស់រានមានជីវិតពីសម័យខ្មែរក្រហមត្រូវស៊ូទ្រាំនឹងការបាត់បង់សមាជិកក្រុមគ្រួសារ ។ ប្រហែលមួយភាគបួននៃចំនួនប្រជាជនកម្ពុជាទាំងអស់ត្រូវបានប៉ាន់ប្រមាណថាស្លាប់ ដោយសារតែគោលនយោបាយដ៏ឃោរឃៅ និងមនោគមវិជ្ជាជ្រុលនិយមរបស់ខ្មែរក្រហម ។ លើសពីនេះទៅទៀត ប្រជាជនភាគច្រើននៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នបាត់បង់សមាជិកគ្រួសារយ៉ាងតិចមួយនាក់ ពីព្រោះរបបខ្មែរក្រហម ។

ចាប់តាំងពីឆ្នាំ១៩៧៩ ប្រទេសកម្ពុជាព្យាយាមផ្សះផ្សា



ប្រជាជននៅខេត្តឧត្តរមានជ័យ ចូលរួមវេទិកាពិភាក្សាសាធារណៈ ស្ដីពីការអប់រំប្រពើប្រល័យពូជសាសន៍ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

ដោយពឹងផ្អែកទៅលើវិធីសាស្ត្រដោះស្រាយ ដែលមាននៅក្នុងទិដ្ឋភាពមួយចំនួននៃសង្គមរបស់យើង ដូចជាការប្រារព្ធពិធីនៃការចងចាំ ការអប់រំពីអំពើយង់ឃ្នងរបស់ខ្មែរក្រហមជាលក្ខណៈផ្លូវការ និងមិនផ្លូវការ ការសារភាពទោសកំហុស មិនមែនជាពាក្យសំដីនៅក្នុងបរិបទកម្ពុជា និងដំណើរការកសាងសន្តិភាពផ្សេងៗទៀត ។ វិធីដោះស្រាយទាំងអស់នេះភាគច្រើននាំឲ្យបុគ្គលមួយចំនួន អត់ឱនឲ្យគ្នាទៅវិញទៅមក ក៏ប៉ុន្តែការអត់ឱនគឺ ជាបញ្ហាផ្ទាល់ខ្លួន ។ សាសនាមានដូចជា ពុទ្ធសាសនា សាសនាមូស្លីម និងគ្រិស្តសាសនា គឺជាទិដ្ឋភាពសង្គមមួយក្នុងចំណោមទិដ្ឋភាពសង្គមដទៃទៀត ដែលត្រូវបានសង្កេតឃើញថា ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយផ្សះផ្សារបួសពីអតីតកាល ដោយស្របតាមជំនឿ និងទំនៀមទម្លាប់របស់អ្នកទាំងនោះ ។ មិនត្រឹមតែជនរងគ្រោះប៉ុណ្ណោះទេ សូម្បីតែជនល្មើសដែលតែងតែអះអាងថាខ្លួនជាជនរងគ្រោះដែរនោះ ក៏ស្វែងរកការអត់ឱនផងដែរ ។ មាស មុត អតីតមេបញ្ជាការកងទ័ពជើងទឹកក្នុងអំឡុងសម័យខ្មែរក្រហម គឺជាឧទាហរណ៍ថ្មីៗមួយ ។ មាស មុត និយាយអំពីការខិតខំប្រឹងប្រែងរបស់គាត់ ដើម្បីកសាងវត្តអារាមសម្រាប់សហគមន៍របស់គាត់ (កាសែតភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥) ។ នេះប្រហែលជាទង្វើសប្បុរសធម៌មួយ ដែលអតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនប្រព្រឹត្ត ដើម្បីស្វែងរកការអត់ឱន ។ អតីតកម្មាភិបាលទាំងនោះយ៉ាងហោចណាស់អាចទទួលបានអារម្មណ៍ធូរស្បើយ សម្រាប់សមិទ្ធផល សង្គម និងសាសនា ដែលបានសម្រេចនៅក្នុងសហគមន៍របស់ខ្លួន ។ បន្ទាប់មក ជនរងគ្រោះអាចនឹងចាប់អារម្មណ៍ទង្វើសប្បុរសធម៌ទាំងអស់នេះ ហើយនិងយល់ឃើញថា ទង្វើនេះជាការសារភាពទោសកំហុសមិនមែន ជាពាក្យសំដី ។ ការអត់ឱនអាចទៅរួចសម្រាប់ ជនរងគ្រោះមួយចំនួន ។

អ្វីដែលគួរឲ្យភ្ញាក់ផ្អើលគឺថា មាស មុត បាននិយាយជាសាធារណៈដោយគ្មានញញើតអំពីការអត់ឱន ។ គាត់អាចនឹងត្រឹមត្រូវត្រង់ចំណុចដែលលើកឡើងថាអតីតខ្មែរក្រហមជាច្រើនត្រូវបានបញ្ជាឲ្យប្រព្រឹត្តបទល្មើស ឬក៏មិនមានឋានៈដែលមានសិទ្ធិអំណាចអាចធ្វើការសម្រេចចិត្តបាន ។ ទោះជាយ៉ាងណាក៏ដោយ អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនមិនអាចបដិសេធបានទេ ពីព្រោះខ្លួនបានប្រព្រឹត្តបទល្មើសដោយខ្លួនឯង ឬធ្វើលើសពីការបញ្ជារបស់ថ្នាក់លើ ដើម្បីប្រព្រឹត្តការរំលោភបំពានសិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ហេតុដូច្នេះហើយ កម្រិតនៃបទល្មើសខុសគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត ។ កម្រិតខុសគ្នានៃបទល្មើសអាចបណ្តាលមកពីសីលធម៌ និងអត្តចរិតរបស់អ្នកមានសិទ្ធិអំណាចតាមតំបន់នៅពេលនោះ ។

ប៉ុន្តែ ការអត់ឱន និងឆន្ទានុសិទ្ធិរបស់តុលាការគឺជារឿងពីរផ្សេងគ្នា ។ យុត្តិធម៌មិនមែនកើតចេញពីការយល់ឃើញរបស់បុគ្គលនោះទេ ប៉ុន្តែកើតចេញពីអង្គហេតុ និងភ័ស្តុតាង ។ នាពេលបច្ចុប្បន្ន មាស មុត ដែលជាជនសង្ស័យនៅក្នុងសំណុំរឿង០០៣ កំពុងប្រឈមមុខនឹងការចោទប្រកាន់ពីបទមនុស្សឃាត និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការអនុវត្តនៃការទទួលខុសត្រូវផ្អែកគតិយុត្តិរបស់ មាស មុត នៅក្នុងសំណុំរឿង០០៣ អាចផ្តល់មេរៀនដ៏ល្អដល់អតីតកម្មាភិបាលខ្មែរក្រហមដទៃទៀត ដើម្បីបញ្ចប់ទម្លាប់បន្ទោសកត្តាខាងក្រៅសម្រាប់ការប្រព្រឹត្តបទល្មើសរបស់ខ្លួន ។ នីតិវិធីច្បាប់មួយនេះអាចធ្វើឲ្យការអត់ឱនកាន់តែជ្រាលជ្រៅបាន ខណៈដែលការចងចាំពីអតីតកាល ជាការចាំបាច់នៅក្នុងសង្គមរបស់យើង ។ ទោះបីជាគោលបំណងស្មុះស្ម័គ្រស្វែងរកការអត់ឱនតាមរយៈទង្វើរបស់ មាស មុត ទាំងប៉ុន្មាន គឺជារឿងល្អ យើងមិនត្រូវចាត់ទុកឆន្ទានុសិទ្ធិ តុលាការក្នុងការកោះហៅ មាស មុត ដើម្បីបង្ហាញការពិតគឺជារឿងគ្មានតម្លៃ ឬមិនមានសារសំខាន់នោះទេ ។

**លី សុខឃាង**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។



# សារមន្ទីរនៃការចងចាំ
# ការប្រារព្ធខួប៤០ឆ្នាំនៃការធ្លាក់ចុះទីក្រុងភ្នំពេញ
# ១៧ មេសា ១៩៧៥ – ១៧ មេសា ២០១៥

*តើយើងអាចបំភ្លេចដោយរបៀបណា? វាជាកិច្ចការមនុស្សជាតិដែលមិនចេះផុតរលត់*

តើពេលវេលាដែលកន្លងផុតទៅ បានធ្វើអ្វីខ្លះដល់ប្រវត្តិសាស្ត្រ? ជាធម្មជាតិ នៅពេលដែលមនុស្សស្លាប់ ការចងចាំរបស់មនុស្សក៏រសាត់បាត់ទៅ ។ ចំណែកឯអារម្មណ៍ដែលដក់ជាប់នឹងអតីតកាលក៏ចាប់ផ្តើមរសាយម្តងបន្តិចៗ ដោយសារតែក្តីបារម្ភពីបច្ចុប្បន្ន និងអនាគត ។ សំណួរមួយបានចោទឡើងថា តើប្រវត្តិសាស្ត្រលែងមានសារសំខាន់ហើយមែនឬទេ? នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកកាន់កាប់ទីក្រុងភ្នំពេញ ដែលមានប្រជាជនប្រមាណពីរលាននាក់កំពុងរស់នៅអំឡុងពេលនោះ ។ ភ្លាមៗនោះ ខ្មែរក្រហមចាប់ផ្តើមអនុវត្តជំហានទី១របស់ខ្លួនដែលប្រើពាក្យថា “ការជម្លៀស” បន្ទាប់មកក៏ក្លាយជា “ការជម្លៀសដោយបង្ខំ” ។ ការជម្លៀសដោយបង្ខំនេះ បានកើតឡើងស្ទើរតែទូទាំងប្រទេសកម្ពុជា ដែលជាការចាប់ផ្តើមដំណើរជីវិតដ៏ជូរចត់របស់ប្រជាជនកម្ពុជាឆ្ពោះទៅរកការព្រាត់ប្រាសគ្នា ការអត់ឃ្លាន ការកាប់សម្លាប់ និងប្រល័យពូជសាសន៍ ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៥ គឺជាថ្ងៃខួបទី៤០ឆ្នាំនៃជំពូកដ៏សែនរន្ធត់ក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ នៅពេលដែលយើងចំណាយពេលវេលាគិតទៅដល់ប្រវត្តិសាស្ត្រនេះ និងផលប៉ះពាល់មកលើសង្គមកម្ពុជា នេះគឺជាប្រការសំខាន់ ដែលយើងគ្រប់គ្នាគួរទាញចំណាប់អារម្មណ៍ផ្តោតទៅលើមូលដ្ឋានគ្រឹះដ៏ចាំបាច់ ដែលជួយដល់ការងាររបស់យើង ។ ការទន់ទោរទៅរកការមិនអើពើព្រងើយកន្តើយ អាចជាគ្រោះថ្នាក់ដូចនឹងការទន់ទោរទៅរកអំពើហិង្សាដូច្នោះដែរ ។ កាលពី៧៥ឆ្នាំមុន នៅថ្ងៃដែល ណាហ្ស៊ីអាល្លឺម៉ង់ ឈ្លានពានប៉ូឡូញ លោក អាល់ដុហ្វ ហ៊ីត្លែ បានតៀនមេបញ្ជាការរបស់ខ្លួនមិនឲ្យបង្ហាញក្តីធម៌មេត្តាបន្តិចសោះចំពោះប្រជាជនប៉ូឡូញ ដោយថ្លែងថា “ជាសំខាន់ តើសព្វថ្ងៃនេះអ្នកណា គឺជាអ្នកដែលនិយាយពីការធ្វើឲ្យជនជាតិអាមេនៀវិនាសសាបសូន្យ? ” ការមិនអើពើព្រងើយកន្តើយ (ក៏ដូចជាភាពអវិជ្ជា) គឺជាការបើកច្រកមួយឲ្យមនុស្សទៅកាន់ភាពអមនុស្សធម៌ ។ ការមិនអើពើព្រងើយកន្តើយ គឺជាវប្បធម៌បណ្តែតបណ្តោយមួយដែលជំរុញឲ្យឈានទៅរកការជិះជាន់កេងប្រវ័ញ្ចគ្នា ហើយក៏ជាសញ្ញាណមួយរបស់សង្គម ដែលបង្ហាញពីការឈានទៅរកការជាន់ដានលើកំហុសអតីតកាលជាថ្មីម្តងទៀត ។ ការមិនអើពើព្រងើយកន្តើយ គឺជារឿងមួយដែលងាយធ្វើបំផុត ។ ដូច្នេះ បើគ្មានកិច្ចប្រឹងប្រែងរបស់យើងទាំងអស់គ្នាដើម្បីការចងចាំ និងការរៀនសូត្រនោះទេ មេរៀនពីអតីតកាលក៏ទំនងជាគ្មានអ្វីទាក់ទងដែរ ។ ជំហានដំបូងក្នុងកិច្ចប្រឹងប្រែងដើម្បីជម្នះនឹងការមិនអើពើព្រងើយកន្តើយ គឺជំរុញឲ្យមានការស្រាវជ្រាវ និងមានសតិសម្បជញ្ញៈ ។ ការស្រាវជ្រាវកម្រិតឧត្តមសិក្សា អាចសម្រេចទៅបានលុះត្រាតែមានកិច្ចប្រឹងប្រែងនៃការចងក្រងឯកសារ តាមរយៈការធ្វើបទសម្ភាស ការប្រមែ

ប្រមូលឯកសារ ការបង្កើតបណ្ណសារ និងការបកប្រែដែលជាមូលដ្ឋានដ៏ចាំបាច់សម្រាប់ធ្វើការវិភាគ និងសំខាន់បំផុតដើម្បីជាមូលដ្ឋានដល់ការអប់រំ ។ ការអប់រំទៀតសោត ត្រូវតែរួមបញ្ចូលទាំងចំណេះដែលមានស្រាប់ និងកម្មសិក្សាដែលជួយឲ្យប្រជាជនត្រិះរិះគិតពិចារណាពីខ្លួនឯង សហគមន៍ និងសង្គមជាតិរបស់ខ្លួនឲ្យបានកាន់តែស៊ីជម្រៅ ។ តន្ត្រី សិល្បៈ ការសម្តែង និងការបង្ហាញពីវប្បធម៌ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សារភ្ជាប់ភាពបែងចែកគ្នា និងបណ្តុះឲ្យមានឆន្ទៈរួម ដើម្បីតម្រង់ទៅរកទស្សនវិស័យថ្មីៗ ។ ប៉ុន្តែ កិច្ចប្រឹងប្រែងតែមួយមុខនេះមិនអាចជម្នះនឹងការមិនអើពើព្រងើយកន្តើយបាននោះទេ ។ កិច្ចប្រឹងប្រែងនេះត្រូវតែធ្វើឡើងជាមួយនឹងការផ្សព្វផ្សាយដ៏ទូលំទូលាយ និងគំនិតដែលអាចផ្លាស់ប្តូរគោលដៅរបស់សង្គមបាន ។ ការផ្លាស់ប្តូរគោលដៅសង្គមគឺជាកិច្ចខ្នះខ្នែងដ៏មានសារសំខាន់ ប៉ុន្តែ ការផ្លាស់ប្តូរនេះមិនមែនជាគោលដៅចុងក្រោយទេ ។ គោលដៅចុងក្រោយរបស់យើង ដូចដែលយើងបានចំណាយពេលដើម្បីការចងចាំ និងឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្ររបស់យើងមិនត្រូវផ្តោតតែលើប្រទេសមួយ វប្បធម៌មួយ ឬក៏តំបន់មួយនោះទេ ។ ជាការពិត គោលដៅចុងក្រោយរបស់យើង គឺជាការផ្លាស់ប្តូរនិយមន័យនៃភាពជាមនុស្ស ។ អំពើរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ គួរតែត្រូវធ្វើឡើងជាសាកលលោក ដើម្បីកាត់ទោសជនដៃដល់ ហើយធានាឲ្យបាននូវភាពយុត្តិធម៌ ។ ជនរងគ្រោះគួរតែទុកចិត្តថា ការឈឺចាប់របស់ខ្លួនត្រូវបានយកចិត្តទុកដាក់ ពុំមានការច្រានចោល ឬក៏បំភ្លេចចោលនោះទេ ។ ជាចុងក្រោយ ភាពជាមនុស្សត្រូវតែយកមកគិតគូរពិចារណា ជាពិសេសដើម្បីសុខុមាលភាពរបស់មនុស្សគ្រប់ៗគ្នា ដោយមិនគិតពីលក្ខខណ្ឌនយោបាយ និងកាលៈទេសៈ ។ ទោះជាយ៉ាងណាក៏ដោយ គោលដៅរបស់យើងមិនទាន់សម្រេចបានទាំងស្រុងនៅឡើយទេ ហើយដូចដែលយើងបានយកចិត្តទុកដាក់ដើម្បីរៀបចំប្រារព្ធខួប៤០ឆ្នាំ នៃជំពូកដ៏ខ្មៅងងឹតក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ទោះបីជា វាមានរយៈពេលយូរប៉ុណ្ណា និងមានឧបសគ្គជាច្រើនដែលធ្វើឲ្យយើងរាថយឆ្ងាយ និងចុះចាញ់ក៏ដោយ ក៏យើងត្រូវបន្តដំណើរទៅមុខ ។ ដើម្បីប្រារព្ធខួប៤០ឆ្នាំ នៃការកាន់កាប់ប្រទេសកម្ពុជារបស់ខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាមានសេចក្តីសោមនស្សរីករាយក្នុងការរៀបចំព្រឹត្តិការណ៍មួយចំនួនដែលមជ្ឈមណ្ឌលបានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នជាតិ និងអន្តរជាតិ ។ ព្រឹត្តិការណ៍នៃការប្រារព្ធពិធីនេះ នឹងរួមបញ្ចូលគោលគំនិត៥ ជាចម្បង ដែលទាក់ទងនឹងការខិតខំទិសដល់ដួងព្រលឹងដែលអាចជួយឲ្យមានអារម្មណ៍ស្ងប់សុខ រូបថត គំនូរតំណាងឲ្យភាពអរូបី ប្រវត្តិសាស្ត្រ ការផ្តួចផ្តើមគំនិតថ្មីទាំងក្នុងប្រទេស និងជាសកល ព្រមទាំងការផ្សព្វផ្សាយភាពយន្ត ។ ព្រឹត្តិការណ៍នេះមានដូចខាងក្រោមៈ

**១)** «អដ្ឋិធាតុចំនួន៨៦៨ៈ គ្មានអ្វីដែលនៅអចិន្ត្រៃយ៍នោះទេ ការស្វែងរកសាច់ញាតិដែលនៅរស់រានមានជីវិត» នឹងប្រារព្ធធ្វើឡើងនៅព្រះវិហារធំនៅវត្តលង្កា ដែលជាកិច្ចសហការរវាងវត្តលង្កា និងឧបត្ថម្ភដោយស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជារាជធានីភ្នំពេញ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក និងក្រុមជាង ក្នុងកងទ័ពជើងទឹកសហរដ្ឋអាមេរិកក្នុង *NCMB* លេខ៥ ។

**២)** «ភ្នំពេញឆ្នាំ១៩៧៩» ពិព័រណ៍រូបថតដែលដាក់តាំងតាមដងទន្លេ ទល់មុខវត្តឧណ្ណាលោម សហការជាមួយនឹងសាលាក្រុងភ្នំពេញ រៀបចំដាក់តាំងជាសាធារណៈ ។

**៣)** «មិនផុតរលត់» ពិព័រណ៍គំនូរ ដោយវិចិត្រករ អ៊ឹង សេរ៉ា និង ជូល្យាន ស៊ុប៊ីស្កី ដែលនឹងដាក់តាំងនៅអគារការិយាល័យក្រុមប្រឹក្សាឧត្តមសិក្សាសហការជាមួយវិទ្យាស្ថានស៊ីករីត (អគារបណ្តោះអាសន្នវិទ្យាស្ថានស៊ីករីត) ស្ថិតក្នុងទីតាំងវិទ្យាស្ថានជាតិអប់រំ ដោយសហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ។

**៤)** «ការជម្លៀសដោយបង្ខំក្នុងរបបខ្មែរក្រហមៈ រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី» សហការជាមួយនឹងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។

**៥)** «ខ្ញុំចង់បានយុត្តិធម៌ៈ ការប្រល័យពូជសាសន៍នៅកម្ពុជា» ពិព័រណ៍ស្តីពីប្រទេសកម្ពុជា សហការជាមួយនឹងសារមន្ទីរហូឡូខូសសហរដ្ឋអាមេរិក ។

**៦)** «ការបើកសម្ពោធពិព័រណ៍ក្រោយវាលពិឃាតៈ ទស្សនវិស័យ ៤០ឆ្នាំនៃប្រល័យពូជសាសន៍កម្ពុជា» កិច្ចពិភាក្សារវាង *Steven Bridges* កុងស៊ុលផ្នែកទូទៅជនជាតិអង់គ្លេសប្រចាំជីខាហ្គោ សហរដ្ឋអាមេរិក អតីតឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា (២០០១-២០០៤) និងឯកអគ្គរដ្ឋទូត *David Scheffer* លេខាធិការជំនាញ

ពិសេស តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម នៃអង្គការសហប្រជាជាតិ និងអតីតឯកអគ្គរដ្ឋទូត ពីបទឧក្រិដ្ឋកម្ម, លោកសាស្ត្រាចារ្យផ្នែកច្បាប់ នៃសាកលវិទ្យាល័យ NFS វេសស្ទើន (ទិសពាយ័ព្យ) និងនាយកមជ្ឈមណ្ឌល សម្រាប់សិទ្ធិមនុស្សអន្តរជាតិ សហការឧបត្ថម្ភដោយមជ្ឈមណ្ឌលសម្រាប់សិទ្ធិមនុស្សអន្តរជាតិ និងសាលាច្បាប់នៃសាកលវិទ្យាល័យ NFS វេសស្ទើន ក្នុងភាពជាដៃគូជាមួយនឹងសមាគមកម្ពុជា នៃអ៊ីលីណយ សហរដ្ឋអាមេរិក ។

**៧)** "កូនមាសម្តាយ ៈ ការបញ្ចាំងខ្សែភាពយន្ត និងវគ្គសំណួរចម្លើយ ដោយនាយក Masahiro Sugano សហការជាមួយនឹងសាកលវិទ្យាល័យ រ៉ាត់ហ្គឺ នូវាក ញូជើស៊ី សហរដ្ឋអាមេរិក នៅបន្ទប់ដាណា ជាន់ទី៤ បណ្ណាល័យដាណា សាកលវិទ្យាល័យ រ៉ាត់ហ្គឺ នូវាក ញូជើស៊ី សហរដ្ឋអាមេរិក ។ សហការឧបត្ថម្ភដោយការផ្តួចផ្តើមគំនិតលើអន្តោប្រវេសន៍ សុខភាព និងមជ្ឈមណ្ឌលឯកសារ Wellbeing និងក្រុមការងារអន្តរជាតិ សិក្សាពីកម្ពុជា និងអាស៊ីអាគ្នេយ៍ ការអភិវឌ្ឍភាសាអាស៊ី និងសម្ពន្ធភាពវប្បធម៌សម្រាប់ការសិក្សាពីអាមេរិកអាស៊ី ។

**៨)** "កុំស្មានបងភ្លេច" ៈ ការបញ្ចាំងខ្សែភាពយន្ត និងការប្រគុំតន្ត្រីពិសេស សហការជាមួយនឹងរោងមហោស្រពទីក្រុងញូយ៉ក ដែលធ្វើឡើងនៅថ្ងៃទី២២-២៨ ពុធ-សុក្រ វេលាម៉ោង ៧ៈ៤០នាទីល្ងាច និងវគ្គសំណួរ-ចម្លើយ ដោយផលិតករ John Pirozzi ។

**៩)** "ប្រសិនបើថ្មចេះនិយាយ" ការបញ្ចាំងខ្សែភាពយន្តភាគខ្លី នៅវិទ្យាស្ថានជាតិអប់រំ (អគារH) ។

**១០)** "ទិវារំឭកការចងចាំ" នឹងរៀបចំឡើងដោយសមាគមវប្បធម៌ខ្មែរ នៃសាកលវិទ្យាល័យ បូស្តុន ម៉ាសាជូសេត នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៥ ដើម្បីប្រារព្ធខួប ៤០ឆ្នាំនៃអំពើប្រល័យពូជសាសន៍កម្ពុជា នៅឡូវែល រដ្ឋម៉ាសាជូសេត សហរដ្ឋអាមេរិក ។

**១១)** "វិទ្យាស្ថានស្លឹករឹត" ពិព័រណ៍ពីរចនាសម្ព័ន្ធសំណង់អគារវិទ្យាស្ថានស្លឹករឹត នៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ស្តីពីទេពកោសល្យ និងការសម្រេចបានឆ្នាំ២០១៥ ដែលរៀបចំឡើង នៅថ្ងៃទី៦-៨ ខែមេសា វេលាម៉ោង៩ព្រឹក-៨ល្ងាច ។ ពិព័រណ៍នេះនឹងបង្ហាញពីលទ្ធផលសម្រេចបានរបស់និស្សិតស្ថាបត្យកម្មចំនួន៥នាក់ និងមានសម្តែងសិល្បៈពេលល្ងាច ។

**១២)** បាវកថា ៈ ដំណើរផ្លូវដ៏វែងឆ្ងាយ ឆ្ពោះទៅរកការចងចាំ និងការគោរពដល់ជនរងគ្រោះនៃរបបខ្មែរក្រហម "ការបង្កើត និងរចនាប្លង់វិទ្យាស្ថានស្លឹករឹត" ។ សេចក្តីសង្ខេប ៈ លោកនាយកវិទ្យាស្ថានស្លឹករឹត ឆាំង យុ និងលោកបណ្ឌិត Zimmer នឹងធ្វើបទបង្ហាញរួមគ្នាមួយលើប្រធានបទប្រវត្តិទូទៅនៃកិច្ចប្រឹងប្រែងដើម្បីរំឭកគុណ និងរៀបចំជាវិទ្យាស្ថាន ដែលរក្សាការចងចាំរបស់ជនរងគ្រោះនៃរបបខ្មែរក្រហមរាប់លាននាក់ ឆ្នាំ១៩៧៥-១៩៧៩ ។ នៅពេលចាប់ផ្តើមបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា នៅពាក់កណ្តាលទសវត្សរ៍ទី៩០ កិច្ចប្រឹងប្រែងរបស់មជ្ឈមណ្ឌល គឺដើម្បីប្រមែប្រមូលឯកសារ ការរៀបចំ និងការរៀបចំជាបណ្ណសារលើឯកសារដើមដែលទាក់ទងនឹងរបបខ្មែរក្រហមឲ្យមានលក្ខណៈជាប្រព័ន្ធ ។ បច្ចុប្បន្ន ឯកសារបានកើនឡើងដល់ទៅចំនួន១លាន ដែលទាក់ទងនឹងរបស់របរភស្តុតាង ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានដើរតួនាទីជាអ្នកផ្គត់ផ្គង់ប្រភពធនធានឯកសារដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលកំពុងប្រើប្រាស់សព្វថ្ងៃ និងដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានផ្តួចផ្តើមធ្វើការងារអប់រំដើម្បីបង្រៀនដល់ពលរដ្ឋកម្ពុជា និងសិស្សានុសិស្ស ពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងផលវិបាកសម្រាប់កម្ពុជាដែរ ។ ជំហានបន្ទាប់សម្រាប់កិច្ចការនេះ គឺការសាងសង់វិទ្យាស្ថានស្លឹករឹត ដែលជាវិទ្យាស្ថានអចិន្ត្រៃយ៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដោយផ្អែកលើកេរដំណែលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា វិទ្យាស្ថានស្លឹករឹតនឹងត្រូវកសាងឡើង ដោយរួមបញ្ចូលសាលាអប់រំអំពើប្រល័យពូជសាសន៍ ជម្រោះ និងការសិក្សាពីសិទ្ធិមនុស្ស, មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍគោលនយោបាយជាតិ និងសារមន្ទីរនៃការចងចាំ ។ បទបង្ហាញនេះ នឹងពន្យល់ពីរបៀបរចនាប្លង់វិទ្យាស្ថានស្លឹករឹត ដែលជួយដល់ការបង្កើតវិធីសាស្ត្រថ្មីៗ ទាក់ទងនឹងការលើកទឹកចិត្ត សម្រាប់សំណង់ស្ថាបត្យកម្មបែបបូជនីយដ្ឋានថ្នាក់ជាតិមួយនេះ ។ ការរចនាប្លង់ស្ថាបត្យកម្មវិទ្យាស្ថាននេះ នឹងធ្វើយ៉ាងណា ដើម្បីបញ្ចៀសពីការចម្លងរចនាសម្ព័ន្ធសំណង់បែបបរទេស ដែលអាចធ្វើឲ្យអ្នកមកទស្សនាមានអារម្មណ៍ធុញថប់ មួហ្មង និងអស់សង្ឃឹម ។ ការរចនាប្លង់នេះ ក៏ឆ្លុះបញ្ចាំងពីគោលគំនិតដែលជ្រើសរើសលោកស្រីស្ថាបត្យករ ហ្សាហា ហាឌីត

ចូលរួមធ្វើកិច្ចការនេះ ក្នុងន័យបង្ហាញពីសំណង់បូជនីយដ្ឋានរចនាដោយស្ត្រីដែរ ។ ប្រការនេះ គឺជាការផ្ទុយស្រឡះពីសំណង់បែបបូជនីយដ្ឋានទូទៅក្នុងពិភពលោក ដែលត្រូវបានរចនាបង្កើតឡើងដោយស្ថាបត្យករបុរស ហើយដែលមានតែជនរងគ្រោះភាគច្រើនជាស្ត្រី និងកុមារ មកប្រារព្ធវិញ្ញាណក្ខន្ធនៅអគារទាំងនោះប៉ុណ្ណោះ ។ បាវកថានេះ សហការជាមួយនឹងសាលាសិក្សាបូព៌ាប្រទេស និងអាហ្វ្រិក, ផ្នែកប្រវត្តិសិល្បៈ និងបុរាណវិទ្យាអាស៊ីអាគ្នេយ៍នៃសកលវិទ្យាល័យឡុងដ៍ ។

## គំហើញវិចិត្រករ
## មិនផុតរលត់

### «នៅពេលដែលអ្នកមិនអាចបញ្ចប់គំនូររបស់ខ្លួនឯងបាន អ្នកនឹងបោះបង់វាចោល»

*ដកស្រង់ចេញពីវិចិត្រករ Giacometti ដោយទស្សនវិទូ Giorgio Agamben*

បើទោះបីជានៅក្នុងផ្នែកសិល្បៈ ឬផ្នែកសច្ចៈ អ្វីៗទាំងអស់នឹងបញ្ចប់ដោយភាពអាថ៌កំបាំង នៅពេលដែលសិល្បករប្រើដៃរចនាទៅលើវត្ថុសិល្បៈណាមួយ ។ វត្ថុសិល្បៈនោះមើលទៅហាក់ដូចជាមានជីវិត ឬហាក់ដូចជាកំពុងទន្ទឹងរង់ចាំអ្វីមួយ ។ «នៅពេលខ្លះវត្ថុនោះហាក់ដូចជាកំពុងគិតអំពីរឿងរ៉ាវអ្វីមួយ» លោក Henri Focillon ធ្លាប់បាននិយាយដូច្នេះ ។

តើនៅពេលណា និងនៅត្រឹមកម្រិតណាដែលដៃរបស់សិល្បករនឹងឈប់ បន្ទាប់ពីខ្លួនបានគូរអស់រយៈជាច្រើននាទី? តើនៅពេលណាដែលសិល្បករនឹងក្រោកចេញពីការងាររបស់ខ្លួន? តើនៅពេលណា ដែលភាពដាច់ខាត និងភាពពិបាកយល់របស់ការងារមួយនឹងអាចបង្ហាញឲ្យឃើញ?

ខួបទី៤០ឆ្នាំ នៃថ្ងៃប្រវត្តិសាស្ត្រ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលនាំប្រទេសកម្ពុជាឲ្យធ្លាក់ចូលទៅក្នុងភាពងងឹតនៃអំពើប្រល័យពូជសាសន៍ ។ សំណួរជាច្រើនអាចនឹងនឹកឃើញនៅពេលដែលយើងគិតដល់អំពីពេលវេលា និងមហន្តរាយដែលនៅតែចងចាំ និងមិនអាចបំភ្លេចបាន ។ តើមានបុគ្គលណាម្នាក់អាចរៀបរាប់អំពីការបំផ្លិចបំផ្លាញទាំងឡាយនោះ? តើប្រជាជនអាចរំដោះខ្លួនចេញពីបញ្ហាផ្លូវចិត្ត និងការស្លាប់ដោយរបៀបណា?

ពិព័រណ៍គំនូរនេះនឹងរំឭកអំពីសំណួរទាំងអស់នេះ ប៉ុន្តែមិនចង្អុលប្រាប់អំពីចម្លើយនោះទេ ។ ក្នុងនាមជាវិចិត្រករ ការងាររបស់យើងគឺស្វែងចេញតាមរយៈរូបភាព និងវត្ថុសិល្បៈជាមួយនឹងភាពប្រឹងប្រែងទៅលើអ្វីដែលពិបាកនឹងសម្រេចបាន និងអ្វីដែលមិនគួរឲ្យជឿ ។ អ្វីៗទាំងអស់នេះនឹងផុសចេញតាមរយៈជីវិតឯកជន និងសមូហភាពរបស់យើងទាំងអស់គ្នា ។

យើងសង្ឃឹមថា ស្នាដៃនេះនឹងផ្តល់ជាសក្ខីកម្មអំពីការបន្តរស់រានមានជីវិត ពោលគឺមិនមែនបង្ហាញអំពីភាពខ្ទេចខ្ទាំនោះទេ ។ ស្នាដៃបង្កើតកើតចេញពីការចងចាំនៃព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងសៀវភៅ «អដ្ឋិធាតុចំនួន៨៦៨: គ្មានអ្វីដែលនៅអចិន្ត្រៃយ៍នោះទេ» ដែលបោះពុម្ពដោយវិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ។

ស្រដៀងគ្នានឹងការរកឃើញកោដ្ឋតម្កល់ធាតុនៅវត្តលង្កា គំនូរមួយផ្ទាំងៗ នៅក្នុងពិព័រណ៍នេះនឹងបង្ហាញពីភាពបន្តរស់រានមានជីវិត បើទោះបីជាជីវិតទាំងអស់នោះត្រូវបានបោះបង់ចោលនៅក្នុងភាពងងឹត ។ យើងបានប្រើទាំងវិធីសាស្ត្រអរូបី និងរូបីដោយបញ្ចូលរូបកោដ្ឋទៅក្នុងគំនូរ និងរូបដែលយើងសូនឡើង ។ នៅក្នុងន័យនេះ រូបគំនូរ និងរូបសូននឹងតំណាងឲ្យកោដ្ឋដែលបង្ហាញអំពីការថែរក្សាការចងចាំ និងជីវិត ។

ពិព័រណ៍ស្តីអំពី «មិនផុតរលត់» នឹងរៀបរាប់អំពីទេវភាពនៃស្នាដៃសិល្បៈ ក៏ដូចជាទេវភាពនៃប្រវត្តិសាស្ត្រ ។ ការបោះបង់ចោលដែលលោក Giacometti បាននិយាយសំដៅទៅលើការដោះលែង ពោលគឺមិនមែនសំដៅទៅលើការចុះចាញ់នោះទេ ។ យើងមិនមានបំណងបកស្រាយអំពីរឿងរ៉ាវសង្គម ឬនយោបាយនោះទេ ។ អ្វីដែលយើងមានបំណងឆ្លុះបញ្ចាំងគឺ ភាពរស់រានមានជីវិតដែលមានតែការចាប់ផ្តើម និងមិនចេះផុតរលត់ ។

ដោយហេតុនេះហើយ ដៃរបស់យើងបានដក់ជាប់នូវបុព្វហេតុប្រវត្តិសាស្ត្រ និងការចងចាំ ។ ហាក់ដូចជា មានជីវិត ហាក់ដូចជាកំពុងរង់ចាំ និងហាក់ដូចជាកំពុងបញ្ចេញនូវដង្ហើមដែលមិនចេះផុតរលត់ ។

ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៥

**អ៊ឹង សេរ៉ា និង ឌូលាន ហ្ស៊ីប៊ីស្គី**

# ពិធីបើកសម្ពោធការតាំងពិព័រណ៌ មិនផុតរលត់ 
# នៅវិទ្យាស្ថានជាតិអប់រំ នៅ










# ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា
# ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥










# គង់ ទួន ហៅ តាន់ អនុប្រធានកងធំទី១ វរសេនាតូច៩១៣ វរសេនាធំ៩១ កងពល៩២០

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៥៩០០១***

គង់ ទួន ហៅ តាន់ មានតួនាទីជាអនុប្រធានកងធំទី១ វរសេនាតូច៩១៣ វរសេនាធំ៩១ កងពល៩២០ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តាន់ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៨ ហើយបានបញ្ជូនខ្លួនមកឃុំឃាំងនៅមន្ទីរស-២១ ជាទីកន្លែងដែលគាត់ត្រូវបានសួរចម្លើយ និងសម្លាប់ចោល ។ ខាងក្រោមគឺជាសេចក្តីសង្ខេបចម្លើយសារភាពរបស់តាន់៖

គង់ទួន ហៅ តាន់ ភេទប្រុស អាយុ២៣ឆ្នាំ កើតនៅភូមិសំរោង ឃុំអណ្តូងសំរោង ស្រុកលើកដែក តំបន់២៥ ។ មុនចូលបដិវត្តន៍ តាន់ ធ្វើចម្ការ និងធ្វើស្រែប្រាំង និងបានរៀនសូត្រដល់ថ្នាក់ ទី៧ ។ ក្រោយពីឈប់រៀន តាន់ បានបួសជាសង្ឃនៅវត្តស្រែក្នុង ។ តាន់ បានចូលបម្រើបដិវត្តន៍នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧១ នៅមន្ទីរឃុំអណ្តូងសំរោង ។ ឆ្នាំបន្ទាប់ក៏បានចូលកងទ័ពនៅស្រុកកោះធំ មាននាទីជាយុទ្ធជនស៊ើបការណ៍កងទ័ពស្រុក ។ ក្រោយមកឈ្មោះ ម៉ង់ អនុបញ្ជាការទ័ពស្រុក តំបន់២៥ (បច្ចុប្បន្នចាប់ខ្លួនហើយ) បានអប់រំបញ្ចុល តាន់ និងមនុស្សពីរនាក់ទៀតឈ្មោះ ស៊ាងលី ប្រធានកងតូច និងឈ្មោះ សារិន ប្រធានកងតូច ឆ្នាំ១៩៧៣ ប្រធានកងពិសេសតំបន់២៥ ឲ្យចូល សេ.អ៊ី.អា ជាមួយគ្នានៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧២ អ្នកទទួលស្គាល់ឈ្មោះ ជា ប្រធានកងទ័ពស្រុកកោះធំ តំបន់២៥ ឆ្នាំ១៩៧៥ ជាលេខាតំបន់២៥, ឈ្មោះ កាត ជាអ្នកអានប្រវត្តិរូប មានតួនាទីជាបញ្ជាការកងទ័ពស្រុកកោះធំ តំបន់២៥ ។ ក្រោយពីបញ្ចុលអ្នកទាំងបីជាសមាជិកសេ.អ៊ី.អា រួចហើយ ឈ្មោះ ជា បានដាក់ទិសឲ្យអ្នកទាំងបីអនុវត្តគឺ៖ ត្រូវបេះរក្សាការសម្ងាត់ក្នុងជួរបដិវត្តន៍ឲ្យបានល្អ ខិតខំកសាងកម្លាំងសេ.អ៊ី.អា ឲ្យបានច្រើន ត្រូវបំផ្លាញកម្លាំងបដិវត្តន៍ ត្រូវបំផុសឲ្យកើតទំនាស់រវាងប្រជាជន និងកងទ័ព ដឹកនាំកងទ័ពឲ្យខូចសីលធម៌ជាមួយកូនចៅរបស់ប្រជាជន ធ្វើឲ្យប្រជាជនលែងទុកចិត្តទ័ព ពេលទ័ពយួនវាយជាមួយទ័ពខ្មែរមិនឲ្យជួយ ហើយបានដាក់សញ្ញាសម្គាល់ឲ្យយន្តហោះវាយប្រហារទីតាំងបោះទ័ព ។ បន្ទាប់មក ម៉ង់ បានណែនាំឲ្យ តាន់, សារូ, និង ស៊ាងលី ឲ្យស្គាល់ខ្សែរយៈសេ.អ៊ី.អា មួយចំនួនមានឈ្មោះ ស៊ុង ប្រធានកងតូចក្នុងកងទ័ពស្រុកកោះធំ បច្ចុប្បន្នជាជំនួយការកងពល ៨០១, ពរិទ្ធ ប្រធានក្រុមស៊ើបការណ៍ស្រុកកោះធំ (ឆ្នាំ១៩៧៣ នៅកងពិសេសតំបន់២៥), ឈ្មោះ សុត អនុក្រុមស៊ើបការណ៍កងទ័ពស្រុកកោះធំ (ឆ្នាំ១៩៧៣ នៅមន្ទីរអប់រំតំបន់២៥), ឈ្មោះ ថុង ខ្មែរកម្ពុជាក្រោម ជាយុទ្ធជនស៊ើបការណ៍ (ឆ្នាំ១៩៧៣ នៅកងកាំភ្លើងធំតំបន់២៥), ឈ្មោះ ដឹម យុទ្ធជនស៊ើបការណ៍ស្រុកកោះធំ ។ ពេលបានស្គាល់ខ្សែរយៈសេ.អ៊ី.អា ហើយ តាន់ និងបក្ខពួកបាន



យោធាខ្មែរក្រហមកំពុងប្រយុទ្ធនៅសមរភូមិមុខ

ធ្វើសកម្មភាពបំផុសឲ្យយុទ្ធជននៅក្នុងអង្គភាពដើរហើរសេរី និងខូចសីលធម៌ជាមួយកូនចៅរបស់ប្រជាជន ។

ឆ្នាំ១៩៧៣ ឈ្មោះខឿន និង ម៉ង់ បានណែនាំ គាត់ឲ្យស្គាល់ខ្មែរសេអ៊ីអាថ្មីចំនួនបីនាក់ទៀត នៅខាងស៊ើបការណ៍របស់កងវរៈលេខ១១៩ មានឈ្មោះ ហ៊ាង ប្រធានកងស៊ើបការណ៍, សេង អនុប្រធានកងស៊ើបការណ៍ និង ធឿន សមាជិកកងស៊ើបការណ៍ ។ ក្រោយពីបានណែនាំស្គាល់គ្នាមក គាត់ រួមជាមួយបក្ខពួកផ្សេងទៀត បានធ្វើសកម្មភាពជាបន្តបន្ទាប់ ។ នៅសមរភូមិបន្ទាយព្រែកថ្មី ពេលវាយខ្មាំងជិតឈ្នះហើយបែរជាបញ្ជាឲ្យដកទ័ពថយវិញ បណ្តាលឲ្យកម្លាំងបដិវត្តន៍របួសពាក់ និងកម្លាំងសេ.អ៊ី.អា របួសពីរនាក់ ។ នៅកោះពាមរាំង ពេលខ្មាំងឡើងមកមិនបញ្ចេញកម្លាំងទ័ពទៅទប់ទល់ជាមួយកម្លាំងរបស់ខ្មាំងទេ បែរជាដកទ័ពចេញអស់ទុកឲ្យខ្មាំងឡើងចុះស្រេចចិត្ត ។

ក្រោយមក គាត់ និង សុត ត្រូវបានដកទៅមន្ទីរកងវរៈ ១១៩ ។ ពេលនោះ ម៉ង់ បានចាត់តាំង គាត់ ឲ្យធ្វើជានីសាររបស់ឈ្មោះ ម៉ន នៅកងធំ៩១ ក្នុងកងវរៈ១១៩ ហើយបានណែនាំឲ្យស្គាល់ខ្មែររយៈមួយចំនួនទៀតមានឈ្មោះ យន អនុយោធាកងធំ ៩១ (ឆ្នាំ១៩៧៥ ធ្វើស្រែនៅកងផលិតរបស់តំបន់២៥), ម៉ក់ យោធាកងធំ (ឆ្នាំ១៩៧៥ ធ្វើស្រែនៅកងផលិតរបស់តំបន់២៥), ជា អនុយោធាកងធំ (ឆ្នាំ១៩៧៥ ធ្វើស្រែនៅកងផលិតរបស់តំបន់ ២៥), ស្រេង នយោបាយកងធំ (ឆ្នាំ១៩៧៣ នៅកងវរៈ១២៤ តំបន់២៥), គារ ប្រធានកងធំ ពេលកងវរៈ១១៩ឡើងមកភាគពិសេសខាងជើងភ្នំពេញអង្គការដកទៅកងវរៈ១២៤ តំបន់២៥, អឿន ប្រធានកងតូច (ឆ្នាំ១៩៧៤ រត់ពីសមរភូមិខាងជើងភ្នំពេញទៅតំបន់២៥), និងចាត់តាំង គាត់ ឲ្យតាមដានសកម្មភាពរបស់ ម៉ន បើធ្វើឲ្យ សេ.អ៊ី.អា បែកការណ៍ឲ្យបាញ់ ម៉ន សម្លាប់ចោលតែម្តង ។

ឆ្នាំ១៩៧៤ គាត់ និងបក្ខពួកបានទៅតំបន់២៥ ហើយបានទាក់ទងខ្មែរចាស់ឡើងវិញ ។ ក្រោយមកឈ្មោះ ខឿន និង ស៊ុង បានណែនាំ គាត់ ឲ្យស្គាល់ខ្មែរថ្មីដែលទើបកសាងបាននៅក្នុងកងវរៈមានឈ្មោះ ណេង ប្រធានកងតូចនៅកងវរៈ១១៩ (ឆ្នាំ ១៩៧៤បាត់ខ្លួននៅក្នុងសមរភូមិ), មាង យី ប្រធានកងតូចនៅកងវរៈ១១៩ (បច្ចុប្បន្នក្តាប់មិនបាន), ព្រឹម ស៊ិន អនុយោធាកងតូចនៅកងវរៈ៨២១ (បច្ចុប្បន្នអង្គការចាប់), សុខ ប្រធានសេដ្ឋកិច្ចកងវរៈ១១៩ (បច្ចុប្បន្នក្តាប់មិនបាន), ព្រង អនុប្រធានសេដ្ឋកិច្ចកងវរៈ១១៩ (បច្ចុប្បន្នក្តាប់មិនបាន), គាម គក់ យោធាកងធំនៅកងវរៈ២១៩ (ស្លាប់ឆ្នាំ១៩៧៤ ដោយជំងឺគ្រុនចាញ់), គង់ ផន ប្រធានកងធំនៅកងវរៈ២១៩ (បច្ចុប្បន្នប្រធាន កងធំ នៅកងវរៈ៨២១ វរសេនាធំ៨២ កងពល៨០១), លី លន យោធាកងធំនៅកងវរៈ២១៩ (ស្លាប់ឆ្នាំ១៩៧៤ នៅសមរភូមិ), ឌុច ផាត់ ប្រធានកងធំនៅកងវរៈ២១៩ (ស្លាប់ឆ្នាំ១៩៧៤ នៅ សមរភូមិ), ឡុច ឡោ យោធាកងធំនៅកងវរៈ២១៩ (បច្ចុប្បន្នយោធាកងធំនៅកងវរៈ៨២១ វរសេនាធំ៨២ កងពល៨០១), ភ្លោ ម៉ន យោធាកងវរៈ២១៩ (ស្លាប់ឆ្នាំ១៩៧៤ដោយសារផ្ទុះ មីន), ឈឹម ឈឿន ប្រធានកងតូចនៅកងវរៈ២១៩ (បច្ចុប្បន្នប្រធានកងតូច នៅកងវរៈ៨២១ វរសេនាធំ៨២ កងពល៨០១), ឈក់ សយ ប្រធានកងតូច នៅកងវរៈ២៩១ វរសេនាធំទី២ កងពល១៤ (បច្ចុប្បន្នកងធំ នៅវរសេនាធំ៩៣ កងពល៩២០), បាវ រឿង យោធាកងតូច នៅកង វរៈ២១៩, អែល សា អនុយោធាកងធំនៅកងវរៈ២១៩ (ស្លាប់ឆ្នាំ១៩៧៥) ។ ក្រោយពីបានស្គាល់ខ្មែររយៈថ្មីហើយ គាត់ និងបក្ខពួកបានរួមគ្នាធ្វើសកម្មភាពជាបន្តបន្ទាប់ បំផុសឲ្យយុទ្ធជនរត់ទៅតំបន់២៥វិញ នៅលើសមរភូមិវាយដកៗ ជាហេតុធ្វើឲ្យខ្មាំងវាយដណ្តើមយកខដុង្គបាន ។

ខែកក្កដា ឆ្នាំ១៩៧៤ គាត់ ត្រូវរបួស ហើយបានទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ២៧ និង២៨របស់ភូមិភាគពិសេស ។ រយៈពេលជាងបីខែនៅក្នុងមន្ទីរពេទ្យ គាត់ មិនបានទាក់ទងជាមួយខ្មែររយៈណាមួយដើម្បីធ្វើសកម្មភាពទេ លុះដល់ខែតុលា ពេលចេញពីមន្ទីរពេទ្យទៅអង្គភាពទើបបានទាក់ទងខ្មែរចាស់ឡើងវិញ ។ គាត់ មាននាទីជាប្រធានមន្ទីរកងធំ និងបានរួមសកម្មភាពជាមួយឈ្មោះ ស៊ិន បំផុសឲ្យយុទ្ធជនរត់ទៅផ្ទះ ។

ឆ្នាំ១៩៧៥ ស៊ុង បានណែនាំ គាត់ និងបក្ខពួកឲ្យស្គាល់ថ្នាក់ដឹកនាំសេ.អ៊ី.អាថ្មីពីរនាក់គឺឈ្មោះ ហឿន យោធាកងវរៈ២១៩ និងឈ្មោះ ណាក់ អនុយោធាកងវរៈ២១៩ បច្ចុប្បន្នជាជំនួយការកងពល៩២០ (ត្រូវបានអង្គការចាប់ខ្លួនហើយ) ។ ក្រោមការដឹកនាំរបស់ ណាក់ និង ហឿន, គាត់ និងបក្សពួកបានបំផុសយុទ្ធជននៅក្នុង

អង្គភាពឲ្យបាញ់បោះសេរីបំផ្លាញគ្រាប់រំសេវ ទុកស្បៀងចោល មិនយកទៅឧបត្ថម្ភយុទ្ធជននៅសមរភូមិមុខ ធ្វើឲ្យបែកការណ៍ បណ្តាលឲ្យយន្តហោះខ្មាំងមកកម្ទេចទីតាំងបោះទ័ពបណ្តាលឲ្យរបួសយុទ្ធជនពីរនាក់ ។ ដើរបំផ្លាញតុ ទូ និងបំផ្លាញទ្វារផ្ទះមួយចំនួនដែលជាប់សោ ។ ទាក់ទងជាមួយពួកចោរព្រៃ និងផ្តល់ស្បៀងឲ្យទៅពួកចោរព្រៃនៅឯភ្នំ ។

ខែធ្នូឆ្នាំ១៩៧៥ កងវរៈ២១៩ វរសេនាធំទី២ កងពល១៤ បានផ្លាស់លេខទៅជាកងវរៈ៨២១ វរសេនាធំ៨២ កងពល៨០១ និងបានផ្លាស់ទីតាំងឲ្យទៅការពារព្រំដែននៅខេត្តស្ទឹងត្រែង ពេលនោះ គាន់ មាននាទីជាប្រធានកងតូច នៅកងធំ២១១ វរសេនាតូច៨២១ វរសេនាធំ៨២ កងពល៨០១ ហើយបានបោះទីតាំងនៅតាមដួរមាត់ទន្លេសេកុងទល់មុខស្រុកសៀមប៉ាង ។ ឈ្មោះ ស៊ុង បានចាត់តាំង គាន់ ឲ្យភ្ជាប់ខ្សែទាក់ទងជាមួយឈ្មោះ សំបុក ដែលជាខ្សែរបស់ ស៊ិន និងបានទទួលផែនការមកអនុវត្តនោះគឺ៖ ទី១ កសាងពង្រីកកម្លាំងសេ.អ៊ី.អា ឲ្យបានច្រើនថែមទៀត ទី២ បំផុសឲ្យកើតមានទំនាស់រវាងកងទ័ព និងប្រជាជននៅតាមមូលដ្ឋាន ទី៣ បំផុសអំពីជំងឺគ្រុនចាញ់ដល់យុទ្ធជនក្នុងការរស់នៅកន្លែងថ្មីដើម្បីឲ្យយុទ្ធជនមានការភ័យខ្លាចនាំគ្នារត់ទៅផ្ទះវិញ និងទី៤ បាញ់ក្របីរបស់ប្រជាជនយកទៅធ្វើម្ហូប ។ បន្ទាប់មក គាន់ និងបក្សពួកបានធ្វើសកម្មភាពមិនឲ្យយុទ្ធជនចេញទៅត្រួតពិនិត្យនៅតាមព្រំដែនញឹកញាប់ឡើយ ។ ពេលធ្វើស្រែឲ្យសម្រុកប្រើគ្រាប់ពូជស្រូវសាបសំណាបឲ្យច្រើន ពេលស្ទូងមិនទាន់ធ្វើឲ្យខូចសំណាបអស់ជាច្រើន ។ លួចរបស់រួមហូប មិនទទួលខុសត្រូវពេលធ្វើការងារ បណ្តោយឲ្យក្របីចូលស៊ីសន្ទូងខូចអស់ជាច្រើន ។

ខែតុលា ឆ្នាំ១៩៧៦ គាន់ បានរាយការណ៍ឲ្យឈ្មោះ ស៊ិន ពីសភាពការណ៍ផ្សេងៗនៅតាមមូលដ្ឋាន ។ ពេលនោះ ស៊ិន បានហៅខ្សែសេ.អ៊ី.អា របស់ ខាំដែង លេខាស្រុកសៀមប៉ាង មានឈ្មោះ សែន, សាំង, ហឿន, ខាន់ ឲ្យមកប្រជុំដើម្បីដាក់ផែនការសម្រាប់ខែតុលា និងខែធ្នូ ឆ្នាំ១៩៧៦ មាន៖ ទី១ ចាត់តាំងកម្លាំងមូលដ្ឋាន និងកម្លាំងទ័ពឲ្យទៅទាក់ទងជាមួយលាវ និងនាំទ័ពលាវចូលមកក្នុងដីកម្ពុជា ទី២ នៅខែធ្នូ ត្រូវរួមជាមួយទ័ពលាវវាយយកស្រុកសៀមប៉ាងរួមជាមួយផែនការវាយផ្លូវលេខ១៩ ទី៣ ពេលបើកការវាយប្រហារកម្លាំងសេ.អ៊ី.អា នៅក្នុងជួរទ័ពត្រូវដណ្តើមយកអាវុធ ហើយរត់ទៅចូលរួមជាមួយទ័ពលាវ ទី៤ សេ.អ៊ី.អា នៅមូលដ្ឋានត្រូវក្តាប់ និងប្រមូលប្រជាជនឲ្យបានដើម្បីជាកម្លាំងជួយឧបត្ថម្ភស្បៀងដល់កងទ័ព ។ ក្រោយពីប្រជុំ សែន បានចាត់តាំងកម្លាំងនៅក្នុងសហករណ៍ឲ្យទៅទាក់ទងជាមួយកងទ័ពលាវឲ្យចូលមកដីខ្មែរជួយជាកម្លាំងដល់កងទ័ពក្បត់ ។ ទ័ពលាវក៏បានចូលមកស៊ើបការណ៍នៅសហករណ៍បាបាំង សហករណ៍សៀមប៉ាង និងសហករណ៍ភូមិខិ ។ នៅពេលដែលប្រជាជនបានប្រទះឃើញទ័ពលាវចូលមកក្នុងទឹកដីរបស់ខ្លួនដូច្នេះក៏បានរាយការណ៍ឲ្យអង្គការ ។ អង្គការក៏បានដាក់បញ្ជាឲ្យកងវរៈ៨២១ ទៅល្បាតតាមចំណុចដែលប្រជាជនបានរាយការណ៍ប្រាប់ត្រៀមចាំកម្ទេចកងទ័ពលាវ ។ ចាប់ពីពេលនោះមកកងទ័ពលាវ និងខ្សែទាក់ទងរបស់ សែន និង ស៊ិន បាត់ដំណឹងលែងឃើញមកទាក់ទងធ្វើសកម្មភាពជាមួយគ្នាទៀត ។ ឯសភាពការណ៍នៅផ្លូវលេខ១៩ ក៏ស្ងាត់ឈឹងដាច់ការទាក់ទងគ្នា ផែនការខែធ្នូឆ្នាំ១៩៧៦ ត្រូវបរាជ័យ ដោយសារដាច់ការទាក់ទងមកពីក្រៅ ចំណែកមេក្បត់ឈ្មោះ កែវ សារឿន ត្រូវបានអង្គការចាប់ខ្លួន ។

ឆ្នាំ១៩៧៧ អង្គភាពរបស់ គាន់ ត្រូវបានទៅការពារព្រំដែននៅតាមចំណុចផ្លូវលេខ១៣ ចេញពីស្ទឹងត្រែងទៅលាវ និងបានបោះទីតាំងនៅភូមិណាអួងជិតកងទ័ពភូមិភាគឦសាន ។ ពេលនោះ គាន់, ឡៅ, ស៊ិន, យី, ស្រ៊ិន, ឆុន, វ៉ែន បានទទួលផែនការពី សំបុក ហើយបានយកផែនការនេះទៅអនុវត្តយ៉ាងសកម្ម ដោយបំផុសពីជំងឺគ្រុនចាញ់ឲ្យយុទ្ធជនខ្លាចរអាខ្ជិលធ្វើការងារ លួចសម្ភារយុទ្ធជននៅក្នុងអង្គភាព ទាក់ទងរកស៊ីឯកជនជាមួយកងទ័ពមូលដ្ឋានធ្វើឲ្យយុទ្ធជនក្នុងអង្គភាពប្រេះឆាខ្វះការសាមគ្គី និងលែងទុកចិត្តគ្នាពេលដើរល្បាតការពារព្រំដែន ។ ក្រោយមក គាន់ និងបក្សពួកបានទាក់ទង ម៉ុង និង អន ដែលជាខ្សែរយៈរបស់ ស៊ិន ហើយបានកសាងកម្លាំង សេ.អ៊ី.អា ជាបន្តបន្ទាប់បន្ថែមទៀត ។

នៅខែកក្កដា ឆ្នាំ១៩៧៧ ឈ្មោះ ស៊ិន និង សំបុក ត្រូវបានអង្គការចាប់ខ្លួន ។ គាន់ និងបក្សពួកមួយចំនួនបានផ្អាកធ្វើសកម្មភាពមួយរយៈ ។ ពីរខែក្រោយមក គាន់ ត្រូវបានផ្លាស់មកនៅវរៈ៩១៣ ក្រោមការដឹកនាំរបស់ ម៉ុង ។ ម៉ុង និង យ៉ុន បានណែនាំ គាន់ ឲ្យស្គាល់ ប្រុញ, អាន់ និង ប៊ុន ផង ។ គាន់ និង អាន់ បានទទួលការ

ចាត់តាំងឲ្យទៅទាក់ទងទ័ពយួន ដើម្បីរៀបចំផែនការឲ្យយួនជួយជាកម្លាំងទ័ពវាយយកភូមិមេរើដនៅខែមករា-ខែកុម្ភៈ ឆ្នាំ១៩៧៨ ។ ពេលជួបជាមួយអ្នកតំណាងទ័ពយួន គាន់ បានរាយការណ៍ប្រាប់យួនអំពីទីតាំងដែលត្រូវវាយយក ពេលវេលា និងច្រកដែលត្រូវចេញចូលពេលធ្វើសកម្មភាព ហើយខាងភាគីខ្មែរក៏បានត្រៀមបម្រុងស្បៀងអាហារមួយចំនួនសម្រាប់ឧបត្ថម្ភកងទ័ពយួន ឯភាគីយួនក៏បានឯកភាពយល់ព្រមជួយ ហើយបានធ្វើការណែនាំ គាន់ និង អាន់ ឲ្យការពារស្បៀងអាហារឲ្យបានគង់វង្ស ហើយឲ្យគូរផែនទីប្រាប់ពីទីកន្លែងបោះទ័ព និងច្រកចេញចូលពេលធ្វើសកម្មភាពនៅក្នុងទឹកដីខ្មែរប្រគល់ឲ្យក្រុមរបស់ខ្លួនងាយស្រួលពេលធ្វើសកម្មភាព ។ បន្ទាប់មក គាន់ និង អាន់ បានធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពដែលខ្លួនបានទៅជួបចរចាជាមួយយួនប្រាប់ទៅម៉ុង និង យ៉ុន ។ ម៉ុង និង យ៉ុន បានណែនាំ គាន់ ឲ្យស្គាល់ ហុក, ជួន, ឈឿន, សាន់, សុន, រឿន, ដែលជាខ្សែសេ.អ៊ី.អា នៅក្នុងវរសេនាធំ៩១ ។ គាន់ និង អាន់ ត្រូវបានចាត់តាំងជាច្រើនដងច្រើនសាឲ្យទៅទាក់ទងជាមួយយួន ដើម្បីប្រាប់ និងណែនាំពីផែនការដែលត្រូវអនុវត្តរួមគ្នានៅខែមករា-កម្ភៈឆ្នាំ១៩៧៨ ក្នុងការវាយដណ្តើមយកមេរើដ ។

ក្រោយមកទៀត គាន់ បានទៅចូលរួមប្រជុំដើម្បីទទួលផែនការថ្មីម្តងទៀតពីឈ្មោះ ម៉ុង, ហុក, និង យ៉ុន ។ ផែនការមានបួនយ៉ាង គឺៈ ទី១ នៅខែមករា និងខែកម្ភៈ ពេលវាយនៅមេរើដ បើកម្លាំងបដិវត្តន៍ខ្សោយត្រូវវាយបន្តយកកោះរំយើល និងស្រុកច្បារនៅខែមីនា-ខែឧសភា ឆ្នាំ១៩៧៨ ។ ទី២ ពេលវាយប្រហារ កម្លាំងសេ.អ៊ី.អា នៅខាងក្នុងត្រូវវាយដណ្តើមយកអាវុធហើយរត់ទៅចូលរួមជាមួយ ទ័ពយួន ។ ទី៣ បើវាយមិនបែក ត្រូវកម្ទេចឃ្លាំងអាវុធគ្រាប់រំសេវ និងឃ្លាំងស្រូវអង្ករចោលឲ្យអស់ ។ ទី៤ បើវាយឈ្នះត្រូវយកប្រជាជនមកជាមួយឲ្យធ្វើស្រែដើម្បីឧបត្ថម្ភដល់កងទ័ព ។ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៨ អង្គការបានចាត់តាំងអង្គភាពវរសេនាធំ៩១ ឲ្យកម្ទេចទីតាំងទ័ពយួននៅបន្ទាយអូរដាក់ដាំ ។ គាន់, សុន និង ឈឿន ជាអ្នកទទួលខុសត្រូវរៀបចំកម្លាំងកងទ័ពក្នុងយុទ្ធនាការវាយប្រហារទ័ពយួននៅបន្ទាយអូរដាក់ដាំនេះ ។ ពេលនោះ អ្នកទាំងបីបានទាក់ទងគ្នារៀបចំគម្រោងការធ្វើសកម្មភាពសេ.អ៊ី.អា ធ្វើយ៉ាងណាកុំឲ្យផែនការកម្ទេចយួននេះបានសម្រេច ។ សុន និង ឈឿន បាននាំទ័ពចូលជាមួយគ្នាខុសគោលដៅ ខុសការចាត់តាំង ឯកម្លាំងទ័ពដុំគ្នាច្រើនធ្វើឲ្យបែកការណ៍ ទ័ពយួនក៏បានបាញ់មុនមកលើកម្លាំងទ័ពរបស់យើង ។ សុន, ឈឿន និង គាន់ បានបញ្ជាទ័ពវាយសម្រុកទៅមុខ ហើយក៏បានបញ្ជាទ័ពឲ្យដកថយវិញ ។ រីឯ គាន់ ដើរពីក្រោយទ័ព នាំទ័ពទៅហួសខ្សែត្រៀមយ៉ាងឆ្ងាយ ហើយក៏នាំកងទ័ពត្រឡប់មកវិញមិនបានសហការគ្នាជួយវាយយួនទេ ធ្វើឲ្យផែនការវាយយួនរបស់បក្សត្រូវបរាជ័យ ។ រីឯផែនការរបស់ក្រុមសេ.អ៊ី.អា ដែលត្រូវអនុវត្ត វាយយកភូមិមេរើដនៅខែមករា ខែកម្ភៈ ឆ្នាំ១៩៧៨ ក៏ត្រូវបរាជ័យដែរ ព្រោះមេដឹកនាំសេ.អ៊ី.អា នៅមូលដ្ឋានឈ្មោះ អាក់ ភួន អនុលេខាតំបន់១០៥ ត្រូវបានអង្គការចាប់ខ្លួននៅខែធ្នូ ឆ្នាំ១៩៧៧ ចំណែក កងទ័ពតំបន់ក៏ដកមកក្រោយទៀត ធ្វើឲ្យការទាក់ទងគ្នាទាំងខាងក្នុង និងខាងក្រៅត្រូវដាច់ ។ ទីបំផុតចលនាសេ.អ៊ី.អា ត្រូវបញ្ចប់សមាជិកមួយចំនួនត្រូវអង្គការចាប់ខ្លួនជាបន្តបន្ទាប់ ។ គាន់, សុន, និងមេដឹកនាំ ឈ្មោះ មូល ណាក់ ក៏ត្រូវអង្គការចាប់ខ្លួនបាននៅក្នុងថ្ងៃតែមួយគឺថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៨ ។

ចម្លើយសារភាពរបស់ គង់ ទួន ហៅ គាន់ បែកចេញជាពីរផ្នែក ។ ផ្នែកទីមួយវាយអង្គុលីលេខសរសេរពីប្រវត្តិ និងសកម្មភាពក្បត់បដិវត្តន៍មុន និងក្រោយថ្ងៃរំដោះរបស់ គាន់ ដោយសង្ខេបមានចំនួន៨ទំព័រ ដែលនៅទំព័រចុងក្រោយផ្នែកខាងក្រោមមានសរសេរថា “ជូនបងពិនិត្យលើសេចក្តីសរុបនេះបន្ថែមទៀត” មានចុះហត្ថលេខា និងឈ្មោះមិត្តភាព និងមានចុះកាលបរិច្ឆេទថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨ ។ ផ្នែកទីពីរជាឯកសារចម្លើយសារភាពសរសេរដោយដៃផ្ទាល់មានចំនួន៤៨ទំព័រ និងថែមចំនួន១២ទំព័រផ្សេងទៀត ដែលជាបញ្ជីរាយឈ្មោះបក្ខពួកដែលបានធ្វើសកម្មភាពក្បត់រួមគ្នាជាមួយ គាន់ មានចំនួន៧៣នាក់ ។ នៅចុងបញ្ចប់នៃចម្លើយសារភាពផ្នែកខាងស្តាំមានស្នាមផ្តិតមេដៃ និងចុះហត្ថលេខារបស់ គង់ ទួន ហៅ គាន់ ចុះកាលបរិច្ឆេទថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៨ ។ នៅផ្នែកខាងឆ្វេងមានចុះហត្ថលេខារបស់អ្នកធ្វើឯកសារឈ្មោះ អ៊ឹម អឿន និងមានចុះកាលបរិច្ឆេទធ្វើឯកសារ ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨ ។ **ឆេង ទេង**

# «វីរភាពរបស់យុវជនបដិវត្តន៍អនាមិកម្នាក់»

***អត្ថបទស្រង់ចេញពីទស្សនាវដ្ដីទង់បដិវត្តន៍លេខពិសេសចេញផ្សាយ ខែកញ្ញា ឆ្នាំ១៩៧៥ D២១៣៨៣***

នៅចុងឆ្នាំ១៩៧០ ចក្រពត្តិអាមេរិក និងបនអាក្បត់ជាតិ លន់ នល់, សិរិមតៈ, សឺង ង៉ុកថាញ់, អ៊ិន តាំ, ចេង ហេង បានបើកវគ្គធំមិនធ្លាប់មានរាគត្បាតប្រជាជនស្លូតត្រង់ដែលស្នេហាជាតិ និងអ្នកបដិវត្តន៍កម្ពុជាយើង ដែលធ្វើការតស៊ូសម្ងាត់នៅក្នុងក្រុងភ្នំពេញ យ៉ាងកាចសាហាវព្រៃផ្សៃបំផុត ។ អាលន់ នល់ ផ្ទាល់បានស្រែកគំរាមតាមវិទ្យុ ឲ្យចាប់ប្រជាជន មហាជនណាដែលហ៊ានតវ៉ាប្រឆាំងជំទាស់នឹងវាយកទៅឲ្យតុលាការសឹកកាត់ទោសប្រហារជីវិត ប៉ុនប៉ងធ្វើឲ្យប្រជាជន មហាជនស្នេហាជាតិ មិនហ៊ានក្រោកឡើងតស៊ូប្រឆាំងនឹងវា ។ ពេលនោះប្រជាជន មហាជន នឹងអ្នកបដិវត្តន៍កម្ពុជាយើងជាច្រើន ត្រូវរងគ្រោះថ្នាក់ជាប់គុកច្រវាក់ប្ដូរហូតដល់ពលីជីវិតទៀត ដោយសារអំពើឃោរឃៅហ្វាស៊ីសរបស់ពួកអាក្បត់នេះ ។ ពិតមែនហើយ ខ្មាំងវារាគត្បាតប្រជាជន មហាជន និងអ្នកបដិវត្តន៍បានខ្លះ តែត្រង់ថាកម្ទេចបដិវត្តន៍ វាកម្ទេចមិនបានជាដាច់ខាត ។

ក្នុងចំណោមអ្នករងគ្រោះទាំងអស់នេះ មានយុវជនម្នាក់មាឌស្គមស្ដើង មុខធ្លុងស្រួច តែត្រូវហើមស្ពុលអស់ពេញទាំងខ្លួន ដៃទាំងពីរជាប់ខ្នោះ ខោអាវប្រឡាក់ទៅដោយឈាម ដាមពាសពេញភ្នែកលឹបជ្រៅ ពោរពេញទៅដោយកំហឹងឆាបឆេះសន្ធោរសន្ធៅ អង្គុយនៅលើគ្រែថ្មក្នុងបន្ទប់គុកងងឹតលេខ៤ ។ យុវជនរូបនេះពុំមាននរណាស្គាល់ឈ្មោះទេ ។ អាខ្មាំងដែលកំពុងតែធ្វើទារុណកម្មទៅលើរូបរាងកាយគាត់ សួរអ៊ីក៏មិនលេចដែរ ។ អ្នកបដិវត្តន៍ឯទៀតដែល



វីរកងទ័ពបដិវត្តន៍ខ្មែរក្រហមម្នាក់ កំពុងបាញ់សន្ធាប់ជាមួយខ្មាំងនៅសមរភូមិ នៅភូមិភាគពាយ័ព្យភ្នំពេញ ខែមិថុនា ឆ្នាំ១៩៧៤

ជាប់ឃុំឃាំងនៅក្នុងគុកដូចគ្នាក៏មិនស្គាល់ ។ មិនដឹងជាគាត់នៅខ្សែណា ។ ខ្សែរបស់គាត់ខូចខាតត្រឹមតែរូបគាត់ម្នាក់ឯងហ្នឹងគត់ ។ អាខ្មាំងវាទំដរិតសួរចម្លើយគាត់ទាំងយប់ទាំងថ្ងៃ ដើម្បីរាតត្បាតខ្សែគាត់ជាបន្តទៅទៀត តែគាត់មិនធ្លាយចេញស្តីមួយម៉ាត់សោះ ។ ខ្មាំងសួររកផ្ទះដែលគាត់ស្នាក់នៅ ក៏គាត់មិនខ្ទីមាត់មួយអ៊ីស ។ ដូច្នេះដំណឹងសព្វសារពើជុំវិញខ្លួនគាត់ គឺគ្មាននរណាដឹងទាំងអស់ ។ អាខ្មាំងក៏មិនដឹង មិត្តយើងដែលជាប់ក្នុងគុកដូចគ្នាក៏មិនដឹង គឺដឹងត្រឹមតែខ្លួនគាត់ម្នាក់ឯងតែប៉ុណ្ណោះ ។

យើងទាំងអស់គ្នាដែលជាប់ឃុំឃាំងនៅក្នុងគុកនោះដែរ ដឹងត្រឹមតែថាយុវជននេះជាយុទ្ធមិត្តម្នាក់ប៉ុណ្ណោះ ព្រោះដឹងថាខ្មាំងចាប់គាត់បាន ដោយមានគ្រាប់បែកនៅក្នុងដៃគាត់ និងឃើញគាត់មានសីលធម៌ប្រយុទ្ធជាមួយខ្មាំងដាច់ខាត មិនខ្លាចលះបង់អ្វីទាំងអស់ ។

ខ្មាំងធ្វើទារុណកម្មមកលើរូបកាយមិត្ត ទាំងយប់ទាំងថ្ងៃចំនួនប្រាំថ្ងៃមកហើយ ។ ដោយសារតែរូបមិត្ត អ្នកជាប់ឃុំឃាំងឯទៀតទាំងអស់ ត្រូវបានអាខ្មាំងលើកទុកមួយអន្លើសិន មិនហៅយកទៅធ្វើទារុណកម្ម ព្រោះវាជាប់ប្រមូលកម្លាំងទាំងអស់របស់វា មកគាបសង្កត់តែលើមិត្តយុវជនអនាមិកម្នាក់នេះតែប៉ុណ្ណោះ ។ វាទំធ្វើយ៉ាងណាឈ្លេចសួរយកចម្លើយឲ្យបាន ព្រោះខ្សែនេះសំខាន់ ។ មិត្តយុវជនអនាមិកនេះចុះទ្រុឌទ្រោមរាងកាយជាខ្លាំង ដោយគាត់ប្ដេជ្ញាមិនហូបបាយខ្មាំងដាច់ខាត ទោះបីអាខ្មាំងវាគាបសង្កត់យ៉ាងណាក្ដី ឬវាលួងលោមទិញទឹកចិត្តដោយទិញសុទ្ធតែម្ហូបបារាំងដ៏ឆ្ងាញ់ពិសា និងមានតម្លៃខ្ពស់មកឲ្យគាត់ហូបក្ដី ។ មិនហូបបាយហើយថែមទាំងអាខ្មាំងវាដាក់ខ្សែភ្លើង បញ្ឆេកទឹកសាប៊ូថែមទៀត ។

ឃើញដូច្នេះ ដឹងដូច្នេះ យើងរាល់គ្នារំជួលចិត្តណាស់ ខ្វោចផ្សាអាណិតអាសូរគាត់ណាស់ ហើយព្រមជាមួយនេះ យើងរាល់គ្នាក៏មានមនោសញ្ចេតនាបដិវត្តន៍ ស្រឡាញ់គោរព និងកោតសរសើរគាត់ខ្លាំងថែមទៀត ។ អ៊ំស្រីម្នាក់ជាប់គុកពីបទចោទប្រកាន់ថា រួមប្រាស្រ័យវិច្ឆេទកម្មនៅក្នុងទីក្រុងភ្នំពេញដែរ ។ តាំងពីជាប់គុកមកគាត់មិនដែលហូបបាយអាខ្មាំងទេ ។ កូនប្រុសអ៊ំតូចៗនៅផ្ទះដាំបាយដាក់ស្រាក់យកមកជូនអ៊ំរាល់ថ្ងៃ ។ ថ្ងៃខ្លះមានបង្អែមទៀតផង ។ តែតាំងពីអាធ្រាត្រនៃថ្ងៃដែលខ្មាំងចាប់យុវជនអនាមិកនេះមកដាក់ក្នុងបន្ទប់គុកងងឹតលេខ៤ អ៊ំហូបបាយលែងចូល ។ អ៊ំតែងរំលែកម្ហូបមួយផ្នែកទុកឲ្យយុវជនអនាមិកនេះ ។ ឯបង្អែម ពេលណាមានគាត់ទុកជូនមិត្តយុវជននេះទាំងអស់ ។ តែមិត្តយុវជនយើងមិនព្រមទទួលយកម្ហូបចំណីនេះដាច់ខាត ។ ពេលអ៊ំស្រីយកម្ហូបចំណីទៅហុចឲ្យម្ដងៗមិត្តគ្រាន់តែញញឹម ហើយគ្រវីក្បាល ដោយមានទឹកភ្នែករលីងរលោងដាក់អ៊ំ ព្រោះមិត្តនឹកខ្វោចផ្សាចំពោះអ៊ំដែលចាស់ហើយ ហើយជានារីទៀត កម្លាំងខ្សោយហើយត្រូវពួកអាចោរក្បត់ជាតិរាតត្បាតចាប់ចងធ្វើទារុណកម្មថែមទៀត ។

ថ្ងៃមួយអ៊ំស្រីបានផ្ដាំកូនរបស់គាត់ឲ្យទិញបារី ប្រេងកូឡា និងអំបិល មកផ្ដល់ឲ្យមិត្តយុវជនអនាមិកនេះ ។ ពេលកូនគាត់យកអីវ៉ែអីវ៉ាន់ទាំងនេះមក អ៊ំស្រីលបបូញមាត់និយាយតិចៗប្រាប់មិត្តយុវជននេះតាមជ្រុងទ្វារថា យកបារីហូបទៅ យកប្រេងកូឡាទុករឹតទៅ! អំបិលទំពារវា ហើយលាបកន្លែងរបួសកុំឲ្យរលួយសាច់ និងលាបកន្លែងហើម កុំឲ្យវាគ្រាំក្នុង ។

ដើម្បីឲ្យអ៊ំអស់ចិត្ត មិត្តយុវជនយើងយកប្រេងកូឡាមួយដប និងអំបិលមួយចិប រួចខ្សិបតាមជ្រុងទ្វារជម្រាបអ៊ំវិញថា «សូមអរគុណអ៊ំច្រើន តែសូមឈប់ទទួលទៀតហើយ ព្រោះនាំតែខាតប្រាក់អ៊ំទទេ សូមអ៊ំទុកសម្រាប់ខ្លួនអ៊ំចុះ!»

ខ្មាំងវាយមិត្តបែកខ្នងដេកមិនបាន បែកក្បាលឈាមហូរដើរមិនរួច ។ រាល់យប់រាល់ថ្ងៃ ខ្មាំងយកមិត្តទៅវាយចំកន្លែងដដែលៗ ដើម្បីកុំឲ្យមិត្តទ្រាំបាន និងអាលសារភាពធ្លាយលក្ខការណ៍សម្ងាត់បដិវត្តន៍ឲ្យវា ។ ខ្មាំងធ្វើទារុណកម្មសព្វបែបយ៉ាងលើរូបរាងកាយមិត្ត ។ ជារៀងរាល់ថ្ងៃ វាបញ្ឆេកទឹកសាប៊ូតាមមាត់ តាមច្រមុះមិត្ត ហើយនាំគ្នាឡើងទន្រ្ទាំលើពោះ ធ្វើឲ្យទឹកសាប៊ូហូរចេញតាមមាត់ តាមបាតវិញ ។ ឥឡូវនេះ មិត្តយុវជនយើងហូរលាមកជាប្រចាំដោយមិនដឹងខ្លួន ។

មិត្តយុវជនយើង បាយក៏មិនហូប ដេកក៏មិនបាន ភ្នែកសម្លឹងមើលពាក្យស្លោកស្តីអំពីលក្ខការណ៍សម្ងាត់បដិវត្តន៍ដែលសរសេរដោយទុក្ករបុគ្គលបដិវត្តន៍មុនៗ នៅតាមជញ្ជាំងបន្ទប់គុកងងឹតទាំងបួនជ្រុង ហើយសម្លឹងមើលឈាមដែលហូរចេញពីដំបៅក្បាលរបស់មិត្តដែលត្រូវរបួសដោយដំបងទារុណកម្ម ហើយដែលហូរប្រឡាក់ពាសពេញខោអាវមិត្ត ។ ភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈ រឹតតែ

ឆាបឆេះសន្ធោរសន្ធៅក្នុងខ្លួនមិត្ត មិត្តប្តេជ្ញាប្រយុទ្ធជាមួយខ្មាំងរហូតដល់ដង្ហើមចុងក្រោយបំផុត ។

ថ្ងៃនេះ ខ្មាំងយកមិត្តទៅធ្វើទារុណកម្មតាំងពីយប់អាធ្រាត្រ មាន់រងាវម្តង ។ លុះដល់ពេលរសៀល ទើបវាសែងមិត្តយកមកបោះចោលលើគ្រែថ្មក្នុងបន្ទប់គុកងងឹតវិញ ។ ពីរម៉ោងក្រោយមក ទើបមិត្តភ្ញាក់ខ្លួនពីសន្លប់ ។ ដោយកំហឹងឆាបឆេះសន្ធោរសន្ធៅពេញដើមទ្រូង មិត្តមិនទុកពេលឲ្យកន្លងផុតទៅដោយឥតប្រយោជន៍ឡើយ មិត្តខំប្រមូលអស់ទាំងកម្លាំងកាយ កម្លាំងចិត្ត ប្រមូលផ្តុំសតិអារម្មណ៍ឲ្យមូល ដើម្បីសរសេរពាក្យបណ្តាំខ្លះ ទុកជូនយុវជនក្រោយៗ ។ មិត្តយកដៃបៀកឈាម និងដុំឈាមរបស់មិត្តដែលហូរប្រឡាក់ដោតជាប្រាណ ឆ្លាក់ជាអក្សរមួយតួម្តងៗយ៉ាងលំបាកលើជញ្ជាំងក្បាលដំណេករបស់មិត្តដូចតទៅៈ

- ត្រូវចែកព្រំដែនមិត្ត និងសត្រូវឲ្យច្បាស់
- ត្រូវចែកព្រំដែនប្រជាជាតិ ប្រជាជនកម្ពុជា និងចក្រពត្តិអាមេរិកឈ្លានពាន ព្រមទាំងបរិវារក្បត់ លន់ នល់ សិរិមតៈ សឺង ង៉ុកថាញ់ អ៊ិន តាំ ឲ្យច្បាស់ ។
- មិនត្រូវលក់ការណ៍សម្ងាត់របស់បដិវត្តន៍ប្រជាជាតិ និងប្រជាជនកម្ពុជា ឲ្យចក្រពត្តិអាមេរិក និងបរិវារដាច់ខាត ។
- តស៊ូការពារស្នាដៃបដិវត្តន៍ ដែលបុព្វបុរសបដិវត្តន៍យើងកសាងឲ្យបានដាច់ខាត និងបន្តកសាងស្នាដៃដោយឈាមស្រស់នេះតទៅទៀត លុះត្រាតែកម្ទេចចក្រពត្តិអាមេរិក និងបរិវារ និងសម្រេចជ័យជម្នះទាំងស្រុង ឲ្យបានដាច់ខាតនៅទីអវសាន្ត ។

**«ជយោ បក្សកុម្មុយនីស្តកម្ពុជា ដ៏រុងរឿង !»**

**«បរាជ័យចក្រពត្តិអាមេរិក និងបរិវារក្បត់ លន់ នល់ សិរិមតៈ សឺង ង៉ុកថាញ់ អ៊ិន តាំ ចេង ហេង»**

ការសរសេរបដាដោយឈាមស្រស់របស់មិត្ត បានសម្រេចហើយ ។ មិត្តសប្បាយរីករាយណាស់ ។ មិត្តភ្លេចអស់នូវការឈឺចុកចាប់ក្រាំគ្រាក្នុងខ្លួនមិត្ត ។ មិត្តប្រវេប្រវារវារចុះពីលើគ្រែថ្មដល់កំរាលឥដ្ឋ រួចវារទៅប្រគោងទ្វារ ហើយសឹកម្រាមដៃចេញក្រៅទ្វារតាមចន្លោះចំរឹងដែកតូចដែលនៅជាប់នឹងទ្វារមិត្ត ហើយបោយដៃហៅយុទ្ធមិត្តឯទៀត ដែលត្រូវជាប់ឃុំឃាំងក្នុងគុកនោះដែរឲ្យមកជិត ។ អ៊ំស្រី យុវជន យុវនារីដែលនៅទីនោះឃើញដូច្នេះ ក៏ប្រញាប់ប្រញាល់មកសួរសុខទុក្ខមិត្តភ្លាម ។ ខ្លះក៏យកប្រេងកូឡាមកឲ្យមិត្ត ។ តែតាមពិត មិត្តយុវជនយើងគ្មានត្រូវការរបស់អ្វីទាំងអស់ មិត្តគ្រាន់តែចង់ឃោសនាអប់រំ អំពីមាគ៌ាតស៊ូសម្ងាត់នៅក្នុងគុក ក្នុងពេលដែលខ្មាំងចាប់ធ្វើទារុណកម្ម ឈ្លេចសួរយកចម្លើយតែប៉ុណ្ណោះ ។ មិត្តចង់ឃោសនាអប់រំដល់យុទ្ធមិត្តឯទៀតដែលកំពុងត្រូវជាប់ឃុំឃាំងក្នុងគុក តាមរយៈអក្សរចារឹកឈាមស្រស់របស់មិត្ត ។ នៅពេលឃើញយុទ្ធមិត្តឯទៀតមកជួបប្រមូលផ្តុំនៅខាងមុខបន្ទប់គុកងងឹតរបស់មិត្តហើយ មិត្តនិយាយដោយទឹកមុខញញឹម និងដោយសំឡេងពោរពេញទៅដោយមនោសញ្ចេតនាបដិវត្តន៍យ៉ាងជ្រាលជ្រៅថាៈ «ខ្ញុំគិតឃើញហើយ! ខ្ញុំនឹងចាប់ហូបបាយឡើងវិញហើយ សុំអ៊ំស្រីយកបាយមកឲ្យខ្ញុំហូបចុះ!»

ឮដូច្នេះ យើងរាល់គ្នាមានការសប្បាយរីករាយជាពន្លឹក ព្រោះយល់ថាមិត្តនឹងមានកម្លាំងបន្តជីវិតតស៊ូជាមួយខ្មាំងបានយូរទៀត ។ ព្រមជាមួយនេះ យើងរាល់គ្នាក៏ចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះផ្ទាំងបដាឈាមស្រស់របស់មិត្ត ដែលសរសេរថែមលើផ្ទាំងបដាចាស់ ។ អ្នកជាប់ឃុំឃាំងក្នុងគុកទាំងអស់ នាំគ្នាមកមើលឈូសរដោយគ្មានគិតគូរ ឬក្រែងរអែងដល់អាខ្មាំងដែលយាមប្រចាំការនៅទីនោះឡើយ ទោះបីវាគំរាមវាយដំច្រំធាក់យ៉ាងណាក្តី ។

ពេលឃើញព្រឹត្តិការណ៍ជ្រួលច្របល់ពេញគុកយ៉ាងនេះ អាខ្មាំងដែលយាមប្រចាំការ ក៏គំរាមវាយដំច្រំធាក់ នឹងធ្វើទោសដល់អ្នកជាប់ឃុំឃាំងក្នុងគុកផ្សេងៗទៀតទាំងអស់ ។ តែយើងរាល់គ្នាគ្មានទៅខ្វល់អើពើនឹងពាក្យគំរាមកំហែងរបស់ខ្មាំងនេះឡើយ ។ យើងនាំគ្នាអានពាក្យស្លោកសរសេរដោយឈាមស្រស់នេះ ហើយខំកត់ត្រាទុកក្នុងខួរក្បាលមួយឃ្លាម្នាក់ៗ ដើម្បីដល់មានឱកាសយើងផ្តុំគ្នាជាអត្ថបទដើមទាំងស្រុង ទុកសម្រាប់ផ្សព្វផ្សាយរៀនសូត្រពង្រឹងគោលជំហរ និងពង្រឹងឆន្ទៈប្រយុទ្ធរបស់យើងរាល់គ្នាឲ្យកាន់តែរឹងប៉ឹងស្រួចស្រាវថែមទៀត ។

អ្នកជាប់ឃុំឃាំងក្នុងគុក កាន់តែប្រមូលផ្តុំគ្នាច្រើនឡើងៗ ប្រជ្រៀតគ្នាមកអានពាក្យស្លោកបដិវត្តន៍នេះថែមទៀត ។ គេទាំងឡាយមិនខ្វីអើពើដល់ការគំរាមកំហែងរបស់អាខ្មាំងដែលឈរយាមនៅទីនោះឡើយ ។ មិត្តខ្លះលាន់មាត់ថា ពាក្យស្លោកបដិវត្តន៍ថ្មីនៅក្នុងបន្ទប់គុកងងឹតលេខ៤នេះជ្រាលជ្រៅណាស់ ។

ក្រោយពេលដែលអ្នកជាប់ឃុំឃាំងទៀត ដើរចេញអស់ពីមុខបន្ទប់គុកងងឹតលេខ៨នេះហើយ អាខ្មាំងដែលយាមប្រចាំការនៅទីនោះ ក៏បើកសោចូលមកក្នុងគុកទាំងភ្នែកនៅកញ្ជឹងក ហើយអើតក្បាលទៅមើលក្នុងបន្ទប់ងងឹតរបស់យុវជនអនាមិកនេះ ដើម្បីរកយល់ហេតុការណ៍ដែលទើបកន្លងមក ។ ដោយវាទើបចេញមកពីកន្លែងភ្លឺ វាមើលអ្វីមិនឃើញទេនៅក្នុងបន្ទប់គុកងងឹតនេះ ។ វាក៏បើកភ្លើងឡើងភ្លឺត្រឹង ។ វាឃើញមិត្តយុវជនយើងកំពុងទំពារបាយឃ្មុមៗ ធ្វើឆើយដាក់វា ។ វាសួរថាៈ

◆ ស៊ីបាយហើយឬអី?

បានជាវាសួរយ៉ាងនេះ ព្រោះមិត្តយើងមិនព្រមហូបបាយទឹក តាំងពីខ្មាំងចាប់បញ្ចូលក្នុងគុកងងឹតនេះមកម្ល៉េះ ។ រួចវាសួរមិត្តយើងថាៈ

◆ ចុះនរណាសរសេរពាក្យថែមលើជញ្ជាំងនេះ?

មិត្តយុវជនយើងធ្វើហី មិនខ្វីនិយាយតបឡើយ ។ ឃើញដូច្នេះអាខ្មាំងបែបទ្រង់ភ័យ ហើយក៏បើកសោចេញទៅវិញភ្លាម ។ ទៅដល់តុយាមវិញ វាក៏សរសេររបាយការណ៍យ៉ាងញាប់ដៃទៅចៅហ្វាយវាភ្លាមដែរ ។

ថ្ងៃបន្ទាប់ អាគិញឃោរឃៅបីនាក់ ចូលមកហៅមិត្តយុវជនអនាមិកនេះទៅបន្ទប់សួរចម្លើយទៀត ។ នៅព្រមពេលជាមួយនោះពួកអាគិញផ្សេងទៀតក៏បាននាំយុវនារីទើបចាប់បានថ្មីម្នាក់មកញាត់បញ្ចូលក្នុងគុកនេះដែរ ។ ពេលក្រឡេកឃើញយុវនារីនេះភ្លាម មិត្តយុវជនអនាមិកនេះភ្ញាក់ព្រើត ហើយតាំងស្រឡាំងកាំងមួយភ្លែត ។ មិត្តនឹកក្នុងចិត្តថា នៅខាងក្រៅ អាខ្មាំងកាន់តែរាតត្បាតខ្លាំងក្លាមែនទែនហើយ ។ ចំណែកឯយុវនារីដែលទើបត្រូវខ្មាំងចាប់មកថ្មីនេះ ពេលឃើញអាខ្មាំងកំពុងនាំមិត្តយុវជនអនាមិកចេញទៅសួរចម្លើយ គាត់ក៏សម្លឹងផ្ទាំង ។ យុវនារីថ្មីនេះធ្លាប់ស្គាល់យុវជនអនាមិកនេះច្បាស់ ។ មិត្តយុវជនយើងញញឹមលើកទឹកចិត្តអ្នកចំណូលថ្មី ហើយក៏ធ្វើជាមិនស្គាល់គ្នាវិញ ។

រាល់ថ្ងៃមិត្តដើរមិនរួចទេ តែថ្ងៃនេះមិត្តខំប្រឹងដើរធ្វើធម្មតា មិនឲ្យអាខ្មាំងគ្រាហ៍ទេ ។ មិត្តចង់បង្ហាញដល់យុទ្ធមិត្តឯទៀតទាំងអស់ឲ្យឃើញថា ថ្ងៃនេះមិត្តមានកម្លាំងគ្រាន់បើហើយកុំឲ្យបងប្អូនបារម្ភអីចំពោះរូបមិត្ត ។ មិត្តដើរដោយដំណើរធូន់ហើយឈ្ងោកមុខ ។ យើងរាល់គ្នាអាចយល់បានថា មិត្តប្រាកដជាមានផែនការអីមួយថ្មីហើយជាមួយខ្មាំង ។

នៅក្នុងបន្ទប់សួរចម្លើយ អាខ្មាំងរៀបចំប្រដាប់ប្រដាហើយស្រេច សម្រាប់ត្រៀមសួរចម្លើយមិត្ត ។ ក្រៅពីព្រនង់កៅស៊ូ ប្រដាប់ខ្សែភ្លើង ធុងទឹកសាប៊ូ មានព្រនង់ដែកមួយដាក់លើតុ នៅចំពីមុខមិត្តយុវជនយើង ។ ឃើញឧបករណ៍ធ្វើទារុណកម្មនៅជុំទិសយ៉ាងនេះ មិត្តយើងបែរជាសប្បាយចិត្តលើសពេលណាៗទាំងអស់ ។ មិត្តនឹកក្នុងចិត្តថា ត្រូវសម្រេចអនុវត្តហិង្សាបដិវត្តន៍ឲ្យបាន ។ មធ្យោបាយមានច្រើនណាស់ ឯកម្លាំងពលំក៏ខ្លាំងក្លាជាងថ្ងៃមុនៗដែរ ។ ដូច្នេះមិត្តប្តេជ្ញាមិនឲ្យខ្មាំងធ្វើទារុណកម្មបានមុនឡើយ ។ តែត្រូវធ្វើយ៉ាងណា ធ្វើឲ្យបានមុនវា ។ ឯឧបសគ្គក៏មានច្រើនណាស់ដែរ ណាមួយដៃជាប់ខ្នោះ ។ ណាមួយមិត្តមានគ្នាតែម្នាក់ឯងគត់ ។ ឯខ្មាំងវាមានគ្នាពេញបន្ទប់ ។ ដូច្នេះគ្រាន់តែរៀបចំខ្លួនក្រោកប្រយុទ្ធខ្មាំងក៏អាចសង្គ្រប់មិត្តជាប់ស្រេចទៅហើយ ។ តែចំណុចខ្សោយខ្មាំងក៏មានច្រើនដែរ ។ មុននឹងធ្វើទារុណកម្មសួរចម្លើយម្តងៗ ខ្មាំងសុទ្ធតែសួរបញ្ជាក់ថា តើសុខចិត្តនិយាយឬមិនសុខចិត្ត? នឹកឃើញដល់ចំណុចត្រង់នេះ មិត្តក៏សម្រេចចិត្តនិយាយជាមួយវាមួយម៉ាត់ទៅចុះ ដើម្បីរៀបចំលក្ខណៈសម្បត្តិសម្រេចភារកិច្ចបដិវត្តន៍ថ្មីឲ្យបាន ។ មិត្តនិយាយដោយផ្អែមល្ហែមទៅរកវា ដើម្បីធ្វើឲ្យវាទុកចិត្ត ។ ផ្អែមនេះ គឺចេញពីឧបាយកលសម្ងាត់នៅក្នុងខ្លួនមិត្ត ។

ខ្ញុំគ្មានអ្វីត្រូវលាក់លៀមទេ ។ ខ្ញុំចង់និយាយយូរហើយ តែគ្នាលោកច្រើនពេក ។ ការណ៍វាស្ងាត់ ខ្ញុំចង់និយាយតែចំពោះលោកអធិការ ឬលោកស្នងការណាម្នាក់ប៉ុណ្ណោះ ។ បើលោកចង់ឆ្លើយឆ្លងលោកត្រូវដោះខ្នោះដៃខ្ញុំចេញ ហើយអញ្ជើញលោកអធិការ ឬលោកស្នងការណាម្នាក់ដែលគួរទុកចិត្តមកនិយាយជាមួយខ្ញុំជាការស្រេច ។

ឮយ៉ាងនេះ អាខ្មាំងពេញបន្ទប់នោះ ចេញចូលសួរគ្នារអ៊ឹះរអ៊ុះចុះឡើង ។ មួយសន្ទុះក្រោយមកមានអាស្នងការម្នាក់ស្រវឹងស្រាធុល ដើរចូលមកសើចគ្រហើៗដាក់មិត្ត ហើយនិយាយថាៈ

◆ ម៉េចអញថាទ្រាំមិនបាន ទ្រាំមិនបានមែន ។ បើនិយាយតាំងពីមុនមក មិនជាទ្រមដល់ម្លឹងទេ រួចវាក៏ងាកទៅនិយាយជាមួយអាគិញនៅជុំវិញនោះថាៈ

◆ ពួកអាឯងចេញចុះ ។ អាឯងរាល់គ្នាមិនចេះធ្វើការទេទុក

ឲ្យអញតែម្នាក់ឯងបានហើយ ។ អាណាកាន់កូនសោដោះខ្នោះពីប្អូននេះចេញទៅ ។ យីផុំក្លិននេះអាក្រក់ណាស់ ចុះពួកអាឯងម្ដេចមិនយកខោអាវប្អូននេះទៅបោកផង? តែមិនអីទេ ក្លិនប៉ុនៗហ្នឹងគិញទ្រាំបាន ។ ប៉ុនរបស់តាងលាក់នៅក្នុងបន្ទប់ ម៉េចក៏គិញមិនខ្លាចមុជចុះទៅរាវរកផង! មិត្តយើងសើចកក្អឹក ។ ពុំមែនអរបានជួបអាស្នងការខាងសគ្រ្កាមចិត្តសាស្រ្តនេះទេ តែសប្បាយនឹងប្រើអាខ្មាំងមួយក្រសួងបានតាមបំណងបដិវត្តន៍របស់មិត្ត ។ មិត្តយើងបានរួចខ្នោះពីដៃស្រឡះខ្លួនបន្តិរ ។ មិត្តលើកដៃចុះឡើងមួយសន្ទុះ មិនឃើញអាស្នងការថាអី ។ មិត្តឡើងឈរពត់ខ្លួនប្រាណព្ធសូរប្រេះប្រសលាន់ចង្កេះ ក៏វាមិនថាអីទៀត ។ ភ្នែកសម្លឹងមើលទៅព្រនង់ដែកនៅចំពីមុខមិត្ត ប្រុងនឹងឆក់សំពងក្បាលអាស្នងការឃោរឃៅនេះ តែមិនត្រូវទំនង ហើយវាអាចគេចទាន់ថ្វីបើវាស្រវឹងដោកយ៉ាងនេះហើយក្ដី ។ មិត្តក៏អង្គុយចុះទៅវិញ ។ អាស្នងការឃោរឃៅបន្ទិសួរមិត្តថាៈ

◆ ទៅ! និយាយទៅ!

មិត្តធ្វើអឹមអៀនដាក់វា រួចនិយាយថាៈ

◆ ខ្ញុំចង់និយាយភ្លាមហ្នឹង តែខ្ញុំខ្លាចលោកមាត់មិនដិត នាំឲ្យគ្រោះថ្នាក់ទាំងខ្ញុំ គ្រោះថ្នាក់ទាំងលោក! (មិត្តយើងនិយាយដើម្បីពន្យារពេល) ។

◆ មិនអីទេ! មិនអីទេ! ក្រសួងគិញ ជាក្រសួងមិនចេះចាញ់មិនចេះមានគ្រោះថ្នាក់អ្វីទាំងអស់ ។ អាស្នងការឃោរឃៅនេះពោលឡើងដោយក្អេងក្អាង ។

មិត្តយើងគិតគូរយ៉ាងវែង ។ អាខ្មាំងវាក៏នាំនិយាយពីនេះពីនោះ តាមរបៀបដែលហៅថាសគ្រ្កាមចិត្តសាស្រ្តរបស់វា ដោយវាស្មានថាមិត្តយើងមិនចេះរបៀបឆ្លើយ ។ តែតាមពិត មិត្តយើងមិនមែនគិតពីរឿងឆ្លើយឆ្លងជាមួយខ្មាំងទេ មួយសន្ទុះក្រោយមកមិត្តក៏ពោលថាៈ

◆ សុំទឹកផឹកបន្តិច! ផឹកហើយសុំមិននិយាយទេ! សុំសរសេរវិញ!

អាស្នងការឃោរឃៅនេះ គ្រាន់តែឮដូច្នេះ វាក៏អរកខិបកខុបហើយពោលថាៈ

◆ អញ្ចឹងហើយៗ! បាន! បាន!

អាខ្មាំងក្រោកក្រេសដើរចេញពីកៅអី ដែលនៅទល់មុខមិត្តហើយបែរខ្នងដាក់មិត្ត ។ មុខវាបែរទៅរកជញ្ជាំង កំពុងចាក់ទឹកពីក្នុងថូប្រហបជញ្ជាំងនោះមកឲ្យមិត្ត ។

ត្រូវនឹងទំនងដៃហើយ កញ្ចឹងកអាខ្មាំងនៅស្រឡះផង ។ មិត្តសម្លឹងចំណុចស្លាប់របស់ខ្មាំងមិនដាក់ភ្នែក ។

ឆក់ពេលដ៏កម្រនេះ មិត្តយើងដែលប្រុងស្រាប់ហើយនោះរហ័សដូចកូនខ្លាឆក់យកព្រនង់ដែកនៅលើតុ មកកាន់ក្ដាប់ណែននៅក្នុងដៃ លើកសំពងចំកញ្ចឹងកអាខ្មាំងមួយព្រនង់ហើយ មួយព្រនង់ទៀត ។ អាខ្មាំងចង្រៃនេះ គ្មានបានស្រែកឲ្យនរណាជួយមួយម៉ាត់ទេ ។ វាដួលផ្កាប់មុខស្រ៊ិបទៅលើកំរាលឥដ្ឋប្រកាច់ប្រកិនកន្ត្រាក់ដៃកន្ត្រាក់ជើងធ្មេចភ្នែកស្លឹ ។ កៅអីនៅក្នុងបន្ទប់នេះដួលទង្គិចគ្នា ឮហាក់ដូចជាមនុស្សកំពុងវាយដាប់ដៃគ្នា ។ តាមពិត គឺអាគិញចង្រៃនេះវាប្រកាច់ ហើយជើងវាទធាក់ទទឹងទទែងពេញទីនោះ ប៉ះតុប៉ះកៅអីដួល ។ មិត្តយុវជនយើងគិតតែពីខំប្រមូលកម្លាំងសំពងតម្រង់ទៅរកតែកន្លែងឆាប់ស្លាប់លើកញ្ចឹងកខ្មាំង ។ សូរស័ព្ទទាំងនេះលាន់ឮទៅក្រៅបន្ទប់ ។ ពួកអាគិញរត់ចូលព្រូមកមើលព្រឹត្តិការណ៍នៅក្នុងបន្ទប់នេះ ឃើញចៅហ្វាយវាបែកក្បាលហូរឈាមដេកស្តូកស្តឹងនៅលើកំរាលឥដ្ឋ ។ ពួកវាចង់ស្ទុះលោតមកជួយ តែវាខ្លាចមិនហ៊ានចូល ព្រោះមិត្តយើងយាមដបចាំយ៉ាងអង់អាច ។

◆ វាមានកាំភ្លើង! វាមានកាំភ្លើង! ពួកអាគិញភ័យស្រែកភ្លាត់សំឡេង ។ អាខ្លះរត់ថយក្រោយវិញ ។ អាណាថយមិនទាន់ក៏ក្រាប ។ ពួកអានៅឆ្ងាយៗឆក់កាំភ្លើងគ្រប់ដៃយកមកព័ទ្ធចាប់មិត្តយើងដែលស្ថិតនៅក្នុងកណ្ដាប់ដៃវាស្រាប់ទៅហើយនោះ ។ បានឱកាសដែលពួកវាកំពុងតែច្រួលច្របល់ដកថយ មិត្តយើងក៏ប្រមូលកម្លាំងក្នុងខ្លួនប្រើងដៃពីរសំពងទៅលើកញ្ចឹងកអាខ្មាំងឃោរឃៅដែលកំពុងប្រកាច់ប្រកិននេះយ៉ាងអស់ទំហឹងដៃឲ្យវាស្លាប់តែហោងតែម្ដង ។ ពេលនោះអាខ្មាំងចលាចលពេញគុក ។ ស្រែកដេរគ្នាបន្ទោសគ្នាចុះឡើងៗថា ប្រហែសទុកចិត្តខ្មែរក្រហមពេក ។ រួចហើយវាក៏បាញ់រះមកលើមិត្តយើងយ៉ាងកម្រោលហួសហេតុជាទីបំផុត ។

នៅក្នុងគុក យើងទាំងអស់គ្នាឮសូរតុកៅអីដួលនឹងស្នូរកាំភ្លើងដែរ តែមិនទាន់ច្បាស់ជាយ៉ាងណា? អ្នកខ្លះវិភាគថា ខ្មាំងឈ្លោះគ្នាបាញ់គ្នា ព្រោះចែកលុយគ្នាមិនស្មើ ។ អ្នកខ្លះថា ខ្មាំងបាញ់មិត្តយុជន

អនាមិកនេះហើយ ។ អ្នកខ្លះទៀតថា មិនមែនទេ ព្រោះបើខ្មាំងចង់សម្លាប់ វាសម្លាប់បាត់ទៅហើយ ។

ប៉ុន្តែយុវនារីម្នាក់ ដែលទើបត្រូវខ្មាំងចាប់មកថ្មីៗ ពីបទចោទប្រកាន់ថាវត់ពន្ធថ្នាំពេទ្យនោះ បារម្ភទៅលើសន្តិសុខរបស់មិត្តខ្លួនជាខ្លាំង ។ នាងខាំមាត់សង្កៀតធ្មេញក្រឹត ប្តេជ្ញាសងសឹកយុទ្ធមិត្តវិញឲ្យបានដាច់ខាត ។ នាងកំពុងតែសញ្ជឹងគិត ស្រាប់តែឃើញអាខ្មាំងសែងមិត្តយុវជនអនាមិកនោះ មកបោះចោលព្រូសនៅក្នុងបន្ទប់គុកងងឹតលេខ៨ ហើយវាហាមប្រាមអ្នកណាទៅអើតសួរនាំអ្វីទាំងអស់ដោយគំរាមថា បើអ្នកណាហ៊ានទៅអើតសួរនាំអី នឹងត្រូវពួកវាចាប់យកទៅធ្វើទារុណកម្ម ។ មិត្តយុវជនអនាមិកនេះសន្លប់បាត់ស្មារតីទៅហើយ! ឈាមហូរចេញពីស្មា និងក្បាលមិត្តជោគជាំពាសពេញគ្រែថ្ម ហើយហូរធ្លាក់មកលើកំរាលឥដ្ឋទៀត ។ យើងរាល់គ្នានៅក្នុងគុក ក៏បានយល់ព្រឹត្តិការណ៍នេះច្បាស់ដឹងថា អាខ្មាំងវាបាញ់មិត្ត ។ ទោះបីជាខ្មាំងហាមប្រាមតឹងតែងយ៉ាងណាក៏ដោយក៏គ្មានអ្នកណាស្តាប់មាត្រានឹងបម្រាមរបស់វាឡើយ ។ យើងរាល់គ្នាចេះតែប្រជ្រៀតគ្នាចូលទៅអើតមើលសួរសុខទុក្ខមិត្តឡើងកកកុញណែនណាន់តាន់តាប់នៅពេញមុខបន្ទប់គុកងងឹតលេខ៨នេះ ។

យុទ្ធមិត្តទាំងអស់ មានការក្រេវក្រោធចំពោះអាខ្មាំងជាខ្លាំង ហើយប្តេជ្ញាថា នឹងសងឈាមយុទ្ធមិត្តវិញឲ្យបានដាច់ខាត ។ ម្នាក់ស្រែកមួយម៉ាត់ម្នាក់ស្រែកមួយម៉ាត់ ចុះឡើង ចុះឡើង ក៏ក្លាយទៅជាចលនាមហាជនរមួលចុះរមួលឡើង រំជើបរំជួលពេញទាំងគុក ។ យូរៗ គេឮសូរសម្រែកខ្លាំងមួយ ផ្ទុះឡើងពីក្នុងជម្រៅបេះដូងដ៏ក្រហមឆ្អិនឆ្អៅរបស់យុទ្ធមិត្តដែលចងគំនុំ និងចងអាឃាតចំពោះខ្មាំងអស់មួយជីវិតៈ "សងសឹក! សងសឹកអាខ្មាំងឲ្យបាន!" "ឈាមត្រូវតែសងដោយឈាម!" បរាជ័យចក្រពត្តិអាមេរិក និងឆ្កែបម្រើវា! ។

ម៉ោង៦ល្ងាច ព្រះអាទិត្យក៏បាំងបិទរស្មីទៅវិញ ខ្យល់ដំនោរត្រជាក់ ក៏បក់មកដល់រំភើយៗ មិត្តយុវជនអនាមិកនេះក៏ភ្ញាក់ពីសន្លប់វិញ ។ មិត្តខំសម្លឹងមើលជុំវិញខ្លួនមិត្ត ឃើញសុទ្ធតែឈាម ។ ឈាមខ្លះកកទាំងដុំៗ ។ ឈាមខ្លះមិនទាន់កកកំពុងតែហូរចេញពីស្នាមរបួសលើខ្លួនប្រាណមិត្ត ។ ខោអាវមិត្តប្រឡាក់ឈាមដោយដុំៗជាថ្មីថែមទៀត ធ្វើឲ្យខ្លួនប្រាណមិត្តប្រឡាក់ជោគជាំទៅដោយឈាម ។ ខ្លួនមិត្តធុំក្លិនអសោចិ៍ ។ តែមិត្តគ្មានយកចិត្តទុកដាក់ទៅលើខ្លួនប្រាណមិត្តឡើយ ។ មិត្តខំសម្លឹងមើលមិនដាក់ភ្នែក តាមប្រហោងចម្រឹងដែកទៅក្រៅបន្ទប់គុកងងឹតនេះដើម្បីរកមើលមិត្តនារី ដែលទើបត្រូវខ្មាំងចាប់មកថ្មី និងអ៊ំស្រីដែលបានផ្តល់ជូនមិត្តហូបបន្តកម្លាំងវាយខ្មាំងបាន ។

មិនខុសបំណងទេ យុទ្ធមិត្តដែលត្រូវជាប់ឃុំឃាំងនៅក្នុងគុកទាំងអស់នាំគ្នាប្រាស់ប្រាល់ៗ ចង់តែមកសួរដំណឹងពីមិត្តប៉ុណ្ណោះ ។ អ៊ំស្រីអើតមកធ្វើមុខមាំជ្រួញចិញ្ចើម ដោយក្តីក្រេវក្រោធចំពោះខ្មាំងជាខ្លាំង ។ គ្រាន់តែឃើញមុខអ៊ំភ្លាម យុវជនអនាមិកក៏ស្រែកថាៈ

◆ សូមអរគុណដល់យុទ្ធមិត្តទាំងអស់ ដែលបានផ្តល់បាយឲ្យខ្ញុំហូប ។ ខ្ញុំហូបទៅមានកម្លាំងពលំខ្លាំងក្លា ហើយបានយកកម្លាំងបាយនេះ ទៅកម្ទេចខ្មាំងបានមួយក្បាលដែរ ។ ថ្ងៃនេះ យើងរំលស់ខ្មាំងបានមួយក្បាលថែមទៀត សូមយុទ្ធមិត្តចាត់ទុកការនេះថាជាជ័យជម្នះរបស់យើងទាំងអស់គ្នា ។

ដំណឹងនេះបានលើកទឹកចិត្តដល់យុទ្ធមិត្តឯទៀតដែលជាប់ឃុំឃាំងនៅក្នុងគុកទាំងអស់ ឲ្យកាន់តែអង់អាចក្លៀវក្លាឡើងក្នុងការតស៊ូជាមួយខ្មាំង ក៏ដូចក្នុងការទ្រាំទ្រទារុណកម្មរបស់ខ្មាំងគ្រប់បែបយ៉ាងដែរ ។

នៅក្រៅបន្ទប់ឃុំឃាំង ពួកអាខ្មាំងទាំងអាធំទាំងអាតូចនាំគ្នាព្រោងព្រាតរៀបចំបង្កើតព្រឹត្តិការណ៍ខ្ចិជ្ជមួយ សំដៅសម្លុតស្មារតីប្រយុទ្ធរបស់អ្នកជាប់ឃុំឃាំងក្នុងគុកទាំងអស់ និងដើម្បីស្តារការអាម៉ាសរបស់វាកាលពីថ្ងៃផង ។ ខ្មាំងយកប៉ូលីសផង ភ្នាក់ងារតម្រួតយោធាផង មកហ៊ុមព័ទ្ធកន្លែងឃុំឃាំង ហើយវាឲ្យតំណាងគ្រប់ក្រសួងដែលទទួលបន្ទុកខាងពិឃាតមនុស្ស ចូលមកយកមិត្តយុវជនអនាមិកនេះ ចេញពីបន្ទប់គុកងងឹតនេះ ទៅប្រល័យចោលយ៉ាងកំណាចហ្វាស៊ីសបំផុត ។

នៅព្រឹកនោះ ខ្មាំងវាចាប់អ្នកជាប់ឃុំឃាំងប្រុសៗ ចាក់សោជាប់ក្នុងគុកងងឹតទាំងអស់គ្នា ។ ដូច្នេះនៅសល់តែនារីទេខាងក្រៅ ។ នៅពេលដែលខ្មាំងទៅចាក់សោយកមិត្តយុវជនអនាមិកនេះ យុវនារី និងនារីដែលជាប់ឃុំឃាំងនៅក្នុងគុកនេះទាំងអស់ បានអង្គុយប្រមូលផ្តុំគ្នានៅមួយកន្លែងយ៉ាងរៀបរយគួរឲ្យខ្មាំងទុកចិត្តបាន ។

លុះខ្មាំងយកយុវជនអនាមិកនេះ ចេញផុតមាត់ទ្វារបន្ទប់គុក

ងងឹតភ្លាម ស្រាប់តែយុវនារី និងនារីយើងទាំងអស់ស្ទុះព្រួទៅដណ្ដើមយកយុទ្ធមិត្តខ្លួន ដោយវាយប្រទាញប្រទង់ជាមួយខ្មាំងអស់មួយសន្ទុះធំ ។ ព្រមជាមួយនេះ មិត្តយើងនាំគ្នាស្រែកអាក្រោសផ្ដន្ទាទោសខ្មាំងទៅតាមកំហឹងពុះពោររៀងៗខ្លួន «អ្នកបដិវត្តន៍ពុំមែនជាអ្នកមានទោសទេ» ពួកអាក្បត់ជាតិឆ្កែបម្រើដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក ជាជនដាច់ទោសឧក្រិដ្ឋ បរាជ័យពួកអាគិញ និងពួកអាតម្រួតយោធាឃោរឃៅក្បត់ជាតិ កម្ទេចពួកអាគិញ និងពួកអាតម្រួតយោធាឃោរឃៅ ទើបយុត្តិធម៌ ។

ឆ្លៀតឱកាសដែលខ្មាំងកំពុងតែច្របូកច្របល់នេះ យុវនារីចំណូលថ្មី ក៏ស្ទុះជ្រែកគេជ្រែកឯងទៅឱ្យបដាក់ត្រចៀកយុវជនអនាមិកនេះយ៉ាងរហ័សថាៈ

◆ ម្ដាយចាស់របស់សមមិត្ត ត្រូវបានអង្គការយកទៅទំនុកបម្រុងនៅតំបន់រំដោះហើយ អង្គការសូមប្រសិទ្ធិពរជូនសមមិត្តឲ្យបានជោគជ័យជានិច្ច តើសមមិត្តមានផ្ដាំអ្វីទេ? ។

ពុដ្ឋច្នេះភ្លាមមិត្តយុវជនអនាមិកមានការរំភើបញាប់ញ័រនិងរំជួលចិត្តជាខ្លាំង ។ មិត្តឡើងអួលដើមក ។ មិត្តនឹកឃើញដល់អង្គការដែលជាដួងព្រលឹងរបស់មិត្ត និងរបស់ប្រជាជនកម្ពុជាស្នេហាជាតិទាំងអស់ ដែលធ្លាប់បានអប់រំ កសាង ថែបំប៉នមិត្តឲ្យទៅជាយុវជនបដិវត្តន៍មួយរូប ដែលស្មោះត្រង់បម្រើជាតិ បម្រើប្រជាជនដាច់ខាត ហើយអង់អាចមោះមុត ហ៊ានប្រយុទ្ធកម្ទេចខ្មាំងក្នុងគ្រប់កាលៈទេសៈ ។ នៅទីអវសានខ្នែជីវិតរបស់មិត្តហើយនេះ ក៏បក្សនៅតែតាមថ្នាក់ថ្នមថែបំប៉នមិត្តឲ្យមានគោលជំហរប្រយុទ្ធដាច់ខាតជាមួយខ្មាំងទៀត ។ មិត្តរឹតតែប្ដេជ្ញាបូជាជីវិតដ៏ក្មេងខ្ចីរបស់មិត្តដើម្បីបក្សបដិវត្តន៍ និងប្រជាជន ក្នុងឋានៈជាអ្នកឈ្នះ ជាអ្នកវាយសម្រុកខ្មាំង និងជាអ្នកប្រយុទ្ធកម្ទេចខ្មាំងជានិច្ច ។ តែមិត្តដាច់ខាតមិនចុះញ៉មសារភាពខ្មាំងឬមិនធ្វើអ្វី ឬមិនឲ្យមានអាកប្បកិរិយាអ្វី ដែលនាំឲ្យខ្មាំងប្រមាថមើលងាយ ឬដែលនាំឲ្យល្អក់ពណ៌ដល់ឥទ្ធិពលដ៏ខ្ពង់ខ្ពស់ និងកិត្តិនាម កិត្តិស័ព្ទដ៏រុងរឿងរបស់បក្សឡើយ ។

ទោះបីជាកំពុងឈឺចុកចាប់ នៅក្នុងខ្លួនប្រាណមិត្តយ៉ាងណាក៏ដោយ មិត្តខំស្ទុះក្រោកឈរពើងដើមទ្រូងដាក់ខ្មាំង ហើយក្ដាប់ដៃស្ដាំយ៉ាងណែនលើកទៅលើ ស្រែកបន្លឺពាក្យស្លោកពោពេញទៅដោយមនោសញ្ចេតនាបដិវត្តន៍ គោរពស្រឡាញ់ និងដឹងគុណបក្សយ៉ាងជ្រាលជ្រៅបំផុត ។ សំឡេងមួយដ៏ស្រួយក្រអៅ បានផ្ទុះចេញពីក្នុងជម្រៅបេះដូងក្រហមឆ្អិនឆ្អៅ និងល្អបរិសុទ្ធរបស់មិត្តថាៈ

◆ ជយោ បក្សកុម្មុយនីស្ដកម្ពុជាដ៏រុងរឿង!

រួចហើយ មិត្តស្រែកផ្ដាំផ្ញើដល់យុទ្ធមិត្តឯទៀត ដែលកំពុងជាប់ឃុំឃាំងនៅក្នុងគុកនេះទាំងអស់គ្នាថាៈ

◆ សូមកុំបោះបង់ចោលហិង្សាបដិវត្តន៍របស់បក្សឲ្យសោះ!

◆ សូមយុទ្ធមិត្ត បន្តការប្រយុទ្ធទៅទៀត ប្រយុទ្ធរហូតដល់ទីអវសាន្ត កុំខ្លាចលះបង់ឡើយ!

រំពេចភ្លាមនោះ សូរសំឡេង ឱសម្រែក ជយោបក្សកុម្មុយនីស្ដកម្ពុជា និងសម្រែកបដិសេធ បកអាក្រាត និងថ្កោលទោសអំពើឧក្រិដ្ឋរបស់ខ្មាំង ក៏បានលាន់ឮកងរំពងកក្រើករំពើកពេញទាំងគុក ធ្វើឲ្យបរិយាកាសអាប់អួរនៅក្នុងគុកនេះប្រែក្លាយទៅជាមហាមិទ្ទីងដ៏ធំមួយ ដែលបកអាក្រាត និងកាត់ទោសឧក្រិដ្ឋរបស់ចក្រពត្តិអាមេរិក និងបរិវារក្បត់ជាតិ ឆ្កែបម្រើដាច់ថ្លៃរបស់វាទាំងអស់ ។

ខ្មាំងបានអូសមិត្តយុវជនអនាមិកនេះ ចេញផុតបាត់ទៅហើយ តែសម្រែកជ័យឃោស ជយោបក្សកុម្មុយនីស្ដកម្ពុជា និងសម្រែកបដិសេធបកអាក្រាតថ្កោលទោសខ្មាំងនៅតែលាន់ឮកងរំពងពេញគុកយ៉ាងយូរក្រោយមកទៀត ។

មិត្តបានពលីជីវិតដ៏ក្មេងខ្ចីរបស់មិត្ត យ៉ាងអង់អាចក្លាហានបំផុត ។ សឹង ង៉ុកថាញ់ អ៊ិន តាំ ចេង ហេង និងបក្ខពួកវាដែលជាបរិវារដាច់ថ្លៃរបស់ចក្រពត្តិអាមេរិក រហូតដល់ដណ្ដើមបានមហាជ័យជម្នះទាំងស្រុង និងជាស្ថាពរ ។

ដោយសារឈាមស្រស់ របស់យុវជន-យុវនារីកម្ពុជាដ៏អង់អាចក្លាហាន និងរបស់ប្រជាជនកម្ពុជាដ៏មហិមា ដែលបានប្រយុទ្ធវាយកម្ទេចខ្មាំង បានធ្វើពលិកម្មគ្រប់បែបយ៉ាងនៅលើគ្រប់សមរភូមិយ៉ាងនេះហើយ ទើបកម្ពុជា មាតុភូមិជាទីស្នេហារបស់យើងទាំងអស់គ្នា ត្រូវបានរំដោះទាំងស្រុង និងជាស្ថាពរដល់សព្វថ្ងៃនេះ ។

យើងខ្ញុំជាយុវជនយុវនារីកម្ពុជាទាំងអស់ ប្ដេជ្ញារៀនសូត្រគំរូវីរភាព គំរូប្រយុទ្ធដាច់ខាត និងគំរូលះបង់ដោយឥតលក្ខខណ្ឌរបស់បុព្វយុទ្ធមិត្តទាំងឡាយ ប្ដេជ្ញាវាយសម្រុកការពារបក្ស ការពារប្រទេស កសាងប្រទេសជាតិ ឲ្យបានខ្លាំងក្លា សម្បូរសប្បាយ និងថ្កុំថ្កើងរុងរឿង យ៉ាងឆាប់រហ័សលោតផ្លោះ ។ **ឆេង ខ៉េង**

# ការស្លាប់របស់ជនភៀសខ្លួនវៀតណាម និងអ្នកនេសាទជនជាតិថៃ នៅកោះពូលូវ៉ៃថ្មី

អ៊ូ គីម ហៅ រ៉េត គឺជាអតីតកងទ័ពជើងទឹកខ្មែរក្រហម កងពល១៦៤ ដែលបានឈរជើងប្រចាំការនៅលើកោះពូលូវ៉ៃថ្មី នៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ តាមអ្វីដែល រ៉េត បានរៀបរាប់ គឺនៅកោះពូលូវ៉ៃថ្មីនេះ ជនភៀសខ្លួនវៀតណាម និងអ្នកនេសាទជនជាតិថៃរាប់រយនាក់ត្រូវបានសម្លាប់ ក្រោមបញ្ជារបស់មេបញ្ជាការកងពល១៦៤ បន្ទាប់ពីកងទ័ពជើងទឹកចាប់ខ្លួនអ្នកទាំងនោះពីក្នុងដែនសមុទ្រនៃប្រទេសកម្ពុជា ។

ជាអ្នកដែលមានស្រុកកំណើតនៅស្រុកបន្ទាយមាស ខេត្តកំពត រ៉េត បានរៀនសូត្រត្រឹមថ្នាក់ទី៧ (សង្គមចាស់) ប៉ុណ្ណោះ ។ ក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ១៨មីនា ឆ្នាំ១៩៧០ រ៉េត បានឈប់រៀន ដោយសារតែភូមិស្រុករបស់គាត់ជាតំបន់ប្រទាញប្រទង់គ្នារវាងកងទ័ពខ្មែរក្រហម និងទាហានលន់ នល់ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧២ រ៉េត បានស្ម័គ្រចិត្តបម្រើចលនាខ្មែរក្រហមតាមរយៈប្រធានឃុំត្នោតចុងស្រង់ ។ គាត់ និងមិត្តភក្តិនៅក្នុងភូមិជាមួយគ្នាយល់ថា ការស្ម័គ្រចិត្តចូលធ្វើជាយោធាខ្មែរក្រហមនេះ គឺដើម្បីរំដោះប្រទេសជាតិ ។ ដំបូង រ៉េត ចូលធ្វើយោធាប្រចាំអង្គភាពវរសេនាតូចលេខ៥៧របស់ស្រុកបន្ទាយមាស បានរយៈពេលពីរឆ្នាំ ដោយមានប្រធានឈ្មោះ សារ៉ែន ។ នៅឆ្នាំ១៩៧៤ ខ្មែរក្រហមបានបញ្ជូន រ៉េត ទៅនៅអង្គភាពយោធាកងអន្តរាគមន៍របស់តំបន់៣៥ ដែលមានទីតាំងស្ថិតនៅពីខាងកើតទឹកវិលខេត្តកំពត ។ ពេលនោះ រ៉េត ត្រូវបានអង្គភាពបញ្ជូនទៅសមរភូមិមុខ ដើម្បីវាយជាមួយទាហាន លន់ នល់ ។ អង្គភាពរបស់ រ៉េត បានវាយចល័តពីខេត្តកំពតចូលទៅទីក្រុងភ្នំពេញ ។

ក្រោយជ័យជម្នះទូទាំងប្រទេសនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនដែលរស់នៅទីក្រុងឲ្យទៅរស់នៅតាមស្រុកស្រែចម្ការនៅតាមជនបទដាច់ស្រយាល ។ ចំណែក រ៉េត និងកងទ័ពមកពីភូមិភាគនិរតីជាច្រើនទៀតត្រូវបានអង្គការបញ្ជូនឲ្យចូលក្នុងកងពល១៦៤ ឈរជើងនៅក្រុងកំពង់សោម ដែលមាន មាស មុត ជាប្រធានកងពល និង សេង អនុប្រធានកងពល ។ ខ្មែរក្រហមបានបង្កើតកងពល១៦៤នេះឡើង គឺដើម្បីការពារដែនកោះ និងទឹកទាំងអស់របស់ប្រទេសកម្ពុជាដែលមានព្រំប្រទល់ជាប់ជាមួយនឹងប្រទេសវៀតណាម និងប្រទេសថៃ ។ កងទ័ពជើងទឹករបស់ខ្មែរក្រហមមានឯកសណ្ឋាន គឺពាក់មួកពណ៌ខៀវ និងខោអាវខ្មៅដូចកងទ័ពខ្មែរក្រហមនៅតាមអង្គភាពផ្សេងទៀតដែរ ។ បន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលជ័យជម្នះភ្លាមៗនោះដែរ ខ្មែរក្រហមបានដាក់ផែនការឲ្យកងទ័ពរបស់ខ្លួនការពារដែនកោះទាំងអស់របស់ខ្លួន និងដាក់ផែនការវាយដណ្តើមកោះដែលបានបាត់បង់លើប្រទេសវៀតណាមមកវិញ ទោះជាខ្មែរក្រហមបានដឹងថា ខ្លួនមិនមានសព្វាវុធគ្រប់គ្រាន់ក៏ដោយ ។ គ្រឿងសព្វាវុធដែលមាន គឺច្រើនជាសព្វាវុធដែលសេសសល់ពីសម័យសង្គ្រាម៥ឆ្នាំ និងកប៉ាល់ដែលសេសសល់ពីរបបលន់ នល់ ប៉ុណ្ណោះ ។ ជាក់ស្តែងនៅចុងខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបញ្ជូនកងទ័ពរបស់ខ្លួនមួយចំនួនក្នុងគោលបំណងវាយយកកោះត្រល់ និងកោះក្រចកសេះពីប្រទេសវៀតណាមមកវិញ តែត្រូវបរាជ័យកងទ័ពខ្មែរក្រហមទាំងអស់ ត្រូវស្លាប់ និងចាប់ខ្លួន ។ បន្ទាប់មកទៀត ខាងភាគីប្រទេសកម្ពុជាបានធ្វើការចរចាជាមួយប្រទេសវៀតណាមតាមផ្លូវការទូត ទើបកងទ័ពខ្មែរក្រហមទាំងនោះមានវាសនាបានត្រឡប់មកវិញ ។ ក្រោយពេលដែលកងទ័ពទាំងអស់ត្រឡប់មកវិញ គឺមិនត្រូវបានទទួលស្វាគមន៍ពីថ្នាក់ដឹកនាំកងពលឡើយ ដោយអង្គការបានដកសេចក្តីទុកចិត្ត និងបញ្ជូនឲ្យទៅធ្វើការកន្លែងផ្សេងវិញ ។

រ៉េត ត្រូវអង្គការចាត់តាំងឲ្យនៅក្នុងកងវរសេនាតូច៦២១ ចំណុះឲ្យកងវរសេនាធំ៦២ ដោយមាន ណន ជាប្រធានកងវរសេនាតូចលេខ៦២១ និង យាង ជាប្រធានវរសេនាធំ៦២ ។ ខ្មែរក្រហមបានបញ្ជូនគាត់ និងកងវរសេនាតូច៦២១ ទៅការពារកោះ

រុង និងកោះតាង ក្នុងមួយរយៈពេលខ្លី ។ វ៉េត រៀបរាប់ឲ្យ ដឹងថា ពេលទៅដល់កោះដំបូងកងទ័ពមានការលំបាកក្នុងជីវភាពរស់នៅ ទាំងការហូបចុក និងទឹកសម្រាប់ប្រើប្រាស់ ទំរាំតែមានកប៉ាល់ដឹក ស្បៀងដឹកទឹកពីក្រុងកំពង់សោមទៅផ្គត់ផ្គង់ឲ្យកងទ័ព ។ ថ្វីត្បិតតែ វ៉េត មិនបានការពារគ្រប់កោះ តែគាត់បានស្គាល់កោះស្ទើរតែទាំងអស់ របស់ខ្មែររួមមានកោះព្រីង, កោះកុក, កោះទន្សាយ, កោះពូលូវៃ ចាស់, កោះពូលូវៃថ្មី, កោះអន្ទ្រង, កោះសេះ, កោះថ្មី, កោះបុស្ស៊ី, កោះស្រមោច, កោះរុង, កោះរុងសន្លឹម, កោះក្រាស, កោះតាកៀវ, កោះស្នាច់, កោះមូល, កោះពោធិ៍, កោះតាង, កោះក្រចកសេះ និងកោះតូចៗជាច្រើនផ្សេងទៀត ។ លើកលែងតែ កោះត្រល់ និង កោះក្រចកសេះប៉ុណ្ណោះ ដែលត្រូវជនជាតិវៀតណាមឈ្លានពាន និង កាន់កាប់ ។

ប្រហែលចុងឆ្នាំ១៩៧៥ វ៉េត និងសមាជិកផ្សេងទៀត ប្រហែល៤០០នាក់របស់កងវរសេនាតូច៦២១ ត្រូវផ្លាស់ឲ្យទៅ ឈរការពារនៅកោះពូលូវៃថ្មី ។ កោះនេះមានទីតាំងនៅជិតនឹង ខ្សែបន្ទាត់ផ្លូវទឹកអន្តរជាតិ និងអាចមើលឃើញទូកប៉ុក្ក កប៉ាល់ ធ្វើ ដំណើរឆ្លងកាត់ទីនេះ បានទាំងពេលយប់ និងពេលថ្ងៃ ។ ចាប់ពីដើម ឆ្នាំ១៩៧៦ ជនភៀសខ្លួនវៀតណាមបានរត់ចេញពីប្រទេសរបស់ ខ្លួនតាមទូកតូចៗ ដែលអាចផ្ទុកមនុស្សបានប្រមាណជាជាង៣០ នាក់ក្នុងមួយទូកៗ បានប្រថុយនឹងគ្រោះថ្នាក់ ដើម្បីបានទៅរស់នៅ ប្រទេសទី៣ ។ ជនភៀសខ្លួនវៀតណាមទាំងនោះកម្រ បានគេចផុត ពីកងទ័ពខ្មែរក្រហម ដែលឈរប្រចាំការនៅលើកោះពូលូវៃនេះ ណាស់ ។ វ៉េត បានឲ្យដឹងថា ក្នុងមួយខែៗខ្មែរក្រហមចាប់ទូកជន ភៀស ខ្លួនវៀតណាមបានយ៉ាងតិច២គ្រឿង ។ ពេលដែលកងទ័ព នៅលើកោះបានឃើញទូកជនភៀសខ្លួនវៀតណាមបើកឆ្លងកាត់ ឬក៏ទូកនេសាទរបស់ជនជាតិថៃ ចូលនេសាទខុសច្បាប់ក្នុងដែនសមុទ្រ កម្ពុជានោះ ប្រធានកងវរសេនាតូច ណន តែងតែរាយការណ៍ទៅ ថ្នាក់ដឹកនាំកងពល បន្ទាប់មកកងពលបានបញ្ជូនកប៉ាល់អន្តរាគមន៍ ពីកំពង់សោមទៅចាប់ជនភៀសខ្លួន និងអ្នកនេសាទទាំងនោះយក មកដាក់នៅកោះពូលូវៃថ្មី ។

ជនភៀសខ្លួនវៀតណាមភាគច្រើនជាជនស៊ីវិលរួមមាន ស្ត្រី និងកូនក្មេងដែលគ្មានអាវុធមកជាប់នឹងខ្លួន ។ នៅលើកោះពូលូវៃថ្មីកងទ័ពខ្មែរក្រហមបានឆែកឆេរ និងរឹបអូសយកទ្រព្យសម្បត្តិ មានតម្លៃដូចជា មាស ពេជ្រ ពីជនភៀសខ្លួនទាំងនោះ ។ ជនភៀស ខ្លួនដែលជាស្ត្រីភាគច្រើនបានលាក់មាសនៅនឹងប្រដាប់ភេទរបស់ ខ្លួន ។ កងទ័ពខ្មែរក្រហមមានការសង្ស័យ ដោយខោផ្នែកខាងមុខ របស់ស្ត្រីទាំងនោះមានរាងប៉ោងខុសប្លែកពីធម្មតា បន្ទាប់ពីឆែក នៅក្នុងខោទ្រនាប់របស់ស្ត្រីទាំងនោះ និងបានឃើញដាក់សុទ្ធតែជា មាសសន្លឹកជាបន្ទះដែលបិតបង់ស្អិតជាប់នឹងប្រដាប់ភេទ ។ កង ទ័ពខ្មែរក្រហមបានប្រមូលយកមាស និងរបស់របរមានតម្លៃទាំង អស់យកទៅដាក់នៅក្នុងមន្ទីរកងវរសេនាតូច ដែលមានទីតាំងនៅ លើកោះពូលូវៃថ្មីនេះ ។ បន្ទាប់មកប្រធានកងវរសេនាតូចឈ្មោះ ណន រាយការណ៍ទៅថ្នាក់ដឹកនាំកងពល និងរង់ចាំទទួលបញ្ជាថា តើ ត្រូវសម្លាប់នៅលើកោះនេះតែម្តង ឬត្រូវបញ្ជូនមកកំពង់សោម ឬ ត្រូវដោះលែងទៅវិញ ។ កាលនោះគ្មានទូរស័ព្ទទេ គឺប្រើទូរលេខ ដើម្បីទាក់ទងគ្នា ។ វ៉េត ឲ្យដឹងថា បើថ្នាក់លើប្រាប់ថា ឲ្យធ្វើម្ហូបទៅ "ធ្វើម្ហូបមានន័យថាសម្លាប់ចោល" ។ នៅក្នុងសម័យខ្មែរក្រហម គ្មានច្បាប់ច្បាស់លាស់ទេ សូម្បីតែប្រជាជនស៊ីវិលដែលរត់ឆ្លងដែន ក៏ត្រូវអង្គការចាត់ទុកថា ជាខ្មាំងប្រុងមកឈ្លានពានទឹកដីកម្ពុជាដែរ អ្នកដែលត្រូវហៅថា "ខ្មាំង" គឺគ្មានវាសនានឹងបានរស់ទេ សូម្បីតែ កូនក្មេងមិនដឹងអី ក៏ត្រូវសម្លាប់ចោលដែរ ។ បើតាម វ៉េត បានឃើញ ផ្ទាល់ភ្នែកនោះ ថ្នាក់ដឹកនាំរបស់កងពលបានបញ្ជាឲ្យសម្លាប់ជន ភៀសខ្លួនវៀតណាម និងអ្នកនេសាទជនជាតិថៃរាប់រយនាក់ នៅ លើកោះពូលូវៃថ្មីនេះ សាកសពជនរងគ្រោះខ្លះត្រូវកប់ និងខ្លះទៀត ត្រូវបោះចោលទៅក្នុងសមុទ្រ ។

នៅឆ្នាំ១៩៧៦-៧៧ ប្រធានកងពលឈ្មោះ មាស មុត ធ្លាប់ធ្វើដំណើរទៅជួបប្រជុំជាមួយកងទ័ពខ្មែរក្រហមដែលរស់នៅ ការពារតាមដែនកោះ ។ មាស មុត បាននិយាយថា "យើងត្រូវការ ពារកោះរបស់យើងឲ្យបានកុំឲ្យខ្មាំងយួនវាឈ្លានពានយកកោះ របស់ខ្មែរយើង" ពេលប្រជុំចប់ មាស មុត បានយកខ្សែភាពយន្ត ឯកសារមកបញ្ចាំងឲ្យកងទ័ពមើលទាំងអស់គ្នា និងមានចែកសណ្តែក ដីលីងឲ្យហូបថែមទៀតផង ។ ភាពយន្តឯកសារនោះឃើញមាន ប៉ុល ពត និងកម្មាភិបាលខ្មែរក្រហមជាច្រើនផ្សេងទៀតធ្វើទស្សន កិច្ចនៅប្រទេសចិន ដែលជាប្រទេសមហាមិត្ត ។

នៅឆ្នាំ១៩៧៩ រ៉េត ដឹងថាកម្លាំងខ្មែរក្រហមបានចាញ់សង្រ្គាមជាមួយប្រទេសវៀតណាម នៅពេលដែលប្រធានវរសេនាតូច ណន បញ្ជាឲ្យកងទ័ពនៅក្រោម បំផ្លាញកាំភ្លើងធំចោលទាំងអស់មុននឹងចាកចេញពីកោះពូលូវ៉ៃថ្មី កុំឲ្យកងទ័ពវៀតណាមយកកាំភ្លើងទាំងនោះទៅប្រើប្រាស់ ។ រ៉េត និងកងទ័ពទាំងអស់បានជិះកប៉ាល់ចេញមកដល់ក្រុងកំពង់សោម ។ ដោយកងទ័ពមានការភ័យខ្លាចក៏នាំគ្នារត់កាត់ព្រៃបែកគ្នា ខ្លះឃើញស្លាប់តាមផ្លូវ ខ្លះឃើញត្រូវរបួស គ្មានអាហារហូបចុក គ្មានទឹកសម្រាប់ផឹក ទម្រាំទៅដល់ព្រំដែនថៃ ។ រ៉េត បានរត់ចូលទៅក្នុងទឹកដីថៃរស់នៅក្នុងជំរំស្រះកែវដែលក្រោមការគ្រប់គ្រងរបស់អង្គការមនុស្សធម៌មួយចំនួន ។

ក្រោយមកទៀត រ៉េត បានសម្រេចចិត្តចូលមកទឹកដីកម្ពុជាវិញ គឺរស់នៅម្តុំចក្រី, លែម និងកំរៀង ។ រ៉េត បានចូលធ្វើជាកងទ័ពខ្មែរក្រហមម្តងទៀត ដើម្បីធ្វើសង្រ្គាមប្រឆាំងជាមួយកងទ័ពវៀតណាម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ រ៉េត បានចូលធ្វើកងទ័ពនៅកងពលធំលេខ៣២០ កងពលតូច៤០៥ ប្រធានកងពល ឈ្មោះ នី កន ។ រ៉េត បានត្រឡប់មករស់នៅស្រុកកំណើតវិញ នៅឆ្នាំ១៩៩២ បន្ទាប់ពីស្ថានភាពស្រុកទេសមានស្ថេរភាពបន្តិច ។ **ស៊ាង ចិន្តា**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញែកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ : ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*





# អតីតគណៈកងពលទី២ ភូមិភាគពាយ័ព្យ

ប៉ុក សុផាត ហៅ ផាត មានតួនាទីជាអនុប្រធានកងពលទី២ ប្រចាំភូមិភាគពាយ័ព្យ បន្ទាប់ពីអង្គការខ្មែរក្រហមចាប់ និងសម្លាប់ អតីតកម្មាភិបាលរបស់ភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៧ និង ១៩៧៨ ។ កងពលទី២ មានភារកិច្ចការពារព្រំដែនចាប់ពីត្រែង, សំឡូត, ប៉ៃលិន រហូតព្រំប្រទល់ ពោធិ៍សាត់ និងកោះកុង ។

ផាត សព្វថ្ងៃមានអាយុ៦៤ឆ្នាំ និងមានស្រុកកំណើត នៅស្រុកសំរោង ខេត្តតាកែវ ។ កាលពីនៅក្មេង ផាត រៀនសូត្របាន ត្រឹមថ្នាក់ទី៧ចាស់ ។ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ, ផាត បានឈប់រៀន និងស្ម័គ្រចិត្តចូលធ្វើកងទ័ព ខ្មែរក្រហមនៅឆ្នាំ១៩៧០ តាមរយៈការអំពាវនាវរបស់សម្តេច ព្រះ នរោត្តម សីហនុ ឲ្យកូនចៅចូលព្រៃម៉ាគី ដើម្បីរំដោះប្រទេស ជាតិ ។ ដំបូង ផាត និងយុវជននៅក្នុងភូមិបានចូលរួមសហការជាមួយ កងទ័ពវៀតណាមខាងជើង ដើម្បីវាយទប់ទល់ជាមួយទាហាន លន់ នល់ និងកងទ័ពវៀតណាមខាងត្បូង ។

នៅឆ្នាំ១៩៧៣ កងទ័ពវៀតណាមខាងជើងបានដកត្រឡប់ ទៅប្រទេសវៀតណាមវិញ បន្ទាប់ពីខ្មែរក្រហមមានកម្លាំង និង សមត្ថភាពគ្រប់គ្រាន់ ដើម្បីទប់ទល់ជាមួយសត្រូវ ។ នៅពេលនោះ កងទ័ពខ្មែរក្រហមមិនមានរៀបជាកងពលទេ គឺមានត្រឹមតែ កងតូច, កងធំ, វរសេនាតូច និងវរសេនាធំ ប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៤ ខ្មែរក្រហមចាប់ផ្តើមរៀបចំជាកងពល ដើម្បីវាយជាទ្រង់ទ្រាយធំ ហើយ ផាត ត្រូវបានដំឡើងទៅជាប្រធានកងវរសេនាតូច នៅក្នុង កងពលទី១ របស់ភូមិភាគនិរតី ដោយ មាន ពេទ្យ សឿន និង ស៊ូ ម៉េត ជាគណៈកងពល ។

នៅដើមឆ្នាំ១៩៧៥កម្លាំងរបស់ ផាត បានវាយជាមួយ ទាហានលន់នល់ នៅស្រុកសំរោង ខេត្តតាកែវ ។ សង្គ្រាមរវាងកង ទ័ពខ្មែរក្រហម និងកងទ័ពខាង លន់ នល់ មានស្លាប់ និងរបួសជា រៀងរាល់ថ្ងៃ ។ ផាត ត្រូវរបួសដៃខាងស្តាំហើយត្រូវដឹកយកទៅ សម្រាកព្យាបាលនៅមន្ទីរពេទ្យកងពល នៅក្រាំងក្រសាំង ។ ខណៈ ពេលនោះមានបុគ្គលិកពេទ្យជាច្រើននាក់បានព្យាបាលដៃឲ្យ ផាត ។ ប៉ុន្តែ ទោះជាការព្យាបាលយ៉ាងណា ក៏ដៃស្តាំរបស់ ផាត ចេះតែហើម ទៅៗ ស្ទើរពេញមួយចំហៀងខ្លួន ។ ក្រោយមកលោកវេជ្ជបណ្ឌិត ជួន ជឿន បានមកពិនិត្យមុខរបួសរបស់ ផាត ហើយគាត់បានគ្រវី ក្បាល ឃើញដូច្នេះ ផាត មានការអស់សង្ឃឹមក្នុងចិត្តថា របួសរបស់ គាត់មិនអាចជាសះស្បើយវិញទេ ។ តែមុននឹងត្រឡប់ទៅវិញ ជួន ជឿន បានប្រាប់ឲ្យបុគ្គលិកពេទ្យចាក់ថ្នាំផ្សះបន្ថែម និងលាង របួស មួងទៀត ។ នៅខណៈពេលនោះពេទ្យបានរកឃើញមានបង់រុំរបួស ដែលពេទ្យភ្លេចមិនបានដោះចេញនៅពេលដែលពួកគេដេររបួស ឡើងវិញ ។ បន្ទាប់ពីឆ្កឹះយកបង់រុំរបួសចេញ និងវះឲ្យហូរខ្ទុះចេញ អស់ ក៏ចាប់ផ្តើមធូរស្រាលរហូតដល់ជាសះស្បើយ ។ បន្ទាប់ពីទទួល ជ័យជម្នះទូទាំងប្រទេសនៅឆ្នាំ១៩៧៥ ភ្លាមខ្មែរក្រហមបានបង្កើត កងពលជើងអាកាស៥០២ និងបានដកកម្លាំងមួយចំនួនរបស់ កងពលទី១ ដើម្បីបញ្ចូលទៅក្នុងកងពល៥០២នេះ ។ ចំណែកកម្លាំង នៅសេសសល់របស់កងពលទី១ ត្រូវបញ្ជូនទៅឲ្យខាងភូមិភាគបស្ចិម របស់ ជូ ជេត ហៅ ស៊ី ។ កងពលទី១ ត្រូវប្រចាំការនៅលង្វែក ។ ផាត ត្រូវអង្គការចាត់តាំងឲ្យឡើងមកធ្វើជាអនុប្រធានវរសេនាធំប្រចាំ នៅបន្ទាយលង្វែក ។

នៅឆ្នាំ១៩៧៦ ផាត, សែ, សុក ភាព និង យឹម យន ត្រូវ អង្គការផ្លាស់ពីកងពលទី១ ឲ្យមកបាត់ដំបង ។ ផាត និង សែ ត្រូវបាន ចាត់តាំងឲ្យនៅក្នុងកងពលទី២របស់ភូមិភាគពាយ័ព្យ ។ ពេលនោះ ផាតទទួលជាប្រធានវរសេនាធំ ប្រចាំនៅត្រែង, សំឡូត និងប៉ៃលិន ។ ចំណែក សុខ ភាព និង យឹម យន ក៏ត្រូវអង្គការបញ្ជូនពីលង្វែកឲ្យទៅ ទទួលវរសេនាធំនៅក្នុងកងពលទី១ ប្រចាំភូមិ ភាគពាយ័ព្យដែរ ។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចាប់ និងសម្លាប់ប្រធាន, អនុប្រធានកងពលទី១ និងទី២ រួមទាំងកម្មាភិបាលថ្នាក់វរសេនាធំ និងវរសេនាតូចរបស់ភូមិភាគពាយ័ព្យស្ទើរតែទាំងអស់ ។ តាម៉ុក បាន ចាត់តាំង ផាត និងឈ្មោះ ដន ដែលជាអតីតមេបញ្ជាការកងទ័ពមក

ពីតាកែវជាមួយគាត់ (តាម៉ុក) ឲ្យឡើងធ្វើប្រធានកងពលទី២ តាម៉ុក បានប្រាប់ថា ពីរនាក់ហ្នឹងអ្នកណាធ្វើជាប្រធានក៏បាន ពេលនោះ ផាត បានប្រាប់ តាម៉ុក ថាឲ្យឈ្មោះដន ទទួលជាប្រធាន ចំណែកគាត់ (ផាត) សុខចិត្តទទួលនាទីជាអនុប្រធាន ។ ផាត បាននិយាយថា រាល់ការងារប្រជុំ ឬសរសេររបាយការណ៍ គឺ គាត់ជាអ្នកទទួលខុសត្រូវ ពីព្រោះ ដន មិនសូវចេះអក្សរ និងការងាររដ្ឋបាល ។

បន្ទាប់ពីកម្មាភិបាលតាមភូមិភាគ, តំបន់, ស្រុក និងក្នុងជួរកងទ័ពត្រូវចាប់ខ្លួន ផាត បានរក្សាទុកនីរសារ និងកងការពារមួយចំនួនដើម្បីប្រើបន្ត ។ ខណៈពេលនោះ សែ ដែលជាគណៈកងពលទី២ដែរ បានប្រាប់ទៅ ផាត វិញថា បងឯងម៉េចបានជាយកកូនចៅរបស់គេមកប្រើប្រយ័ត្នគេរៀបចំគម្រោងសម្លាប់បងឯងចោល ព្រោះមេរបស់គេត្រូវចាប់អស់ហើយ ប្រយ័ត្នគេគុំ ។ ផាត បានឲ្យដឹងថា មុននឹងយកនីរសារ និងកងការពារចាស់ៗនោះមកប្រើ គឺ គាត់បានសួរនីរសារ និងកងការពារទាំងនោះហើយ ថាមេមិត្តឯងអង្គការចោទថាក្បត់ទៅហើយ ចុះពួកមិត្តឯងមានក្បត់ដូចមេដែរអត់? ពេលនោះនីរសារ និងកងការពារយំលើកដៃសំពះថា ខ្ញុំមិនដែលបានដឹងអីទេ ខ្ញុំមិនដឹងថាក្បត់យ៉ាងម៉េចទេ បើងបើមិនបានក្បត់ដូចមេទេ មកធ្វើការជាមួយគ្នាបន្តទៀត តាំងពីពេលនោះមក យកមកប្រើរហូត ។ នៅក្នុងឆ្នាំ១៩៧៨ មិនចាំថាពាក់កណ្តាលឆ្នាំ ឬចុងឆ្នាំទេ តាគី ដែលជាអនុលេខាភូមិភាគពាយ័ព្យ បានមកជួបជាមួយ ផាត លើកចុងក្រោយមុនពេលត្រូវបានខ្មែរក្រហមចាប់ខ្លួន ។ តាគី បានហៅ ផាត ថាបងៗ ។ ផាត មានការភ្ញាក់ផ្អើល និងសង្ស័យថា ហេតុអីបាន តាគី ហៅគាត់ថាបងៗ ព្រោះទាំងអាយុនិងឋានៈនៅក្នុងបក្ស គឺ ផាត តូចជាង តាគី ទេ មើលទៅគាត់ហាក់បីដូចជាខ្លាច ឬដឹងរឿងអ្វីមុន ។ ផាត ក៏ធ្លាប់បានទៅប្រជុំ និងធ្វើការជាមួយ រស់ ញឹម នៅផ្ទះរបស់គាត់ក្នុងមន្ទីរពេទ្យព-២ ខេត្តបាត់ដំបង ចំនួនពីរទៅបីដងដែរ ទៅលើកចុងក្រោយ ផាត បានសៀតកាំភ្លើងខ្លីនៅចង្កេះ ពេលនោះកងការពារម្នាក់របស់ តា ញឹម ឈ្មោះព្រះអង្គខ្មៅសួរថា បងឈប់សិន បង! សូមទោសមានយកកាំភ្លើងមកដែរទេ ផាត ឆ្លើយប្រាប់ត្រង់ថា យកមក ។ ផាត គិតក្នុងចិត្តថា ទៅផ្ទះមេមិនគួរណាដាក់កាំភ្លើងទៅចឹងទេ ។ ពេលនោះឃើញ តាញឹម បើកភ្នែកធំៗមើលមករក ផាត ។ ពេលនោះ តាញឹម ត្រវីក្បាល និងពោលពាក្យថា ផាត អើយ ឯងមិនដឹងថា ពួកថ្នាក់ក្រោមវាក្បត់ចឹងសោះ ផាត បានគិតថា តាញឹម និយាយនេះក្នុងន័យសម្រាលខ្លួនគាត់ តែចម្លើយនេះ មើលទៅដូចជារសេមរសាម មិនបានដឹងថា គាត់បានដឹងកងពលខាងក្រោមគាត់ក្បត់មែន ឬក៏អត់ទេ ។ ផាត ឲ្យដឹងទៀតថា តាញឹម មានរាងមាឌធំខ្ពស់ស្រដៀងនឹង ប៉ុល ពត តែសម្បុរខ្មៅជាង ប៉ុល ពត ។ ពេលនៅផ្ទះ តាញឹម ស្លៀកតែសារុងសូត្រ និងពាក់អាវយឺតសដៃខ្លីប៉ុណ្ណោះ ។ បន្ទាប់ពី ផាត បានចេញពីផ្ទះ តាញឹម បានរយៈពេល២ថ្ងៃ អង្គការបានចាប់ខ្លួន តាញឹម យកទៅបាត់ ។ សភាពការណ៍នៅភូមិភាគពាយ័ព្យនៅពេលនោះច្របូកច្របល់ខ្លាំងណាស់ ចោទគ្នាទៅវិញទៅមក កាច់កុងគ្នា ចាប់គ្នាដូចជាផ្ទាយខ្លាំងណាស់ ។ ពេលនោះគណៈតំបន់ និងគណៈស្រុកសំឡូត "ចាស់" ឈ្មោះ ដូ ក៏ត្រូវចាប់ខ្លួនដែរ ។ តាម៉ុក បានចាត់តាំងឲ្យ ផាត ទទួលខុសត្រូវស្រុកសំឡូតបន្ថែមលើតួនាទីកងទ័ព ។ នៅពេល ផាត ដឹកនាំនៅស្រុកសំឡូត គឺប្រជាជនមានអាហារហូបគ្រប់គ្រាន់ ។ ផាត ឲ្យដឹងថា ប្រជាជននៅស្រុកសំឡូត ចូលចិត្ត និងស្រឡាញ់រាប់អានគាត់គ្រប់ៗគ្នា ។ ផាត គ្រប់គ្រងស្រុកសំឡូតបានតែរយៈពេលបួនខែ ទើបមានអ្នកថ្មីទៅគ្រប់គ្រងជំនួសវិញ ។

ផាត បានឲ្យដឹងទៀតថា ពេលប្រជុំទទួលផែនការពី តាម៉ុក និងអង្គការលើម្តងៗ ឧទាហរណ៍ដូចថា តាម៉ុក ឬអង្គការថ្នាក់លើដាក់ផែនការឲ្យធ្វើ១០នោះ ផាត យកមកអនុវត្តតែត្រឹម៥ទេ បើធ្វើតាមផែនការទាំងអស់នោះគឺងាប់ថ្នាក់ក្រោមអស់ហើយ ។ ផាត បន្ថែមថា គាត់ធ្លាប់នាំកម្មាភិបាល ថ្នាក់ក្រោមប្រហែល១៥ទៅ ២០នាក់ទៅរៀនសូត្រ តែមិនមែនយកទៅសម្លាប់ទេ គឺពេលរៀនសូត្រចប់ គាត់បាននាំអ្នកទាំងអស់នោះត្រឡប់មកវិញ ។

នៅក្នុងសម័យខ្មែរក្រហម ឲ្យតែហៅទៅរៀនសូត្រអ្នកណាក៏គេយល់ដែរ ភាគច្រើនមិនបានត្រឡប់មកវិញទេ ។ ពេលអង្គការចង់ចាប់អ្នកណាម្នាក់តែងតែប្រើវិធីសាស្ត្រ ដោយកុហកថា អង្គការហៅឲ្យទៅរៀនសូត្រ នៅជំនាន់នោះគ្មានផ្លូវអាចរត់គេចបានទេ ពេលទៅប្រជុំរៀនសូត្រ អង្គការមានកន្លែងឲ្យស្នាក់នៅមានបន្ទប់ដូចជាផ្ទះសំណាក់បច្ចុប្បន្នអ៊ីចឹង ។ ពេលនោះមានយោធាប្រចាំការប្រាប់ថា អ្នកណាត្រូវសម្រាកនៅបន្ទប់ណាៗ គឺត្រូវចូលទៅបន្ទប់រៀងៗខ្លួន អ្នកណាត្រូវរៀនៗ អ្នកណាត្រូវត្រឡប់ទៅវិញ ទៅវិញ

អ្នកណាត្រូវចាប់ខ្លួន ចាប់ខ្លួនអីចឹងទៅ ។

នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមកដល់ប្រទេសកម្ពុជា ផាត ត្រូវដំឡើងជាប្រធាន កងពលទី២ ប្រចាំការនៅសំឡូត និងប៉ៃលិន ។ ផាត បានឃើញកម្មាភិបាលខ្មែរក្រហម និងប្រជាជនរត់ភៀសខ្លួនទៅជាយដែនថៃ ដោយសារតែសង្គ្រាមនិងភ័យខ្លាចវត្តមានកងទ័ពវៀតណាម ។ ផាត បាននាំកងកម្លាំងខ្មែរក្រហមចាំត្រៀមទប់ទល់ជាមួយកងទ័ពវៀតណាម ទុកផ្លូវឲ្យប្រជាជនរត់ទៅមុនពេលនោះ ផាត បានជួបជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់រួមមាន ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី និង មានភ្ញៀវទូតមួយចំនួនទៀត ។ ពេលនោះ ប៉ុល ពត ដឹងថា ផាត ជាអ្នកដឹកនាំកម្លាំងនៅទីនេះ ពិតជាដឹងភូមិសាស្ត្រច្រើន ក៏សួរថា មើលមិត្ត ឥឡូវយួនដេញជិតទាន់ហើយ បើទៅនៅប៉ៃលិនយ៉ាងម៉េចដែរ? ពេលនោះ ផាត ភ័យផងគិតផង ហើយបានប្រាប់វិញថា អ៊ំ ទៅនៅប៉ៃលិនមិនបានទេ មានតែនៅសំឡូតទេ ផ្លូវទៅវាពិបាកធ្វើដំណើរបន្តិច តែយើងអាចទប់ទល់ និងដកថយបានពីព្រោះមានព្រៃច្រើន កម្លាំងយួនមិនងាយចូលដល់ ។ ពេលនោះ ប៉ុល ពត បានយល់ព្រម ។ ផាត បាននាំមេដឹកនាំទាំងនោះទៅស្នាក់នៅតាសាញ់ក្នុងស្រុកសំឡូត ។ បន្ទាប់មកខ្មែរក្រហមបានប្រមូលបានកម្លាំងរាប់ម៉ឺននាក់នៅតាមព្រំដែនកម្ពុជា-ថៃ និងបានរៀនចំជាច្រើនកងពល ដើម្បីបន្តធ្វើសង្គ្រាមប្រឆាំងជាមួយកងទ័ពវៀតណាម និងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ នៅឆ្នាំ១៩៨៥ ផាត ត្រូវបានថ្នាក់លើដកពីសំឡូតមកទទួលជាអនុកងពល៦១៦ ដែលប្រចាំការនៅខេត្តព្រះវិហារ ។ នៅឆ្នាំ១៩៩៧ តាម៉ុក បានចាត់តាំង ផាត ឲ្យត្រឡប់មកសំឡូត ដើម្បីសហការជាមួយ មាស មុត និង អៀង ផាន ដែលបានផ្តាច់ខ្លួនចេញពីរាជរដ្ឋាភិបាលកម្ពុជាវិញ បន្ទាប់ពីមានព្រឹត្តិការណ៍ថ្ងៃ៥-៦ ខែកក្កដា ឆ្នាំ ១៩៩៧ នៅភ្នំពេញ ។ នៅទីបញ្ចប់ ផាត បានសម្រេចចិត្តចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅប៉ៃលិនក្នុងឆ្នាំ១៩៩៨ ។ **សុខ ខណ្ណៈ**



កងទ័ពបដិវត្តន៍ខ្មែរក្រហម ធ្វើដំណើរទៅវាយប្រយុទ្ធទល់នឹងកងទ័ពវៀតណាម នៅសមរភូមិ នៅខែធ្នូ ឆ្នាំ១៩៧៧

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

*(តពីលេខមុន)*

## *៣) បែបបទនៃការវិវត្តផ្នែកសាសនា*

*ចម្ប៉ាគឺជាអាណាចក្រហិណ្ឌូ ។ នៅក្នុងចំណោមប្រាសាទកសាងឡើងដោយជនជាតិចាមនៅកន្លែងមួយចំនួននៅវៀតណាមទំនើបបច្ចុប្បន្ននេះ ប្រាសាទសំខាន់បំផុតមានទីតាំងនៅ មីសុន និង ប្រាសាទ ប៉ូណាហ្គា នៅញ៉ាចាង ។ ប្រាសាទហិណ្ឌូទាំងនេះបញ្ជាក់ថាចាមទទួលឥទ្ធិពលយ៉ាងខ្លាំងពីឥណ្ឌា ជាពិសេសនៅមុនពេលនៃការរីកចម្រើនឡើងរបស់អាណាចក្រស្រីវិទ្យា កាន់សាសនាហិណ្ឌូ ពុទ្ធសាសនា ដែលបានកាន់កាប់ស៊ូម៉ាត្រា ជ្វាភាគខាងលិច និងឧបទ្វីបម៉ាឡេស៊ី ចាប់ពីសតវត្សរ៍ទី៧ ដល់ទី១៣ ។ តាមរយៈការគ្រប់គ្រងច្រកសមុទ្រម៉ាឡាកា និងស៊ុនដា (Sunda) អាណាចក្រនេះ គ្រប់គ្រងផ្លូវដឹកជញ្ជូនគ្រឿងទេសរវាងប្រទេសឥណ្ឌា និងចិន ។ ស្រីវិទ្យា គឺជាមហាអំណាចវប្បធម៌ និងនយោបាយថ្នាក់តំបន់មួយទៀតដែលមានឥទ្ធិពលលើចម្ប៉ា ។ អាណាចក្រនេះបានលុកលុយញ៉ាចាង នៅក្នុងឆ្នាំ៧៧៤ និងផាន់រ៉ាង ក្នុងឆ្នាំ៧៨៧ ។ ស្រីវិទ្យាមានឥទ្ធិពលលើចម្ប៉ា តាមរយៈសង្គ្រាម និងសន្តិភាព ។ បន្ថែមពីលើសាសនា ចម្ប៉ារៀនសូត្រផ្នែកការិយាធិបតេយ្យគ្រប់គ្រងរដ្ឋបាល និងស្ថាបត្យកម្មពីឥណ្ឌា ។*



*ប្រាសាទរចនាបថចាម នៅមីសុន បច្ចុប្បន្នប្រទេសវៀតណាម*

សាសនាអ៊ីស្លាម បានចូលមកដល់ឥណ្ឌូនៅសតវត្សរ៍ទី១៣ តាមរយៈការឈ្វានពាន និងពាណិជ្ជកម្ម ។ នៅដើមសតវត្សរ៍ទី១៥ (Gaes Aceh) នៅចុងខាងក្រោមស៊ូម៉ាត្រា បានក្លាយទៅជាក្រុងកាន់សាសនាអ៊ីស្លាម ។ នៅពេលនោះ សាសនាអ៊ីស្លាមបានរីករាលដាលទៅដល់ផ្នែកផ្សេងៗទៀត នៃស៊ូម៉ាត្រា និងផ្នែកផ្សេងទៀតនៃស្រីវិជ្ជ័យ ។ ស្រីវិជ្ជ័យ ដែលមានទំនាក់ទំនងជនជាតិ និងភាសាជាមួយចម្ប៉ារាប់សតវត្សរ៍មកហើយ បានបន្តពង្រីកសាសនាអ៊ីស្លាមទៅចម្ប៉ា ។ ប៉ុន្តែ ភ័ស្តុតាងខ្លះបានបង្ហាញថា សាសនាអ៊ីស្លាមត្រូវបានផ្សព្វផ្សាយនៅចម្ប៉ាក្នុងសតវត្សរ៍ទី១២ ប៉ុន្តែ រីករាលដាលខ្លាំងនៅក្នុងសតវត្សរ៍ទី១៥ ដូចនៅក្នុងស្រីវិជ្ជ័យដែរ ។ ពាណិជ្ជករអារ៉ាប់, ពែរ (Persian) និងឥណ្ឌា ពីក្រុមសាសនាអ៊ីស្លាមផ្សេងៗមានវត្តមាននៅចម្ប៉ាតាំងពីសតវត្សរ៍ទី៨ ។

សាសនាអ៊ីស្លាមខ្លួនឯង គឺជាការច្នៃប្រឌិតផ្នែកសាសនា ដែលប្រតិបត្តិដោយពាណិជ្ជករ និងអ្នកចេះដឹងបរទេស ។ បើប្រៀបធៀបទៅនឹងសាសនាហិណ្ឌូ សាសនាអ៊ីស្លាមផ្តល់នូវមធ្យោបាយងាយស្រួលក្នុងការធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយព្រះតាមរយៈការបួងសួងនៅគ្រប់កន្លែងទាំងអស់ ដោយពុំចាំបាច់មានពិធីធំដុំ ។ ជាងនេះទៅទៀត ការចូលសាសនាក៏ងាយស្រួលដែរ ។ គំនិតអំពីភាតរភាព អ្នកកាន់សាសនាអ៊ីស្លាម ក៏បានជួយពន្លឿនការផ្លាស់ប្តូរសាសនាដែរ ដោយសារតែពាណិជ្ជកម្មរវាងកោះ និងប្រទេសទាំងនេះ តម្រូវឲ្យមានការជឿទុកចិត្ត និងការការពារប្រឆាំងនឹងអ្នកប្រកួតប្រជែងដែលមានឥទ្ធិពលផ្សេងៗ ។

នៅប្រហែលជាទន្ទឹមនឹងការធ្លាក់វីចាយ៉ា ទៅក្នុងដៃវៀតណាមក្នុងឆ្នាំ១៤៧១ ចាមនៅភាគខាងជើងជាច្រើន បានប្តូរសាសនាទៅអ៊ីស្លាម ។ មានហេតុផលមួយចំនួនសម្រាប់ការផ្លាស់ប្តូរសាសនានេះ ។ ទីមួយ ជនជាតិចាមអស់ជំនឿចិត្តជាមួយសាសនាហិណ្ឌូ ដោយសារពួកគេបាត់បង់ដែនដីភាគខាងជើង ជាបន្តបន្ទាប់ទៅវៀតណាម ។ ពួកគេជឿថា ព្រះហិណ្ឌូពិតជាគួរតែអាចការពារកុំឲ្យបាត់បង់ទឹកដី ប៉ុន្តែ ព្រះមិនបានការពារពួកគេទេ ដូច្នេះ ជនជាតិចាមបានងាកមករកសាសនាអ៊ីស្លាម ដែលសាសនានេះក៏មិនបានការពារពួកគេដែរ ។ ការសម្លាប់រង្គាលបន្ទាប់ពីដណ្តើមបានវីចាយ៉ា កាន់តែធ្វើឲ្យការប្តូរសាសនានេះលឿនបន្ថែមទៀត ។ ទីពីរ នៅពេលដែលតំបន់ភាគខាងជើងត្រូវបានក្តាប់យកដោយវៀតណាម សាសនាអ៊ីស្លាម បានផ្តល់នូវមធ្យោបាយសម្រាប់ជនជាតិចាមបន្តជំនឿ នៅក្នុងសាសនាថ្មី ។ ទីបី អ្នកផ្សព្វផ្សាយសាសនាអ៊ីស្លាមពីមជ្ឈិមបូព៌ា និងគូចារ៉ាត់ (Gujarat) នៅក្នុងចម្ប៉ាដែលផ្តល់ជំនួយដល់ជនជាតិចាម នៅពេលលំបាក ដែលជាពេលវេលាល្អបំផុតសម្រាប់ការផ្លាស់ប្តូរសាសនា ។ អ៊ីស្លាម ក៏បានផ្តល់ដល់ជនជាតិចាមដើម្បីធ្វើទំនាក់ទំនងជាមួយរដ្ឋកាន់សាសនាអ៊ីស្លាមនៅជាប់សមុទ្រ ។ ប៉ុន្តែនៅភាគខាងត្បូង ប៉ាន់ឌូរ៉ាំងហ្គា នៅតែជាតំបន់កាន់សាសនាហិណ្ឌូនៅពេលនេះ ។

## ការផ្លាស់ប្តូរសាសនារបស់ជនអន្តោប្រវេសន៍ចាមនៅកម្ពុជា



វិហារសាសនាអ៊ីស្លាមនៅឃុំត្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

នៅក្នុងចំណោមជនអន្តោប្រវេសន៍ចាមដែលផ្លាស់ទីលំនៅមកកម្ពុជា នៅក្នុងដំណាក់កាលទីមួយ គឺជាអ្នកដែលបានផ្លាស់ប្តូរទៅកាន់សាសនាអ៊ីស្លាម ។ ការដែលថា ចាមភាគច្រើននៅកម្ពុជាសព្វថ្ងៃជាអ្នកកាន់សាសនាអ៊ីស្លាម ទាមទារឲ្យមាននូវការពន្យល់មួយ

ជាពិសេស នៅពេលដែលការផ្លាស់ទីលំនៅធំលើកដំបូងបង្អស់របស់ពួកគេមកកាន់កម្ពុជានៅសតវត្សរ៍ទី១៥ មិនមែនជនជាតិចាមទាំងអស់ សុទ្ធតែជាអ្នកកាន់សាសនាអ៊ីស្លាមនោះទេ ។ អ្នកស្រាវជ្រាវខ្លះជឿថា ពាណិជ្ជករម៉ាឡេមានឥទ្ធិពលលើជនជាតិចាម ព្រោះទំនាក់ទំនងជនជាតិ និងភាសារវាងក្រុមទាំងពីរនេះ គឺមានលក្ខណៈខ្លាំងតាំងពីមុនមាន ការភៀសខ្លួននៅចម្ប៉ាមកម្លេះ ។ ក្រុមទាំងពីរនេះក៏ធ្វើពាណិជ្ជកម្មតាមសមុទ្រជាមួយគ្នាយ៉ាងល្អ និងមានទំនាក់ទំនងយ៉ាងមានសន្តិភាពជាមួយគ្នា ។ ជនជាតិចាមខ្លះ ក៏រស់នៅតាមប្រកសមុទ្រម៉ាឡាកាដែរ ។ ពាណិជ្ជករជនជាតិម៉ាឡេ មានវត្តមាននៅកម្ពុជាយ៉ាងយូរតាំងពីមុនសតវត្សរ៍ទី១៥ម្លេះ ។ អ្នកខ្លះសន្មតថាជនជាតិម៉ាឡេ បានមកដល់កម្ពុជានៅដើមសតវត្សរ៍ទី១៣ ព្រោះអ្នកដែលនៅកម្ពុជាជាអ្នកកាន់សាសនាអ៊ីស្លាម នៅពេលពួកគេមកដល់ ហើយស៊ូម៉ាត្រាទើបតែផ្លាស់ប្តូរទៅកាន់សាសនាអ៊ីស្លាមកាលពីដើមសតវត្សរ៍ទី១៣ ។ តាមការពិត ព្រះរាជាអស្ចារ្យពីរអង្គរបស់កម្ពុជា ជ័យវរ្ម័នទី២ និងជ័យវរ្ម័នទី៧ បានលាក់ខ្លួន និងហ្វឹកហ្វឺននៅស្រីវិជ័យ មុនពេលឡើងកាន់អំណាច ។ ស្រីវិជ័យ បានឈ្លានពានកម្ពុជានៅសតវត្សរ៍ទី៩ ។ ដូច្នេះ អាណាចក្រទាំងពីរ បានបង្កើតនូវទំនាក់ទំនងទាំងសន្តិភាព និងសង្គ្រាមជាមួយគ្នា ។ ដូចដែល ស្រីវិជ័យមានឥទ្ធិពលលើចម្ប៉ាទាំងខាងផ្នែកប្រតិបត្តិវប្បធម៌ និងសាសនាជនជាតិម៉ាឡេបន្តមានឥទ្ធិពល លើជនជាតិចាមអន្តោប្រវេសន៍ ជាពិសេសផ្លាស់ប្តូរពួកគេទៅអ៊ីស្លាម ។

នៅពេលជនជាតិចាមមកដល់កម្ពុជា ពួកគេរកជំនួយពីជនជាតិម៉ាឡេដើម្បីផ្សាំទៅនឹងប្រទេសថ្មី ។ អ្នកនិពន្ធសៀវភៅនេះជឿជាក់ថា នៅពេលមកដល់កម្ពុជា ជនជាតិចាមបានប្រកាន់យកផ្លូវពីរ ។ ទីមួយ ជនជាតិចាមកាន់សាសនាហិណ្ឌូ ដែលជួបប្រាស្រ័យជាមួយជនជាតិម៉ាឡេកាន់សាសនាអ៊ីស្លាមតិចតួចនៅកម្ពុជា ហើយតាមរយៈនេះ មិនបានប្តូរទៅកាន់សាសនាអ៊ីស្លាម បានចូលរស់នៅលាយឡំជាមួយប្រជាជនខ្មែរភាគច្រើន និងត្រូវបានគេគិតថា ជាជនជាតិខ្មែរ ។ ប៉ុន្តែ នៅពេលជនជាតិចាមកាន់សាសនាហិណ្ឌូជួបជាមួយពាណិជ្ជករម៉ាឡេ ការផ្លាស់ប្តូរសាសនាអាចកើតឡើង ។ តាមការពិត ជនជាតិចាមកាន់សាសនាហិណ្ឌូ ប្រហែលជាមានភាពងាយស្រួលជាងនៅពេលនៅជាអ្នកកាន់សាសនាហិណ្ឌូ និងនៅពេលទទួលយកពុទ្ធសាសនាពីជនជាតិខ្មែរ ដែលនៅពេលនោះ បានចាប់ផ្តើមប្រកាន់យកសាសនាព្រះពុទ្ធខ្លះហើយ ។ សម្រាប់អ្នកដែលមិនបានប្តូរសាសនាទៅអ៊ីស្លាម ការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ មិនមានអ្វីខុសពីជនជាតិខ្មែរទេ ។ សព្វថ្ងៃនេះ ជនជាតិចាមរស់នៅខេត្តបាត់ដំបង បានបាត់បង់លទ្ធភាពរបស់ខ្លួនក្នុងការនិយាយភាសាចាម ទំនងជាដោយសារពួកគេបានជួបប្រទះជាមួយជនជាតិខ្មែរនៅក្នុងផ្នែកនេះរបស់ប្រទេស នៅពេលពួកគេបោះទីលំនៅដំបូង ។

ជនជាតិចាមអន្តោប្រវេសន៍មួយក្រុមផ្សេងទៀត ដែលបានជួបជាមួយជ្វា(ម៉ាឡេ) ត្រូវបានប្តូរទៅអ៊ីស្លាម និងចាប់ពីពេលនោះមកនៅតែជាក្រុមជនជាតិភាគតិចកាន់សាសនាអ៊ីស្លាមនៅកម្ពុជា ។ ក្រុមនេះអាចមានអ្នកមុខអ្នកការ និងអ្នកចេះដឹងជនជាតិចាម ដែលនៅតែច្បាស់លាស់អំពីអត្តសញ្ញាណរបស់ពួកគេសូម្បីតែក្នុងពេលភៀសខ្លួន ។ ការជួបជាមួយអ្នកកាន់សាសនាអ៊ីស្លាមជនជាតិម៉ាឡេ អាចជាភ័ព្វសំណាងល្អរបស់ពួកគេ ដោយសារជនជាតិម៉ាឡេ និងជនជាតិចាម មានភាសាស្រដៀងគ្នា ។ ដូចគ្នាដែរជនជាតិចាមខ្លះនៅក្នុងក្រុមនេះ ជាអ្នកកាន់សាសនាអ៊ីស្លាមរួចហើយ ។

## ៤) ជនជាតិចាមនៅក្នុងនយោបាយកម្ពុជា

ទំនាក់ទំនងខ្មែរ និងចម្ប៉ា បានចាប់ផ្តើមមានវិបត្តិនៅក្នុងសតវត្សរ៍ទី១២ នៅពេលចម្ប៉ាមាន សង្គ្រាមទាំងជាមួយវៀតណាម និងអាណាចក្រខ្មែរ ។ ក្នុងឆ្នាំ១១៤៥ នៅក្នុងរជ្ជកាលរបស់ព្រះបាទសូរ្យវរ្ម័នទី២ កងទ័ពខ្មែរបានឈ្លានពាន និងគ្រប់គ្រងវិចាយ៉ាអស់រយៈពេល៤-៥ឆ្នាំ ។ ប៉ុន្តែ នៅឆ្នាំ១១៧៧ ជនជាតិចាមអាចរៀបចំទ័ពទូកយ៉ាងចំណានដែលអាចធ្វើដំណើរឡើងតាមដីសណ្តទន្លេមេគង្គ និងបឹងទន្លេសាប ដើម្បីមកលួចប្លន់ក្រុងអង្គរ ។ នោះគឺជាជ័យជម្នះគួរឲ្យភ្ញាក់ផ្អើលមួយ បើពិនិត្យមើលអំពីអំណាចរបស់អាណាចក្រខ្មែរនៅពេលនោះ ។ ប៉ុន្តែ ក្រុមទូករបស់ជនជាតិចាមដដែលនេះ ត្រូវបានបំផ្លាញនៅពេលក្រោយមក ដោយព្រះបាទជ័យវរ្ម័នទី៧ ។ ក្រោយមក ស្តេចអង្គនេះបានហ្វឹកហ្វឺន ព្រះអង្គម្ចាស់ចាមមួយអង្គ និងបានអនុញ្ញាតឲ្យព្រះអង្គម្ចាស់នេះដឹកនាំទ័ពធ្វើការវាយប្រហារវិចាយ៉ា ជាការសងសឹកចំពោះការឈ្លានពានអង្គរដោយជនជាតិចាម ។ ជ័យជម្នះនេះ បានអនុញ្ញាតឲ្យកម្ពុជាភ្ជាប់ចម្ប៉ា

ជាខេត្តមួយរបស់ខ្លួន នៅចន្លោះចុងសតវត្សរ៍ទី១២ និងដើមសតវត្សរ៍ទី១៣ ។

ផ្នែកសំខាន់បំផុតនៃទំនាក់ទំនងខ្មែរ-ចាម គឺនៅក្នុងរបៀបដែលជនអន្តោប្រវេសន៍ចាមធ្វើអន្តរាគមន៍នៅក្នុងជម្លោះផ្ទៃក្នុងរបស់កម្ពុជា ។ នៅចុងសតវត្សរ៍ទី១៦ និងដើមសតវត្សរ៍ទី១៧ សហគមន៍ចាម-ម៉ាឡេនៅកម្ពុជា មានទំហំធំដែលអាចមានឥទ្ធិពលនៅក្នុងនយោបាយកម្ពុជា ។ ឧទាហរណ៍ ព្រះមហាក្សត្រខ្មែរមួយព្រះអង្គ ត្រូវបានធ្វើឃាតនៅក្នុងព្រះរាជវាំងរបស់ព្រះអង្គនៅស្រីសន្ធរដោយមនុស្សមកពីអឺរ៉ុបមួយក្រុមដែលដឹកនាំដោយជនជាតិព័រទុយហ្កាល់ឈ្មោះ ឌីហ្គោ វេឡូសូ (Diego Veloso) និងជនជាតិអេស្ប៉ាញម្នាក់ឈ្មោះ ប្លាស រុយអ៊ីស (Blas Ruiz) ។ នេះគឺជាអ្នកមកពីអឺរ៉ុបមួយក្រុម ដែលបានបំភិតបំភ័យប្រជាជនជាមួយនឹងកាំភ្លើងរបស់ពួកគេ ។ ក្រុមនេះបានតែងតាំង ព្រះរាជាថ្មីមួយអង្គ ព្រះនាមបរមរាជាទី៥ (Paramaraja V) សោយរាជ្យពីឆ្នាំ១៥៩៧-១៥៩៩ ។ ព្រះបាទបរមរាជាទី៥ ជាមនុស្សប្រឆាំងនឹងអ្នកកាន់សាសនាអ៊ីស្លាម ។ ជាលទ្ធផល ជម្លោះបានកើតឡើងរវាងពួកអឺរ៉ុប និងអ្នកកាន់សាសនាអ៊ីស្លាម ហើយពួកអឺរ៉ុបជាច្រើនត្រូវបានសម្លាប់ ។ អ្នកកាន់សាសនាអ៊ីស្លាមបានដកថយទៅត្បូងឃ្មុំ និងបានបង្កការបះបោរ ។ មេដឹកនាំក្រុមអ្នកកាន់សាសនាអ៊ីស្លាម គឺ ប៉ូ រ៉ាត់ (Po Rat) និង លក្ខស្មាណា (Leaksmana) ។ នៅត្បូងឃ្មុំ អ្នកកាន់សាសនាអ៊ីស្លាម បានប្រកាសតំបន់ស្វយ័តដែលមាន ប៉ូ រ៉ាត់ ជាស្តេច ។ ស្តេចបរមរាជាទី៥ ត្រូវបានធ្វើឃាតនៅក្នុងការព្យាយាមយកជ័យជម្នះលើក្រុមបះបោរ ។ ចុងក្រោយ កងទ័ពរបស់ប៉ូ រ៉ាត់ និងលក្ខស្មាណា ត្រូវបានបណ្តេញចេញពីត្បូងឃ្មុំ និងបានភៀសខ្លួនទៅកាន់កន្លែងដែលនៅសល់ចុងក្រោយរបស់ចម្ប៉ា ។

នៅក្នុងឆ្នាំ១៧៨២ កងទ័ពកាន់សាសនាអ៊ីស្លាមពីត្បូងឃ្មុំដឹកនាំដោយឌួន សេត (Duon Set) បានធ្វើការវាយប្រហារឧដុង្គ ដែលជាការឆ្លើយតបទៅនឹងសកម្មភាពនៅក្នុងព្រះបរមរាជវាំង៖ មន្ត្រីខ្មែរ ម្នាក់បានឡើងសោយរាជ្យបន្ទាប់ពីការតស៊ូបង្ហូរឈាមជាមួយគូប្រកួត ។ នៅក្នុងអំឡុងពេលនេះ អ្នកបន្តវេនស្របច្បាប់នៅជាទារកនៅឡើយ ។ កងកម្លាំងកាន់សាសនាអ៊ីស្លាមអាចបណ្តេញអ្នកមុខអ្នកការខ្មែរ និងក្រុមរបស់គាត់ចេញពីឧដុង្គ ដែលចេញពីទីនោះ បានភៀសខ្លួនទៅកាន់បាងកក ។ ប៉ុន្តែ បន្ទាប់ពីជ័យជម្នះ ឌួន សេត បានតែងតាំងខ្លួនឯងជាមេដឹកនាំ និងកាន់កាប់រាជធានី ។ គាត់បានតែងតាំងអ្នកកាន់សាសនាអ៊ីស្លាមមួយចំនួនឲ្យកាន់តំណែងខ្ពស់ៗក្នុងរាជធានី និងបានបោះទីលំនៅរបស់ចាម និង ម៉ាឡេ នៅជ្រោយចង្វារ និងភ្នំពេញ ។ ក្រោយមក ឌួន សេត និងកងកម្លាំងត្រូវបានបណ្តេញចេញពីឧដុង្គដោយអភិបាលខេត្តខ្មែរមួយរូប ដែលអាចប្រមូលការគាំទ្រពីក្នុងចំណោមក្រុមខ្មែរថ្នាក់ខ្ពស់ ។ ឌួន សេត ត្រូវបានសម្លាប់នៅក្នុងពេលវាយប្រហារ ។

នៅពាក់កណ្តាលសតវត្សរ៍ទី១៩ ចាមបានដើរតួនាទីចុងក្រោយរបស់ខ្លួននៅក្នុងជម្លោះបន្តរាជវង្ស ។ ព្រះបាទអង្គ ឌួង (១៨៤៨-១៨៦០) បានជ្រើសតាំងបុត្រារបស់ព្រះអង្គឈ្មោះ នរោត្តម ជាអ្នកស្នងរាជ្យ ។ ប៉ុន្តែ ព្រះអនុជរបស់ព្រះបាទនរោត្តម ព្រះនាម ស៊ី វត្ថា ជំទាស់នឹងការសម្រេចនេះ ហើយសង្គ្រាមស៊ីវិលបានផ្ទុះឡើង ។ ចាម និងជ្វា ដែលពីមុននោះបានផ្លាស់ទីលំនៅទៅចូវដុក បានត្រឡប់មកកម្ពុជាវិញ និងបានប្រមូលការគាំទ្រពីសំណាក់អ្នកកាន់សាសនាអ៊ីស្លាមនៅត្បូងឃ្មុំ ដើម្បីប្រឆាំងនឹងកងកម្លាំងដែលគាំទ្រព្រះអង្គម្ចាស់ស៊ី វត្ថា ។ ពួកគេទទួលបានជោគជ័យក្នុងការការពារព្រះរាជបល្ល័ង្កសម្រាប់អ្នកបន្តរាជ្យដែលពេញច្បាប់ ។ អ្នកកាន់សាសនាអ៊ីស្លាម ត្រូវផ្តល់រង្វាន់ជាមួយនឹងតំណែងខ្ពស់ៗ និងទ្រព្យសម្បត្តិ ។ បន្ទាប់ពីឡើងគ្រងរាជ្យក្នុងឆ្នាំ១៨៦៤ ព្រះបាទនរោត្តម បានផ្លាស់ប្តូររាជធានីទៅភ្នំពេញក្នុងឆ្នាំ១៨៦៥ ។ អ្នកគាំទ្រកាន់សាសនាអ៊ីស្លាមរបស់ព្រះអង្គបានមកជាមួយព្រះអង្គ និងបោះទីតាំងនៅជ្រោយចង្វារ នៅម្ខាងទន្លេសាប ទល់មុខនឹងព្រះបរមរាជវាំង និងនៅកន្លែងដែលអ្នកកាន់សាសនាអ៊ីស្លាមមួយចំនួនតូចបានរស់នៅតាំងពីក្នុងពេលកាន់អំណាចរបស់ ឌួន សេត ។

## ៥) ព្រះរាជាខ្មែរកាន់សាសនាអ៊ីស្លាម

ការកាន់កាប់កម្ពុជា ដែលប្រជាជនភាគច្រើនកាន់សាសនាព្រះពុទ្ធសាសនា ដោយព្រះរាជាកាន់សាសនាអ៊ីស្លាម គឺជាព្រឹត្តិការណ៍អស្ចារ្យមួយ ជាពិសេសនៅពេលពិចារណាអំពីការដែលថាខ្មែរខ្លះគឺ ជាអ្នកប្រឆាំងនឹងសាសនាអ៊ីស្លាមនៅពេលនោះ ។ រាមាធិបតីទី១ ដែលកាន់អំណាចនៅចន្លោះឆ្នាំ១៦៤២ និង១៦៥៨ គឺជាព្រះមហាក្សត្រទីមួយ និងចុងក្រោយដែលកាន់សាសនាអ៊ីស្លាម

នៅកម្ពុជា ។

បើយោងតាម អេនតូនី រីដ (Anthony Reid) អាស៊ីអាគ្នេយ៍ បានចូលទៅក្នុងយុគសម័យពាណិជ្ជកម្មមួយចាប់ពីសតវត្សរ៍ទី១៥ ដល់សតវត្សរ៍ទី១៧ ។ ចាប់ផ្តើមពីសតវត្សរ៍ទី១៥ រីដ សង្កេតឃើញមានការរីកចម្រើនផ្នែកពាណិជ្ជកម្មរីកសាយភាយចេញពីក្រុងកំពង់ផែសំខាន់ៗ នៅទូទាំងអាស៊ីអាគ្នេយ៍ ។ ការរីកចម្រើនផ្នែកពាណិជ្ជកម្មបានរួមចំណែកដល់ការផ្លាស់ប្តូរផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយ ។ ការរីកចម្រើនផ្នែកពាណិជ្ជកម្ម ត្រូវបានជំរុញដោយពាណិជ្ជកម្មផ្នែកគ្រឿងទេស និងឈើក្រអូប នៅដើមសតវត្សរ៍ទី១៤ ទន្ទឹមនឹងដំណាំពាណិជ្ជកម្មនៅទូទាំងប្រជុំកោះ ។ សកម្មភាពពាណិជ្ជកម្ម បានបង្កើនតម្រូវការផ្នែកដឹកជញ្ជូន និងនាវាចរណ៍ដែលល្អជាងមុន ដើម្បីឲ្យដល់ក្រុងទាំងឡាយ នៅអាស៊ីអាគ្នេយ៍ ។ ក្រុងកំពង់ផែខ្លះ បានរីកចម្រើនលើសគេ រហូតក្លាយជាមជ្ឈមណ្ឌលប្រជុំជនមនុស្សមកពីគ្រប់ទិសទីដែលមធ្យោបាយដោះដូរត្រូវបានបង្កើតឡើង និងគាំទ្រដើម្បីជួយឲ្យក្រុងទាំងនេះក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ច និងវប្បធម៌ ។ ការបង្ហាញផ្នែកសង្គមនៃការធ្វើពាណិជ្ជកម្មដែលរួមមានប្រព័ន្ធហិរញ្ញវត្ថុទំនើបជាងនៅទូទាំងតំបន់ ការកើនឡើងនូវចំនួនអ្នកប្រកបអាជីវកម្មនៅទីក្រុង ការផ្លាស់ប្តូរសាសនាជាមួយនឹងការចូលមកដល់នូវសាសនាគ្រឹស្ត និងអ៊ីស្លាម និងបច្ចេកវិទ្យាយោធាទំនើបជាងមុន ។ យុគសម័យពាណិជ្ជកម្មបានប៉ះពាល់កម្ពុជាក្នុងរបៀបស្រដៀងគ្នាដែរ ។ ក្នុងសតវត្សរ៍ទី១៦ ក្រុងខុដុគ្គ មានអ្នកពាណិជ្ជករ មន្ត្រី និងអ្នកផ្សព្វផ្សាយសាសនាដែលមានជាតិសាសន៍ផ្សេងៗ ដូចជា ជនជាតិប៉័ទុយហ្កាល់ អេស្ប៉ាញ ហូឡង់ បារាំង ថៃ ជប៉ុន ចិន ចាម និងជ្វា ។

ជនជាតិជ្វា គ្របដណ្តប់ផ្លូវពាណិជ្ជកម្មរវាងរដ្ឋនៅអាស៊ីអាគ្នេយ៍ ។ ជនជាតិជ្វាមកពីឧបទ្វីបម៉ាឡេ មានវត្តមាននៅតាមកំពង់ផែចម្ប៉ា តាំងពីយូរមុនសតវត្សរ៍ទី១៥ ។ នេះបង្កភាពងាយស្រួលដើម្បីឲ្យពួកគេមកដល់ក្រុងរបស់កម្ពុជាតាមរយៈដីសណ្ត ទន្លេមេគង្គ ។ កំណត់ហេតុប្រចាំថ្ងៃរបស់អ្នកជំនួញ ជនជាតិហូឡង់ ឈ្មោះ វ៉ាន់ ហ្គាឡិន (Van Galen) ដែលមានវត្តមាននៅកម្ពុជា ឆ្នាំ១៦៣៦ បានបង្ហាញថា "ជ្វាពីប៉ាហាង (Pahang), ប៉ាតានី (Pattani), ចូហរ (Johor) និង ចាំប៊ី (Jambi) ដែលធ្វើពាណិជ្ជកម្មសម្លៀកបំពាក់ ម្រេច បារត សំណប៉ាហាំង ស្បែកបបែល និងស្លា" មានចំនួនច្រើននៅភ្នំពេញ ។ ប៉ុន្តែ នៅក្នុងការស្ទង់មតិឆ្នាំ១៩៣៧ ម៉ាសែល នេ (Marcel Ner) បានកត់សម្គាល់ថា ជ្វាទាំងនោះមក ពីបូណេអូ (Borneo), តំបន់មីណាងកាបៅ (Minangkabau region) នៅលើកោះស៊ូម៉ាត្រា ឧបទ្វីបនៃសិង្ហបុរី និងត្រឹងហ្កានូ (Trenganu) ។

ជាទូទៅ ចាម និងជ្វា ត្រូវបានគេមើលឃើញថា ជាមនុស្សតែមួយក្រុម ដោយសារ ក្រុមទាំងពីរនេះជាអ្នកកាន់សាសនាអ៊ីស្លាម និងនិយាយភាសាស្រដៀងគ្នា ។ ប្រភពដើមចូលចិត្តបញ្ចូលក្រុមទាំងពីរ ។ តាមការពិត ការបញ្ចូលក្រុមជាតិពន្ធុទាំងពីរនេះ នៅតែកើតមានសព្វថ្ងៃនេះ ទាំងនៅក្នុងចំណោមអ្នកកាន់សាសនាអ៊ីស្លាម និងមិនកាន់សាសនាអ៊ីស្លាមនៅកម្ពុជា ។ ទោះបីជាមានការសរសេរតិចតួចអំពីពាណិជ្ជកម្មរបស់ចាម ពួកគេមានតួនាទីសំខាន់នៅក្នុងនយោបាយកម្ពុជា និងការតស៊ូអំណាចនៅក្នុងរាជវាំង ដូចដែលបានរៀបរាប់ខាងលើ ។

ជនបរទេសក៏មានតួនាទីសំខាន់ដែរ មិនថាតែនៅក្នុងវិស័យពាណិជ្ជកម្មទេ ប៉ុន្តែក្នុងនយោបាយកម្ពុជាដែរ ។ ជនជាតិអេស្ប៉ាញឈ្មោះ ប្លាស រុយអ៊ីស ឌឺ ហ៊ឺណាន់ ហ្គន់ហ្សាឡេស (Blas Ruiz De Hernan Gonzales) និងជនជាតិព័រទុយហ្កាល់ឈ្មោះ ឌីហ្គោ បែលឡូសូ វេឡូសូ (Diego Belloso Veloso) បានព្យាយាមឲ្យព្រះបាទបរមរាជាទី៤ ១៥៧៦-១៥៩៤) ឡើងសោយរាជ្យវិញ ។ ព្រះអង្គត្រូវបានទម្លាក់ពីព្រះរាជបល្ល័ង្កនៅអំឡុងពេលឈ្លានពានរបស់ថៃក្នុងឆ្នាំ១៥៩៤ ។ អ្នកទាំងពីរ នេះត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៥៩៩ ពេលប្រយុទ្ធជាមួយទាហានថៃ ។

## ការឡើងកាន់អំណាច

ចៅពញា ខេន (Chao Ponhea Cand) ដែលនឹងក្លាយជាព្រះរាជាខ្មែរមូស្លីម ព្រះនាមព្រះបាទរាមាធិបតីទី១ គឺជាព្រះរាជបុត្រទីពីររបស់ព្រះបាទ ជ័យ ជេដ្ឋា ដែលមានព្រះរាជបុត្រពីរអង្គទៀត រួមមាន ចៅពញា តូ និងចៅពញា នូ ចៅពញា ខេន ជាអ្នកផ្លាស់ប្តូរទៅកាន់សាសនាអ៊ីស្លាម បន្ទាប់ពីឡើងកាន់អំណាច ខណៈដែលសមាជិកញាតិវង្សរបស់ព្រះអង្គមិនមែនជាអ្នកកាន់សាសនាអ៊ីស្លាមទេ ។ ព្រះបាទទាំងពីរអង្គ បានឡើងសោយរាជ្យជាព្រះរាជា

ហើយបានសោយទិវង្គតនៅក្នុងរាជការដែលខ្លួនកាន់កាប់ផងដែរ ។

បើយោងទៅតាម ម៉ាក់ ភឿន នៅក្នុងឆ្នាំ១៦៣២-១៦៣៨ ចៅពញា តូ ត្រូវបានឪពុកមាឈ្មោះ អ៊ូតី ធ្វើឃាត ដោយមានជំនួយពីអ្នកផ្សព្វផ្សាយសាសនាជនជាតិព័រទុយហ្គាល់ បន្ទាប់ពីអ្នកទាំងពីរបានស្រឡាញ់មនុស្សស្រីតែម្នាក់ ។ បន្ទាប់មក ចៅពញា នូ ត្រូវឡើងគ្រងរាជ្យ ប៉ុន្តែ៦ឆ្នាំក្រោយមក នៅឆ្នាំ១៦៤០ ព្រះអង្គបានសោយទិវង្គតនៅក្រោមកាលៈទេសៈគួរឲ្យសង្ស័យ ។ ការសោយទិវង្គតនេះប្រហែលជាមានជាប់ពាក់ព័ន្ធ ជាមួយឪពុកមារបស់ព្រះអង្គឈ្មោះ អ៊ូតី ដែលក្រោយមកបានតែងតាំងបុត្រារបស់ព្រះអង្គផ្ទាល់ ព្រះនាម អង្គ ណាន ឲ្យឡើងគ្រងរាជ្យ ។ ការនេះបាននាំទៅដល់ការដណ្តើមរាជបល្ល័ង្ករវាង អ៊ូតី និងចៅពញា ខេន សម្រាប់រយៈពេលពីរឆ្នាំបន្ទាប់មកទៀត ។

ពង្សាវតារបានបញ្ជាក់ថា ព្រះអង្គម្ចាស់ បានធ្វើសកម្មភាពនៅក្នុងឆ្នាំរោង (១៦៤១) ដោយមានជំនួយពីមេទ័ពប្អូនរូប ។ បើទោះបីជាអត្តសញ្ញាណរបស់មេទ័ពទាំងនេះមិនត្រូវបានគេស្គាល់ ម្នាក់ក្នុងចំណោមនេះត្រូវបានគេគិតថាជាអ្នកកាន់សាសនាអ៊ីស្លាម ។ គាត់បានធ្វើការវាយប្រហារ និងធ្វើឃាត អ៊ូតី និងព្រះរាជបុត្ររបស់ព្រះអង្គ ព្រះនាម ព្រះបាទ បទុម រាជា ។ មន្ត្រីបរមរាជវាំង បានគាំទ្រ ចៅពញា ខេន ពីព្រោះព្រះអង្គជាអ្នកស្នងរាជស្របច្បាប់ ដោយអះអាងថា ការសោយទិវង្គតរបស់អ៊ូតី និងព្រះបាទ បទុម រាជា គឺជារឿងត្រឹមត្រូវ ។ ចៅពញា ខេន បានឡើងគ្រងរាជ្យឆ្នាំ១៦៤២ ជាព្រះបាទរាមាធិបតីទី១ ។ ព្រះអង្គបានបង្កើតទំនាក់ទំនងល្អជាមួយអ្នកកាន់សាសនាអ៊ីស្លាម នៅមុនពេលឡើងគ្រងរាជ្យ ។ ឥទ្ធិពលរបស់អ្នកកាន់សាសនាអ៊ីស្លាមនៅក្នុងឆាកជីវិតរបស់ព្រះអង្គបានបន្តនៅក្នុងអំឡុងពេលនៃរាជវង្សរបស់ព្រះអង្គ ។ វាគួរឲ្យចាប់អារម្មណ៍ដែលថា ព្រះបិតារបស់ព្រះអង្គ ព្រះនាម ជ័យ ជេដ្ឋា និង ឪពុកមា អ៊ូតី បានស្រឡាញ់ស្ត្រីកាន់សាសនាអ៊ីស្លាម ប្រហែលជាមកពីខេត្តទ្រាំងរបស់វៀតណាម ។

ប្រភពហូឡង់បានរកឃើញថា ចៅពញា ខេន បានប្រព្រឹត្តអំពើមនុស្សឃាតច្រើនជាងប្រភពខ្មែរបានបញ្ជាក់ ។ ចៅពញា ខេន មិនត្រឹមតែធ្វើឃាតឪពុកមា អ៊ូតីទេ ថែមទាំងអ្នកមុខអ្នកការដែលមានវត្តមាននៅអំឡុងពេលនៃការវាយប្រហារប្រហែលជានៅព្រះទីនាំងរបស់ព្រះបាទ អ៊ូតី ។ ចំណែកឯ បរមរាជាទី១ គេនិយាយថា ព្រះអង្គត្រូវបានធ្វើឃាតនៅអំឡុងពេលនៃការប្រមាញ់សត្វ ។ ចៅពញា ខេន បានបន្តសម្លាប់អ្នកបម្រើនៅក្នុងរាជដំណាក់ និងមន្ត្រីជាន់ខ្ពស់ដែលស្និទ្ធនឹងស្តេចទាំងពីរអង្គនេះ ។ ប៉ុន្តែ រាជបុត្រាបីអង្គរបស់ព្រះបាទ អ៊ូតី ត្រូវបានឲ្យរួចរស់ជីវិត ។ បុត្រាទាំងនេះត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុងវត្ត ប៉ុន្តែមិនដល់មួយឆ្នាំក្រោយមកផង ម្នាក់ក្នុងចំណោមនោះត្រូវបានធ្វើឃាត បន្ទាប់ពីរាមាធិបតីបានដឹងអំពីគម្រោងការបះបោរ ។

ជាងនេះទៅទៀត កំណត់ត្រារបស់ហូឡង់បានបង្ហាញទៀតថា ចៅពញា ខេន មិនមែនធ្វើសកម្មភាពតែម្នាក់ឯងទេ ។ ព្រះចៅទទួលបានជំនួយពីបងប្រុសរបស់ខ្លួនម្នាក់ដែលរំពឹងថាបានបែងចែកអំណាចជាមួយគ្នា ។ ប៉ុន្តែ ចៅពញា ខេន បានសម្រេចចិត្តកម្ចាត់បងប្រុសរបស់ខ្លួនចោល ។ បើទោះបីជាកំណត់ត្រានេះមិនច្បាស់លាស់ វាហាក់បីដូចជាថា ចៅពញា ខេន បានចោទប្រកាន់បងប្រុសរបស់ខ្លួនថា មានសាហាយជាមួយមហេសីម្នាក់ក្នុងចំណោមមហេសីជាច្រើនរបស់ព្រះអង្គ ។ ប្រភពហូឡង់បានបង្ហាញទៀតថា ចៅពញា ខេន បានដុតផ្ទះរបស់បងប្រុសខ្លួន ចាប់ខ្លួន និងសម្លាប់នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៦៤២ ។

បើយោងតាម ដេវីដ ឆេនឡឺរ (David Chandler) ព្រះបាទរាមាធិបតីទី១ គឺជាស្តេចឃោរឃៅល្មមគួរសមមួយអង្គ ។ ព្រះអង្គក៏ទទួលខុសត្រូវចំពោះការសម្លាប់ជនជាតិហូឡង់ជាច្រើន នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៦៤៣ ដែលពោលគឺបន្ទាប់ពីព្រះអង្គបានប្តូរសាសនាទៅកាន់សាសនាអ៊ីស្លាម ។ មុននេះ ទំនាក់ទំនងរវាងរាជវាំងកម្ពុជា និងក្រុមហ៊ុន VOC បានធ្លាក់ចុះនៅក្នុងឆ្នាំ១៦៤៣ ។ រីជីម័រតេ (Regemorte) និងសហការីរបស់គាត់ជាមួយនឹងមន្ត្រីក្រុមហ៊ុន VOC រហូតដល់ទៅ៣៥នាក់ ត្រូវបានធ្វើឃាត និង៦០នាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន ។ ក្នុងឆ្នាំ១៦៤៣ ហូឡង់បានបញ្ជូនកប៉ាល់សង្គ្រាម ចំនួន៥មកកម្ពុជានៅក្នុងយុទ្ធនាការសងសឹកមួយ ប៉ុន្តែ ពួកគេជួបប្រទះនូវការវាយឆ្មក់នៅក្បែរភ្នំពេញ ។ ជនជាតិហូឡង់១២០នាក់ត្រូវបានសម្លាប់ ។ ជនជាតិព័រទុយហ្គាល់ ចាម និង ជ្វា ជាមនុស្សនៅក្នុងចំណោមអ្នកនៅខាងកម្ពុជា ។ ទំនាក់ទំនងរវាងប្រទេសទាំងពីរត្រូវបានបញ្ចប់អស់រយៈ

*ពេលមួយទសវត្សរ៍បន្ទាប់ពីនោះ ។*

## *ការផ្លាស់ប្តូរទៅសាសនាអ៊ីស្លាម*

*វិល ព្រះរាជាបានធ្លាក់ក្នុងអន្លង់ស្នេហ៍ភ្លាមៗ និងចង់រៀបអភិសេកជាមួយនាង ប៉ុន្តែឪពុករបស់ខាងស្រីដែលត្រូវគេនិយាយថាជា*



*ពិធីបុណ្យម៉ាឡុតរបស់ជនជាតិចាម នៅឃុំចាន់គៀក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង*

*ពង្សាវតារបានកត់ត្រាថា រាមាធិបតីទី១ បានប្តូរទៅកាន់សាសនាអ៊ីស្លាមនៅចន្លោះឆ្នាំ១៦៨៣ និង១៦៨៥ ។ ប៉ុន្តែប្រភពហូឡង់បានបង្ហាញឲ្យឃើញនូវកាលបរិច្ឆេទលឿនជាងនេះៈ យ៉ាងហោចណាស់មុនខែវិច្ឆិកា ឆ្នាំ១៦៨២ ប៉ុន្មានខែបន្ទាប់ពីព្រះរាជាកម្ចាត់ដៃគូជិតាស់ ។ បើពិនិត្យមើលអំពីការស្លាប់របស់បងប្រុសរបស់ចៅពញា ខេន នៅខែមេសា ឆ្នាំ១៦៨២ ការផ្លាស់ប្តូរសាសនាគួរតែ កើតឡើងនៅចន្លោះខែមេសា និងខែវិច្ឆិកា ។*

*រឿងរ៉ាវចាប់ផ្តើមនៅពេលព្រះបាទរាមាធិបតីទៅទស្សនកិច្ចខេត្តមួយដែលមានឈ្មោះថា ស្រីសឈរ នៅខាងកើតខុដុគ្គ ខេត្តកណ្តាលបច្ចុប្បន្ននេះ ជាកន្លែងដែលព្រះអង្គជួបជាមួយនារីកាន់សាសនាអ៊ីស្លាមស្រស់ស្អាតមួយរូបឈ្មោះ នាង វ៉ាស់ (Neang Vas) ។ ប្រភពមិនបានបញ្ជាក់ថាតើ នាង វ៉ាស់ ជាជនជាតិចាមឬជ្វាទេ ។ បើយោងទៅតាមអ្នកកត់ត្រាពង្សាវតារម្នាក់ឈ្មោះ ទឹកអ្នកជាប់ខ្សែស្រឡាយរាជវង្សចម្ប៉ាបានជិតាស់ ។ បើយោងទៅតាមប្រពៃណីចម្ប៉ា គាត់ចង់ឲ្យព្រះរាជាប្តូរសាសនាទៅអ៊ីស្លាម ។ ប៉ុន្តែ ព្រះរាជាពេលនោះបានសម្រេចចិត្តយកនាង ទៅរាជធានីធ្មើជាស្រីស្នំ ។*

*អ្នកកត់ត្រាពង្សាវតារម្នាក់ឈ្មោះ វ៉ាតាន ជួន (Vatan Juon) បានបញ្ជាក់ថា មុនពេលប្រគល់ នាង វ៉ាស់ ទៅឲ្យព្រះរាជា “ម្តាយនាង វ៉ាស់ ឈ្មោះនាង ម៉ាស់ បានប្រមូលផ្តុំមិត្តភក្តិ និងឪពុកម្តាយរបស់គាត់ ក៏ដូចជាចាស់ទុំចាម ។ នៅពេលជួបជុំគ្នា គាត់បានសែនព្រលឹងដូចតាមប្រពៃណីចាម ។ នៅពេលនោះ ទួន ជែ (Tuon Zhe) ដែលមានកាំបិតស្នៀតបុរាណមួយ បានថ្វាយវាជូនព្រះមហាក្សត្រ ។ នៅពេលជាមួយគ្នានោះ គាត់បានស្នើសុំការអនុញ្ញាតស្រោចទឹកមន្តថ្វាយព្រះមហាក្សត្រ ។ ព្រះមហាក្សត្របានយល់ស្រប” ។*

*គ្រួសាររបស់នាង វ៉ាស់ បានបន្តថ្វាយព្រះរាជានូវអំណោយ*

*និងផ្តល់ឲ្យនាងនូវការផ្គត់ផ្គង់ជាបន្តនូវទឹកមន្ត ។ នាងនឹងប្រើទឹកមន្តនេះសម្រាប់ឲ្យព្រះរាជាទទួលទាន និងសម្រាប់ស្រោច ។ គេនិយាយថា ចុងក្រោយ សេចក្តីស្រឡាញ់របស់ព្រះរាជាបានកើនឡើងរហូតដល់បានតែងតាំងនាងពីស្រីស្នំទៅជា “ព្រះមហាក្សត្រីខាងឆ្វេងប្រចាំខែសីហា” និងបានតែងតាំងមន្ត្រីកាន់សាសនាអ៊ីស្លាមឲ្យកាន់តំណែង ទទួលបន្ទុកកិច្ចការអ្នកកាន់សាសនាអ៊ីស្លាម នៅកម្ពុជា ។ ចុងក្រោយនាង វ៉ាស់ បានឡើងកាន់តំណែង ជាប្រធានស្រីស្នំព្រះបរមរាជវាំង ។ ទួន ដែ ដែលជាឪពុករបស់នាង ត្រូវបានតែងតាំងជាប្រធានកិច្ចការអ្នកកាន់សាសនាអ៊ីស្លាម ខណៈដែលមេទ័ពទាំងបួនដែលជួយរាមាធិបតីទី១ដណ្តើមរាជបល្ល័ង្ក ត្រូវបានដាក់ឲ្យទទួលខុសត្រូវលើទ័ពរបស់ប្រទេស ។*

*សេចក្តីស្រឡាញ់របស់ព្រះរាជាចំពោះអ្នកកាន់សាសនាអ៊ីស្លាមនៅជាបន្ត ។ ពង្សាវតារ VJ & P63 បានបង្ហាញថា ក្នុង “រដូវដែលជនជាតិម៉ាឡេយូ” នៅក្នុងឆ្នាំរកា ព្រះមហាក្សត្របានមកលេងភូមិ នាង វ៉ាស់ ។ នេះវាស្របទៅនឹងខែបួស (វ៉ាម៉ាដន) និងការថ្វាយបង្គំនៅពេលល្ងាច ត្រូវបានធ្វើឡើងនៅទីនោះ ។ ខារ៉ូល ខឺស្ទីន (Carol Kersten) បានបញ្ជាក់ថា ឆ្នាំនោះប្រហែលជាឆ្នាំ១៦៨៥ ។ ខែបួសនៅក្នុងឆ្នាំនេះប្រហែលជាត្រូវនឹងខែតុលា និងវិច្ឆិកា ។ “ម៉ាឡេយូ” គឺពាក្យមើលងាយជនជាតិ ដែលត្រូវបានប្រើប្រាស់ដោយអ្នកកត់ត្រាពង្សាវតារខ្មែរ ដើម្បីសំដៅទៅការថ្វាយបង្គំរបស់អ្នកកាន់សាសនាអ៊ីស្លាម ។ ព្រះរាជាបានសម្រេចយ៉ាងនេះ ។ ពង្សាវតារ DV & VJ បានបង្ហាញថា នៅពេលទៅដល់ភូមិៈ “អ្នកកាន់សាសនាអ៊ីស្លាមបាននាំមកនូវអំណោយថ្វាយព្រះរាជា ក៏ដូចជាទឹកមន្តសម្រាប់ឲ្យព្រះរាជាស្រង់ទឹក ។ បន្ទាប់ពីស្រង់ទឹករួច មេដឹកនាំសាសនាម្នាក់បាននិយាយជាមួយព្រះរាជាអំពីការកាន់សាសនាអ៊ីស្លាម” ។ ពួកគេសរសេរថា នៅក្រោមឥទ្ធិពលរបស់មន្តអាគម ព្រះរាជាបានយល់ព្រម ។*

*ម៉ៃឃើល វិកឃ័រី (Michael Vickery) បានផ្តល់នូវមូលហេតុពីរយ៉ាងដែលនាំឲ្យព្រះរាជាព្រមប្តូរទៅកាន់សាសនាអ៊ីស្លាមៈ ទីមួយ គាត់ចង់ឲ្យទទួលបានការគាំទ្រពីក្រុមប្រជាជន ដែលរួមមានទាំងអ្នកកាន់សាសនាព្រះពុទ្ធ និងអ្នកកាន់សាសនាអ៊ីស្លាម ។ ខណៈដែលប្រជាជនកម្ពុជាភាគច្រើនជាអ្នក កាន់សាសនាព្រះពុទ្ធ-ហិណ្ឌូ សាសនាអ៊ីស្លាមមានប្រជាប្រិយភាពនៅក្នុងអាស៊ីអាគ្នេយ៍ ។ ការណ៍នេះបាន នាំឲ្យព្រះរាជាមើលហួសពីវៀតណាម និងថៃសម្រាប់ការគាំទ្រ និងពាណិជ្ជកម្ម ។ ព្រះរាជាត្រូវបានដកស្រង់សម្តីថា “ប្រជាជនខ្មែរស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំហើយ នៅសល់តែអ្នកកាន់សាសនាអ៊ីស្លាមទេដែលមិនទាន់សម្តែងការគោរព និងភក្តីភាព ។ ប្រសិនបើខ្ញុំទទួលយកសាសនារបស់ពួកគេ ខ្ញុំនឹងបាននាង វ៉ាស ហើយទន្ទឹមនោះដែរ អ្នកកាន់សាសនាអ៊ីស្លាមនឹងប្រគល់សេចក្តីស្មោះចំពោះខ្ញុំ ។ ប្រសិនបើកូនប្រុសដែលនៅរស់របស់ អ៊ូតី ក្បត់ខ្ញុំ ខ្ញុំនៅមានអ្នកកាន់សាសនាអ៊ីស្លាមដើម្បីពឹងពាក់” ។ ទីពីរ ព្រះពុទ្ធសាសនាមិនបានផ្តល់ដល់ព្រះរាជានូវមធ្យោបាយសម្រាប់លាងបាប ប៉ុន្តែការប្តូរសាសនាទៅអ៊ីស្លាមបានផ្តល់ដល់ព្រះអង្គនូវការលើកលែងទោសដែលត្រូវការជាចាំបាច់ ។ ព្រះរាជាព្រួយបារម្ភថា ព្រះអង្គនឹងមានជោគវាសនាអាក្រក់ដោយធ្វើឃាត អ៊ូតី និងបុទមរាជា ។ នៅពេលដែលព្រះអង្គសួរយោបល់ព្រះសង្ឃ ព្រះសង្ឃទាំងនោះបានឆ្លើយតបថា “អំពើល្អ និងអំពើបាប មិនអាចដោះដូរគ្នាដូចសងលុយ និងខ្ចីលុយទេ ។ អំពើនីមួយៗកំណត់ផលរៀងៗខ្លួន ។ ប្រសិនបើធ្វើអំពើល្អច្រើន អ្នកនោះនឹងមានវាសនាល្អ ។ ប្រសិនបើធ្វើអំពើអាក្រក់ច្រើន អ្នកនោះនឹងមានវាសនាអាក្រក់” ។ ប៉ុន្តែ នៅពេលព្រះរាជាសួរយោបល់អ្នកកាន់សាសនាអ៊ីស្លាម ពួកគេបានឆ្លើយតបថាៈ “អ៊ីស្លាមនិយាយថា ប្រសិនបើមនុស្សម្នាក់ទទួលយកសាសនាដោយសារតែគុណភាពរបស់វា នោះព្រះអាល់ឡោះនឹងទទួលបាបជំនួស” ។*

*ទំហំនៃការសម្លាប់ ដែលបានកើតឡើងនៅអំឡុងពេលនៃការដណ្តើមអំណាចក្សាររបស់ព្រះរាជា បានធ្វើឲ្យគេកាន់តែជឿជាក់លើអំណះអំណាងដែលថា ព្រះរាជាមានការភ័យខ្លាចចំពោះផលលំបាកនៃអំពើបាបរបស់ព្រះអង្គ ។ ពង្សាវតារបានកត់ត្រាថា អ៊ូតី និង បុទមរាជា ត្រូវបានធ្វើឃាត ដែលអាចត្រូវបានគេមើលឃើញថាជាទង្វើត្រឹមត្រូវ ដោយសារអ្នកទាំងពីរនេះបានដណ្តើមអំណាចពីអ្នកស្នងតំណែងស្របច្បាប់ ។ ដូច្នេះ គំនិតអំពីការភ័យខ្លាចបាបនេះ ត្រូវបានយល់ស្របគ្នាទាំងប្រភពខ្មែរ និងហូឡង់ ។ មូលហេតុមួយផ្សេងទៀត ការផ្លាស់ប្តូរសាសនា ត្រូវបានយល់ស្របគ្នាដោយប្រភពទាំងពីរ ទាក់ទងនឹងមិត្តភាពជិតស្និទ្ធរបស់ព្រះមហាក្សត្រ*

ជាមួយអ្នកកាន់សាសនាអ៊ីស្លាម ។ អ្នកទាំងនេះ ប្រហែលជាអាចមាន ឥទ្ធិពលលើការយល់ឃើញរបស់ព្រះមហាក្សត្រចំពោះសាសនា ។

**ការរីកសាយភាយនៃសាសនាអ៊ីស្លាម**

ពង្សាវតារ VJ បានបញ្ជាក់ថា បន្ទាប់ពីការប្តូរទៅកាន់សាសនាអ៊ីស្លាម ព្រះរាជាបានទាមទារថា មន្ត្រីវាំងក៏បានផ្លាស់ប្តូរសាសនាដែរ ។ អ្នកដែលបដិសេធនឹងត្រូវដកចេញពីតំណែង ។ ពង្សាវតារបានផ្តល់កសិណថា អ្នកមុខអ្នកការកម្ពុជាក្នុងទ្រង់ទ្រាយធំបានយល់ព្រមប្តូរសាសនា ។ អ្នកប្តូរសាសនាជាបុរសត្រូវឆ្លងកាត់ការកាត់ចុង ។ ស្បែកដែលកាត់ចោលត្រូវកម្កល់ទុកនៅក្នុងព្រះវិហារសាសនាអ៊ីស្លាមមួយនៅក្នុងភូមិឃ្លាំងស្បែក នៅខេត្តកណ្តាល ប្រមាណជា៣០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ។ អ្នកភូមិឃ្លាំងស្បែកបានបញ្ជាក់ថា ភូមិរបស់ពួកគេគឺភូមិមួយក្នុងចំណោមភូមិអ៊ីស្លាមចំណាស់បំផុតនៅកម្ពុជា ។ ព្រះវិហារនៅក្នុងភូមិនេះឈ្មោះ អាល់ អាក់បា ឌូបៃ ឃ្លាំងស្បែក *(Al Akbah Dubai Khleang Sbek)* មានទីតាំងនៅចុងភូមិភាគខាងជើង ត្រូវបានសាងសង់នៅលើស្នាមព្រះវិហារចាស់បំផុតនៅកម្ពុជា ។ បើទោះបីជារចនាសម្ព័ន្ធដែលថែរក្សាស្បែកចុងលិង្គទាំងនោះលែងនៅសេសសល់ក៏ដោយ អ្នកភូមិនៅតែចងចាំទីតាំងនេះ ។

បន្ទាប់ពីការប្តូរសាសនាដោយមន្ត្រីរាជវាំងរបស់ព្រះអង្គ ព្រះរាជាបានដាក់ចេញនូវកំណែទម្រង់មួយចំនួន ។ សមាជិកជាបុរសរបស់ព្រះបរមរាជវាំង ត្រូវតែផ្លាស់ប្តូរនូវសម្លៀកបំពាក់កាលពីមុនកាន់សាសនាអ៊ីស្លាម និងត្រូវតែពាក់អាវស្រុង ។ ពួកគេក៏ត្រូវបានបញ្ជាឲ្យកាន់កាំបិតស្នៀត ។ ព្រះរាជា មានកាំបិតស្នៀតពណ៌មាស និងយកម៉ូតសម្លៀកបំពាក់តាមប្រពៃណីវាំងជ្វា ។

ប្រវត្តិនៃការផ្លាស់ប្តូរសាសនារបស់ព្រះបាទរាមាធិបតីទី១ បានបង្ហាញឲ្យឃើញនូវផ្នែកគួរឲ្យចាប់អារម្មណ៍មួយនៃអត្តសញ្ញាណចាម ។ នៅប្រហែលជាអំឡុងពេលនៃការប្តូរសាសនានេះ ជនជាតិចាម ត្រូវបានគេស្គាល់តិចតួចនៅឡើយ ។ ដូចដែលបានកត់សម្គាល់ខាងលើ ពួកគេមិនទាន់បញ្ចប់នូវការផ្លាស់ទីលំនៅមកកម្ពុជានៅឡើយ ។ ដូច្នេះ អត្តសញ្ញាណរបស់អ្នកកាន់សាសនាអ៊ីស្លាមនៅកម្ពុជា ត្រូវបានដឹកនាំបន្តឡើង និងមានឥទ្ធិពលដោយជនជាតិជ្វា ដែលបន្តិចម្តងៗ ត្រូវបានគេមើលឃើញថា ជាជនជាតិតែមួយជាមួយជនជាតិចាម ។ ទន្ទឹមនោះដែរ ជនជាតិចាមបានបណ្តោយទៅតាមជ្វា ។ ប៉ុន្តែ ជនជាតិចាមមានអត្តសញ្ញាណផ្ទាល់ខ្លួនជាចាម ប៉ុន្តែ វាមិនសំខាន់គ្រប់គ្រាន់នៅដំណាក់កាលនោះ ។ ដូចគ្នាផងដែរ ជនជាតិចាម ដែលអាណាចក្ររបស់ពួកគេភាគច្រើននៅមិនទាន់មានការប៉ះពាល់នៅឡើយ មិនមានចេតនាចាត់វិធានការសំខាន់ណាមួយពាក់ព័ន្ធនឹងការបង្កើតអត្តសញ្ញាណរឹងមាំនៅកម្ពុជា ដែលនៅពេលនោះជាប្រទេសបរទេសសម្រាប់ពួកគេនៅឡើយ ។

ពង្សាវតារខ្មែរក៏បានបង្ហាញផងដែរថា នៅពេលដែលបានក្លាយជាអ្នកកាន់សាសនាអ៊ីស្លាម ព្រះរាជាហាក់បីដូចជាមិនសូវផ្តល់សារសំខាន់ដល់អ្នកកាន់ព្រះពុទ្ធសាសនា និងអ្នកកាន់សាសនាហិណ្ឌូទេ ។ ប៉ុន្តែ មិនមានព័ត៌មានណាមួយអំពីការព្យាយាមរបស់ព្រះរាជាក្នុងការធ្វើឲ្យប្រជាជនទាំងមូលប្តូរសាសនាទៅអ៊ីស្លាមទេ ។ ព្រះមហាក្សត្រលែងគាំទ្រ ឬចូលរួមពិធីសាសនារបស់សាសនាព្រះពុទ្ធ ឬទៅវត្ត ហើយមិនមានការខ្វល់ខ្វាយអំពីគម្ពីរសាសនា ។ បើពិនិត្យមើលអំពីការដែលថា ព្រះរាជានៅពេលនោះជាអ្នកកាន់សាសនាអ៊ីស្លាម វាជារឿងធម្មតាដែលព្រះអង្គលែងចូលចិត្ត ឬមានកាតព្វកិច្ចណាមួយទៅនឹងស្ថាប័នព្រះពុទ្ធសាសនា ។ អ្នកកាន់សាសនាព្រះពុទ្ធ និងហិណ្ឌូ កាន់តែមានអារម្មណ៍ថា មិនសូវមានការយកចិត្តទុកដាក់ ។ ចំណែកឯជនជាតិចាម និងជ្វា មេដឹកនាំរបស់ពួកគេត្រូវបានតែងតាំងឲ្យកាន់តំណែងខ្ពស់នៅក្នុងព្រះរាជាណាចក្រ ហើយព្រះវិហារអ៊ីស្លាមត្រូវបានសាងសង់នៅទូទាំងប្រទេស ។ នេះគឺជាការព្យាយាម និងការរីកលូតលាស់យ៉ាងចំហលើកដំបូងនៃវិហារសាសនាអ៊ីស្លាមនៅក្នុងប្រទេសកម្ពុជា ។ សព្វថ្ងៃនេះ មានព្រះវិហារសាសនាអ៊ីស្លាមច្រើនជាង៣០០នៅទូទាំងប្រទេស ដែលត្រូវបានសាងសង់នៅលើគ្រឹះ ដែលបានបង្កើតឡើងនៅរាជវង្សព្រះបាទរាមាធិបតីទី១ ។

កំណត់ហេតុប្រចាំថ្ងៃរបស់អ្នកជំនួញជនជាតិហូឡង់ឈ្មោះ ពីទ័រ វ៉ាន់ រីជីម័រតេ *(Pieter van Regemortes)* បានបង្ហាញថា នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៦៤២ ព្រះមហាក្សត្របានដាក់ចេញនូវបទបញ្ជាថ្មីមួយដែលហាមប្រាមការចិញ្ចឹម ការសម្លាប់ និងលក់ដូរសត្វជ្រូក ។ រីជីម័រតេ បាននិយាយ ដល់ជនជាតិម៉ាឡេសំខាន់ពីររូបនៅក្នុងកំណត់ហេតុប្រចាំថ្ងៃរបស់គាត់ឈ្មោះ អ៊ីនឆេ ឡាណាង *(Inche Lanang)* និង អ៊ីនឆេ អាសាម *(Inche Assam)* ។ អ៊ីនឆេ

ឡាណាន ជាអ្នកជំនួញម្នាក់មកពីខេត្តប៉ាតានី និងដើរតួនាទីសំខាន់នៅក្នុងជំនួញរវាង បាតាវា (ហូឡង់) និងកម្ពុជា ។ គាត់ក៏បានចូលរួមនៅក្នុងបេសកកម្មរបស់ហូឡង់ទៅប្រទេសឡាវ នៅក្នុងឆ្នាំ១៦៤១-១៦៤២ ។ ទំនាក់ទំនងជិតស្និទ្ធរបស់គាត់ជាមួយជនជាតិហូឡង់ បានផ្ដល់ឲ្យគាត់នូវឥទ្ធិពលខ្លះនៅក្នុងព្រះបរមរាជវាំង ។ អ៊ីនឈេ អាសាម ក៏ជាជនជាតិម៉ាឡេដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយពាណិជ្ជកម្មហូឡង់នៅកម្ពុជា ។ ប្រភពហូឡង់ខ្លះបានអះអាងថា គាត់ជាមនុស្សមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាពីដើមដល់ចប់ រជ្ជកាលព្រះបាទរាមាធិបតីទី១ ។ មានជនជាតិម៉ាឡេមួយទៀតដែលជាមនុស្សជំនិតរបស់ព្រះរាជា ។ នៅក្នុងឆ្នាំ ១៦៥៧ អ៊ីនឆេ អាសាម បានក្លាយជាអ្នកជំនួញមានឥទ្ធិពលបំផុតនៅកម្ពុជា ។ គាត់ក៏មានអំណាចដែរ នៅក្នុងព្រះបរមរាជវាំង ។ គាត់បានតែងតាំងជនជាតិម៉ាឡេឲ្យកាន់តំណែងផ្សេងៗ នៅក្នុងព្រះបរមរាជវាំង ដែលម្នាក់ក្នុងចំណោមនោះគឺជាអ្នកឆ្លើយឆ្លងជាមួយជនជាតិហូឡង់ ។

## ការធ្លាក់ចុះនៃព្រះបាទរាមាធិបតីទី១

កំណត់ហេតុរបស់ ពីទ័រ វ៉ាន់ រីជីម័រតេ បានបង្ហាញឲ្យឃើញអំពីស្ថានភាពផ្លូវចិត្តរបស់ព្រះរាជា ក្នុងឆ្នាំ១៦៤២ ។ គាត់កំពុងសរសេរអំពីការសម្លាប់ជនជាតិហូឡង់ពីរនាក់នៅកម្ពុជា នៅពេលនោះ ប៉ុន្តែ អ្នកជំនួញជនជាតិហូឡង់នៅតែត្រូវការធ្វើការជាមួយព្រះបរមរាជវាំង ។ រីជីម័រតេ បានកត់សម្គាល់ថា ព្រះមហាក្សត្រដឹកស្រវឹងជាញឹកញាប់ អវត្តមានពីកិច្ចការប្រទេសជាតិក្នុងរយៈពេលយូរ និងមិនស្ម័គ្រចិត្តដោះស្រាយបញ្ហាស្មុគស្មាញ ។ ស្ថានភាពផ្លូវចិត្តទន់ជ្រាយនេះ ក៏បានបង្ហាញដែរនៅក្នុងពង្សាវតារ ។

របាយការណ៍មួយរបស់ ហេនឌ្រិក អ៊ីនឌិជ (Hendrick Indijck) និង ពីទ័រ ឃែតធីង (Pieter Kettingh) បានបង្ហាញថា គិតត្រឹមឆ្នាំ១៦៥៦ ព្រះបាទរាមាធិបតីទី១ កំពុងស្នាក់នៅលើទូក ព្រោះ "ព្រះសង្ឃ" នៅក្នុងព្រះបរមរាជវាំងបានថ្វាយយោបល់ ឲ្យជៀសវាងរស់នៅក្នុងព្រះបរមរាជវាំង សម្រាប់រយៈពេល៣ឆ្នាំ ។ នេះគឺជារឿងមិនទំនងទាល់តែសោះ ព្រោះខណៈដែលព្រះបាទរាមាធិបតីទី១ ជាអ្នកកាន់សាសនាអ៊ីស្លាម ព្រះអង្គនៅតែស្វែងរកយោបល់ពីព្រះសង្ឃពុទ្ធសាសនា ។ របាយការណ៍នេះ ក៏បានបញ្ជាក់ថា ព្រះរាជាពាក់ឈ្នួត និងសម្លៀកបំពាក់បែបម៉ាឡេ ប៉ុន្តែ សូម្បីតែនៅពេលនោះ ព្រះរាជា "នៅតែស្រវឹងជាញឹកញាប់នៅឡើយ" ។

កូនប្រុសដែលនៅរស់រានមានជីវិតរបស់ អ៊ូតី ឈ្មោះ អង្គស៊ូ និងអង្គតាន ប្រហែលជាបានរៀបចំផែនការវាយប្រហាររួចហើយ ដោយសារតែពួកគេត្រូវបានទុកឲ្យរស់នៅក្នុងវត្ត បន្ទាប់ពីព្រះបិតា និងព្រះរាមរបស់ព្រះអង្គទាំងពីរត្រូវបានធ្វើគុត ។ ឱកាសរបស់ព្រះអង្គបានមកដល់នៅក្នុងអំឡុងអន្តរកាលមួយគឺនៅពេលដែលព្រះបាទរាមាធិបតីទី១ កំពុងផ្លាស់ប្ដូរសាសនាពីពុទ្ធសាសនាទៅអ៊ីស្លាម ដែលទំនងជាធ្វើឲ្យមន្ត្រីបរមរាជវាំង និងប្រជារាស្ត្រមិនពេញចិត្ត ។ បន្ទាប់ពីទទួលបានការគាំទ្រពី ទាហានខ្មែរ និងវៀតណាម នៅក្នុងខែមិថុនា ឆ្នាំ១៦៥៨ ក្រុមអ្នកបះបោរដឹកនាំដោយអង្គស៊ូ និងអង្គតាន បានធ្វើការវាយប្រហារ ។ រាមាធិបតីទី១ អាចគ្រាន់តែរកការគាំទ្រពីក្រុមអ្នកផ្សព្វផ្សាយសាសនាជនជាតិព័រទុយហ្កាល់ និងសម្ព័ន្ធមិត្តកាន់សាសនាអ៊ីស្លាម ។ ពង្សាវតារខ្មែរបានចង្អុលបង្ហាញថា ព្រះរាជាត្រូវមេទ័ពខ្មែររបស់ព្រះអង្គបោះបង់ចោលនៅលើសមរភូមិ ។ វាហាក់បីដូចជាថា ការទាមទារមួយរបស់អង្គស៊ូ គឺថាព្រះរាជាដកខ្លួនឲ្យឆ្ងាយពីជនជាតិម៉ាឡេ ។ ប៉ុន្តែ គិតត្រឹមពេលនោះ វាហាក់បីដូចជាថា ព្រះរាជាបានកំណត់ខ្លួនព្រះអង្គថា ជាជនជាតិម៉ាឡេយ៉ាងពេញលេញទៅហើយ ។ ចំនួនទ័ពរបស់ព្រះអង្គមានចំនួនតិចជាង ។

ព្រះអង្គត្រូវចាប់ខ្លួន និងធ្វើគុតនៅសាយហ្គន ។ សពព្រះរាជាត្រូវបានធ្វើបុណ្យតាមពិធីព្រះពុទ្ធសាសនា បូជាហើយផេះរបស់ព្រះអង្គតម្កល់នៅក្នុងចេតិយនៅសាយហ្គន ។ ផ្ទុយទៅវិញ សមាជិកព្រះបរមរាជវាំង នៅតែគិតថា ព្រះបាទរាមាធិបតីទី១ ជាអ្នកកាន់ព្រះពុទ្ធសាសនាដែលបានក្លាយជាអ្នកកាន់សាសនាអ៊ីស្លាម ដោយចៃដន្យ ដោយសារត្រូវអំពើ និងគិតខុសមួយពេល ។ រជ្ជកាលរបស់ព្រះបាទរាមាធិបតីទី១ បានបញ្ចប់នៅក្នុងឆ្នាំ១៦៥៨ ហើយការរីកចម្រើននូវសាសនាអ៊ីស្លាម នៅកម្ពុជា ក៏ត្រូវបញ្ចប់ដំណាលគ្នាដែរ ។ ឱកាសរបស់ជនជាតិចាម ឬជនជាតិម៉ាឡេដើម្បីក្លាយជាអ្នកមានមុខមានមាត់នៅក្នុងសង្គមកម្ពុជាត្រូវបានបញ្ចប់ដំណាលគ្នាជាមួយនឹងការដួលរលំរបស់ព្រះបាទរាមាធិបតីទី១ដែរ ។

**(តទៅលេខក្រោយ)** **អេង កុកថាយ**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthpechet@dccam.org ។

**◆ទីកន្លែង : អគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

*“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។*





















# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Join Criminal Enterprise*" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Common Criminal Plan*" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# តើអ្វីជា «ភាពវិសាមញ្ញ» ចំពោះភាពយុត្តិធម៌

**(តចប់)**

អង្គជំនុំជម្រះសាលាដំបូងក៏បានកំណត់ថា ដោយសារផលវិបាកនៃឧក្រិដ្ឋកម្មកើតឡើងពី នួន ជា និង ខៀវ សំផន ដែលត្រូវបានចោទប្រកាន់នេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលស្ថិតនៅក្នុងកិច្ចដំណើរការនីតិវិធី និងជនរងគ្រោះជាច្រើនរូបបន្ថែមទៀត ធ្លាប់បានទទួលរងការឈឺចាប់ដោយមិនអាចវាស់បាន រួមទាំងការទទួលរងផ្នែករាងកាយ ការបាត់បង់ភាពថ្លៃថ្នូរ បាត់បង់សេដ្ឋកិច្ច ជំងឺផ្លូវចិត្ត និងសេចក្តីវិនាសអន្តរាយកើតឡើងពីការបាត់បង់សមាជិកគ្រួសារ ឬសាច់ញាតិជិតស្និទ្ធ ។ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាអ្វីដែលពុំធ្លាប់មានពីមុនមក និងជាជំហានដ៏សំខាន់មួយនៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។ ការចូលរួមរបស់ជនរងគ្រោះ បានធ្វើឡើងនៅក្នុងដំណាក់កាលជំនុំជម្រះ ហើយទាមទារឲ្យមានការបន្សាំទៅក្នុងកិច្ចដំណើរការនីតិវិធីនោះ ដើម្បីធានាឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។ បទពិសោធនៅក្នុងការជំនុំជម្រះដែលមានសមាជិកមេធាវីតំណាងជាច្រើនរូប ដើម្បីតំណាងតាមក្រុមនីមួយៗ ត្រូវបានកំណត់ចំនួនដើមបណ្តឹងរដ្ឋប្បវេណី (ដើមបណ្តឹងរដ្ឋប្បវេណីក្រោម១០០នាក់) នៅក្នុងសំណុំរឿង០០១ ត្រូវបានរៀបចំឡើងវិញ ដើម្បីចូលរួមនៅក្នុងកិច្ចដំណើរការនៃសំណុំរឿង០០២ ទាក់ទងនឹងជនរងគ្រោះចំនួន៤០០០នាក់ចុងក្រោយ ដែលត្រូវទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដ ។

វិធានផ្ទៃក្នុង ដែលបានធ្វើវិសោធនកម្ម តាមរយៈកិច្ចប្រជុំពេញអង្គពីសមាជិកចៅក្រមគ្រប់រូបរបស់តុលាការបង្កើតឲ្យមានមេធាវីនាំមុខជាតិម្នាក់ និងមេធាវីនាំមុខអន្តរជាតិម្នាក់ ដើម្បីការពារឲ្យផលប្រយោជន៍ជាសមូហភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលជំនុំជម្រះ ទោះបីជា ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ រក្សាទុកការការពារក្តីតាមផ្លូវច្បាប់ជាលក្ខណៈបុគ្គលក៏ដោយ ។ មុខងារសំខាន់ ដែលហៅថាជាមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺការសហការណ៍គ្នាក្នុងការត្រៀម ការពារសិទ្ធិស្របតាមផ្លូវច្បាប់នៅក្នុងយុទ្ធសាស្ត្រជាប់ទាក់ទងដូចៗគ្នាមួយ ដែលស្ថិតក្នុងការរក្សាផលប្រយោជន៍ខ្ពស់បំផុតនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងមូល ។

ការឈានចូលដល់ការទទួលបានសំណង ត្រូវធ្វើឡើងតាមរយៈដំណើរវិវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ វិធានផ្ទៃក្នុងបានកំណត់យ៉ាងច្បាស់លាស់ថា សំណងត្រូវផ្តល់ជូនជាលក្ខណៈផ្លូវចិត្ត និងសមូហភាព ហើយច្រានចោលរាល់សំណងថវិកាជាលក្ខណៈបុគ្គល ។ អំឡុងពេលជំនុំជម្រះនៃសំណុំរឿង០០១ប្រឆាំងនឹង ឌុច ភាពទ័លក្ររបស់ ឌុច បានរារាំងអង្គជំនុំជម្រះសាលាដំបូងចេញពីការសម្រេចឲ្យ ឌុច សងសំណង ហើយបានបង្គាប់ឲ្យដាក់ឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្ទាល់ទៅក្នុងសាលក្រមដែលកំណត់ពីពិរុទ្ធភាព ក៏ដូចជាការចងក្រង និងបោះពុម្ពសេចក្តីថ្លែងសុំអភ័យទោស ដែលបានធ្វើឡើងអំឡុងពេលជំនុំជម្រះក្តី ។ នៅក្នុងការបង្ហាញឲ្យឃើញពីបទពិសោធន៍នៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០២ សមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់សំណង ត្រូវបានពន្យាតលើសពីទម្លាប់នៃកំណត់សម្គាល់លើការផ្តល់សំណងប្រឆាំងនឹងទណ្ឌិត ដើម្បីសម្រេចបានមុខងារបន្ថែមមួយទៀត ក្នុងការឆ្លើយតបទៅនឹងសំណងរបស់ជនរងគ្រោះ ។ ជាពិសេស អង្គជំនុំជម្រះវិសាមញ្ញត្រូវទទួលបានសមត្ថកិច្ចក្នុងការបង្កើតឲ្យមានភាគីទីបីដែលជាការបង្កើតគម្រោងជាក់លាក់ ដែលសម្របសម្រួលដោយអង្គភាពគាំពារជនរងគ្រោះរបស់តុលាការ និងត្រូវធានានូវការសន្យាផ្តល់ជំនួយពីខាងក្រៅ ។ កិច្ចដំណើរការនីតិវិធីថ្មី និងមានលក្ខណៈប្លែកនេះបានបើកផ្លូវដល់ការពិចារណាពីតួនាទីយ៉ាងទូលំទូលាយរបស់គម្រោងនៃការចងចាំ ការអប់រំ មន្ទីរពេទ្យព្យាបាលរបួសផ្លូវចិត្ត និងពិព័រណ៍សារមន្ទីរ ដោយពុំមានភ្ជាប់ទៅនឹងការរួមបញ្ចូលថវិការបស់ទណ្ឌិតនោះទេ ។

ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រមលើសំណុំរឿង០០២ ដំណាក់កាលទី១ កាលពីខែសីហា បានយល់ព្រមអនុវត្តគម្រោងសំណងចំនួន១១ប្រភេទជាក់លាក់ ដែលត្រូវបានបង្ហាញដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យមានការទទួលស្គាល់ពីភាពឈឺចាប់ដែលកើតចេញពីឧក្រិដ្ឋកម្មក្នុងប្រធានបទនៃការជំនុំជម្រះនេះ ហើយផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបញ្ជាក់ពីការឈឺចាប់នេះ ។ គម្រោងទាំងនេះ ត្រូវបានដាក់ផែនការដើម្បីពិភាក្សាជាមួយសង្គមស៊ីវិល និងជនរងគ្រោះព្រមទាំងអ្នកតំណាងរបស់ខ្លួន និងត្រូវបានផ្តល់ជំនួយគ្រប់គ្រាន់ទុកជាមុន រួមទាំងបង្កើតឲ្យមានគម្រោងទិវាជាតិនៃការចងចាំ ការសាងសង់ស្តូបដើម្បីរំឭកដល់ជនរងគ្រោះនៃការជម្លៀសដោយបង្ខំ គម្រោងប្រើប្រាស់វិធីព្យាបាលតាមរបៀបចង្រ្កងជាសក្ខីកម្ម គម្រោងបង្កើតក្រុមជួយខ្លួនឯង គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍ គម្រោងតាំងពិព័រណ៍ចល័ត គម្រោងនៃការអប់រំ ការតាក់តែងជំពូកដាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្ងាប់មនុស្សនៅទួលពោធិ៍ជ្រៃ ដោយដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមសាលាក្នុងប្រទេសកម្ពុជា ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព គម្រោងបោះពុម្ពព្រឹត្តិបត្រពិភាក្សាពីអង្គហេតុ និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ការបោះពុម្ពពីរលើកស្តីពីសាលក្រមនៅក្នុងសំណុំរឿង០០២ដំណាក់កាល ទី១ សម្រាប់ចែកជូនប្រជាជននៅតាមភូមិក្នុងប្រទេសកម្ពុជា និងការផ្សព្វផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ផែនការត្រូវបានចាប់ផ្តើមសម្រាប់ជាគម្រោងសំណង ដែលអាចធ្វើដូចគ្នា និងមានការផ្តល់ជំនួយជាមុន ប្រសិនបើរកឃើញពិរុទ្ធភាពនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ ។

ដំណាលគ្នានឹងការពិភាក្សាពីសាលក្រមលើសំណុំរឿង០០២ ដំណាក់កាលទី១ កាលពីឆ្នាំមុន អង្គជំនុំជម្រះសាលាដំបូង បានចាប់ផ្តើមធ្វើការជំនុំជម្រះក្នុងដំណាក់កាលទី២ នៃសំណុំរឿង០០២ ។ សវនាការលើភ័ស្តុតាងទាំងនោះ បច្ចុប្បន្នបានចាប់ផ្តើមពេញលេញហើយ និងបានពិចារណាលើបទចោទទាក់ទងនឹងសហករណ៍ត្រាំកក់ រួមទាំងការប្រព្រឹត្តលើអ្នកកាន់ព្រះពុទ្ធសាសនា ព្រមទាំងទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ បន្ទាប់មក ការជំនុំជម្រះនឹងបន្តទៅពិភាក្សាលើបទចោទទាក់ទងនឹងការដ្ឋានការងារជាក់លាក់ចំនួនបីទីតាំងទៀត ។ ក្រោយមក ការជំនុំជម្រះនឹងបន្តពិចារណាអំពីការប្រព្រឹត្តទៅលើក្រុមគោលដៅ ជនជាតិចាម និងវៀតណាម រួមទាំងបទចោទលើអំពើប្រល័យពូជសាសន៍ ក៏ដូចជាមន្ទីរសន្តិសុខ បន្ថែមទៀត និងការបោសសម្អាតផ្ទៃក្នុង ការរៀបការដោយបង្ខំ និងបទល្មើសរំលោភ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីជនជាប់ចោទ ។

ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានបន្ថែមថ្ងៃសវនាការរបស់ខ្លួនសម្រាប់ដំណាក់កាលទី២ នៃការជំនុំជម្រះប្រឆាំងនឹង ខៀវ សំផន និង នួន ជា ពីចំនួនបីថ្ងៃទៅបួនថ្ងៃក្នុងមួយសប្តាហ៍វិញ ។ ការធ្វើដូច្នេះ ដើម្បីពន្លឿនការជំនុំជម្រះ ។ បច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូង រំពឹងថាការជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីដំណាក់កាលទី២ នឹងបន្តរហូតដល់ដើមឆ្នាំ២០១៦ ហើយសាលក្រមរបស់ខ្លួននឹងត្រូវចេញនៅត្រឹមឆ្នាំ២០១៧ ។

ការពន្យារពេលដោយចៃដន្យ និងសភាពអូសបន្លាយពេលវេលានៃកិច្ចដំណើរការនីតិវិធីនេះ គឺអាចយល់បានថាជាការទទួលយកបាន ជាពិសេសសម្រាប់ជនរងគ្រោះ ។ ប៉ុន្តែ ការពន្យារពេលនេះ បានឆ្លុះបញ្ចាំងពីរបៀបអនុវត្តការគោរពសិទ្ធិជាអន្តរជាតិ ដែលអង្គជំនុំជម្រះប្រកាន់យកទាំងនៅអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ។ ការពន្យារពេលចំពោះ កិច្ចដំណើរការនីតិវិធីដ៏មានសារសំខាន់កើតឡើងពីកត្តាផ្សេងៗពីគ្នា ដែលត្រូវលើកឡើងក្នុងពេលខុសៗគ្នាក្នុងកម្រិតខុសៗគ្នានៃប្រសិទ្ធភាពដំណើរការនីតិវិធី ។ ការពន្យារពេលទាំងនេះរួមមានការទាមទារឲ្យបង្ហាញពី ៖

**ក)** ស្ថានភាពសុខភាពជនជាប់ចោទ

**ខ)** ការលើកដៃរបស់ភាគីនីមួយៗនៅក្នុងបរិបទច្បាប់

**គ)** ការប្រព្រឹត្តជាក់ស្តែងដោយមេធាវីការពារក្តី

**ឃ)** ការទាមទារឲ្យមានការបកប្រែផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរទៅជាបីភាសាផ្លូវការ ភាសាអង់គ្លេស ភាសាខ្មែរ និងភាសាបារាំង លើគ្រប់ដំណើរការនីតិវិធី ការងើបឡើងជំទាស់ការចេញសេចក្តីសម្រេច និងសាលក្រម

**ង)** និងការខ្វះជំនួយក្នុងពេលបណ្តោះអាសន្នដែលមានការ

ប៉ះទង្គិចលើទឹកចិត្ត និងលទ្ធភាពរបស់បុគ្គលិកសំខាន់ៗ ។

ការស៊ើបអង្កេតតាមផ្លូវតុលាការកំពុងបន្តនៅពេលបច្ចុប្បន្ន ក្នុងសំណុំរឿងពីរបន្ថែមទៀត គឺសំណុំរឿង០០៣ និងសំណុំរឿង ០០៤ ទាក់ទងនឹងជនជាប់ចោទមួយចំនួន ។ ពុំទាន់មានជនជាប់ចោទណាម្នាក់ ត្រូវចាប់ខ្លួន ឬចោទប្រកាន់ជាផ្លូវការនៅឡើយទេ ហើយអត្តសញ្ញាណរបស់ជនជាប់ចោទទាំងនោះត្រូវរក្សាការសម្ងាត់ ។ បទឧក្រិដ្ឋកំពុងស្ថិតក្រោមការស៊ើបអង្កេត គឺអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងការបំពារបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។

មានសាច់រឿងឧក្រិដ្ឋកម្មចំនួន១០ ដែលអាចកើតមាននៅក្នុងសំណុំរឿង០០៣ និងសាច់រឿងឧក្រិដ្ឋកម្មចំនួន៥៥ ដែលអាចកើតមាននៅក្នុងសំណុំរឿង០០៤ ។ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចតាមផ្លូវច្បាប់ ក្នុងការស៊ើបអង្កេតលើសាច់រឿងឧក្រិដ្ឋកម្មទាំងអស់ដែលអាចកើតមាន ហើយសហចៅក្រមស៊ើបអង្កេតកំពុងដំណើរការ ។

ចាប់តាំងពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបច្ចុប្បន្ន ចាប់ផ្តើមការងាររបស់ខ្លួននៅក្នុងខែតុលា ឆ្នាំ២០១២ មានទីតាំងស៊ើបអង្កេតលើសកំណត់ចំនួន៩០កន្លែង ត្រូវបានធ្វើការស្រាវជ្រាវ ហើយសាក្សីច្រើនជាង៣៥០រូប បានបញ្ចប់ការផ្តល់បទសម្ភាស ។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើឲ្យស៊ើបសួរបន្ថែម ស្នើសុំជាផ្លូវការឲ្យសហចៅក្រមស៊ើបអង្កេតពន្យាតការស៊ើបអង្កេតរបស់ខ្លួនលើសំណុំរឿង០០៣ ដោយរួម បញ្ចូលបទចោទថ្មី មានដូចជាការរៀបការដោយបង្ខំ និងបទល្មើសរំលោភ ។

កាលពីខែមុន អង្គជំនុំជម្រះវិសាមញ្ញបានបើកកិច្ចប្រជុំពេញអង្គ ហើយបានយល់ស្របធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង ដោយអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេត "កាត់បន្ថយវិសាលភាព ស៊ើបអង្កេតរបស់តុលាការ តាមរយៈការដកចេញនូវអង្គហេតុជាក់លាក់ ដរាបណាអង្គហេតុដែលនៅសេសសល់គឺជាភាពតំណាងឲ្យវិសាលភាពនៃសំណើដែលបានដាក់" ។ វិសោធនកម្មលើវិធានផ្ទៃក្នុងផ្សេងទៀតនឹង "អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងកាត់បន្ថយវិសាលភាពជំនុំជម្រះដោយការដកចេញនូវអង្គហេតុជាក់លាក់មាននៅក្នុងដីកាចោទប្រកាន់" ។ វិសោធនកម្មទាំងនេះ ផ្តល់សិទ្ធិអំណាចដ៏មានសារប្រយោជន៍ ដែលអាចប្រើដើម្បីរក្សាទុកនូវភាពជាតំណាងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ ប៉ុន្តែដើម្បីពន្លឿនរយៈពេលនឹងត្រូវចំណាយ ដែលជាប់ទាក់ទងនឹងសំណុំរឿងដ៏ស្មុគស្មាញទាំងនេះ ។ ការបញ្ជាក់ពីការកំណត់ទាំងនេះ នឹងក្លាយជាការវិនិច្ឆ័យ និងអាចប្តឹងសាទុក្ខឡើងវិញបាន ។

តាមរយៈពេលនឹងត្រូវចំណាយនៅក្នុងសំណុំរឿងទាំងនេះតុលាការបានព្យាករណ៍ថា ការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ អាចបញ្ចប់នៅត្រឹមត្រីមាសទី១ នៃឆ្នាំនេះ និងចេញសេចក្តីសម្រេចមួយក្នុងទម្រង់ជាដីកាដំណោះស្រាយស្តីពីថា តើជនសង្ស័យណាខ្លះនឹងត្រូវចោទប្រកាន់ រួចបញ្ជូនទៅជំនុំជម្រះ ។ បើតាមសំណុំរឿង០០៤ ការស៊ើបអង្កេតកំពុងដំណើរការទៅរកការចេញសេចក្តីសន្និដ្ឋាន ហើយយើងគួរតែគិតទុកជាមុនពីដីកាដំណោះស្រាយនៅក្នុងពេលឆាប់ៗនេះ ។

សហព្រះរាជអាជ្ញា ធ្លាប់បានថ្លែងជាសាធារណៈថា នឹងគ្មានសំណុំរឿងបន្ទាប់ពីសំណុំរឿង០០៣ និង០០៤នោះទេ ហើយរឿងនេះបានធ្វើឡើងវិញម្តងទៀតជាសាធារណៈ និងជាផ្លូវការដោយសហព្រះរាជអាជ្ញាអន្តរជាតិនាពេលថ្មីៗនេះ ។ ដូច្នេះ ចំនួនរឿងក្តីដែលកំពុងមាន គឺតំណាងដល់ចំនួនសរុបនៃចំនួនរឿងក្តី ដែលត្រូវបានបញ្ជាក់ដោយអង្គជំនុំជម្រះវិសាមញ្ញ ។

តាំងពីឆ្នាំ២០១៤ អង្គជំនុំជម្រះវិសាមញ្ញបានចេញគម្រោងផែនការពេញលេញមួយជាសាធារណៈ ដែលធ្វើរៀងរាល់ត្រីមាស ដោយលម្អិតអំពីកិច្ចការដែលនៅសេសសល់ តម្រូវឲ្យបំពេញនៅក្នុងដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន និងដំណើរការនេះត្រូវធ្វើឲ្យបានតាមគោលដៅ ។ ផែនការបង្ហាញពីការគូសវាសផ្នែកសំខាន់ដាក់ស្តែងលើនីតិវិធីដែលនៅសេសសល់ បានរៀបចំតាមអ្វីដែលដាក់បញ្ចូលដោយចៅក្រម និងសហព្រះរាជអាជ្ញា បង្ហាញនូវការលើកយកគោលសំខាន់ៗដាក់ស្តែង ដើម្បីនាំផ្លូវឆ្ពោះទៅរកភាពជោគជ័យលើនីតិវិធីដែលនៅសេសសល់ និងទាមទារឲ្យមានការគ្រោងទុកពេលវេលា ដែលនឹងត្រូវចំណាយសម្រាប់បំពេញចំពោះចំនួនរឿងក្តីនាពេលបច្ចុប្បន្ន ។ ដំណើរការក្នុងត្រីមាសមុន នៅសេស

សល់ចំណុចសំខាន់ៗចំនួន១៥ នៅក្នុងសំណុំរឿងទាំងបី ។ ការជំនុំជម្រះនៅដំណាក់កាលទី២ នៃសំណុំរឿង០០២ គួរតែចេញសេចក្តីសន្និដ្ឋានរបស់ខ្លួនលើសវនាការអង្គសេចក្តី, ភ័ស្តុតាង នៅក្នុងឆ្នាំ២០១៦ ហើយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងគួរតែអាចចេញនៅឆ្នាំ២០១៧ ។ ការទទួលបានបណ្តឹងសាទុក្ខត្រូវប៉ាន់ស្មានថា នឹងកើតមាននៅត្រឹមឆ្នាំ២០១៩ ។ ដោយសារសំណុំរឿង ០០៣ និងសំណុំរឿង០០៤ កំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត ដូច្នេះពុំទាន់ច្បាស់នៅឡើយទេថា តើសំណុំរឿងជាលទ្ធផលនឹងត្រូវចោទប្រកាន់ហើយបញ្ជូនទៅជំនុំជម្រះ ។ ប៉ុន្តែ ដូចដែលខ្ញុំបានកត់សម្គាល់ពីខាងលើថា ការងារស៊ើបអង្កេត និងដីកាដំណោះស្រាយសម្រាប់សំណុំរឿងនីមួយៗ ព្រមទាំងសេចក្តីសម្រេចទាំងការបញ្ជូនរឿងទៅជំនុំជម្រះ ឬប្រានចោលការចោទប្រកាន់ គួរតែមាននៅត្រឹមចុងឆ្នាំនេះ ។ ប្រសិនបើមានបណ្តឹងសាទុក្ខលើដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ បន្ទាប់មកយើងអាចប៉ាន់ស្មានបានពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងឆមាសទី១ នៃឆ្នាំ២០១៦ ។

អាចកត់សម្គាល់បានថា មានការចូលរួមដែលមិនធ្លាប់មានពីមុនមកដោយប្រជាជនកម្ពុជា ក្នុងនាមជាអ្នកតាមដានការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញ ។ ចាប់តាំងពីពេលបើកអង្គជំនុំជម្រះក្នុងថ្ងៃដំបូងនៃនីតិវិធីជំនុំជម្រះប្រឆាំងនឹង ឌុច ក្នុងឆ្នាំ២០០៩ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ សរុបប្រជាជនមានចំនួន ១៦៥,៤០៧នាក់ ស្ទើរតែគ្រប់ប្រជាជនដែលមានសញ្ជាតិកម្ពុជាទាំងអស់ពីទូទាំងប្រទេសបានដឹងពីការជំនុំជម្រះដោយផ្ទាល់ ។ ចំនួននេះលើសពីចំនួនអ្នកតាមដានសរុបនៅតុលាការ ញូរ៉ឹមប៊ឺក និងតុលាការយោធាទីក្រុងតូក្យូបន្ទាប់ពីសង្គ្រាមលោកលើកទី២ តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន តុលាការពិសេសសម្រាប់ប្រទេសលីបាណន់ និងតុលាការព្រហ្មទណ្ឌអន្តរជាតិបូកបញ្ចូលគ្នាទៅទៀត ។ តុលាការបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល រួមទាំងមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជួយសម្រួលការធ្វើដំណើររបស់ប្រជាជនកម្ពុជារាប់រយនាក់ ទៅសាលាក្តីស្ថិតក្នុងរាជធានីភ្នំពេញ នៅពេលព្រឹកព្រលឹម ហើយបន្ទាប់មកដឹកជញ្ជូនប្រជាជនទៅតាមភូមិរៀងខ្លួន ហើយដល់លំនៅដ្ឋាននាពេលយប់ បន្ទាប់ពីតុលាការផ្អាកសវនាការរបស់ខ្លួនក្នុងថ្ងៃដដែលនោះ ។ វាអាចជាការលំបាក និងធ្វើដំណើរវែងឆ្ងាយ ពេលខ្លះ ទាមទារឲ្យប្រជាជនឡើងឡានដឹកអ្នកដំណើរនៅម៉ោង២ទៀបភ្លឺ ដើម្បីចូលរួមការបើកសវនាការនីតិវិធីនៅក្នុងថ្ងៃដដែលនោះ ។ ប៉ុន្តែប្រជាជនកម្ពុជាគ្រប់រូប និងគ្រប់វ័យធ្វើដូចនេះ ប្រកបដោយឆន្ទៈរបស់ខ្លួន ព្រោះពួកគាត់ជឿលើការនាំយកការចោទប្រកាន់នៃឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នង កាលពី៤ទសវត្សរ៍មុន ដើម្បីភាពយុត្តិធម៌ ។

លើសពីនេះទៅទៀត ប្រជាជនជាច្រើនដែលបានធ្វើដំណើរមកកាន់តុលាការ ដែលទទួលការយល់ដឹង និងកម្មវិធីអប់រំខុសៗគ្នាបាននាំយកព័ត៌មានស្តីពីអង្គជំនុំជម្រះវិសាមញ្ញទៅប្រជាជនកម្ពុជាទូទាំងប្រទេស ។ ការផ្តួចផ្តើមគំនិតមួយ ដឹកនាំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបញ្ជូនក្រុមអ្នកអប់រំទៅតាមមហាវិទ្យាល័យ សាលានៅតាមតំបន់នីមួយៗ និងតាមភូមិដើម្បីបង្កើតថ្នាក់រៀន និងសិក្ខាសាលាអប់រំប្រជាជនអំពីតុលាការ និងដំណើរការរបស់តុលាការ ។ ចាប់ពីថ្នាក់រៀនដែលមានសិស្ស៧០នាក់ ទៅសាលប្រជុំធំដែលអាចផ្ទុកមនុស្សច្រើនជាង៤០០នាក់ ។ ការជួបជុំមួយពេលនេះបានឈានដល់មនុស្សរាប់រយនាក់ក្នុងមួយខែ និងចង្អុលបង្ហាញប្រជាជនឲ្យស្គាល់ពីរបៀបស្វែងយល់ និងរបៀបបន្តការតាមដានដំណើរការជំនុំជម្រះ ។ កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំមុន មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្សព្វផ្សាយសាលក្រមក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ ទៅប្រជាជនកម្ពុជារាប់ពាន់នាក់នៅ២២កន្លែងតាមរយៈក្រុមការងារដែលលាតត្រដាងពីគោលបំណង ដែលធ្វើឲ្យរូបភាពនៃយុត្តិធម៌មានចលនាឡើងនៅតាមទីក្រុង និងភូមិនានានៅតាមទីជនបទដាច់ស្រយាលនៃប្រទេស ។ ជាឧទាហរណ៍ ពេលខ្លះនីតិវិធីទាំងនោះ ធ្វើឲ្យប៉ះទង្គិចផ្លូវចិត្តផ្ទាល់ខ្លួនក្នុងចំណោមប្រជាជនទូទៅយ៉ាងខ្លាំង ។

ខ្ញុំមានផ្ទាំងគំនូរដើមមួយដាក់តាំងនៅផ្ទះរបស់ខ្ញុំដែលគូរដោយវិចិត្រករក្នុងស្រុកម្នាក់កាលពីថ្ងៃទី៧ ខែសីហា នៅក្នុងភូមិមួយនៅប្រទេសកម្ពុជា ។ វាពណ៌នាអំពីអ្នកភូមិមួយក្រុមបានប្រមូលផ្តុំគ្នាជុំវិញទូរទស្សន៍ចាស់មួយ ដាក់បញ្ចាំងពីសាលក្រមដែលត្រូវប្រកាសប្រឆាំងនឹងអតីតមេដឹកនាំរបស់ពួកគេ គឺ ខៀវ

សំដែន និង នួន ជា ។ អាចកត់សម្គាល់បានថា មនុស្សច្រើនជាង ៤៣៤.០០០ នាក់ បានចូលរួមនៅក្នុងកម្មវិធីផ្សព្វផ្សាយចំណេះដឹងដែលរាប់ទាំងទស្សនកិច្ចសិក្សា ការមើលខ្សែភាពយន្ត ការបង្រៀននៅតាមសាលា និងការជួបប្រជុំក្នុងសាលនៅតាមទីប្រជុំជន ក៏ដូចជាមនុស្សមកពីខាងក្រៅមួយចំនួនដែលអង្គុយនៅក្នុងបន្ទប់សវនាការ ដើម្បីចូលរួមតាមដានការជំនុំជម្រះ ។

កម្មវិធីផ្សព្វផ្សាយចំណេះដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញរួមមានកម្មវិធីទូរស័ព្ទចូលក្នុងវិទ្យុប្រចាំសប្តាហ៍ រៀបចំដោយតុលាការ និងការសង្ខេបសវនាការនៅក្នុងកម្មវិធីទូរទស្សន៍ ដោយក្រុមហ៊ុនផលិតកម្មឯកជន ។ ប្រតិចារឹកនៃបទអត្ថាធិប្បាយតាមវិទ្យុដែលត្រូវផ្សាយចេញជាសាធារណៈនៅលើគេហទំព័រតុលាការ *(http://www.eccc.gov.kh/en/media-center/weekly-radio)* ។ កម្មវិធីទូរទស្សន៍ "ការប្រឈមមុខនឹងយុត្តិធម៌" ត្រូវចាក់ផ្សាយបីពេលក្នុងមួយសប្តាហ៍ នៅលើប៉ុស្តិ៍ទូរទស្សន៍ចំនួនពីរ និងនៅលើប្រព័ន្ធអ៊ីនធើណេតជាច្រើន ឧទាហរណ៍ៈ *(http://krtmonitor .org/category/case-002-facing-justice-videos/)* ។ សកម្មភាពទាំងពីរ បានទៅដល់អ្នកតាមដានយ៉ាងទូលំទូលាយ នៅទូទាំងប្រទេស ជាមួយព័ត៌មានបច្ចុប្បន្នស្តីពីការជំនុំជម្រះ និងជួយដល់ការអប់រំចំពោះសាធារណជន ។

ការផ្តួចផ្តើមគំនិតពីសង្គមស៊ីវិលផ្សេងទៀត មូលនិធិ *Robert Bosch Stiftung* គេហទំព័រឃ្លាំមើលសាលាក្តីខ្មែរក្រហម (http : // *www.cambodiatribunal.org/)* ដែលសហការជាមួយសកលវិទ្យាល័យច្បាប់ Northwestern នៅក្នុងភាពជាដៃគូជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គេហទំព័រឃ្លាំមើលសាលាក្តីខ្មែរក្រហម ផ្តោតលើការជំនុំជម្រះប្រចាំថ្ងៃរបស់អង្គជំនុំជម្រះវិសាមញ្ញតាមរយៈអត្ថបទវីដេអូ និងជួនកាលមានបទអត្ថាធិប្បាយផ្នែកច្បាប់ ហើយជាច្រើនឆ្នាំមកនេះបានក្លាយជាធនធានលើអ៊ីនធើណេតដ៏មានសារសំខាន់ដូចគ្នានឹងគេហទំព័រផ្ទាល់របស់តុលាការ *(http://www.eccc.gov.kh)* ។ តុលាការផ្ទាល់ក៏ បានរៀបចំព័ត៌មានទាក់ទងនឹងដំណើរការតុលាការដែលមានប្រវែងសមរម្យ ដើម្បីដាក់ដំណើរការនៅលើអនឡាញក្នុងភាសាផ្លូវការទាំងបី រួមទាំងតាមព័ត៌មានសង្គមទៀតផង ។ ដូច្នេះសមាគមអន្តរជាតិក៏ដូចជាប្រជាជនកម្ពុជា អាចចូលទៅក្នុងគេហទំព័រអាចដឹងដូចគ្នារវាងដំណើរវិវត្ត និងការដាក់បញ្ចូលឯកសារតុលាការសំខាន់ៗប្រចាំថ្ងៃ ក៏ដូចជាទំព័រកាសែត និងរបាយការណ៍សារព័ត៌មានដែលផ្សព្វផ្សាយជាសំឡេង ។

ត្រូវតែទទួលស្គាល់ថា មានការត្រឡប់ថយក្រោយ នៅពេលខ្លះជាអកុសលការពន្យារពេលត្រូវធ្វើឡើងដោយសារអង្គហេតុមួយចំនួន ដែលមិនខុសប្លែកពីតុលាការព្រហ្មទណ្ឌអន្តរជាតិនោះទេ ។ ប៉ុន្តែរឿងអវិជ្ជមានពេលខ្លះ លេចចេញនៅក្នុងសារព័ត៌មាន និងនៅក្នុងការប៉ាន់ស្មានរបស់អ្នកចេះដឹងមួយចំនួនអំពីអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែដាក់នៅក្នុងទស្សនៈត្រឹមត្រូវ ។

អនុញ្ញាតឲ្យខ្ញុំធ្វើការបញ្ជាក់ឲ្យចំការរិះគន់ជាសាធារណៈខ្លះដែលខ្ញុំនឹងផ្តោតទៅលើលក្ខណៈទូទៅ ដើម្បីជាផលប្រយោជន៍ ។ ទីមួយ ដោយកត់សម្គាល់លើការថ្លែងជាសាធារណៈពីមន្ត្រីជាន់ខ្ពស់មានរឿងវិវាទលើការជ្រៀតជ្រែកផ្នែកនយោបាយមកលើអង្គជំនុំជម្រះវិសាមញ្ញ ។ មេធាវីការពារក្តីបានរុញច្រានរឿងនេះចូលក្នុងតុលាការ ដែលត្រូវបានដោះស្រាយដោយរួចរាល់ គឺអង្គជំនុំជម្រះតុលាការ កំពូលពីបញ្ហាដែលកើតឡើងនៅក្នុងវិធាន និងកិច្ចដំណើរការតុលាការ ។ មិនខុសពីកន្លែងផ្សេងនៅពេលដែលបញ្ហាស៊ើបនៅចំពោះមុខតុលាការ ត្រូវតែមានការប្រុងប្រយ័ត្នលើបញ្ហានេះ ប៉ុន្តែ ឯករាជភាពរបស់តុលាការ គឺជានិយាមពុំមែនជាអញ្ញត្រកម្មនោះឡើយ ។

ការរិះគន់មួយទៀតគឺថាអង្គជំនុំជម្រះវិសាមញ្ញត្រូវប្រឡូកប្រឡាក់ដោយអំពើពុករលួយ ។ នៅប៉ុន្មានឆ្នាំដំបូងអង្គជំនុំជម្រះមានការចោទប្រកាន់ទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលរបស់តុលាការដែលនាំទៅរកការធ្វើកំណែទម្រង់យ៉ាងចាំបាច់មួយ ដើម្បីធានានូវសុចរិតភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ កាលពី ពីរទៅបីឆ្នាំមុនកុងស៊ុលឯករាជ្យម្នាក់ត្រូវតែងតាំងដោយកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ហើយគាត់បានរាយការណ៍យ៉ាងទៀងទាត់ និងសម្ងាត់អំពីការចោទប្រកាន់លើការប្រព្រឹត្តមិនសមរម្យ ។

ទីបី អ្នកអត្ថាធិប្បាយផ្នែកច្បាប់ខ្លះធ្វើការជំទាស់នឹងវិធានកំណត់ពីសំឡេងភាគច្រើនលើសលុបនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ នេះជាវិធានដែលចេញពីការចរចាដែលប្រើរយៈពេលយូរ និងមានភាពលម្អិតជាមួយរដ្ឋាភិបាលនៅក្នុង

ពេលបង្កើតអង្គជំនុំជម្រះ ហើយជាលទ្ធផលចេញពីការពិតដែលមានសមាសភាពចៅក្រមរបស់កម្ពុជាភាគច្រើននៅក្នុងអង្គជំនុំជម្រះនីមួយៗ ។

ជាយូរមកហើយ គឺថាជំហររបស់អង្គការសហប្រជាជាតិនៅក្នុងការជជែកពិភាក្សាបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីរកឲ្យបាននូវចៅក្រមអន្តរជាតិភាគច្រើននៅក្នុងអង្គជំនុំជម្រះនីមួយៗ និងព្រះរាជអាជ្ញាអន្តរជាតិមួយរូប ។ ប៉ុន្តែនោះពុំមែនជាអ្វីដែលការចរចាបានបញ្ចប់នោះទេ ។ ផ្ទុយទៅវិញ សំឡេងភាគច្រើនលើសលុបត្រូវបានផ្លាស់ប្តូរ ដោយសារតែភាពចាំបាច់ត្រូវការពារដល់ផលប្រយោជន៍នៃការជំនុំជម្រះប្រកបដោយយុត្តិធម៌នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងវិធានទាំងនេះ ពុំមានសេចក្តីសម្រេចណាមួយ មានសុពលភាពនោះទេ បើកាលណាពុំមានយ៉ាងហោចណាស់ចៅក្រមអន្តរជាតិមួយរូប ចូលរួមក្នុងការចេញសេចក្តីសម្រេចរបស់ចៅក្រមកម្ពុជាទាំងអស់ ឬយ៉ាងហោចណាស់ចៅក្រមកម្ពុជាពីររូបចូលរួមនៅក្នុងការចេញសេចក្តីសម្រេចរបស់ចៅក្រមអន្តរជាតិទាំងអស់ នៅតាមអង្គជំនុំជម្រះដោយឡែកៗពីគ្នា ។

យុត្តិសាស្ត្រដែលមានលក្ខណៈទូលំទូលាយ និងគួរឲ្យចាប់អារម្មណ៍ និងសេចក្តីសម្រេចនីមួយៗរបស់អង្គជំនុំជម្រះវិសាមញ្ញឆ្លុះបញ្ចាំងពីគោលការណ៍នៃភាពចុះសម្រុងគ្នានៅក្នុងការចេញសេចក្តីសម្រេច ដែលមានសំឡេងភាគច្រើនលើសលុប ។ បញ្ហាទាក់ទងនឹងសំឡេងភាគច្រើនលើសលុបនេះ ពុំមែនជាបញ្ហាធំដុំនោះទេ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង ។

មានពេលមួយនោះ ការទាមទាររបស់សំឡេងភាគច្រើនលើសលុប បានជាប់ជំពាក់ជំពិនខ្លាំងនៅចំពោះមុខអង្គបុរេជំនុំជម្រះ ។ ចៅក្រមមានសិទ្ធិ ហើយក៏បានបញ្ចេញការខ្វែងគំនិតគ្នានេះ លើការបំភ្លឺឲ្យច្បាស់ពីចម្ងល់ពាក់ព័ន្ធនឹងទស្សនៈផ្ទុយគ្នាអំពីបញ្ហាច្បាប់ ។ មានរឿងជាច្រើនរបស់ចៅក្រមអន្តរជាតិ នៅអង្គជំនុំជម្រះនេះផ្ទាល់ ដែលទទួលយកទស្សនៈផ្ទុយគ្នាស្តីពីបញ្ហាច្បាប់ជាក់លាក់មួយឲ្យបំភ្លឺឡើងវិញ ម្តងទៀតថាពុំចាំបាច់ឲ្យមានទស្សនវិស័យអន្តរជាតិដែលដូចគ្នាទាំងអស់លើបញ្ហាច្បាប់ជាពិសេសណាមួយនោះទេ ។

ចុងបញ្ចប់ រយៈពេល និងថ្លៃចំណាយលើការស៊ើបអង្កេត និងការជំនុំជម្រះរបស់តុលាការវិសាមញ្ញ គឺស្ថិតក្នុងចំណោមការរិះគន់ និងត្រូវបានលើកមកនិយាយក្នុងសារព័ត៌មានជាប់រហូត ។ យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ មានន័យថា “ល្បែងដែលចំណាយពេលយូរ” ហើយទាមទារឲ្យមានការទ្រទ្រង់ដល់ស្ថេរភាពថវិកាសម្រាប់ការចំណាយពេលនៅក្នុងអាណត្តិរបស់តុលាការមួយ ។ ការស៊ើបអង្កេត និងការចោទប្រកាន់លើឧក្រិដ្ឋកម្មសាហាវឃោរឃៅដែលពាក់ព័ន្ធនឹងជនរងគ្រោះរាប់ពាន់ រាប់សែននាក់ ពេលខ្លះរហូតដល់រាប់លាននាក់ ហើយទីតាំងឧក្រិដ្ឋកម្មដ៏ធំធេង និងមានសាក្សីរាប់ម៉ឺននាក់នោះ សុទ្ធតែជាបញ្ហាប្រឈមដ៏ស្មុគស្មាញ ដែលតម្រូវឲ្យមានពេលវេលាគ្រប់គ្រាន់ និងធនធានសំខាន់ៗ ដើម្បីសិក្សាឲ្យបានច្បាស់លាស់ ។

ការគោរពតាមស្តង់ដារអន្តរជាតិនៃដំណើរការត្រឹមត្រូវតាមច្បាប់នៅក្នុងតុលាការអន្តរជាតិ ឬតុលាការដែលមានការចូលរួមពីអន្តរជាតិ ទាក់ទងនឹងបទឧក្រិដ្ឋអន្តរជាតិ ចំណាយថវិកា និងពេលវេលាច្រើន បានចោទឡើងជាសំណួរទាក់ទងនឹងសមត្ថភាពមេធាវីការពារក្តី ដែលនឹងជជីកតាមផ្លូវច្បាប់នូវរាល់វិធីការពារដែលជឿថាអាចទៅរួចនៅក្នុងកិច្ចដំណើរការនីតិវិធីសម្រាប់ផលប្រយោជន៍របស់កូនក្តីខ្លួន ។ សម្រាប់ការទទួលស្គាល់ពេលវេលាដែលបានចំណាយ និងភាពស្របច្បាប់នៃសាលក្រមទាំងនេះ គឺសុទ្ធតែជាវិធីចាំបាច់ដែលបានប្រើប្រាស់អស់ទៅហើយ ។

អង្គជំនុំជម្រះវិសាមញ្ញទទួលជំនួយស្ម័គ្រចិត្ត ហើយក៏ពុំមែនជាផ្នែកនៃការវាយតម្លៃកញ្ចប់ថវិការបស់អង្គការសហប្រជាជាតិនោះដែរ ។ ទោះបីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ត្រូវផ្តល់ដោយតុលាការអន្តរជាតិ ឬដោយតុលាការដែលមានការចូលរួមពីភាគីអន្តរជាតិដូចជាអង្គជំនុំជម្រះវិសាមញ្ញក្តី ទោះបីយុត្តិធម៌អន្តរជាតិត្រូវបានផ្តល់ជំនួយតាមរយៈការវាយតម្លៃ ឬក៏តាមរយៈការផ្តល់ជំនួយស្ម័គ្រចិត្តក្តី តម្រូវឲ្យមានការផ្តល់ដំណឹងពីការចំណាយទៅលើការបើកប្រាក់បៀវត្សរ៍ អត្ថប្រយោជន៍បន្ថែម និងការចំណាយរួមសម្រាប់បុគ្គលិកអន្តរជាតិ តម្លៃសេវារបស់មេធាវីការពារក្តីដែលមានចំនួនច្រើន ចំណាយលើសាក្សីជារួម (រួមទាំងការការពារសាក្សី) ថ្លៃបកប្រែផ្ទាល់មាត់ ថ្លៃបកប្រែលើក្រដាស (មានចំនួន

ច្រើន) ចំណាយលើសម្ភារ រួមមាន បន្ទប់សវនាការ ការិយាល័យ និងកុំព្យូទ័រសម្រាប់បុគ្គលិក ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍បន្ថែមរបស់បុគ្គលិកជាតិ មន្ត្រីទំនាក់ទំនងកិច្ចការសាធារណៈ សេវាគាំពារជនរងគ្រោះទាក់ទងនឹងការជំនុំជម្រះ ។

ថវិកាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនេះបញ្ចាំងពីដំណើរការចំណាយរបស់ខ្លួន ។ រីឯពេលធ្វើការពិនិត្យលើថវិកាក្នុងតុលាការជាតិវិញ កម្រមានតួលេខថវិកានេះបញ្ចាំងពីចំនួនសរុបការចំណាយលើប្រតិបត្តិការខ្លួនណាស់ ដែលផ្ទុយទៅវិញត្រូវគិតនៅក្នុងបញ្ជីទោលនៃថវិកាតុលាការអន្តរជាតិ ឬតុលាការដែលមានការចូលរួមពីសំណាក់ភាគីអន្តរជាតិ ។ នៅពេលធ្វើការលើរឿងយុត្តិធម៌អន្តរជាតិ ហើយបើទោះបីជាយុត្តិធម៌នៅក្នុងស្រុក ទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងនាមជាតុលាការកម្ពុជា អន្តរជាតូបនីយកម្ម ធ្វើឲ្យយឺតអស់ជាច្រើនឆ្នាំ ហើយបន្ទាប់មកក៏លើសពីមួយទសវត្សរ៍គិតចាប់ពីមានវត្តមានរបស់តុលាការ មនុស្សមួយចំនួនចាប់ផ្តើមមានចម្ងល់ចំពោះតម្លៃសរុបនៃស្ថាប័ននេះ ។ វាអាចយល់បានថាគឺគ្រាន់តែជាតម្លៃមូលដ្ឋាននៃយុត្តិធម៌អន្តរជាតិប៉ុណ្ណោះ ។

នេះជាមេរៀនដ៏សំខាន់ពីជុំវិញពិភពលោក ដែលការផ្តល់វិភាគទានស្ម័គ្រចិត្ត ពុំអាចទ្រទ្រង់បានលើការច្នៃថវិកាយូរអង្វែងសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលមានគ្រប់លក្ខណៈ ។ ប៉ុន្តែការពិត នៅមានទៀត គឺថា របៀបដោះស្រាយការចរចាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញបានឯកភាព ដោយមហាសន្និបាតទាមទារឲ្យមានវិភាគទានស្ម័គ្រចិត្ត ហើយនេះជាបញ្ហាប្រឈមដែលត្រូវជួបប្រទះ នាពេលបច្ចុប្បន្ន ។

រៀងរាល់ឆ្នាំ បុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញ និងលេខាធិការដ្ឋានអង្គការសហប្រជាជាតិ រៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំរបស់អង្គជំនុំជម្រះវិសាមញ្ញ រួចបញ្ជូនទៅប្រទេសផ្តល់ជំនួយសំខាន់ៗ ដើម្បីពិនិត្យ និងអនុម័ត ។ កញ្ចប់ថវិកាដែលបានអនុម័តរួចហើយ ក្លាយជាចំណែកសំខាន់សម្រាប់ការផ្តល់វិភាគទានស្ម័គ្រចិត្តក្នុងចំណោមប្រទេសម្ចាស់ជំនួយ និងជាអ្វីដែលបានរំពឹងទុកពីរាជរដ្ឋាភិបាលកម្ពុជា សម្រាប់សមាសភាពភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ តាមកាតព្វកិច្ចរបស់រដ្ឋាភិបាល ដូចចែងនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងកម្ពុជា និងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលអនុវត្តលើការបើកប្រាក់បៀវត្សរ៍របស់បុគ្គលិកជាតិនៃអង្គជំនុំជម្រះ និងការចំណាយលើសម្ភារ (បន្ទប់សវនាការ និងអគារការិយាល័យ ។ល ។) ។

ត្រឹមចុងខែមករា ឆ្នាំ២០១៥ អង្គជំនុំជម្រះវិសាមញ្ញទាមទាររកការចំណាយសរុប ចាប់តាំងពីពេលដែលខ្លួនត្រូវបានបង្កើត ដែលត្រូវចំណាយលើសពី២៣៧លានដុល្លារសហរដ្ឋអាមេរិក ។ សមាសភាពភាគីអន្តរជាតិសម្រាប់រយៈពេលជាង១០ឆ្នាំមុន សរុបចំនួន១៧៧លានដុល្លារសហរដ្ឋអាមេរិក និងសមាសភាពភាគីជាតិចំនួន៦០លានដុល្លារ ។ ម្ចាស់ជំនួយធំជាងគេក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ នេះរួមមាន ប្រទេសជប៉ុន (៣៥ភាគរយ) សហរដ្ឋអាមេរិក (១១ភាគរយ) ប្រទេសអូស្ត្រាលី (១០ភាគរយ) ប្រទេសអាល្លឺម៉ង់ (៦ភាគរយ) ចក្រភពអង់គ្លេស (៥ភាគរយ) សហភាពអឺរ៉ុប (៤ភាគរយ) ប្រទេសបារាំង (៣ភាគរយ) ប្រទេសស៊ុយអែត (៣ភាគរយ) ប្រទេសន័រវេ (៣ភាគរយ) និងសាធារណរដ្ឋកូរ៉េ ប្រទេសកាណាដា ប្រទេសដាណឺម៉ាក ប្រទេសហ្វាំងឡង់ និងប្រទេសហូឡង់ ចំនួន១ភាគរយនៃប្រទេសនីមួយៗ លើតម្រូវការសរុប ។ រដ្ឋាភិបាលប្រទេស ផ្សេងទៀត បានចូលរួមផ្តល់វិភាគទានសំខាន់ៗ ប៉ុន្តែមានចំនួនតិចតួច ។ រដ្ឋាភិបាលកម្ពុជាក៏បានផ្តល់វិភាគទានចំនួន៣១ភាគរយ នៃកញ្ចប់ថវិកាជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញ ចំណែកសមាសភាពភាគីជាតិដែលនៅសេសសល់ត្រូវបានបំពេញដោយម្ចាស់ជំនួយបរទេស ដែលកំពុងផ្តល់វិភាគទានដល់សមាសភាពភាគីអន្តរជាតិដែរ ។

នៅក្នុងឆ្នាំ២០១៤ ម្ចាស់ជំនួយធំជាងគេដល់សមាសភាពភាគីអន្តរជាតិ រួមមានសហរដ្ឋអាមេរិក ប្រទេសជប៉ុន ប្រទេសអូស្ត្រាលី ប្រទេសស៊ុយអែត ប្រទេសដាណឺម៉ាក ប្រទេសអាល្លឺម៉ង់ ចក្រភពអង់គ្លេស សាធារណរដ្ឋកូរ៉េ និងប្រទេសអូទ្រីស ។ ឆ្នាំ២០១៤ កញ្ចប់ថវិការបស់ភាគីអន្តរជាតិមាន២៣.៤លានដុល្លារ ។ ការផ្តល់វិភាគទានចំនួនមួយលានដុល្លាររបស់ប្រទេសន័រវេ នៅឆ្នាំ២០១៤ ត្រូវប្រើប្រាស់សម្រាប់ភាគីជាតិ ដែលបានទទួលជំនួយពីប្រទេសឈីលី ប្រទេសអាល្លឺម៉ង់ ប្រទេសម៉ាឡេស៊ី និងប្រទេសហ្គាតា ក៏ដូចជាពីប្រទេសកម្ពុជា គ្រប់ចំនួនតាមកញ្ចប់ថវិកា ៦.៣៨ លានដុល្លារ ។ ម្ចាស់ជំនួយអន្តរជាតិធំមួយក៏បានផ្តល់

ជំនួយកម្ចីសម្រាប់ភាគីជាតិដើម្បីជួយបំពេញតម្រូវការ នៅឆ្នាំ ២០១៤ ។

មូលនិធិសម្រាប់រយៈពេលខ្លី នៅក្នុងឆ្នាំ២០១២ និង២០១៣ តម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រីកមូលដ្ឋានរបស់ម្ចាស់ជំនួយ និងស្វែងរកការបន្ថែមជំនួយពីម្ចាស់ជំនួយដែលកំពុងមាន ។ កង្វះថវិការបស់អង្គជំនុំជម្រះវិសាមញ្ញជាច្រើនដង បានផ្តល់លទ្ធផលនាំឲ្យរងនូវគម្លាតនៃការផ្តល់ជំនួយប៉ះពាល់ដល់ទឹកចិត្តរបស់បុគ្គលិក និងអាចនាំឲ្យបុគ្គលិកបាត់បង់ទឹកចិត្តធ្វើការងារបន្តរហូតដល់មានការធ្វើកូដកម្ម ។ ប៉ុន្តែ ជាចុងក្រោយយើងទទួលបានជោគជ័យរៀងរាល់ឆ្នាំ ក្នុងការលើកឡើងនូវការផ្តល់ជំនួយស្ម័គ្រចិត្តគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការផ្នែកថវិកា ហើយទាំងកញ្ចប់ថវិកាជាតិ និងអន្តរជាតិ ត្រូវធ្វើឲ្យមានស្ថេរភាព ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់វិភាគទានពីក្នុងកញ្ចប់ថវិកាជាតិរបស់ខ្លួន ដើម្បីបើកប្រាក់បៀវត្សរ៍ដល់បុគ្គលិកខាងភាគីជាតិក្នុងរយៈពេល៦ខែ គឺមួយត្រីមាសចុងក្រោយ ក្នុងឆ្នាំ២០១៣ និងមួយត្រីមាសដំបូងនៅឆ្នាំ២០១៤ ។ ថ្មីៗនេះ តាមការពិភាក្សារវាងអគ្គលេខាធិការ អង្គការសហប្រជាជាតិ លោក បាន គីមូន និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់វិភាគទានសម្រាប់ត្រីមាសទីបួនក្នុងឆ្នាំ ២០១៤ ដើម្បីបើកប្រាក់បៀវត្សរ៍ដល់បុគ្គលិកជាតិនិងការសន្យាផ្តល់ប្រាក់បៀវត្សរ៍ ដល់បុគ្គលិកជាតិចំនួន៦ខែ នៅក្នុងអំឡុងឆ្នាំ ២០១៥ ។

ផ្នែកសំខាន់មួយនៃស្ថេរភាពថវិកាបានក្លាយជាសមត្ថកិច្ចរបស់មហាសន្និបាតកាលពីខែមីនាឆ្នាំ២០១៤ដឹកនាំដោយលោកអគ្គលេខាធិការ ក្នុងវិធានការពិសេសមួយដើម្បីប្តេជ្ញាស្វែងរកឲ្យបានថវិកា១៥.៥លានដុល្លារ ប្រសិនបើចាំបាច់ គឺជាធនធានដែលបានមកពីជំនួយស្ម័គ្រចិត្តនៃភាគីអន្តរជាតិ របស់អង្គជំនុំជម្រះវិសាមញ្ញសម្រាប់ឆ្នាំ២០១៤ ។ នេះជាវិធីសាស្ត្រថ្មី និងប្លែកដែលតុលាការអាចប្រើប្រាស់ ដើម្បីជៀសវាងកុំឲ្យមានការឡើងចុះហួសហេតុនៃលំហូរសាច់ប្រាក់ពីម្ចាស់ជំនួយ ដែលអាចប៉ះពាល់ដល់ដំណើរការតុលាការ ។ ក្នុងនាមជាអ្នកជំនាញពិសេសនៃអគ្គលេខាធិការ ខ្ញុំនៅតែបំពេញការងារក្នុងការជួយសម្រួលដល់ការរៃអង្គាសជំនួយតាមធនធានស្ម័គ្រចិត្ត ក្នុងបន្ទុកមួយដើម្បីរកខ្ទង់ចំណាយដែលតុលាការអាចប្រើប្រាស់បាននៅពេលណាដែលត្រូវការបន្ទាន់ ។ ការឯកភាពលើបន្ទុកហិរញ្ញវត្ថុពុំអាចធ្វើលើកិច្ចសន្យារាប់ឆ្នាំ ចំពោះបុគ្គលិកអន្តរជាតិបានទេ ដូច្នេះត្រូវធ្វើឲ្យមានភាពនឹងនរលើស្ថានភាពបុគ្គលិក ដែលពុំមានលក្ខណៈច្បាស់លាស់ និងអាចផ្តោតការយកចិត្តទុកដាក់ពេញលេញ លើការបន្ធូរបន្ថយដល់អាណត្តិតុលាការ ។

សេចក្តីសម្រេចរបស់អគ្គលេខាធិការកាលពីខែមេសា ក្នុងការផ្តល់សមត្ថកិច្ចផ្នែកហិរញ្ញវត្ថុ ពិសេសនេះ ទាក់ទងនឹងតុលាការ បានបង្ហាញពីសារសំខាន់នៃការរក្សារការសម្ងាត់របស់រដ្ឋសមាជិកអង្គជំនុំជម្រះវិសាមញ្ញ និងបញ្ជាក់ពីអាទិភាពដ៏ខ្ពង់ខ្ពស់ ផ្អែកតាមការងាររបស់ពួកគេ ។ អគ្គលេខាធិការ អង្គការសហប្រជាជាតិបច្ចុប្បន្ន បានពិនិត្យសំណើសម្រាប់ការសន្យាផ្តល់ជំនួយឡើងវិញ សម្រាប់ឆ្នាំ ២០១៥ នៅពេលបញ្ហានេះត្រូវលើកឡើងជាថ្មីនៅខែក្រោយ ។ ជាថ្មីម្តងទៀត ការស្រុះស្រួលផ្នែកថវិកាអាចងាកចេញពីបញ្ហារាំងស្ទះនូវលំហូរសាច់ប្រាក់ ប៉ះពាល់ដល់ការលើកឡើងពីការលៃពេលវេលានៃការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ ។ វាអាចងាកឆ្ងាយពីការសម្រាលឧបសគ្គនៃលំហូរសាច់ប្រាក់ ប៉ះពាល់ដល់ការលើកឡើងការលៃលកពេលវេលាផ្តល់វិភាគទានរបស់ម្ចាស់ជំនួយ ។ ខណៈដែលពុំអាចមើលឃើញកិច្ចការទាំងនេះ គឺជាការចូលរួមយ៉ាងសំខាន់ដើម្បីប្រសិទ្ធភាពនៃការងារផ្នែកច្បាប់របស់តុលាការ ។

យុត្តិសាស្ត្រយ៉ាងទូលំទូលាយ នៃអង្គជំនុំជម្រះវិសាមញ្ញបង្ហាញថា យុត្តិធម៌អន្តរជាតិ និងសករាជថ្មីនៃយុត្តិធម៌កម្ពុជា គឺការងារមួយ នៅទីក្រុងភ្នំពេញ កំពុងជះឥទ្ធិពលមិនត្រឹមតែដល់ការងារអន្តរជាតិ និងតុលាការព្រហ្មទណ្ឌដែលមានការចូលរួមពីភាគីអន្តរជាតិប៉ុណ្ណោះទេ ថែមទាំងតុលាការក្នុងស្រុកនៃប្រទេសកម្ពុជានាពេលអនាគតទៀតផង ។ កម្មវត្ថុទាំងពីរ កំពុងកើតមានឡើងហើយ ប៉ុន្តែលទ្ធផលពេញលេញ អង្គជំនុំជម្រះលើយុត្តិធម៌ក្នុងស្រុក និងនៅក្រៅប្រទេសនឹងក្លាយជាផលប្រយោជន៍យូរអង្វែង ។ អង្គការសហប្រជាជាតិ និងប្រទេសផ្តល់ជំនួយ បានខិតខំប្រឹងប្រែងបន្តស្វែងរកយុត្តិធម៌នេះ ដល់ជនរងគ្រោះកម្ពុជារាប់លាននាក់ រហូតដល់អាណត្តិការងាររបស់ស្ថាប័នវិសាមញ្ញនេះត្រូវបានបញ្ចប់យ៉ាងពេញលេញទៅតាមផ្លូវច្បាប់ ។

**ដេវីដ សេហ្វហ្វើ**

# ប្រទេសកម្ពុជា ៖ ប្រវត្តិនៃអំពើហិង្សា

ភាជ អាង បានពុទ្ធាហានខ្មែរក្រហមវ័យចំណាស់ម្នាក់ និយាយថា ដើម្បីធ្វើឲ្យអ្នកទោសឆ្លើយ អ្នកទោសត្រូវបានចងព្យួរជើងឡើងលើនៅក្នុងបរិវេណវត្តនេះ ហើយជ្រមុជក្បាលចូលទៅក្នុងធុងទឹកយ៉ាងធំមួយ ។ វិធីបែបនេះត្រូវធ្វើរហូតដល់ជនរងគ្រោះ "ឆ្លើយសារភាព" ។ បន្ទាប់មក អ្នកទោសត្រូវបានយកទៅកម្ទេចចោល ។ ក្រោយពីរំដោះ សាកសពត្រូវបានរកឃើញនៅក្នុងរណ្ដៅជុំវិញវិហារ ។ ចំណែកឯខាងក្នុងវិញ សុះ ស៊ីម អាយុ ៦២ឆ្នាំ ដែលជាស្ត្រីវ័យចំណាស់ម្នាក់រស់នៅក្បែរវត្ត បានមានប្រសាសន៍ថា ជញ្ជាំងមានស្នាមប្រឡាក់ឈាមយ៉ាងក្រាស់ឃ្មឹក ហើយថា "ខ្លួនត្រូវចំណាយពេលដល់ទៅមួយអាទិត្យដើម្បីលាងសម្អាត" ។

ប្រសិនបើជញ្ជាំងនៅវត្តស្លួនពេជ្រអាចនិយាយបានវិញ ជញ្ជាំងទាំងនោះប្រាកដជាអាចប្រាប់ពីរឿងរ៉ាវដ៏ឃោរឃៅនេះ ។ អស់រយៈពេលបីឆ្នាំ វត្តស្លួនពេជ្រ ដែលស្ថិតនៅក្បែររាជធានីភ្នំពេញនៃប្រទេសកម្ពុជា ត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខនិងគុកមួយរបស់ខ្មែរក្រហម ។ វត្តស្លួនពេជ្រ គឺជាគុកមួយក្នុងចំណោមគុកប្រហែល២០០ ផ្សេងទៀតដែលត្រូវបានបង្កើតឡើងក្នុងរបបវាលពិឃាត ដែលគ្រប់គ្រងប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ឧបាសក អាង ដែលមានអាយុ ៦៧ ឆ្នាំ បានរំឭកថា ជាច្រើនឆ្នាំក្រោយមក "ឆ្អឹងនៅរាយប៉ាយ" ។ ឆ្អឹងមួយចំនួនត្រូវបានដាក់នៅក្នុងស្តូបធ្វើពីស៊ីម៉ងត៍ ដែលមានសភាពទ្រុឌទ្រោមនិង ក្រោយមកទៀត ត្រូវបានផ្លាស់ទៅដាក់ក្នុងស្តូបរំឭកវិញ្ញាណក្ខន្ធថ្មីមួយ កាលពីឆ្នាំ២០១០ ។ មន្ត្រីមូលដ្ឋានបានប៉ាន់ប្រមាណថា មានមនុស្សចំនួន ១.៥៦៧ នាក់ត្រូវបានសម្លាប់នៅវត្តស្លួនពេជ្រ ក្រោមរបបខ្មែរក្រហម ប៉ុន្តែរណ្ដៅសាកសពទាំងនោះមិនត្រូវបានជីកគាស់ទាំងអស់នោះទេ ។ ដូច្នេះចំនួនមនុស្សស្លាប់ពិតប្រាកដមិនទាន់បានដឹងនៅឡើយ ។

ស្រុកភាគច្រើននៅក្នុងប្រទេសកម្ពុជាមានមន្ទីរសន្តិបាលឬគុកដូចវត្តស្លួនពេជ្រដែរ ដែលមន្ទីរទាំងនោះអាចជាសាលារៀន វិហារ ឬអគាររដ្ឋាភិបាលជាដើម ។ នៅទីកន្លែងទាំងនោះ ប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៅតែបន្តយាយីគ្មានទីបញ្ចប់ដល់ជីវិតរស់នៅប្រចាំថ្ងៃ ។ នៅតំបន់មួយចំនួន ជនដៃដល់ និងជនរងគ្រោះរស់នៅក្បែរគ្នាដោយមិនទាន់ផ្សះផ្សានឹងគ្នានៅឡើយ ។ នៅក្នុងស្ថានភាពបែបនេះ ភាពរន្ធត់កាលពីអតីតកាលមិនត្រូវបាននិយាយញឹកញាប់ទេ ដោយធ្វើឲ្យយុវជនកម្ពុជាពិបាកយល់ពីភាពឆ្កួតលីលាដែលធ្លាប់បានរួតរឹតមកលើប្រទេសរបស់ខ្លួន ។ អាង បាននិយាយថា "មនុស្សជំនាន់ក្រោយមិនជឿលើអ្វីៗដែលបានកើតឡើងក្នុងសម័យខ្មែរក្រហមនោះទេ ។ ទោះបីជាខ្លួនឃើញលលាដ៍ក្បាល និងឆ្អឹងក៏ដោយ ក៏ខ្លួននៅតែមិនជឿ"

កាលពី៤០ឆ្នាំមុន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកក្នុងទីក្រុងភ្នំពេញ ហើយប្រកាសថា ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជារយៈពេលពីរពាន់ឆ្នាំឈានដល់ទីបញ្ចប់ ។ "១៧ មេសា មហារុងរឿង" ដែលត្រូវបានដាក់បញ្ចូលទៅក្នុងភ្លេងជាតិរបស់របបកម្ពុជាប្រជាធិបតេយ្យ គឺជាការចាប់ផ្ដើមនៃរបប ៣ ឆ្នាំ ៨ ខែ និង ២០ ថ្ងៃ ដែលប្រជាជនកម្ពុជាប្រមាណ ១.៧ លាននាក់បានបាត់បង់ជីវិត ។ ខ្មែរក្រហម និងមេដឹកនាំដ៏មហិមារបស់របបនេះគឺ ប៉ុល ពត បានព្យាយាមបង្កើតរបបកុម្មុយនីស្តពឹងផ្អែកលើវិស័យកសិកម្មដ៏បរិសុទ្ធអស្ចារ្យជាងគេមួយ ។ មួយប៉ប្រិចភ្នែកសោះ ចំណងសង្គមត្រូវបានកាត់ផ្ដាច់ និងទំនៀមទម្លាប់ដ៏ចំណាស់ត្រូវបានលុបបំបាត់ចោលគ្មានសល់ ។

នៅពេលដែលរបបនេះដួលរលំ ដោយសារតែការឈ្លានពានរបស់វៀតណាមកាលពីខែមករា ឆ្នាំ១៩៧៩ កម្ពុជាបាត់បង់បញ្ញវន្តស្ទើរតែទាំងអស់ ។ ទីក្រុង និងទីប្រជុំជនត្រូវធ្វើប្រជាភិវឌ្ឍស្ទើរតែពីចំណុចសូន្យឡើងវិញ ។ វាហាក់ដូចជាប្រទេសកម្ពុជាទាំងមូលត្រូវក្រឡាប់ចាក់ និងអន្ត្រនយ៉ាង គំហុក ដោយបន្សល់ទុកក្រុម ប៉ុល ពត និយម ដែលស៊ាំទៅនឹងគោលការណ៍ឥតមនុស្សធម៌ ដែលខ្លួន ពិបាកនឹងទទួលស្គាល់អំពីអ្វីដែលកើតឡើងចេញពីសេរី

ភាពណាស់ ។ រ៉ូបឺត ខាលម៉ៃយើល ជាអ្នកនិពន្ធនៃសៀវភៅថ្មីមួយមានចំណងជើងថា "នៅពេលពពកធ្លាក់ពីលើមេឃ" ឬ "When Clouds Fell from the Sky" ជាភាសាអង់គ្លេស បាននិយាយថា របបខ្មែរក្រហមបានជះឥទ្ធិពលខ្លាំងទៅលើប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្រោយៗមកទៀត ។ លោក រ៉ូបឺត បាននិយាយថា "មានអ្នកចេះដឹងតិចតួចណាស់ដែលនៅសេសសល់កាលពីឆ្នាំ ១៩៧៩ ដែលនៅពេលនោះរបបខ្មែរក្រហមបានដួលរលំ ។ ដូច្នេះ វាច្បាស់ណាស់ថាការបាត់បង់ធនធានមនុស្សយ៉ាងច្រើននេះបានប៉ះពាល់ខ្លាំងមកលើប្រទេសកម្ពុជា" ។ លោកបានបន្តទៀតថា "ដោយប្រកាន់ខ្ជាប់នូវទស្សនវិស័យស្ដីពីថាតើខ្លួនចង់ឃើញប្រទេសថ្មីនេះក្លាយទៅជាបែបណាមួយនោះ ខ្មែរក្រហមបានបំផ្លាញចក្ខុវិស័យផ្សេងៗទៀតដោយចេតនា" ។

វាជាការពិបាកក្នុងការនិយាយថាតើចក្ខុវិស័យមួយនេះអាចនឹងបង្កើត ប្រសិនបើខ្មែរក្រហមមិនបានឡើងកាន់អំណាច ។ ដូចជាចន្លោះខ្មៅងងឹតមួយ របបកម្ពុជាប្រជាធិបតេយ្យមានឥទ្ធិពលយ៉ាងខ្លាំងក្លា ដែលអាចធ្វើឲ្យអ្វីៗកើតមុន ឬក្រោយរបបនេះខុសប្លែកពីអ្វីៗបានកើតរួចហើយ ។ នៅពេលប្រៀបធៀបជាមួយនឹងសុបិនអាក្រក់មួយ កម្ពុជាមុនពេលបដិវត្តន៍ត្រូវបានមនុស្សជាច្រើនចាត់ទុកថាជា "យុគសម័យមាស" ។ សម្រាប់ប្រជាជនមួយចំនួន ដែលមានវ័យធំល្មមអាចនឹងចងចាំបាននិយាយថា ថ្វីបើកម្ពុជាមានបញ្ហាច្រើនក៏ដោយ កម្ពុជានៅក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់នរោមត្ដ សីហនុ គឺជារដ្ឋមួយមានម្ចាស់ការលើខ្លួនឯងរុងរឿង និងមានសន្តិភាព យ៉ាងហោចណាស់នៅ ក្នុងអំឡុងពេលនោះ ។ នៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៦០ ផលិតផលក្នុងស្រុកសរុបរបស់ប្រជាជនកម្ពុជាម្នាក់ៗមានកម្រិតប្រហាក់ប្រហែលទៅនឹងផលិតផលក្នុងស្រុកសរុបរបស់ប្រជាជនកូរ៉េខាងត្បូង ។ នៅពេលដែលនាយករដ្ឋមន្ត្រីសិង្ហបុរី លី ក្វាន់យូ ធ្វើទស្សនកិច្ចមកកាន់ទីក្រុងភ្នំពេញ នៅឆ្នាំ១៩៦៧ គាត់ស្ញើចសរសើរទីក្រុងដ៏ស្រស់បំព្រងមួយនេះ និងបាននិយាយទៅកាន់ព្រះអង្គម្ចាស់ នរោត្ដម សីហនុ ថា : "ខ្ញុំសង្ឃឹមនៅថ្ងៃណាមួយទីក្រុងរបស់ខ្ញុំនឹងដូចនេះដែរ" ។

អ្វីទាំងអស់នេះអាចយកមកវាយតម្លៃទៅលើអ្វីៗដែលកើតក្រោយមកទៀត ។ នៅក្រោមការ ដឹកនាំរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា ដែលគ្រប់គ្រងប្រទេសមួយនេះ ក្នុងបែបបទមួយ ឬបែបបទមួយទៀត ចាប់តាំងពីការដួលរលំរបស់ ប៉ុល ពត កម្ពុជាបានធ្វើដំណើរយ៉ាងវែងឆ្ងាយ ។ ហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សត្រូវបានជំនួស និងនៅក្នុងករណីខ្លះទៀតមានភាពហួសប្រមាណ ។ នៅទីបំផុត កេរដំណែលចុងក្រោយរបស់ខ្មែរក្រហមបានដួលរលំនៅចុងទសវត្សរ៍ឆ្នាំ១៩៩០ ហើយមេដឹកនាំនៅរស់រានមានជីវិតរបស់របបនេះនឹងត្រូវបានកាត់ទោសនៅតុលាការដែលមានការគាំទ្រដោយអង្គការសហប្រជាជាតិនៅទីក្រុងភ្នំពេញ ។ ជារួម ប្រទេសកម្ពុជាបានវិលត្រឡប់ទៅរកភាពប្រក្រតីវិញ ហើយសេដ្ឋកិច្ចនៅតែលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងអំឡុងពេលមានស្ថិរភាពនយោបាយដែលពុំធ្លាប់មានពីមុនមក ។

**(នៅមានត)**

**សេីបាស្ទីន ស្ត្រេងចូ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.dccam.org*

# មានទោសព្រោះអ្វី?

***(តពីលេខមុន)***

*- បាទ! ខ្ញុំដឹងហើយ គឺបងតែងតែប្រាប់ប្អូនៗទាំងអស់ថា "ស្មៀមជាជាងស្រដី" ខ្ញុំចាំគ្រប់ពេល ។ តែពេលនេះខ្ញុំសួរបងទេ តើមិនមែនសួរប្រធានសង្កាត់ឯណា?*

*- រឿងនេះ បើតាមបងមើលឃើញថា វាបែងចែកវណ្ណៈពិតមែន តែបើយើងពិនិត្យឲ្យជ្រៅទៅ យើងនឹងដឹងថា អង្គការថ្នាក់លើដែលហៅយើងទាំងអស់គ្នាថា ប្រជាជនថ្មីនោះគឺត្រឹមត្រូវហើយ គឺថ្មី ត្រង់ថា យើងបានទទួលមាគ៌ានយោបាយរបស់បក្សក្រោយគេ ប៉ុន្តែដល់អ្នកទទួលមកអនុវត្ត មិនយល់ន័យរបស់ពាក្យថា ថ្មីឬចាស់នេះ ក៏បែងចែកឲ្យដាច់ឆ្ងាយពីគ្នាទៅវិញ រហូតដល់ហ៊ានហៅយើងថា ជាពួកកម្ទេលចក្រពត្តិទៀតផង ហើយផ្សំនឹងពួកយុវជន នារីដែលទទួលឥទ្ធិពលនយោបាយជ្រុលពេក ក៏បែរជាស្អប់យើងទៅ ដោយភ្លេចគិតថា ទាំងសាច់ ទាំងឈាម ទាំងសសៃ ឆ្អឹង ក៏ជាខ្មែរដូចតែគ្នាសោះទេ ។ ហើយម្យ៉ាងទៀត ដោយការជឿជាក់ងប់ងល់ពេកទៅ មានអ្នកខ្លះហ៊ាននិយាយថា ឪពុកម្ដាយរបស់ខ្លួនក៏ជាខ្មាំងដែរ ឲ្យតែធ្វើខុសឬប្រឆាំងនឹងបដិវត្តន៍របស់ខ្លួន ។ នេះជាការយល់ឃើញរបស់បងទេ ហើយឯងកុំចាប់អារម្មណ៍ពីរឿងគេស្អប់ គេស្រឡាញ់ទៀតទៅ ខំតែធ្វើការទៅបានហើយ ។*

*- បាទបង!*

*- ឈប់និយាយទៅ ព្រោះជិតដល់ភូមិហើយ ។*

*យប់នេះភ្លៀងរលឹមស្រិចៗ ដំណក់ទឹកភ្លៀងស្រក់លើស្លឹកចេកនៅក្បែរផ្ទះ ផ្ដល់នូវភាពត្រជាក់ស្រឹប បងប្អូនដែលនៅក្នុងផ្ទះរួមនេះនាំគ្នានិទ្រាយ៉ាងសុខសាន្ត ខ្ញុំដេកមិនលក់ទេ ព្រោះស្នូបង្រ្កានដែល អាប៉ក់ ធ្វើហើយចងនៅមាត់បង្អួចញ៉ិកៗ អង្រួនចិត្តខ្ញុំឲ្យនឹកស្រណោះវាខ្លាំងណាស់ ខ្ញុំនឹកសរសើរនូវទឹកចិត្តជាយុវជនរបស់វា ទោះជាវាឈឺស្កាំងស្កមពិបាកក្នុងខ្លួនវាប៉ុន្មាន ក៏វាមិនដែលត្អូញថ្ងូរ ឲ្យអ្នកណាដឹងថា ខ្លួនវាមិនអាចរស់បាន វាខំប្រមូលកម្លាំងដែលនៅសេសសល់បន្តិចបន្តួច តាំងអារម្មណ៍និយាយដាស់តឿនខ្ញុំទាំងដង្ហើមដង្ហក់ ។ ខ្ញុំមិននឹកស្មានថា ពាក្យដាស់តឿនរបស់វា ក្លាយជាពាក្យបណ្ដាំចុងក្រោយបង្អស់របស់វាសោះ ។ ខ្ញុំយកក្រមាដែលមានស្នាមថ្នេរដេរប៉ះរបស់វាមកដណ្ដប់ ខ្ញុំនឹកឃើញស្នាមញញឹមជាចុងក្រោយរបស់វានៅពេលខ្ញុំចេញទៅធ្វើការនៅព្រឹកមិញ ។ ខ្ញុំស្រណោះចង្រ្កងដង្កៀបក្ដាមដែលវាធ្វើកាលវានៅជា ហើយវាអួតប្រាប់ខ្ញុំថា នេះជាគន្រ្ទឹធម្មជាតិរបស់វា និងអ្វីៗជាច្រើនទៀតដែលវាបន្សល់ទុក ។*

*២ខែកន្លងទៅ បងប៉េង ដែលជាទីពឹងផ្អែកនៅក្នុងគ្រួសារយុវជននេះ និងអាប៉ែន ត្រូវបងប្អូន គាត់មកសុំធានាយកទៅនៅស្រុកកំណើតវិញ ។ ខ្ញុំនៅកណ្ដោចកណ្ដែងកណ្ដាលព្យុះភ្លៀងម្នាក់ឯង អាលាស់ វាមកដេកជាមួយខ្ញុំ ធ្វើការជាមួយខ្ញុំ តែវាមានបងប្អូននៅជាមួយគ្រាន់នឹងទីពឹងគ្រាន់បើជាងខ្ញុំ ។*

*ចាប់តាំងពីអាប៉ក់វាស្លាប់ ហើយបងប៉េង និងអាប៉ែន បានចាកចេញទៅ ខ្ញុំពីរនាក់ អាលាស់ ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការនៅសិប្បកម្មចាក់ចានឆ្នាំង និងផាលភ្ជួររាស់ស្រែនៅកន្លែងធ្វើការងារថ្មីនេះ មើលទៅវាធ្ងន់គ្រាន់បើបន្តិច ព្រោះធ្វើការនៅក្នុងម្លប់ តែរីតតែយ៉ាប់យ៉ឺនជាងនៅចម្ការពោត ស្រូវ ព្រោះពីពេលព្រឹកទល់ល្ងាចខ្ញុំធាក់កង់បង្វិលដិតរំលាយដែកគ្មានឈប់ ម្នាក់ៗក្រិនគូថដូចស្វាទៅហើយ ខ្ញុំធ្វើការនៅក្នុងសិប្បកម្មនេះបានប្រហែល១ខែ ស្រាប់តែឪពុកខ្ញុំមកសុំយកមករស់នៅស្រុកកំណើតវិញ ។ ខ្ញុំមិនចង់ឃ្លាតឆ្ងាយពីផ្នូរ អាប៉ក់ ឡើយ ព្រោះវាជាមិត្តកម្សត់កម្រ តាំងពីចេញពីតាកែវមកម្ល៉េះ តែដោយនឹកអាណិតឪពុកដែលគាត់ខំដើរកាត់ស្រុកកាត់ព្រៃមករកខ្ញុំទៅហើយ ខ្ញុំក៏សម្រេចចិត្តទៅតាមបំណងរបស់គាត់ ទាំងអាល័យផ្នូរ អាប៉ក់ ក្រៃលែង ។ ខ្ញុំទៅលាផ្នូរ អាប៉ក់ ជាចុងក្រោយៈ*

*- អាប៉ក់ អញលាឯងសិនហើយ! ពីពេលនេះទៅអញលែងបានមកបោចវល្លិ៍ បោចស្មៅ ថែ ផ្នូររបស់ឯងទៀតហើយ ។ តែអញសង្ឃឹមថានឹងមានថ្ងៃដែលយើងរង់ចាំដូចពាក្យឯងនិយាយនោះបានមកគាស់យកឆ្អឹងរបស់ឯងទៅធ្វើបុណ្យថ្ងៃណាមួយមិនខានឡើយ ។ សូមឯងនៅទីនេះសិនចុះ ហើយឲ្យបានសុខ!*

មកដល់ស្រុកកំណើត ខ្ញុំសង្ឃឹមថានឹងបាននៅរួមរស់ជាមួយក្រុមគ្រួសារខ្ញុំ នៅក្នុងឋានៈជា ឧបករណ៍ដាច់ថ្លៃរបស់អង្គការ ។ ខ្ញុំក្តី គ្រួសារខ្ញុំក្តី បងប្អូនដែលជាពលរដ្ឋខ្មែរទាំងអស់ក្តី សុទ្ធតែបានបំពេញតួនាទីនៅក្នុងទឹកភក់ ហាលភ្លៀងផ្គររន្ទះ ហាលខ្យល់ ហាលកំដៅថ្ងៃ ហាលព្យុះរងាញ័រញាក់ យ៉ាងណាក៏គ្មានត្អូញត្អែរ ប្រឹងធ្វើការដើម្បីដូរយកបបរមួយវែកតែប៉ុណ្ណោះ ។ រដូវច្រូតកាត់បានបញ្ចប់ អង្គការបានដាក់ចុះនូវផែនការថ្មីមកឲ្យប្រជាពលករទៀត ។ ពេលនេះ អង្គការប្រមូលក្រុមយុវជនយុវនារី រៀបចំចាត់តាំងជាកងចល័ត ហើយរស់នៅដាច់ដោយឡែកពីភូមិ ហើយអង្គការបង្កើតឲ្យមានប្រធានពួក ប្រធានក្រុម ប្រធានក-ខ-គ-ឃ រហូតឡើងទៅដើម្បីគ្រប់គ្រងកម្លាំង ឲ្យបានណែននៅក្នុងកណ្តាប់ដៃដ៏ខ្ញុំក្រិដ្ឋរបស់ខ្លួន ។ ភារកិច្ចថ្មីៗមាន លើកភ្លឺស្រែ ជីកប្រឡាយ ធ្វើអាងទឹក ។

នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ១៩៧៧ ហើយក៏ជាឆ្នាំអង្គការធ្វើបដិវត្តន៍វប្បធម៌ដែរ នៅវេលា ម៉ោង៦.៣០ នាទីល្ងាច សន្តិសុខស្រុកត្បូងឃ្មុំ មកចាប់ខ្ញុំយកទៅដាក់គុកដោយមិនដឹងមូលហេតុពីទោសកំហុសឡើយ ។

-មិត្តសូភា នៅទេ? (ខ្ញុំសូមប្រើឈ្មោះខ្ញុំជាសិស្សសិន)

ខ្ញុំក្រឡេកទៅរកម្ចាស់សំណួរ ឃើញបង ណូយ ជាប្រធាន "ឃ" កងចល័តយុវជន តើមានការអីទៅ បានជាគាត់មករកខ្ញុំដោយខ្លួនឯងអ៊ីចឹង?

- ប្រធាន"ខ"ខ្ញុំឈ្មោះ ទិត ឆ្លើយតប

- បាទ មិត្តភា នៅទីនេះទេ មានការអីដែរបង?

- ស្នើសុំមិត្តភា ឲ្យទៅជួយតខ្សែភ្លើងមួយភ្លែត កាលណោះអង្គការធ្វើទិវាពលកម្មអន្តរជាតិ ០១ ឧសភាដែរ

ខ្ញុំឆ្លើយតបទៅវិញ ដោយមិនទាន់ពាក់អាវផងថាៈ

-ខ្ញុំមិនចេះតភ្លើងទេបង!

-មិនអីទេ គ្រាន់តែជួយកាន់ខ្សែភ្លើង ទៅបានហើយមកឆាប់ពាក់អាវមក!

ខ្ញុំពាក់អាវហើយក៏ដើរចេញតាម បងណូយ មកកាន់មន្ទីរ "ឃ" កងចល័ត មកដល់ភ្លាម ខ្ញុំ ឃើញក្រុមសន្តិសុខស្រុក៤នាក់ប្រដាប់ដោយកាំភ្លើងគ្រប់គ្នា និងម៉ូតូពីរគ្រឿង បានស្ទុះមកភ្ជង់កាំភ្លើងតម្រង់មករកខ្ញុំគ្រប់ទិសទាំង៤ ខ្ញុំស្រឡាំងកាំង ព្រោះមិនដឹងថា មានរឿងអ្វីឡើយ ។

-លើកដៃឡើង ហើយនៅឲ្យស្ងៀម!

ខ្ញុំមិនលើកដៃទេ តែខ្ញុំឈរយ៉ាងស្ងៀមស្ងាត់ ។

-មិត្តឯងចូលទៅចងដៃទៅ!

ខ្ញុំឮតែពាក្យថា "ចង" ខ្ញុំស្ទើរតែទន់ជង្គង់ដួល ព្រោះពេលបន្តិចទៀតនេះ ខ្ញុំនឹងត្រូវយកទៅដាក់គុកហើយ ។ សន្តិសុខម្នាក់ចូលមកចងដៃខ្ញុំទៅក្រោយ ហើយចងមុខខ្ញុំទៀត រួចបណ្តើរខ្ញុំឲ្យឡើងជិះម៉ូតូមួយគ្រឿង ដែលមានគ្នាម្នាក់ជាអ្នកបើកបរ ហើយម្នាក់ទៀត អង្គុយជិះនៅខាងក្រោយខ្ញុំ។ ចំណែកគ្នាពីរនាក់ទៀតជិះម៉ូតូតាមពីក្រោយ ។ ខ្ញុំមិនដឹងថា សន្តិសុខទាំងនេះនាំខ្ញុំទៅទីកន្លែងណាឡើយ ព្រោះពេលនោះយប់ងងឹតទៅហើយ ហើយគេចងមុខខ្ញុំមិនឲ្យមើលអ្វីឃើញទៀត ។ មួយសន្ទុះធំ ទើបម៉ូតូបន្ថន់ល្បឿនហើយឈប់ ម្នាក់ដែលជិះពីក្រោយខ្ញុំ លោតចុះហើយទាញខ្ញុំទម្លាក់ពីលើម៉ូតូ ដួលផ្កាប់មុខនឹងដី ខ្ញុំប្រឹងក្រោក តែក្រោកមិនរួច ព្រោះដៃត្រូវជាប់ចំណង សន្តិសុខចាប់ទាញកអាវខ្ញុំពីក្រោយលើកឡើងឲ្យខ្ញុំក្រោកឈរ ហើយក៏ស្រាយមុខខ្ញុំចេញ ខ្ញុំក្រឡេកមើលទៅលើរោងដែលនៅជុំវិញខ្លួនខ្ញុំ ឃើញសុទ្ធតែអ្នកមានទោសជាច្រើន ជើងជាប់ខ្នោះ ភ្នែកអ្នកទាំងអស់គ្នាសម្លឹងមករកខ្ញុំ ដែលជាអ្នកទោសថ្មីទើបមកដល់ ។

សន្តិសុខបណ្តើរខ្ញុំឲ្យឡើងទៅលើរោងមួយខ្ពស់ពីដីត្រឹមចង្កេះ ហើយយកញញួរប៉ុនកដើងវ៉ៃស្នៀតខ្នោះចេញ រួចទាញជើងខ្ញុំបញ្ចូលក្នុងរន្ធខ្នោះ ហើយវាយស្នៀតបញ្ចូលវិញយ៉ាងណែន រួចហើយក៏ស្រាយចំណងខ្ញុំចេញ រួចស្តីថាៈ

-អាឯងដេកគិតទៅ ថាឯងបានធ្វើអ្វីខ្លះខុសនឹងមាគ៌ាអង្គការ?

សន្តិសុខទាំងនោះចេញទៅកន្លែងបាត់អស់ នៅសល់តែអ្នកទោសជើងជាប់ខ្នោះជាមួយគ្នាប៉ុណ្ណោះ ។ អ្នកទោសម្នាក់ដែលនៅជាប់ខ្ញុំ គាត់មានអាយុប្រមាណ៤០ឆ្នាំ សួរមកខ្ញុំដោយសំឡេងតិចៗ

-នែ៎! ក្មួយ តើមានរឿងអ្វីដែរ បានជាត្រូវចាប់មកទីនេះ?

-បាទ ពូ! ខ្ញុំមិនដឹងថា មានរឿងអីដែរ ។

បុរសទណ្ឌិតម្នាក់ដែលជាប់ខ្នោះទល់មុខខ្ញុំសួរម្តង

-ចុះក្មួយជាប្រជាជនឬធ្វើអ្វីដែរ?

-បាទ! ខ្ញុំជាកងចល័តសង្កាត់ស្ទួង កំពុងជីកអាងទឹកស្រាប់តែអង្គការចាប់មកតែម្តង ។

-ចុះក្មួយជាអ្នកជម្លៀស ឬក៏អ្នកមូលដ្ឋាន?

-បាទ! ខ្ញុំជាអ្នកជម្លៀសឆ្នាំ១៩៧៥ មកពីភ្នំពេញ

-ចុះក្មួយមានធ្លាប់ធ្វើទាហាន ឬក៏ប៉ូលីសដែរទេ កាលនៅភ្នំពេញនោះ?

-អត់ទេពូ! ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ ហើយក៏ឈប់រៀនទៅធ្វើជាកម្មករដុះថ្ម ឬធាក់ស៊ីក្លូ ។

-ចុះពួកពូៗមានរឿងអីដែរ?

-ហ៊ឺ...គ្មានរឿងអីធំដុំទេក្មួយអើយ ស្រាប់តែអង្គការចាប់មក ហើយចោទថា សុទ្ធតែពាក់ស័ក្តិ៥ ពូមិនដែលស្គាល់ស័ក្តិនោះយ៉ាងដូចម្តេចផង បើជីវិតពូនៅតែក្នុងស្រែចម្ការរហូតហ្នឹង ។ ណ្ហើយ ដេកទៅក្មួយ កុំមាត់ប្រយ័ត្នសន្តិសុខឮ នឹងវាយធ្វើបាបឥឡូវហ្នឹងហើយ ។

ភាពស្ងប់ស្ងាត់ក៏កើតមានឡើងនៅក្នុងមន្ទីរសន្តិសុខស្រុកត្បូងឃ្មុំ ។ យប់នេះ ខ្ញុំដេកមិនលក់ទេ ព្រោះរកនឹកមើលពីទោសកំហុសរបស់ខ្លួន ហើយណាមួយនឹកទៅឪពុកម្តាយ បើគាត់ដឹងច្បាស់ជាកើតទុក្ខរីងរៃមិនខានឡើយ ណាមួយសត្វសង្កើច និងមូសវាព្រួតគ្នាខាំខ្ញុំយ៉ាងខ្លាំង ព្រោះខ្ញុំជាមនុស្សចំណូល ថ្មីវាប្លែកក្លិន ។

ពន្លឺព្រះច័ន្ទ បានចាំងចូលតាមប្រហោងដំបូលរហែកធ្លុះធ្លាយ ហើយដុំរំនឹងបន្ទប់ខ្ញុំនៅខាងចុងគេ ដែលមានជញ្ជាំងបាំងធាងដូង ដែលពុកជ្រុះស្លឹកអស់សល់តែធាងប្រហោងរខេករខាក ធ្វើឲ្យបន្ទប់នេះ មានពន្លឺច្បាស់បន្តិច ។ ខ្ញុំឃើញអ្នកទោសនៅក្នុងបន្ទប់នោះមាន៣០នាក់ សុទ្ធតែប្រុសទាំងអស់ហើយ មានរាងកាយស្គមកំប្រឹងដូចៗគ្នា ក្បាល និងជង្គង់ធំត្រមែង សាច់ស្បែកស្វាំងឆ្អឹងជំនីរអណ្តែតឡើង ដូចជីអាចម៌បំណាស់ ដែលគេទើបនឹងភ្ជួររួចអីចឹង ពោះផតស្មើរដល់ឆ្អឹងខ្នង ដេកស្ពុកស្ពឹងហាក់គ្មានកន្លល់ពីជីវិតខ្លួនឡើយ ចង់យកទៅសម្លាប់ពេលណា ថ្ងៃណាក៏មិនខ្វល់ ព្រោះជីវិតយើងទាំងអស់ជាអ្នកទោសនេះ ដូចសត្វជ្រូកនៅក្នុងទ្រុងអ្នកកាប់សាច់លក់ទៅហើយនោះ ។

នៅពេលជិតភ្លឺសង្កើច និងមូសប្រហែលវាបឺតឈាម ខ្ញុំឆ្អែតហល់អស់ហើយ បានជាមិនសូវមានសកម្មភាពខ្លាំងក្លាដូចពីក្បាលព្រលប់ ខ្ញុំក៏សម្ងំដេកលក់ទៅ ។ ស្រាប់តែព្រឹកព្រាងៗឡើង សូរជួងដែកយ៉ាំងឡាងបន្លឺឡើងម៉ឺងៗ ស្ងាត់បន្តិចស្រាប់តែឮសំឡេងអ្នកទោសរាប់លេខរៀងឮល្មើយៗពី បន្ទប់ដើមគេបង្អស់ ។ អ្នកទោសរាប់លេខកើនឡើងៗរៀងៗ មកជិតដល់បន្ទប់ខ្ញុំ ពូម្នាក់ដែលនៅជាប់ខ្ញុំគាត់ប្រាប់ខ្ញុំថាៈ

-នែ៎ក្មួយ! ឯងចាំរាប់បន្តពីពូណា កុំឲ្យខុសប្រយ័ត្នគេវាយ ។

ខ្ញុំក្រឡេកទៅខាងក្រៅ ឃើញសន្តិសុខពីរនាក់ស្ពាយកាំភ្លើងជាប់ស្មា ដៃកាន់រំពាត់ប៉ុនមេដៃ ម្នាក់មួយៗកំពុងឈរពិនិត្យលេខរៀងគ្រប់ៗបន្ទប់ ។ លេខរៀងមកដល់ខ្ញុំត្រឹមទី២៣០ ហើយក៏បានបន្ត ឆ្លងទៅបន្ទប់ដែលនៅជាប់ខ្ញុំតៗ ទៅរហូតដល់ចុងគេបង្អស់ ។ សន្តិសុខពីរនាក់នេះ ត្រួតពិនិត្យលេខរៀង និងចំនួនមនុស្សត្រឹមត្រូវហើយក៏ទៅកន្លែងដើមខ្លួនវិញ ។

ខ្ញុំសួរពូដែលនៅជាប់ខ្ញុំ

-ពូ! លេខរៀងខ្ញុំនេះ នៅទៀងទាត់ត្រឹមហ្នឹងឬ?

-មិនទៀងទេ! ជួនឡើងលើសហ្នឹង ជួនធ្លាក់ចុះតិចជាងហ្នឹង គឺវាអាស្រ័យតែអង្គការចាប់អ្នកថ្មីចូលទៀត ឬក៏យកអ្នកចាស់ចេញតែប៉ុណ្ណោះ ។

បន្ទាប់មក ខ្ញុំឃើញសន្តិសុខបណ្តើរអ្នកទោសម្តងម្តៅទៅសាមសិបនាក់ ដែលមានចងត្រឹមកន្ទាក់ដៃទៅក្រោយខ្នងតែអត់មានចងបិទមុខទេ ហើយអ្នកទាំងនោះយួរបំពង់ឫស្សីម្នាក់ពីរគ្រប់គ្នា ។

-ពូ! តើសន្តិសុខយកអ្នកទោសនេះទៅណា?

-សន្តិសុខឲ្យយកទឹកនោមទៅចាក់ចោល ហើយបត់ដៃបត់ជើងនៅពេលព្រឹក និងដងទឹកទុកផឹក ខ្លួនយើងផង ។ តែបន្តិចទៀតគង់តែមកដល់បន្ទប់យើងទេក្មួយឯងចាំមើលទៅ ។

សន្តិសុខបញ្ចេញអ្នកទោសម្តងមួយបន្ទប់ឲ្យទៅបត់ជើងលុះត្រឡប់មកវិញដាក់ខ្នោះរួចរាល់ ហើយទើបបញ្ចេញមួយបន្ទប់បន្ទាប់ទៀត ។ មិនយូរប៉ុន្មាន ក៏វិលមកដល់បន្ទប់ខ្ញុំ ។ សន្តិសុខម្នាក់បានកាន់ញញួរមកឈរនៅមុខបន្ទប់ខ្ញុំ អ្នកទាំងអស់បែរខ្នងបន្តគ្នាដើម្បីចងដៃគ្នាម្នាក់ម្តងៗ ចំណែកអ្នកទោសនៅដើមគេ គឺសន្តិសុខកាន់ញញួរជាអ្នកចងឲ្យ ខ្ញុំអត់មានខ្សែចងដៃទេ សន្តិសុខយកក្រមាខ្ញុំមកចងជំនួសខ្សែ តែអត់មានរុំមុខទេ ។ រួចហើយសន្តិសុខលើក

ញញួរដំស្នៀតខ្នោះបញ្ចេញ ហើយលើកបង្ហើបខ្នោះឲ្យអ្នកទោសដកជើងចេញ អ្នកទោសបានឈោងយកបំពង់ទឹកនោម និងបំពង់ទឹកផឹកដែលព្យួរនៅចុងជើងទាំងដៃជាប់ចំណង ហើយក្រោកឈរទើបចុះមកឈរតម្រង់ជួរនៅមុខរោងរួចហើយរាប់លេខរៀងតាមបន្ទប់អ្នកនៅឈរមុខរាប់មុន ហើយបន្តៗគ្នារហូតអ្នកនៅចុងក្រោយស្រែក ប្រាប់ចំនួនលេខសរុបហើយស្រែកប្រាប់ថា “អស់” ។ លុះគ្រប់គ្នាហើយទើបសន្តិសុខបញ្ជាឲ្យដើរទៅអណ្តូងទឹក ទុកបំពង់មួយនៅទីនោះសម្រាប់ដងទឹកចាក់ទុកឲ្យ ចំណែកបំពង់មួយទៀត ដែលដាក់ទឹកនោម សន្តិសុខឲ្យយកទៅចាក់នៅក្នុងបង្គន់ ហើយអង្គុយបត់ជើងទាំងអស់គ្នាទៅ តែត្រូវប្រយ័ត្នរអិលជើងធ្លាក់ក្នុងរណ្តៅបង្គន់ ព្រោះគ្មានបង្កាន់ដៃសម្រាប់តោងទប់ខ្លួនទេ ។ បត់ជើងរួចហើយ ទើបក្រោកដើរមកអណ្តូងទឹកយកបំពង់មួយទៀតដែលមានទឹកពេញស្រាប់ ។ ខ្ញុំបានបំពង់ពីរដូចគេដែរ ។ មកដល់មុខបន្ទប់សន្តិសុខឲ្យតម្រង់ជួររាប់លេខដូចពេលចេញទៅដែរ ទើបសន្តិសុខបញ្ជាឲ្យឡើងទៅលើរោងវិញ យកបំពង់ព្យួរនៅកន្លែងដើមរួចហើយលើកជើងដាក់ចូលខ្នោះវិញ ទើបដំស្នៀតខ្នោះបញ្ចូលវិញយ៉ាងណែនរួចហើយស្រាយខ្សែចងដៃ អ្នកដែលនៅដើមគេចេញ ហើយអ្នកនៅដើមគេនោះស្រាយបន្តបន្ទាប់មកដូចពេលចងអ៊ីចឹងដែរ ។

មួយសន្ទុះក្រោយមកទៀត ខ្ញុំឃើញសន្តិសុខពីរនាក់ដើរសំដៅមកបន្ទប់ខ្ញុំ ម្នាក់មានកាន់សសៃក្រចៅមួយដុំមកជាមួយផង ។

-នែ៎! អានេះឯងយកក្រចៅនេះវេញធ្វើខ្សែទៅ សន្តិសុខប្រើពាក្យសុទ្ធតែអានេះ អានោះ ឬក៏ហៅឈ្មោះតែម្តង ទោះអ្នកទោសនោះមានវ័យចាស់ក៏ដោយ ។

ខ្ញុំទទួលយកដុំក្រចៅ ហើយឆ្ងល់ថា តើសន្តិសុខឲ្យវេញខ្សែអ្វីទៅ? ហើយបានបញ្ចេញអ្នកទោស ខ្លះដែលនៅក្នុងបន្ទប់ខ្ញុំឲ្យទៅធ្វើការ ។ ពូនៅជិតខ្ញុំ និងបងប្រុសម្នាក់នៅជាប់ខ្ញុំដែរនោះ និងអ្នកទោសប្រាំពីរនាក់ផ្សេងទៀត សន្តិសុខអត់បញ្ចេញឲ្យទៅធ្វើការទេ គឺនៅដាក់ខ្នោះជើងដដែល ។ អ្នកទោសប្រាំពីរនាក់នេះ សុទ្ធតែប្រធានសង្កាត់ ប្រធានភូមិ ប្រធានគ ប្រធានឃ ដែលអង្គការចាប់មក ហើយម្នាក់ៗសុទ្ធតែមានស័ក្តិដែលអង្គការពាក់ឲ្យគ្រប់ៗគ្នាដែរ ព្រោះវាជាឆ្នាំដែលអង្គការធ្វើបដិវត្តន៍វប្បធម៌ស្អីនោះ ។

-ពូ! តើសន្តិសុខឲ្យខ្ញុំវេញខ្សែអីទៅ?

-សន្តិសុខឲ្យវេញខ្សែសម្រាប់ចងដៃខ្លួនឯងហ្នឹងណា

គាត់និយាយផង ព្រមទាំងលើកខ្សែមកបង្ហាញខ្ញុំផង

-ក្លួយត្រូវវេញឲ្យធំដូចគេអ៊ីចឹង ហើយត្រូវកោសសសៃក្រចៅនេះឲ្យទន់ ទើបចងទៅវាមិនសូវឈឺដៃ ។

ខ្ញុំអង្គុយវេញខ្សែទាំងជើងម្ខាងជាប់ខ្នោះ ហើយពូ និងបងថាគាត់ជួយធ្វើផង ។ ស្រាប់តែទិដ្ឋភាពគួរឲ្យរន្ធត់កើតមានឡើងនៅមុខរោងខ្ញុំ ។

-ពូ! តើគេចងដៃ និងចងរុំមុខអ្នកទោសនោះយកទៅណា?

-គាត់និយាយឆ្លើយសំណួរខ្ញុំ ដោយគាត់មិនទាំងងាកទៅមើលទិដ្ឋភាពនោះផង ។

-ជូនកាលសន្តិសុខយកទៅសួរចម្លើយ ជូនកាលសន្តិសុខយក បើអត់ឃើញសន្តិសុខបណ្តើរមកវិញទេនោះ ។

-តើទិដ្ឋភាពទាំងនេះមានរាល់ថ្ងៃឬទេពូ?

-ចាំតែមើលទៅនឹងបានឃើញហើយ!

ថ្ងៃនេះ សន្តិសុខមិនហៅខ្ញុំទៅសួរចម្លើយទេ គឺគ្រាន់តែឲ្យខ្ញុំវេញខ្សែតែប៉ុណ្ណោះ ។ ខ្ញុំអង្គុយវេញខ្សែ ហើយភ្នែកលួចសម្លឹងមើលទៅខាងក្រៅ ឃើញសន្តិសុខឈរយាមបណ្តាក់នៅតាមតូបតូចៗ ដែលសង់ជាប់របងលួសបន្លាដោយប្រុងប្រយ័ត្នបំផុត ម្នាក់ៗមានទឹកមុខកាចសាហាវណាស់ គ្មានយោគយល់ និងមេត្តាដល់មនុស្សដែលបាត់បង់សេរីភាពនេះឡើយ ។ ចរិយារបស់សន្តិសុខទាំងនោះដូចជាសត្វខ្លាកំណាចរង់ចាំលោតសង្គ្រប់កូនម្រឹគអ៊ីចឹង ។

នៅម៉ោងប្រមាណ១១ថ្ងៃត្រង់ ខ្ញុំឃើញរទេះរុញឆ្នាំងបបរដែលមានចានស្ពាបព្រាយ៉ាងច្រើន មកឈប់នៅមុខរោងខ្ញុំ ។ សន្តិសុខឡើងទៅពិនិត្យមើលចំនួនមនុស្សដែលគេបញ្ចេញទៅធ្វើការ និងមនុស្សដែលនៅជាប់ខ្នោះ រួចហើយគេចុះមកវិញដួសបបរហុចបន្តគ្នាមក ចំពោះអ្នកនៅជាប់ខ្នោះ សន្តិសុខឲ្យបបរតែមួយចានបាយទាបដែលយើងញុំារាល់ថ្ងៃនេះ តែអត់បានចេញទេ បើគិតជាចំនួនស្លាបព្រាវិញតែដប់ទៅដប់ប្រាំស្លាបព្រាប៉ុណ្ណោះ និងសម្លស្ងោរដើមចេកមួយកូនចានចង្កឹះ ចំណែក អ្នកចេញធ្វើពលកម្ម សន្តិសុខឲ្យបបរមួយចានដូចគ្នាហ្នឹងដែរ តែដាក់ពេញចាន និងសម្លមួយកូនចាន ដូចគ្នា ។ រីឯចានស្លាបព្រាវិញ គឺកខ្វក់ជាងចានដាក់បាយឲ្យឆ្មាទៅទៀត ។

ពូនៅជាប់ខ្ញុំ និងបងថា ហើយនឹងអ្នកនៅជាប់ខ្នោះទាំងអស់

នាំគ្នាហូបយ៉ាងប្រញឹបប្រញាប់ដោយក្តីស្រេកឃ្លានបំផុត ។ អ្នកទាំងអស់គ្នាហុតបបរ និងសម្លទាល់តែអស់ហើយ ស្ទើរនឹងលិទ្ធចានឲ្យស្ងួតទៀត ព្រោះមិនឆ្អែត ។

ចំណែកខ្ញុំ ហូបមិនរួចឡើយ ព្រោះនឹកអាណោចអាធ័មខ្លួនឯងមិនគួរណាមកជាប់នៅទីនេះដោយ មិនដឹងមានរឿងអ្វីផង ណាមួយនឹកដល់ម្តាយមិនដឹងថា នៅពេលនេះគាត់នឹងត្រូវខ្លោចផ្សាអាណិតកូន យ៉ាងណាទេ ។ ខ្ញុំឲ្យបបរខ្ញុំទៅពូ និងបងថា ។

- ពូ បង យកបបរខ្ញុំទៅហូបចុះ ខ្ញុំមិនឃ្លានទេ

- ទេៗ មិនយកទេ ទោះក្មួយឃ្លាន មិនឃ្លានក៏ខំប្រឹងលេបទៅ ព្រោះបើដល់ពេលឃ្លាន ក្មួយគ្មានអ្វីហូបទេ ចំណែកអ្នកនៅទីនេះឃ្លានណាស់ តែក៏មិនព្រមទទួលយកដែរ ព្រោះអ្នកដែលនៅក្នុងបន្ទប់យើងនេះមានចិត្តតែមួយ គឺមិនព្រមឆ្អែតពោះតែឯង ហើយទុកឲ្យក្មួយឃ្លានខ្លោចផ្សាក្រហាយពោះនោះទេ ។ ដូចក្មួយឃើញស្រាប់ហើយ នូវបបររបស់អ្នកចេញទៅធ្វើការ គឺយើងទាំងអស់គ្នាមិនហ៊ានប៉ះពាល់លួចស៊ីតែឯងនោះទេ ព្រោះនេះជាបបររបស់អ្នកទោសក្នុងម្នាក់ៗសម្រាប់បន្តជីវិតឲ្យរស់ មួយពេលៗដូចៗគ្នា ។

បន្ទាប់មក អ្នកទោសដែលចេញទៅធ្វើការពីព្រឹកនោះក៏ត្រឡប់មកវិញ និងបានផ្ងូតទឹកគ្រប់ៗគ្នា ហើយមកឈរតម្រៀបជួរនៅពីមុខបន្ទប់ រាប់លេខរួចហើយ ទើបសន្តិសុខបញ្ជាឲ្យឡើងលើរោង ហើយមកកាន់កន្លែងរៀងៗខ្លួន សន្តិសុខបានដាក់ខ្នោះជើងរួចរាល់ហើយ ក៏ចាប់ផ្តើមហូបបបរដែលគេដួស ទុកដាក់ឲ្យតាមកន្លែងរួចជាស្រេច ។

នៅម៉ោងមួយរសៀលទើបសន្តិសុខមកបញ្ចេញឲ្យទៅធ្វើការទៀត ។ នៅពេលរសៀលពន្លឺថ្ងៃ ចាំងចូលចំពីមុខបន្ទប់ ជះចំហាយក្តៅភាយៗមកលើយើងទាំងអស់គ្នាដែលនៅជាប់ខ្នោះ ធ្វើឲ្យបែកញើសជោគខ្លួនគ្រប់ៗគ្នា ។

- ពូ! តើយើងអាចសុំគេទៅផ្ងូតទឹកបានទេ?

- មិនបានទេក្មួយ ទ្រាំសិនទៅបន្តិចទៀតថ្ងៃនឹងបាំងដើមស្វាយខាងមុខនោះហើយ ។

- ចុះពេលណាទើបគេឲ្យយើងផ្ងូតទឹកម្តង?

បងថា គាត់ឆ្លើយជំនួសថាៈ

- គឺមួយអាទិត្យ ទើបសន្តិសុខបញ្ចេញឲ្យផ្ងូតទឹកម្តង តែបើយើងបានធ្វើការរាល់ថ្ងៃយើងនឹងបាន ផ្ងូតទឹករាល់ថ្ងៃដែរ ។

ព្រះអាទិត្យបានលាចាកទីបលោក ដោយនាំយករស្មីពណ្ណរាយ អំណាចនៃកំដៅ និងទុក្ខសោករបស់មនុស្សសត្វដែលត្រូវបង្ខំឲ្យធ្វើការ ធ្វើទារុណកម្មដ៏សែនលំបាកយ៉ាប់យ៉ឺនក្រៃលែង ទៅសម្ងំពួននៅឯជើងមេឃម្ខាងនៃបស្ចិមទិស ។ រីឯព្រះអនុជក៏បានអើតមុខប្រិមៗប៉ះប្រះមាត់ព្រៃពីទិសខាង កើតមកជំនួសម្តង ប៉ុន្តែលោកហាក់ដូចជានឿយណាយធុញទ្រាន់ នឹងសើចចំអកដល់មនុស្សដែលត្រូវធ្វើបាប ហើយនិងមនុស្សដែលធ្វើបាបគេ ដែលពោរពេញដោយអំពើឃោរឃៅអសីលធម៌ ឃ្លាតឆ្ងាយពីសន្តានចិត្តមនុស្សធម៌ ដែលរស់នៅក្នុងសង្គមមនុស្សដូចគ្នានេះណាស់ ។ លោកបណ្តែតខ្លួនឡើងយឺតៗ ស្ទើរនឹងខ្ជិល តែនេះជាកាតព្វកិច្ចមេត្តាធម៌របស់លោកដែលត្រូវបំពេញតែប៉ុណ្ណោះ ។

ស្នូរជួងម៉ឺងៗ ៗ ខ្លាំងៗ ហើយរសាត់ឆ្ងាយទៅៗ រហូតបាត់សំឡេងស្នូរស័ព្ទរាប់លេខរៀងក៏ចាប់ផ្តើមជាថ្មីទៀត បន្ទាប់ពីសកម្មភាពរាប់លេខអស់ចំនួនមនុស្សទៅ សភាពស្ងាត់ជ្រងំក៏វិលមកគ្របដណ្តប់លើមន្ទីរសន្តិសុខទាំងមូល អ្នកទោសម្នាក់ៗសម្ងំដោយស្ងៀមឈឹងដូចកណ្តុរខ្លាចឆ្មាអ៊ីចឹង តែបើត្រូវនិយាយគ្នាគឺនិយាយខ្សឹបៗ ឬក៏ធ្វើកាយវិការដាក់គ្នាទៅវិញទៅមកតែប៉ុណ្ណោះ ។

ចំណែកអ្នកទោសដែលនៅបន្ទប់ជាប់ខ្ញុំ មានម្នាក់កំពុងឈឺខ្លាំង ដាច់បបរពីរបីថ្ងៃមកហើយ កំពុងថ្ងូររហិសគួរឲ្យសង្វេគ យូរៗឮសំឡេងខ្សឹបខ្សៀវសួរគ្នា

- យ៉ាងម៉េចហើយ ឯងពិបាកក្នុងខ្លួនណាស់ឬ?

- ឯងកុំថ្ងូរឮពេកប្រយ័ត្នសន្តិសុខមកវាយថែមទៀត ឯងដេកផ្ងារមកគ្នារឹតដើមទ្រូងឲ្យឯង ។

នេះជាវាចាដ៏ស្មោះស្ម័គ្រស្រឡាញ់រាប់អានគ្នា ជួយរំលែកទុក្ខគ្នា ហើយក៏វាចាដែលផុសចេញពីបេះដូងដ៏បរិសុទ្ធ និងពោរពេញទៅដោយសីលធម៌ មនុស្សធម៌ មកលើមនុស្សដូចគ្នា ហើយក៏ជាកាយវិការកល្យាណមិត្តដែលពុំអាចកាត់ថ្លៃបាន ។

សន្ធិយារាត្រីបានរំលងផុតទៅ ព្រះអាទិត្យក៏ប្រតិស្ឋានពីទិសខាងកើតមកវិញ ហើយសកម្មភាពរបស់អ្នកទោសដែលត្រូវធ្វើបានមុនគេបង្អស់ គឺរាប់លេខរៀងដូចព្រឹកមុនៗដដែល ។

**(តទៅលេខក្រោយ)** **ឌុ សុភា**

# ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ

***រឿងពិតរបស់ ជា សីហា***

***(តពីលេខមុន)***

គេយកចិញ្ចៀនខ្ញុំបាន ហើយគេដាក់ខ្ញុំឲ្យអង្គុយវិញ ។ មួយស្របក់មកទៀត គេយកបបរខាប់មួយចានគ្រោង និងស្លាបព្រាមកដាក់ពីមុខខ្ញុំ ។

ក្លិនដ៏ឈ្ងុយឆ្ងាញ់របស់បបរ ធ្វើឲ្យខ្ញុំបំភ្លេចទុក្ខសោក និងអ្វីៗទាំងអស់ ថែមទាំងលែងនឹកស្តាយស្រណោះចិញ្ចៀនដែលគេទើបនឹងយកទៅអម្បាញ់មិញនេះផង ។ ខ្ញុំប្រញាប់យកស្លាបព្រាដួសបបរទាំងក្តៅល្មមដាក់ចូលក្នុងមាត់ខ្ញុំ ។ រសជាតិឆ្ងាញ់ពិសារកអ្វីមកប្រៀបពុំបាននៃទឹកបបរខាប់ ធ្វើឲ្យខ្ញុំមានកម្លាំងព្រឺសឡើង បីដូចជាអាហារទិព្វ ។ ខ្ញុំទទួលទានបបររហូតដល់អស់ពីចាន ។ បន្ទាប់មកទាហានម្នាក់នោះនៅតែមិនអស់ចិត្ត បានវិលមករកខ្ញុំវិញ ។ គាត់បញ្ជាខ្ញុំឲ្យស្រាយក្រណាត់រុំរបួសនៅជើងទាំងពីររបស់ខ្ញុំ ។ ខ្ញុំធ្វើតាមបញ្ជា ។ នៅពេលរបួសបើកចំហឡើង ខ្ញុំឃើញដង្កូវពីរបីវារចេញពីមុខរបួស គាត់បញ្ជាខ្ញុំឲ្យបិទវិញ ។ ខ្ញុំសូមអនុញ្ញាតបោះក្រណាត់រុំរបួសនោះចោល ហើយខ្ញុំហែកក្រមារុំសាជាថ្មី ។ ដំបៅឈឺចាប់ពើតឥតល្ហែ ប៉ុន្តែសេចក្តីសង្ឃឹមចាប់ផ្តើមមានបន្តិចមកវិញ ។ មួយស្របក់មកទៀត ស្រាប់តែមានរថយន្តធំសម្រាប់ដឹកទាហានមួយគ្រឿងមកឈប់ជិតខ្ញុំ ។ នៅលើនោះមានទាហានបួនប្រាំនាក់ប្រដាប់ដោយអាវុធគ្រប់ដៃអង្គុយលើកៅអីវែង ។ ទាហានម្នាក់ដែលសាកសួរខ្ញុំតាំងពីដំបូងបានបញ្ជាឲ្យគេលើកខ្ញុំដាក់ទៅលើកៅអីវែងលើរថយន្ត ។ ទាហានដែលនៅស្រាប់លើរថយន្តបានយកចម្រៀកក្រណាត់ខ្មៅមកចងបិទភ្នែករបស់ខ្ញុំ ។ ខ្ញុំស្លុតចិត្តដោយនឹកថា អ្វីដែលខ្ញុំសង្ឃឹមពីមុននេះ ឥឡូវប្រែប្រួលទៅហើយ ។ ខ្ញុំខទានឡើងជាភាសាអង់គ្លេសថា សូមមេត្តាបញ្ជូនខ្ញុំទៅកាកបាទក្រហមអន្តរជាតិ ។ ខ្ញុំឮសំឡេងឆ្លើយតបមកវិញថា យល់ព្រម ។ ខ្ញុំជិះរថយន្តអស់រយៈពេលប្រមាណជាងមួយម៉ោង ។ រថយន្តឈប់ហើយមានដៃមួយមកទាញស្មាខ្ញុំ ឲ្យខ្ញុំធ្លាក់ពីលើរថយន្តទៅដី ។ ខ្ញុំឈឺចាប់បន្តិចដែរ ព្រោះអុកគូទ ។ គេទាញយកក្រណាត់ចេញពីភ្នែកខ្ញុំ ។ រថយន្តវិលត្រឡប់ទៅវិញ ឯទ្វាររបងក៏បិទជិតទៅតាមក្រោយ ។ ខ្ញុំអង្គុយលើដីតែម្នាក់ឯង ភ្នែកខ្ញុំគយគន់ទិដ្ឋភាពជុំវិញខ្លួន ។ អគារមួយខ្នងពីរជាន់លាបពណ៌សនៅពីមុខខ្ញុំ ។ មានដើមស្នួលមួយដើមធំនៅពីចំហៀង និងសួនច្បារនៅចំពីមុខអគារ ។ ពីខាងក្រោយអគារ ខ្ញុំឃើញមានភ្លឺស្រះមួយចំហៀងវែងទៅក្រោយ ។ នៅខាងក្រោមដើមស្នួលមានទីធ្លាធំទូលាយ និងមានគំនរឈើចាស់ៗនៅជាប់នឹងជញ្ជាំងរបង ។ អគារ និងបរិស្ថានរបស់សំណង់នោះ ហ៊ុមព័ទ្ធដោយរបងស៊ីម៉ងត៍ដែលមានលួសបន្លា និងបន្ទះស័ង្កសីព័ទ្ធពីលើមួយជាន់ទៀត ។ ទីនោះស្ងាត់ជ្រងំ ខ្ញុំនឹកថា ប្រហែលជាទីស្នាក់ការកាកបាទក្រហម ឬក៏ជាផ្ទះរបស់លោកធំណាម្នាក់ ។ មួយសន្ទុះក្រោយមក ខ្ញុំឃើញបុរសចំណាស់ម្នាក់ស្លៀកខោរីតចង្កេះជើងខ្លីទុកដងខ្លួនទទេ ដើរចេញពីខាងក្រោយអគារមកជិតខ្លួនខ្ញុំ ហើយដើរបង្ហួសទៅមើលឈើចាស់ៗនៅប្របជញ្ជាំងរបង ។ បុរសនោះ មិនរវល់នឹងវត្តមានរបស់ខ្ញុំបន្តិចសោះ ។ ខ្ញុំគិតថា ខ្ញុំជាមនុស្សចំណូលថ្មី ខ្ញុំត្រូវសម្តែងការគួរសមចំពោះបុរសនោះជាចាំបាច់ ។ នៅពេលគាត់ត្រឡប់មកវិញ ខ្ញុំនិយាយទៅកាន់គាត់ថា ខ្ញុំសូមប្រណិបតន៍លោកឪ សូមលោកឪមេត្តាស្រោចស្រង់ជីវិតខ្ញុំផង ។ ខ្ញុំត្រេកអរណាស់ដែលបានមកជ្រកក្រោមម្លប់លោកឪ ។ គាត់គំហកដាក់ខ្ញុំថា អាណាជ្រកក្រោមម្លប់អាណា? នេះជាគុក អ្ហែងមិនដឹងទេអី? គ្មានថ្ងៃចេញទេអាវ៉ាអើយ ។ ខ្ញុំទន់ដៃទន់ជើង អស់សេចក្តីសង្ឃឹមរលីងពីខ្លួន បន្ទាប់ពីឮសម្តីរបស់បុរសចាស់នោះ ។ ខ្ញុំអង្គុយត្រមង់ត្រមោចម្នាក់ឯងរហូតដល់ពេលល្ងាចទើបទាហានបណ្តើរអ្នកជាប់គុកប្រមាណដប់នាក់ចូលមក ។ ម្នាក់ៗ ជាប់ច្រវាក់នៅកជើងទាំងពីរ ។ ដៃកាន់ច្រវាក់ចំកណ្តាលហើយលើកឡើងមិនឲ្យច្រវាក់ធ្លាក់អូសដី ។ អ្នកទាំងអស់នោះរួសរាយរាក់ទាក់មករកខ្ញុំ មិនដូចអាកប្បកិរិយារបស់បុរសម្នាក់មុននោះឡើយ ។ យើងសំណេះសំណាលគ្នា សួរសុខទុក្ខគ្នាដូចបងប្អូន ។

ក្នុងចំណោមមនុស្សទាំងនោះ មានបុរសម្នាក់ឈ្មោះ ម៉េន បានយកចិត្តទុកដាក់ទំនុកបម្រុងខ្ញុំលើសអ្នកដទៃ ។ តម្រួតទាហានម្នាក់បានដេញខ្ញុំឲ្យចុះស្រះមុជទឹកជម្រះខ្លួន ។ ខ្ញុំប្រកែកថា ខ្ញុំពុំអាចចុះទៅក្នុងស្រះនោះម្នាក់ឯងបានទេ ព្រោះ ជើងខ្ញុំពិការទាំងពីរ ។ បុរសឈ្មោះ ម៉េន គ្រាហ៍ខ្ញុំទៅមាត់ស្រះ ។ តម្រួតហាម ម៉េន មិនឲ្យជួយខ្ញុំដោយពោលពាក្យជាភាសាសៀមថា វាធ្វើដំណើរតាំងពីស្រុកខ្មែរមកដល់ស្រុកសៀមបានត្រឹមតែដើរទៅមុជទឹកស្រះធ្វើមិនបាន! កុំជួយវា! ។ ពេលតម្រួតទាហានដើរចេញទៅ ម៉េន បានយកធុងទៅដងទឹកក្នុងស្រះមកស្រោចលើខ្ញុំ ។ ខ្ញុំដុសលាងខ្លួន និងសម្លៀកបំពាក់ដែលជាប់នឹងខ្លួន ហើយផឹកទឹករហូតដល់អស់ចិត្ត ។ នៅទីនោះ គ្មានសាប៊ូទេ ។ ខ្ញុំលាងដំបៅ និងស្រះ ហើយរុំទៅវិញដោយកំណាត់ក្រមាដែលនៅសល់ ។ ដំបៅបានធ្វើឲ្យជើងរបស់ខ្ញុំកាន់តែខ្វាំងឡើង ។ ជើងខាងឆ្វេងតាំងពីបាតជើងដល់កជើងឡើងក្រហមក្តៅធំ ។ ជើងខាងស្តាំ តាំងពីកជើងដល់ជង្គង់ហើមដូចគ្នា ។ មុខរបួសក្លាយជាដំបៅបើកចំហធំមានពណ៌ក្រហមភ្លែត ។ ការឈឺពើតផ្សាកាន់តែធំឡើង ។

នៅពេលល្ងាចនេះ គេចែកអាហារឲ្យបរិភោគ ។ ម្នាក់ៗ បានបាយប្រមាណមួយចានចង្កឹះស្រូបសម្លឆាសណ្តែកបណ្តុះបន្តិច ។ ខ្ញុំទទួលទានដោយឆ្ងាញ់ពិសាក្រៃលែង ពីព្រោះឱជារសរបស់អាហារនេះ ខ្ញុំខានបានជួបជាយូរមកហើយ តាំងពីពួកខ្មែរក្រហមមកគ្រប់គ្រងអំណាចនៅកម្ពុជា ។ យប់នោះ ខ្ញុំទទួលទានដំណេកលើគ្រែម្នាក់ឯងនៅជាន់ខាងក្រោម ។ ខ្ញុំដេកលង់លក់រហូតទល់ភ្លឺ ។ បុរសឈ្មោះ ម៉េន ចុះពីជាន់ខាងលើមកដាស់ខ្ញុំ ហើយគ្រាហ៍ខ្ញុំទៅលុបលាងមុខ ។ ជើងរបស់ខ្ញុំកាន់តែហើម និងកាន់តែឈឺខ្លាំងឡើង ។ ខ្ញុំប្រកាច់ម្តងៗ នៅពេលដែលប្រែខ្លួន ។ ខ្ញុំខ្លាចសត្វរុយដែលវាប៉ុនប៉ងមករោមដំបៅខ្ញុំ ។ គ្រាន់តែរុយមួយក្បាលហើរតម្រង់មកជិតខ្ញុំ សាច់ដុំជើងខ្ញុំក៏ចាប់កន្ត្រាក់ ហើយរមួលទាល់តែខ្លួនខ្ញុំ ទាំងមូលរមួលតាមហើយ ប្រកាច់មួយសន្ទុះទើបសាច់ដុំរលាមកធម្មតាវិញ ។ ថ្ងៃនោះ ជាថ្ងៃដំបូងដែលជំងឺប្រកាច់ចាប់ផ្តើមធ្វើទុក្ខខ្ញុំ ត្រូវនឹងថ្ងៃបន្ទាប់ដែលខ្ញុំមកដល់មន្ទីរឃុំឃាំងនោះ ។ ព្រឹកនោះ មន្ត្រីខាងមន្ទីរព័ត៌មានកងទ័ពបានមកថតរូបខ្ញុំ ហើយសាកសួរអំពីដើមទង និងអំពីតម្រាយផ្លូវនៃការរត់ភៀសខ្លួនរបស់ខ្ញុំ ។ ខ្ញុំពុំអាចឆ្លើយសំណួររបស់គាត់ដោយនឹងនបានទេ ព្រោះជំងឺប្រកាច់មករំខានកិច្ចសន្ទនានោះជាញឹកញយ ។ ខ្ញុំលើកដៃសំពះអង្វរដល់មន្ត្រីនោះ ឲ្យមេត្តាដាក់ទានថ្នាំពេទ្យឲ្យខ្ញុំ ដើម្បីបំបាត់អាការៈរោគរបស់ខ្ញុំនេះ ។ គាត់ឲ្យខ្ញុំសរសេរឈ្មោះថ្នាំដែលត្រូវព្យាបាលជំងឺនេះឲ្យគាត់ ដើម្បីយកទៅទិញនៅឱសថដ្ឋាន ។ ខ្ញុំផ្ញៀតផ្តាំតាមគាត់ឲ្យប្រាប់ឈ្មោះ យាង ដែលជាចៅកែថ្នាំពេទ្យធំ នៅស្រុកអារញ្ញនេះ ហើយឲ្យឈ្មោះ យាង នោះមកជួយខ្ញុំផង ។ ប្រមាណពីរម៉ោងក្រោយមក មន្ត្រីនោះបានយកថ្នាំបំបាត់ការឈឺចាប់មួយបន្ទុះមកឲ្យខ្ញុំ ឯថ្នាំសម្រាប់មេរោគដែលខ្ញុំសរសេរឲ្យនោះឥតឃើញមានឡើយ ។ ម្យ៉ាងទៀតឈ្មោះ យាង ដែលខ្ញុំបានផ្តាំផ្ញើដំណឹងទៅឲ្យនោះ បានបដិសេធថា ពុំដែលស្គាល់ឈ្មោះរបស់ខ្ញុំទេ ។ ខ្ញុំទទួលទានថ្នាំបំបាត់ការឈឺចាប់បានមួយសន្ទុះប្រសិទ្ធភាពរបស់ថ្នាំបានសម្រួលដល់ការសន្ទនារវាងមន្ត្រីព័ត៌មាននិងខ្ញុំបានមួយរយៈពេល ។ ស្អែកឡើង មន្ត្រីនោះ បានមកសាកសួរខ្ញុំបន្ថែមទៀត ។ ការឈឺចាប់បានបង្ខំខ្ញុំឲ្យសុំអភ័យទោសពីគាត់ដោយពុំអាចអត់ទ្រាំនៅចំពោះការសន្ទនានេះបានទេ ។ ថ្នាំបានសម្រាលការឈឺចាប់របស់ខ្ញុំតែមួយភ្លែតៗ ។ ខ្ញុំនឹកក្នុងចិត្តថា តើខ្ញុំអាចកើតជំងឺតេតាណូសឬ? កាលខ្ញុំនៅរៀនខ្ញុំទទួលថ្នាំការពារជំងឺតេតាណូសនោះសព្វគ្រប់អស់ហើយ ។

នៅល្ងាចនោះ មានអ្នកភៀសខ្លួនថ្មីៗទៀតបានមកដល់ ។ ក្នុងចំណោមអ្នកមកដល់ថ្មីទាំងនោះ មានអ្នករបួសពីរបីនាក់ដោយគ្រាប់កាំភ្លើងរបស់ខ្មែរក្រហម ។ ខ្លះត្រូវចំក ត្រូវដៃ ត្រូវជើង ។ របួសទាំងនោះ ពុំសូវធ្ងន់ប៉ុន្មានទេ ហើយឥតទាន់បានទទួលការព្យាបាលនៅឡើយដែរ ។ លើកលែងតែម្នាក់ដែលមានរបួសនៅត្រង់ក មានស្ថានភាពដុនដាបជាងគេ ។ គ្រាប់កាំភ្លើងមួយគ្រាប់បានទម្លុះកគាត់ពីមុខធ្លាយទៅក្រោយ ។ ទាំងអស់គ្នា លើកលែងតែអ្នកមានរបួសធ្ងន់ត្រូវគេដាក់ខ្នោះជើងទាំងពីរភ្ជាប់គ្នានឹងច្រវាក់មួយ ឬច្រវាក់មួយដាក់ពីរនាក់ភ្ជាប់គ្នានៅកជើង ។ នៅពេលល្ងាចជិតយប់ គេឲ្យខ្ញុំឡើងទៅដេកជុំគ្នាជាមួយអ្នកឯទៀត ។ ទោះបី រូបខ្ញុំមានការឈឺចាប់អំពីដំបៅរបួសរបស់ខ្ញុំក្តី ក៏ខ្ញុំមានចិត្តបារម្ភ ចំពោះស្ថានភាពរបស់បុរសម្នាក់ដែលមានរបួសនៅក ។ ខ្ញុំយកដៃទៅស្ទាបខ្លួនបុរសនោះមានសភាពត្រជាក់ស្រេង ។ ខ្ញុំឲ្យខោយ៉ាងធំមួយទៅបុរសនោះ ខ្ញុំទុកកំណាត់មុងមួយទៀតសម្រាប់ខ្លួនខ្ញុំ ។ បុរសឈ្មោះ ម៉េនជួយសិកខោនោះឲ្យអ្នក របួស ។ ចង្កេះខោទៅដល់កបុរសនោះល្មម ។ ព្រឹកឡើង

គេឲ្យចុះមកដីទាំងអស់គ្នា គោរពភ្លេងជាតិថៃ និងគោរពព្រះមហាក្សត្រ ទើបទទួលចំណាត់ការឲ្យបំពេញការងារតាមបញ្ជារបស់តម្រួត ។ រូបខ្ញុំ និងអ្នករបួសដទៃទៀតឥតឲ្យទទួលការងារអ្វីទេ ។ យើងអង្គុយលើគំនរឈើក្រោមដើមស្នួលរង់ចាំពេលបាយថ្ងៃមកដល់ ។ យើងឃ្លានខ្លាំងណាស់ ។ គ្រាន់តែពុស្នូរចាន ស្លាបព្រាទង្គិចគ្នានៅឯមន្ទីរ គឺនៅបន្ទាយទាហានជិតគ្នានេះ ក្រពះ ពោះវៀនរបស់ខ្ញុំក្រញ្ឆោលឡើងស្ទើរដាច់ ។ អ្នកឯទៀត ក៏មានអាការៈដូចគ្នានេះដែរ ។

មន្ទីរឃុំឃាំងដើមស្នួលនោះនៅក្រោមការគ្រប់គ្រងរបស់កងទ័ព ។ អ្នកធ្វើការនៅទីនោះជាតម្រួតយោធា ។ ខ្ញុំសង្កេតឃើញមានតម្រួតយោធាបីនាក់ដែលមកធ្វើការទៀងទាត់ជារៀងរាល់ថ្ងៃយប់ ។ តម្រួតយោធាម្នាក់ឈ្មោះ យុង មានឋានន្តរស័ក្តិជា "មូ" ប្រហែលស្មើនឹង "ពលបាលទោ" នៃឋានានុក្រមកងទ័ពខ្មែរ ហើយមានមូម្នាក់ទៀតមិនស្គាល់ឈ្មោះធ្វើការឆ្លាស់វេនគ្នា ។ មានតម្រួតផ្សេងៗទៀតដែលមានជាជំនួយការ ។ គេចាត់ឲ្យខ្មែរម្នាក់ដែលប៉ិនប្រសប់ជាងគេ ហើយចេះភាសាសៀមច្បាស់មើលមកលើពួកយើង ។ បុរសនោះឈ្មោះ តាសារឿង ។ គេតាំងខ្លួនជាអ្នកមានអំណាចលើពួកយើង ។ គេអាចជេរស្តី ឬវាយពួកយើងបាន ។ យើងញញើតនឹងម្នាក់នេះណាស់ ព្រោះគេជាអ្នកបកប្រែភាសាឲ្យតម្រួត ។ គេអាចនិយាយមួលបង្កាច់យើងប្រាប់តម្រួតថាយ៉ាងដូចម្តេចក៏បានដែរ ។ ខ្ញុំហៅបុរសនេះថា "លោកឪ" ។ មានបុរសចាស់ម្នាក់ទៀតទទួលមុខងារជាជាងឈើ ។ បុរសនោះឈ្មោះ តាអំ ។ គាត់នេះហើយដែលខ្ញុំឃើញគាត់មុនគេ នៅពេលខ្ញុំទើបមកដល់ក្នុងមន្ទីរឃុំឃាំងនេះ ។ គាត់ជាមនុស្សស្ងាត់ស្ងៀម ប៉ុន្តែគំរោះគំរើយក្នុងការនិយាយស្តី ។ នៅមានមនុស្សម្នាក់ទៀត ដែលទទួលបានឥទ្ធិពលខ្លាំងក្លាពីតម្រួតសម្រាប់ចាត់ចែងលើពួកយើង ។ បុរសនោះជាកូនខ្មែរកាត់ចិនមានមុខងារជាអ្នកចែកបាយឲ្យពួកយើង ។ នរណាដែលឲ្យបុរសនោះពេញចិត្តអាចទទួលបានចំណែក បាយ និងសម្លច្រើនដោយដួសបាយដួសសម្លឲ្យកំពុងវែករង្វាល់ ។ ផ្ទុយទៅវិញ បើនរណាធ្វើឲ្យគេមិនពេញចិត្ត គេដួសបាយ ដួសសម្លត្រឹមតែកាចវែក ឬគេអាចវាយក្បាលអ្នកនោះនឹងវែក ដោយចោទថា គ្មានសណ្តាប់ធ្នាប់ ។

នៅមន្ទីរឃុំឃាំងនេះ យើងជាជនភៀសខ្លួនទាំងអស់គ្នា ពុំមានសុវត្ថិភាពទេ យើងមានអារម្មណ៍ថា ពួកតម្រួត និងទាហានប្លែកៗដែលចូលមកមន្ទីរឃុំឃាំងនេះ សម្លឹងមកពួកយើងដោយអរិភាព ។ ពួកនេះនិយាយមករកយើង ហាក់ដូចជា យើងជាអ្នកទោសឧក្រិដ្ឋ ជាមនុស្សព្រៃ ។ គេបញ្ជាយើងឲ្យធ្វើអ្វីក៏បានដែរ ។ យើងខ្លាចពួកនេះឡើងញ័រសាច់ ។ គេគំរាមកំហែងយើងថា នឹងយកយើងទៅប្រហារជីវិតនៅពេលខាងមុខ ។ ខ្ញុំឮពាក្យខ្សឹបខ្សៀវតាំងពីពេលខ្ញុំមកដល់ថា ពួកនេះសាហាវណាស់ បើគេមិនពេញចិត្តនឹងយើង គេយកយើងទៅវាយសម្លាប់នៅក្បែររបងគុកនេះ ។ បើយើងមានកំហុសតិចតួចដូចជា មានជើងមិនស្អាតទៅជាន់ឲ្យប្រឡាក់ក្តារក្រាល មិនគោរពឆាយាល័ក្ខណ៍ស្តេចនៅពេលដើរកាត់ ធ្វើឲ្យច្រវាក់ធ្លាក់លើក្តារដោយពុំប្រយ័ត្ន មិនស្តាប់បង្គាប់គេជាដើម គេអាចវាយទាត់ធាក់យើងតាមអំពើចិត្ត ។ នៅពេលព្រឹក និងរសៀល គេបណ្តើរពួកយើងដែលមានកម្លាំងចេញទៅធ្វើការក្នុងបន្ទាយ ដោយជើងជាប់ច្រវាក់ ។ ពេលថ្ងៃត្រង់ និងល្ងាច គេចែកបាយឲ្យយើងម្នាក់មួយវែកស្មើប្រមាណមួយចានចង្កឹះ ហើយច្រូចទឹកឆាពីលើ ។ ពីមួយថ្ងៃទៅមួយថ្ងៃ អ្នកទោសឆ្លងដែនទាំងនេះចុះស្គមបន្តិចម្តងៗ រហូតមានតែស្បែកសណ្តាប់ឆ្អឹង ។ ពួកយើងកម្របានបន្ទោរបង់ណាស់ ព្រោះតែពុំមានកាកអាហារនៅក្នុងពោះវៀន ។ ត្រយដើមក្ទុម្ពទេស ដែលគេដាំធ្វើរបងនៅមាត់ស្រះស្ទើរតែប៉ិចពុំទាន់ ពួកយើងក្តិចដាក់ចូលមាត់បាត់ទៅហើយ ។ សេចក្តីឃ្លានអាហារ សេចក្តីទ្រាំទ្រនឹងពាក្យតិះដៀលប្រមាថ ធ្វើឲ្យខ្ញុំឈឺចាប់ទាំងកាយ ទាំងចិត្ត ស្ទើរតែទ្រាំរស់ទៅមុខទៀតពុំកើត ។ បើខ្ញុំដឹងថា ពួកតម្រួត ពួកទាហាន សៀមមានសន្តានចិត្តអាក្រក់ដល់កម្រិតនេះ ខ្ញុំពិតជាសុខចិត្តឲ្យខ្មែរក្រហមសម្លាប់នៅលើមាតុភូមិរបស់យើងចុះ ព្រោះយ៉ាងហោចណាស់ខ្មែរក្រហម ក៏មានឈាមជ័រជាខ្មែរដែរ ។ កាលនៅក្រោមរបបខ្មែរក្រហមឯស្រុក ការខ្វះខាតអាហារ ការធ្វើការធ្ងន់ ការគំរាមកំហែង ក៏ពុំស្មើដូចពេលនេះដែរ ។ ខ្ញុំពិតជាខកចិត្តខ្លាំងណាស់ ។

នៅក្នុងចំណោមពួកយើង មានតែនារីម្នាក់ប៉ុណ្ណោះ ។ នាងមានរូបឆោមសមគួរ និងកិរិយាមារយាទស្រគត់ស្រគំ ឧស្សាហ៍ក្នុងការងារ និងយកចិត្តទុកដាក់រាប់អានអ្នកទោសដូចគ្នា ។ យើងដេកទាំងអស់គ្នាក្នុងបន្ទប់ធំមួយ ប៉ុន្តែមានរបាំងសម្រាប់បន្ទប់របស់នាង ។ រៀងរាល់ពេលយប់ដែលវេនរបស់មូម្នាក់នោះ តែងមកបង្ខិតអូសទាញរូបនាងនោះចេញទៅក្រៅបន្ទប់បាត់រហូតដល់ភ្លឺទើបឃើញ នាង

នោះមកដល់បន្ទប់វិញ ។ យើងជាខ្មែរដូចគ្នា ជាអ្នកទោសឆ្លងដែនដូចគ្នា យើងឈឺចាប់ណាស់ ចំពោះអំពើឃោរឃៅរំលោភសិទ្ធិមនុស្សរបស់មូម្នាក់នោះ ។ ពួកយើងគ្រាន់តែបានកេះគ្នាសម្តែងទឹកមុខក្រៀមក្រំ និងឈឺចាប់ចំពោះទារុណកម្មនោះ ដោយសាត់ស្ងៀម ។ ចំណែកឯមូ យុង ជាតម្រួតយោធាម្នាក់មានចរិតចាស់ទុំ មានការយោគយល់ច្រើន ។

ជំងឺរបស់ខ្ញុំបណ្តាលមកពីរបួសនឹងចម្រូងបុស្សីនៅពេលធ្វើដំណើរមក ឥឡូវនេះកាន់តែខ្លាំងឡើង ។ ជើងរបស់ខ្ញុំទាំងពីរហើមតឹងណែនស្ទើរប្រេះ មុខរបួសក្លាយជាដំបៅរីកចំហធំបណ្តាលឲ្យខ្ញុំឈឺចាប់ពើតផ្សា អត់ទ្រាំលែងបាន ។ ឈឺគ្មានពេលស្រាកស្រាន្ត មុនដំបូងខ្ញុំថ្ងូរខ្សឹបខ្សើង ប៉ុន្តែ យូរៗទៅ ខ្ញុំក៏តាំងស្រែកឲ្យគេជួយស្រែកទាំងថ្ងៃទាំងយប់គ្មានឈប់ឈរ ។ ស្រែកហៅមចុរាជ ស្រែកឲ្យឆាប់ស្លាប់ ព្រោះតែសេចក្តីឈឺចាប់នោះ ធ្វើឲ្យខ្ញុំទ្រាំលែងបាន ។ ពីរថ្ងៃក្រោយមក ស្ថានភាពជំងឺរបស់ខ្ញុំកាន់តែដុនដាបទៅទើបតម្រួតបញ្ជាឲ្យបុរសម្នាក់ឈ្មោះ សារ៉ាន់ ដែលមានរបួសត្រង់កដោយត្រូវគ្រាប់ កាំភ្លើងទៅយករទេះរុញសម្រាប់ដឹកសម្រាមមកដឹកខ្ញុំយកទៅចោលនៅសាលខ្មោចនៅមន្ទីរពេទ្យទាហាន ។ សារ៉ាន់ លើកខ្ញុំដាក់លើរទេះ ហើយរុញចេញពីមន្ទីរឃុំឃាំងទៅកាន់មន្ទីរពេទ្យ ។ ចេញផុតពីមន្ទីរឃុំឃាំងបានបន្តិចទៅជួបក្រុមទាហានកំពុងហាត់ ។ ទាហានពីរបីនាក់ដើរសំដៅមករកយើង ហើយស្រែកបញ្ជាឲ្យខ្ញុំចុះពីរទេះ ហើយឲ្យ សារ៉ាន់ ឡើងលើរទេះទុកឲ្យខ្ញុំរុញម្តងវិញ ។ យើងស្តាប់ភាសាសៀមមិនបាន ប៉ុន្តែ យើងយល់ពីបញ្ជារបស់ពួកគេ ដោយកាយវិការ ។ សារ៉ាន់ និងខ្ញុំក៏លើកដៃសំពះអង្វរគេ ព្រោះតែខ្ញុំមានជំងឺធ្ងន់ពុំអាចចុះពីរទេះបានទេ ។ ពួកគេគំហកដាក់យើងឲ្យយើងធ្វើតាមបញ្ជារបស់គេ ។ ជាកុសលរបស់ខ្ញុំសំឡេងកញ្ចែបន្លឺឡើងឯឆ្ងាយគឺជាសញ្ញាហៅទាហានឲ្យទៅប្រជុំ ។ ពួកគេវិលត្រឡប់ទៅវិញ សារ៉ាន់ រុញរទេះដឹកខ្ញុំបន្តដំណើរទៅមុខទៀត ។ ទៅដល់កណ្តាលទីធ្លារបស់មន្ទីរពេទ្យ ជាចៃដន្យវេជ្ជបណ្ឌិតក្មេងម្នាក់ពាក់ប្រដាប់ស្តាប់នោកដៃម្ខាងកាន់ឈើច្រត់ ដើងរុំដោយមនោសិលា ដើរកាត់ពីមុខរទេះដែលដឹកខ្ញុំ ។ ខ្ញុំខំទានជាភាសាអង់គ្លេសផង ជាភាសាសៀមផង សូមឲ្យគេជួយខ្ញុំ ខ្ញុំក៏ជាពេទ្យនៅស្រុកខ្មែរដែរ ។ លោកវេជ្ជបណ្ឌិតនោះងក់ក្បាលហើយ ធ្វើសញ្ញាឲ្យ សារ៉ាន់ រុញរទេះដឹកខ្ញុំទៅកាន់អគារមួយនៅខាងឆ្វេងដៃ ។ រំពេចនោះ វេជ្ជបណ្ឌិតបានសួរសាកល្បងមកខ្ញុំថា “បើឯងធ្វើពេទ្យ តើជំងឺរបស់ឯងត្រូវព្យាបាលដោយថ្នាំអ្វី? ” ។ គេបញ្ជាឲ្យខ្ញុំចង្អុលមុខថ្នាំនោះ ដែលមាននៅក្នុងទូដាប់ជញ្ជាំងម្ខាងបន្ទប់ ។ ខ្ញុំធ្វើតាមបញ្ជា ។ លោកវេជ្ជបណ្ឌិតងក់ក្បាលយល់ព្រម ។ តាមបញ្ជារបស់លោកវេជ្ជបណ្ឌិត គិលានុបដ្ឋាកម្នាក់បានចាក់ថ្នាំឲ្យខ្ញុំលាងរបួសឲ្យខ្ញុំដោយផ្ចិតផ្ចង់ ។ ថ្នាំដែលគេចាក់ឲ្យខ្ញុំមានកម្រិតខ្លាំងហួសប្រមាណ ។ ឧទាហរណ៍ ថ្នាំព្យាបាលជំងឺតេតាណូសឈ្មោះ តេតាណុល តាមធម្មតាគេចាក់តែមួយ ឬពីរអំពូលតែប៉ុណ្ណោះ ចំណែកម្តងនេះ ខ្ញុំឃើញគេចាក់ឲ្យខ្ញុំម្តងដប់មួយអំពូល ។ ឯថ្នាំផ្សះ ប៉េនីស៊ីលីនវិញ គេចាក់ឲ្យខ្ញុំដល់ទៅពីរលានឯកតាលាយជាមួយ ស្រ្តិបតូមីស៊ីន មួយក្រាម ។ ខ្ញុំពុំមានចិត្តតក់ស្លុតនឹងបរិមាណថ្នាំដែលគេព្យាបាលឲ្យខ្ញុំនោះទេ ព្រោះខ្ញុំនឹកថា បើស្លាប់ដោយសារការប្រើថ្នាំលើសកម្រិតប្រសើរជាងការទ្រាំឈឺចាប់ហួសប្រមាណ ។ គេព្យាបាលឲ្យខ្ញុំរួចហើយ ទើបគេព្យាបាលរបួសឲ្យ សារ៉ាន់ ទៀត ។ ជាសំណាងរបស់ សារ៉ាន់ ដែរ ព្រោះគ្រាប់កាំភ្លើងដែលទម្លុះករបស់គាត់ពីមុខទៅក្រោយឥតមានប៉ះពាល់ដល់ចំណែកសំខាន់នៃសរីរៈទេ ។ នេះជាសំណាងមួយក្នុងគ្រោះថ្នាក់មួយពាន់ ។ ក្រោយការព្យាបាលការឈឺចាប់របស់ខ្ញុំបានស្រាកស្រាន្តយ៉ាងឆុតឆាប់ ។ ខ្ញុំបានថ្លែងអំណរគុណចំពោះទឹកចិត្តដ៏ល្អរបស់លោកវេជ្ជបណ្ឌិត និងលោកគិលានុបដ្ឋាក ដែលបានស្រោចស្រង់ជីវិតខ្ញុំ ។ សារ៉ាន់ រុញរទេះ ដឹកខ្ញុំមកមន្ទីរឃុំឃាំងវិញ ។ យើងទាំងពីរនាក់មានអនុស្សាវរីយ៍យ៉ាងច្រើនជាមួយគ្នា ។ តាំងពីពេលនោះមកជំងឺរបស់ខ្ញុំបានសះស្បើយជាលំដាប់ ។ មួយខែក្រោយមក ខ្ញុំអាចក្រោកឈរ និងដើរបានបន្តិចៗ ។ របួសរបស់ សារ៉ាន់ ក៏ជាសះស្បើយដែរ ។ ការបរិភោគអាហារមិនគ្រប់គ្រាន់ ធ្វើឲ្យយើងម្នាក់ៗមានសភាពទ្រុឌទ្រោមទៅជាលំដាប់ ។ គេផ្តល់អាហារឲ្យយើងល្មមតែឲ្យយើងរស់ទាំងត្រដរ ឬស្លាប់បន្តិចម្តងៗ ។ នៅពេលយប់មួយ ខ្ញុំនឹកបារម្ភអំពីជំងឺនៅត្រង់រន្ធគូទរបស់ខ្ញុំដែលមានសាច់ដុះរីកណែនប៉ុន្តែ ពុំមានការឈឺចាប់ទេ ។ ខ្ញុំយកដៃទៅស្ទាបមើលវា ស្រាប់តែវារបេះមួយកូនដុំចេញមក ។ ខ្ញុំយកវាទៅពិនិត្យមើលឯទីភ្លឺ ខ្ញុំស្ទើរស្លុតស្មារតី ពីព្រោះកូនដុំនោះ មិនមែនអ្វីក្រៅពីចៃតឹកកែដែលខ្ញុំធ្លាប់ឃើញវាខាំជញ្ជក់ឈាម គោក្របី ឬឆ្កែនោះឡើយ ។ ឥឡូវវានាំគ្នាមកសម្ងំខាំបឺតឈាមខ្ញុំរហូតដល់ខ្លួនវាឡើងមូលដូចផ្លែជន្លង់ ។ នៅ

ពេលនោះដែរ មានអ្នកភៀសខ្លួនទើបមកដល់ថ្មីម្នាក់ឈ្មោះ ឱ បានហុចប្រាក់ឲ្យខ្ញុំចំនួនម្ភៃបាត ។ ម្ភៃបាតសម្រាប់ខ្ញុំនៅពេលនោះមានតម្លៃលើសលប់ណាស់ ។ ខ្ញុំឲ្យគេទិញបារី ទិញស្ករ ទិញថ្នាំលេបសម្រាប់ព្យាបាលរបួសឲ្យខ្លួនខ្ញុំ ។

ប្រមាណពីរខែក្រោយមក យប់មួយខ្ញុំយល់សប្តិឃើញឪពុកខ្ញុំមកប្រាប់ថា ឲ្យខ្ញុំទ្រាំ ចាំគាត់នាំខ្ញុំទៅវត្តក្នុង ឲ្យជួបគ្នីគ្នា ខ្ញុំនៅទីនោះហើយឲ្យខ្ញុំបរិភោគបាយឲ្យឆ្អែតសិមគាត់នាំខ្ញុំទៅវត្តក្រៅទៀត ។ រំពេចនោះឪពុកខ្ញុំចាប់យកកូនខ្ទមមួយទំនងជាខ្ទមអ្នកតានៅមាត់អូរ បោះទៅកណ្តាលអូរហើយទាញដៃខ្ញុំ លោតទៅជាន់លើខ្ទមនោះហើយផ្លោះទៅមាត់អូរម្ខាងទៀត ។ ខ្ញុំភ្ញាក់ពីដំណេកពោរពេញដោយសេចក្តីសង្ឃឹម ព្រោះជាយល់សប្តិចម្លែក ។ តើខ្មោចឪពុកខ្ញុំ គាត់ស្លាប់នៅពេលជម្លៀសមកដល់ភូមិទួលគ ក្នុងខែកញ្ញា ឆ្នាំ ១៩៧៥ មកជួយខ្ញុំមែនឬ? ។ ទោះជាពិតឬមិនពិតក្តីក៏ជាសេចក្តីសង្ឃឹមរបស់ខ្ញុំមួយដែរ ។

ពីរថ្ងៃក្រោយមក តម្រួតហៅពួកយើងឲ្យមកប្រជុំរើសអ្នកស្ម័គ្រចិត្តទៅធ្វើទាហានតស៊ូនៅព្រំដែន ។ ពួកយើងស្ម័គ្រចិត្តទាំងអស់គ្នា ទាំងចាស់ទាំងក្មេង ទាំងអ្នកជាទាំងអ្នកឈឺ ។ ប៉ុន្តែគេជ្រើសយកតែអ្នកមានកម្លាំងមាំមួនតែប៉ុណ្ណោះ ។ ស្អែកឡើងគេហៅឈ្មោះអ្នកស្ម័គ្រចិត្តចេញពីមន្ទីរឃុំឃាំងទៅឡើងរថយន្តនៅមុខបន្ទាយ ។ មិត្តសារ៉ាន់មិត្ត ម៉េន ជាមិត្តដ៏ល្អរបស់ខ្ញុំបានទៅចោលរូបខ្ញុំហើយ ។ គេបានទៅធ្វើទាហានតស៊ូកម្ចាត់ពួកខ្មែរក្រហមនៅឯក្នុងប្រទេសរបស់យើងមុនខ្ញុំ ។ តើយើងនឹងបានជួបគ្នាវិញឬទេ? ។ ខ្ញុំមានអារម្មណ៍ថានៅតែលតោល ហើយមិនដឹងថាដល់ថ្ងៃណាទើបខ្ញុំបានចេញទៅតស៊ូនឹងគេ? ។ ជើងរបស់ខ្ញុំទាំងពីរពុំទាន់បានសះស្បើយមែនទែននៅឡើយ នៅឈឺខ្ទាំហើយស្ពឹកស្រាញ ដើរពុំទាន់បានមាំទាំ ។ អ្វីដែលខ្ញុំនឹកឃើញថា អស្ចារ្យសម្រាប់ខ្លួនខ្ញុំគឺ រោគក្រពះពោះវៀនរបស់ខ្ញុំបានជាសះស្បើយអស់ ។ តាំងពីកុមារភាពមក ខ្ញុំមានរោគចុកពោះប្រចាំជីវិតរបស់ខ្ញុំ ។ រោគនេះព្យាបាលពុំជាសោះ ។ រៀងរាល់ថ្ងៃខ្ញុំតេងតែទទួលទានថ្នាំព្យាបាលក្រពះពោះវៀនជានិច្ច បើគ្មានថ្នាំទេខ្ញុំពិតជារងនូវការចុកចាប់ក្នុងពោះយ៉ាងខ្លាំងពុំលែងឡើយ ។ មកដល់សម័យខ្មែរក្រហមពុំមានថ្នាំពេទ្យទំនើបខ្ញុំ តែងទទួលទានថ្នាំបុសឈើជាជំនួស ជួនកាលជាថ្នាំដែលយល់សប្តិឃើញ ។ ថ្នាំនោះគ្រាន់តែជួយសម្រន់ការចុកចាប់របស់ខ្ញុំដូចថ្នាំពេទ្យទំនើបដែរ ។ ឥឡូវនេះខ្ញុំបានជាពីរោគចុកពោះនោះហើយ ។ តើដោយសារអ្វី? ។

ពីរអាទិត្យក្រោយមកទៀត ព្រឹកមួយតម្រួតហៅយើងមកប្រជុំហៅឈ្មោះ ហើយប្រាប់យើងថា ពួកឯងត្រូវទៅតុលាការនៅស្រុកកាប៊ីន? ដើម្បីឲ្យគេកាត់ទោស ។ ពួកឯងត្រូវឆ្លើយប្រាប់តុលាការថា ពួកឯងទើបមកដល់កាលពីម្សិលមិញ ។ បើនរណាឆ្លើយខុសពីនេះ ឯងមុខជាមានរឿងធំជាមិនខាន ។ មានរថយន្តមួយគ្រឿងមកឈប់ចាំពួកយើងនៅមុខមន្ទីរឃុំឃាំង ។ យើងឡើងលើរថយន្ត ហើយរថយន្តនាំយើងទៅស្រុកកាប៊ីន ។ នៅតាមផ្លូវដែលយើងធ្វើដំណើរមក យើងឃើញទេសភាពតាមជនបទ តាមទីប្រជុំជនគួរឲ្យរំភើបចិត្តណាស់ព្រោះយើងខានឃើញទិដ្ឋភាពបែបនេះជាយូរមកហើយ ។ ប្រមាណមួយម៉ោងក្រោយមក យើងទៅដល់មុខមន្ទីរតុលាការ ។ តម្រួតពីរនាក់បណ្តើរយើងឡើងទៅក្នុងមន្ទីរ ។ គេឲ្យយើងអង្គុយលើកៅអីវែងនៅយ៉ាងមុខសាលធំ ។ ភ្នែកយើង គយគន់មនុស្សម្នាទៅមកចុះឡើងក្នុងមន្ទីរដោយឥតនឿយណាយ ។ មនុស្សម្នាទាំងនោះក៏សម្លឹងមក យើងដោយងឿងឆ្ងល់ឬដោយអាណោចមកលើរូបកាយស្គមកំព្រីសរុំព័ទ្ធដោយកំណាត់សំពត់រហែករយ៉ៃ ។

ខ្ញុំជាប់រវល់គយគន់ទិដ្ឋភាពនៃសាលាកាត់ក្តី ពុំដឹងថាពេលវេលាកន្លងទៅអស់រយៈពេលប៉ុន្មានទេ ហើយស្រាប់តែខ្ញុំភ្ញាក់នឹងសំឡេងតម្រួតដែលហៅឈ្មោះឲ្យពួកយើងដើរចូលក្នុងសាលាក្តី ។ យើងអង្គុយលើកៅអីដោយស្ងាត់ស្ងៀម និងប្រុងប្រយ័ត្ន ។ មន្ត្រីតុលាការហៅឈ្មោះយើងម្តងម្នាក់ឲ្យងើបឈរ ។ ហៅគ្រប់គ្នាហើយស្រាប់តែមន្ត្រីម្នាក់ទៀតមានសាច់ឈាមជាកូនចិន ពាក់អាវវែងខ្មៅអ៊ុលកឃុលដើរចូលមកឈរកណ្តាលតុវែងពីមុខយើង ហើយនិយាយប្រកាសថា តាមអ្នកបកប្រែភាសាខ្មែរដែលខ្ញុំចាំបានខ្លះ ពួកឯងបានចូលមកក្នុងប្រទេសថៃដោយខុសច្បាប់ ។ តាមច្បាប់នៃប្រទេសថៃពួកឯងម្នាក់ៗត្រូវជាប់គុក៤៨ម៉ោង និងពិន័យជាប្រាក់សែសិបបាត ។ បើគ្មានប្រាក់បង់ត្រូវជាប់គុកបន្ថែម តុលាការបិទសវនាការ ។ ចៅក្រមអម្បាញ់មិញចេញពីសាលទៅបាត់ ។

**(តទៅលេខក្រោយ)**

**ថា សីហា**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ







ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 184, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.